# ក្រមអត្ថបទគតិយុត្ត

## គ្រប់គ្រងមុខងារសាធារណៈ

## ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឆ្នាំ ២០១០

**អារម្ភកថា**

## មាតិកា

**សេចក្តីផ្តើម**


| ល.រ | លិខិតបទដ្ឋានគតិយុត្ត | ទំព័រ |
|---|---|---|
| **១. សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល** | | ១ |
| ១.១ | ព្រះរាជក្រម លេខ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា | ៣ |
| ១.២ | ព្រះរាជក្រម លេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល | ២១ |
| **២. ការរៀបចំក្របខ័ណ្ឌទូទៅក្នុងមុខងារសាធារណៈ** | | ២៥ |
| | ❖ ព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧ /២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ | ២៧ |
| **៣. លក្ខន្តិកៈនៃក្របខ័ណ្ឌមន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | | ៣៥ |
| ៣.១ | ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល | ៣៧ |
| | ❖ ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល | ៣៩ |
| ៣.២ | ក្របខ័ណ្ឌមន្ត្រីក្រមការ | ៤៧ |
| | ❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ | ៤៩ |
| ៣.៣ | ក្របខ័ណ្ឌមន្ត្រីលេខាធិការរដ្ឋបាល | ៥៧ |
| | ❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០០ /១០៣ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល | ៥៩ |
| ៣.៤ | ក្របខ័ណ្ឌមន្ត្រីភ្នាក់ងាររដ្ឋបាល | ៦៥ |
| | ❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០០ /១៣៥ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល | ៦៧ |
| ៣.៥ | ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ៧៣ |
| | ❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០២ /១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ៧៥ |
| ៣.៦ | ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម | ៨៣ |
| | ❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០២ /១៥២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម | ៨៥ |

| | | |
|---|---|---|
| ៣.៧ | ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម | ៩៣ |
| | ❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០២ /១៥៣ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម | ៩៥ |
| ៣.៨ | ក្របខ័ណ្ឌមន្ត្រីភ្នាក់ងារបច្ចេកទេស | ១០១ |
| | ❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០២ /១៥៤ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស | ១០៣ |
| **៤.ប្រព័ន្ធបៀវត្ស** | | ១០៩ |
| ៤.១ | បៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្ស | ១១១ |
| | ❖ ព្រះរាជក្រឹត្យ លេខ នស/រកត/១២០១ /៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល | ១១៣ |
| | ❖ សេចក្តីណែនាំលេខ ០០៣ សណនមស ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០១ ស្តីពីការអនុវត្តន៍គោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល | ១២៧ |
| ៤.២ | ការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការ | ១៣៥ |
| | ❖ អនុក្រឹត្យ លេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិលនិងប្រាក់កម្រៃគរុកោសល្យក្នុងវិស័យអប់រំ | ១៣៧ |
| | ❖ អនុក្រឹត្យ លេខ ៩៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល | ១៤១ |
| | ❖ អនុក្រឹត្យ លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភសម្រាប់មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល | ១៥១ |
| ៤.៣ | ប្រាក់បំណាច់មុខងារសម្រាប់មុខដំណែងក្រៅក្របខ័ណ្ឌមន្ត្រីរាជការ | ១៥៧ |
| | ❖ អនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីប្រាក់បំណាច់របស់សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ទីប្រឹក្សា ព្រមទាំងមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ | ១៥៩ |
| ៤.៤ | ការបន្ថែមប្រាក់បៀវត្សជូនមន្ត្រីរាជការ | ១៦១ |
| | ❖ អនុក្រឹត្យ លេខ ២៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការបន្ថែមប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និវត្តជន និងមន្ត្រីបាត់បង់សមត្ថភាពពលកម្ម | ១៦៣ |
| | ❖ អនុក្រឹត្យ លេខ ០៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលៈ កែប្រែពីចំនួន៣០០រៀល ទៅ ចំនួន ៣៤៥ រៀល | ១៦៥ |
| | ❖ អនុក្រឹត្យ លេខ ១៤០ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលៈ កែប្រែពីចំនួន៣៤៥រៀលទៅចំនួន៤០០ រៀល | ១៦៩ |
| | ❖ អនុក្រឹត្យ លេខ ១៥១ អនក្រ.បក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការកែប្រែតម្លៃឯកតា | ១៧៣ |

| | | |
|---|---|---|
| | នៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលៈ កែប្រែពីចំនួន៤០០រៀល ទៅចំនួន ៤៦០ រៀល | |
| | ❖ អនុក្រឹត្យ លេខ ៤៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការកែប្រែតម្លៃ ឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលៈ កែប្រែពីចំនួន៤៦០រៀល ទៅ ចំនួន ៥០០ រៀល | ១៧៧ |
| | ❖ អនុក្រឹត្យ លេខ ១៩៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលៈ កែប្រែពីចំនួន៥០០រៀល ទៅចំនួន ៦០០ រៀល | ១៨១ |
| | ❖ អនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលៈ កែប្រែពីចំនួន៦០០រៀល ទៅ ចំនួន ៧២០ រៀល | ១៨៥ |
| | ❖ អនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលៈ កែប្រែពីចំនួន៧២០រៀល ទៅ ចំនួន ៨៧០ រៀល | ១៨៩ |
| | ❖ សារាចរណែនាំ លេខ០០១ សរណន.សអយ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០០៦ របស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការកែប្រែតម្លៃសន្ទស្សន៍បៀវត្សមូលដ្ឋាន របស់មន្ត្រីរាជការស៊ីវិល | ១៩៣ |
| **៥.ប្រាក់ឧបត្ថម្ភផ្សេងៗ** | | ១៩៩ |
| ៥.១ | ប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស | ២០១ |
| | ❖ អនុក្រឹត្យ លេខ១០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ ស្តីពីការកំណត់ប្រាក់របប បេសកកម្មក្នុង និងក្រៅប្រទេស | ២០៣ |
| ៥.២ | ប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម | ២១១ |
| | ❖ សេចក្តីសម្រេច លេខ ៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការ ស៊ីវិល | ២១៣ |
| ៥.៣ | ប្រាក់ឧបត្ថម្ភមន្ត្រីជាប់កិច្ចសន្យានិងពលករអណ្តែត | ២១៧ |
| | ❖ សារាចរណែនាំ លេខ ០០១ សហវ ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១០ ស្តីពីការប្រើប្រាស់ និងការផ្តល់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត | ២១៩ |
| **៦.ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ** | | ២២៥ |
| | ❖ អនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តការផ្លាស់ប្តូរ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល | ២២៧ |
| | ❖ លិខិត លេខ ២០៦ ម.ស.ប.រ ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ១៩៩៥ របស់រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ស្តីពីការតម្លើងថ្នាក់ឬកាំបៀវត្សប្រចាំឆ្នាំ | ២៣៣ |

| | | |
|---|---|---|
| | ❖ លិខិត លេខ ៦០០ម.ស.ន.ក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្តីពីនីតិវិធីក្នុងការបំពេញបែបបទមួយចំនួនលើការដំឡើងថ្នាក់ជូនមន្ត្រីរាជ ការស៊ីវិល | ២៣៧ |
| **៧.នីតិវិធីនៃការតែងតាំងមន្ត្រីរាជការស៊ីវិល** | | ២៤៥ |
| | ❖ សារាចរណែនាំ លេខ ០២ សរណន ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការជ្រើសរើសនិងតែងតាំងមន្ត្រីរាជការស៊ីវិល | ២៤៧ |
| | ❖ សារាចរណែនាំ លេខ ១០ សរណន ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីនីតិវិធីនៃការតែងតាំងមន្ត្រីរាជការស៊ីវិល | ២៥១ |
| | ❖ ប្រកាស លេខ ១៨៨ មស.គ្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ ស្តីពីការបំពេញបែបបទមួយចំនួនក្នុងការតែងតាំង ផ្ទេរ និងកែសម្រួលបៀវត្សជូនដល់មន្ត្រីរាជការស៊ីវិល | ២៥៥ |
| | ❖ ប្រកាស លេខ ៧៧៥ មស.គ្រ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០០ ស្តីពីការពិនិត្យនិងផ្តល់ទិដ្ឋាការលើសំណុំលិខិតបៀវត្សប្រចាំខែនិងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល | ២៥៩ |
| **៨.ការផ្តល់គ្រឿងឥស្សរិយយស** | | ២៧៣ |
| | ❖ ព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥ /០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា | ២៧៥ |
| | ❖ អនុក្រឹត្យ លេខ ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស | ២៨១ |
| | ❖ សារាចរណែនាំ លេខ០១ សរណន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំបែបបទស្នើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា | ២៨៥ |
| | ❖ សេចក្តីណែនាំ លេខ ៣៣៦ សហវ.ប ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីនីតិវិធីនិងបែបបទនៃការពិនិត្យវាយតម្លៃលក្ខណៈសម្បត្តិផ្តល់គ្រឿងឥស្សរិយយស និងមេដាយការងារជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២៩១ |
| **៩.ការស្ថិតនៅក្រៅក្របខ័ណ្ឌដើម** | | ២៩៧ |
| | ❖ អនុក្រឹត្យ លេខ ៥០ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការស្ថិតនៅក្រៅក្របខ័ណ្ឌដើមចំពោះមន្ត្រីរាជការស៊ីវិលមន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ | ២៩៩ |
| | ❖ អនុក្រឹត្យ លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៩៨ ស្តីពីដាក់មន្ត្រីរាជការឲ្យនៅក្រៅក្របខ័ណ្ឌដើមក្នុងពេលទៅបំពេញការងាររៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ៣០៥ |
| | ❖ អនុក្រឹត្យ លេខ ៧២ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការដាក់មន្ត្រីរាជការឱ្យនៅក្រៅក្របខ័ណ្ឌដើមក្នុងពេលបំពេញការងាររៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ | ៣១១ |

| | | |
|---|---|---|
| ១០.ស្ថានភាពទំនេរគ្មានបៀវត្ស | | ៣១៧ |
| | ❖ អនុក្រឹត្យ លេខ ១១៦ អនក្រ.កត ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ៣១៩ |
| ១១.ការឈប់សម្រាក | | ៣២៥ |
| | ❖ សេចក្តីសំរេច លេខ ៧៣ ស រ ច ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៨២ ស្តីពីម៉ោងធ្វើការ និងពេលឈប់សម្រាករបស់កម្មាភិបាល បុគ្គលិក កម្មករ | ៣២៧ |
| | ❖ សេចក្តីណែនាំលេខ១៣០០ ផក.បព ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៨២ នៃក្រសួងផែនការដើម្បី អនុវត្តសេចក្តីសម្រេចលេខ៧៣ សរចចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៨២ នៃក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីពេលម៉ោងធ្វើការ និងពេលឈប់សំរាករបស់ កម្មាភិបាល បុគ្គលិក កម្មករ | ៣៣៣ |
| | ❖ អនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកំណត់រយៈពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា | ៣៣៩ |
| | ❖ អនុក្រឹត្យលេខ ៣៤ អនក្រ.អនក្រ.បក ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ១៩៩៨ របស់រាជរដ្ឋាភិបាល ស្តីពីការសុំច្បាប់ឈប់ពិសេសនៃមន្ត្រីរាជការដែលឈរឈ្មោះជាបេក្ខជនតំណាងរាស្រ្ត | ៣៤៣ |
| ១២.ការគ្រប់គ្រងវត្តមាននិងវិធានការវិន័យ | | ៣៤៧ |
| | ❖ អនុក្រឹត្យ លេខ ១០ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៧ ស្តីពីនីតិវិធីនៃការអនុវត្តវិន័យចំពោះមន្ត្រីរាជការស៊ីវិល | ៣៤៩ |
| | ❖ សេចក្តីណែនាំ លេខ ៥១ សហវ.ប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ស្តីពីវិធានការពង្រឹងការគ្រប់គ្រងក្របខណ្ឌនិងវត្តមានមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ៣៥៧ |
| ១៣.ការចូលនិវត្តន៍ | | ៣៦៣ |
| | ❖ សារាចរណែនាំ លេខ ០៣ សរ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការដាក់មន្ត្រីរាជការទាំងពីរភេទឲ្យចូលនិវត្តន៍ | ៣៦៥ |
| | ❖ អនុក្រឹត្យ លេខ ៨០ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការឲ្យចូលនិវត្តតាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា | ៣៦៩ |
| | ❖ អនុក្រឹត្យ លេខ ២២១ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកំណត់កាលបរិច្ឆេទនៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍ | ៣៧៥ |
| ១៤. ប្រាក់ឧបត្ថម្ភពេលបញ្ចប់អាជីព | | ៣៧៩ |
| ១៤.១ | ប្រាក់ឧបត្ថមសម្រាប់ការលាឈប់ដោយស្ម័គ្រចិត្ត | ៣៨១ |
| | ❖ អនុក្រឹត្យ លេខ ០៥ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩២ ស្តីពីការកែលម្អបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ | ៣៨៣ |

| | | |
|---|---|---|
| ១៤.២ | **របបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ** | ៣៩៥ |
| | ❖ អនុក្រឹត្យ លេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា | ៣៩៧ |
| | ❖ អនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី | ៤០៣ |
| ១៤.៣ | **ការកែសម្រួលប្រាក់ឧបត្ថម្ភនិងប្រាក់សោធន** | ៤០៩ |
| | ❖ អនុក្រឹត្យ លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការបន្ថែមបៀវត្សជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ | ៤១១ |
| | ❖ អនុក្រឹត្យ លេខ ២០១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភម្តងគត់ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និងព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណៈភាព សុំលាឈប់ពីការងារ សុំចូលនិវត្តមុនកាលកំណត់ និងមិនគ្រប់លក្ខខណ្ឌចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទា វិជ្ជាជីវៈ | ៤១៣ |
| | ❖ អនុក្រឹត្យ លេខ ៤២ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០ ស្តីពីការកែសម្រួលការអនុវត្តបើកប្រាក់សោធនចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ | ៤១៩ |
| ១៤.៤ | **សារាចរណែនាំការអនុវត្តរបបសោធននិវត្តនិងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ** | ៤២៥ |
| | ❖ សារាចរណែនាំ លេខ០០៨ ស.អ.យ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ស្តីពីការអនុវត្តសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ | ៤២៧ |
| | ❖ សារាចរណែនាំ លេខ ០០៧ ស.អ.យ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការតម្លើងប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់និវត្តជននិងជនបាត់សម្បទាវិជ្ជាជីវៈ | ៤៣៧ |
| | ❖ សារាចរណែនាំ លេខ០០៨ ស.អ.យ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការបន្ថែមប្រាក់ ១៥ ទៅ ២៥ ភាគរយ ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន | ៤៤១ |
| | ❖ សារាចរណែនាំ លេខ០០១ សរ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការតម្លើងប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់និវត្តន៍ជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ | ៤៤៥ |
| | ❖ សារាចរណែនាំ លេខ០៥ សរ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការបើកប្រាក់សោធនសំរាប់និវត្តជន ជនបាត់បង់ | ៤៤៩ |

| | | |
|---|---|---|
| | សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ដែលកំពុងទទួលមុខតំណែងក្នុងមុខងារនយោបាយ | |
| | ❖ សារាចរណែនាំ លេខ០០៥ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការតម្លើងប្រាក់សោធនសម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ | ៤៥៣ |

# សេចក្តីផ្តើម

មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលបម្រើការងារនៅតាមក្រសួង ស្ថាប័នចំណុះរាជរដ្ឋាភិបាលត្រូវបានគ្រប់គ្រងដោយសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងត្រូវផ្សារភ្ជាប់ខ្លួនទៅនឹងក្របខ័ណ្ឌជាក់លាក់ដែលកំណត់ដោយព្រះរាជក្រឹត្យក្របខ័ណ្ឌដោយឡែកនីមួយៗ។ ដំណើរវិវត្តន៍នៃអាជីពមន្ត្រីរាជការ គឺផ្អែកលើប្រភេទក្របខ័ណ្ឌដែលម្នាក់ៗស្ថិតនៅ ដែលក្របខ័ណ្ឌទាំងបួននោះ គឺក្របខ័ណ្ឌ “ **ក** “ “ **ខ** “ “ **គ** “ និង “ **ឃ** “ ហើយត្រូវបានកំណត់ជាប្រភេទផ្សេងៗទៅតាមវិស័យការងារ ដូចជាផ្នែករដ្ឋបាល បច្ចេកទេស អប់រំជាដើម។ ក្របខ័ណ្ឌនីមួយៗត្រូវបែងចែកជា៣ឋានន្តរស័ក្តិ ដែលនោះជាការបញ្ជាក់ឧបនិស្ស័យនៃការកាន់កាប់មុខតំណែងក្នុងរចនាសម្ព័ន្ធរដ្ឋបាល ហើយឋានន្តរស័ក្តិនេះក៏ត្រូវបានបែងចែកជាថ្នាក់បន្តដើម្បីកំណត់កម្រិតសន្ទស្សន៍បៀវត្សផងដែរ ដោយឋានន្តរស័ក្តិទី១ មាន៦ថ្នាក់ ឋានន្តរស័ក្តិទី២មាន១០ថ្នាក់ និង ឋានន្តរស័ក្តិទី៣ មាន១៤ថ្នាក់។

ផ្តើមចេញពីការជ្រើសរើសចូលបម្រើការងារតាមការប្រឡងប្រជែងដែលជាគោលការណ៍ទូទៅនោះ បេក្ខជននឹងត្រូវទទួលការតាំងស៊ប់ដោយភ្ជាប់ខ្លួនទៅនឹងថ្នាក់ ឋានន្តរស័ក្តិនៃក្របខ័ណ្ឌ បន្ទាប់ពីកម្មសិក្សាប្រកបដោយជោគជ័យ នោះគឺជាចំណុចចាប់ផ្តើមនៃអាជីពជាមន្ត្រីរាជការដោយពិតប្រាកដ។

មន្ត្រីរាជការអាចត្រូវទទួលការតែងតាំងក្នុងមុខនាទី ការផ្លាស់ប្តូរការងារ ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការផ្តល់គ្រឿងឥស្សរិយយស ឬ ការប្រែប្រួលស្ថានភាពជាវិជ្ជមាន ឬ អវិជ្ជមាន ជាលក្ខណៈហិរញ្ញវត្ថុ ឬ មិនមែនហិរញ្ញវត្ថុចំពោះខ្លួន ម្យ៉ាងដោយតម្រូវការនៃសេវាសាធារណៈ និងម្យ៉ាងជាបច្ច័យនៃសមិទ្ធកម្មការងារនិងការប្រព្រឹត្តរបស់ខ្លួន។ ការប្រែប្រួលស្ថានភាពអាជីពមន្ត្រីរាជការទាំងនេះ គឺផ្អែកលើបទបញ្ញត្តិច្បាប់និងវិធានទូទៅជាធរមាន។

ស្ថិតក្នុងជីវភាពជាមន្ត្រីរាជការដែលបំពេញសេវាសាធារណៈដើម្បីប្រយោជន៍ទូទៅនោះ មន្ត្រីម្នាក់ៗទទួលបានការឧបត្ថម្ភជាបៀវត្សនិងប្រាក់បន្ទាប់បន្សំផ្សេងៗពីរដ្ឋជាថ្នូរនៃការងាររបស់ខ្លួន ហើយដែលការឧបត្ថម្ភនេះ ក៏អាចនៅតែមានបន្តនៅពេលមន្ត្រីបញ្ចប់អាជីពរបស់ខ្លួនក្នុងស្ថានភាពការចូលនិវត្តន៍ ឬ ការបាត់បង់សម្បទាវិជ្ជាជីវៈផងដែរ។

លើសពីនេះ មុខងារសាធារណៈនៃព្រះរាជាណាចក្រកម្ពុជាក៏បានផ្តល់នូវភាពទន់ភ្លន់មួយចំនួនក្នុងការគ្រប់គ្រងអាជីព ដោយបានទទួលស្គាល់និងអនុញ្ញាតឲ្យមានស្ថានភាពស្ថិតនៅក្រៅក្របខ័ណ្ឌដើម ស្ថានភាពទំនេរគ្មានបៀវត្ស និងការឈប់សម្រាកពីការងារជាបណ្តោះអាសន្ន ដោយអាចរក្សាក្របខ័ណ្ឌដដែលដែលនោះជាភាពអនុគ្រោះចំពោះអាជីពមន្ត្រីរាជការ។

ទន្ទឹមនឹងការទទួលស្គាល់សិទ្ធិដល់មន្ត្រីរាជការដែលមានបង្ហាញនៅផ្នែកខាងដើម មន្ត្រីរាជការម្នាក់ៗក៏ត្រូវជាប់កាតព្វកិច្ចចំពោះសេវាសាធារណៈដែលតម្រូវឲ្យម្នាក់ៗត្រូវមានឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវ វប្បធម៌សេវាសាធារណៈ ការអនុវត្តដោយខ្ជាប់ខ្ជួនក្រមសីលធម៌វិជ្ជាជីវៈនៅក្នុងការបំពេញមុខនាទីរបស់ខ្លួន។ ការខកខាន ឬ ប្រព្រឹត្តផ្ទុយនឹងកាតព្វកិច្ច នឹងបណ្ដាលឲ្យមន្ត្រីរាជការប្រឈមនឹងទណ្ឌកម្ម ជាយថាហេតុ។

ក្របខ័ណ្ឌមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ថិតនៅក្រោមសហលក្ខន្តិកៈទូទៅ និងត្រូវចំណុះផ្ទាល់លក្ខន្តិកៈដោយឡែកក្នុងប្រភេទក្របខ័ណ្ឌវិស័យរដ្ឋបាលនិងបច្ចេកទេស ដែលមានបួនកម្រិតដូចដែលមានកំណត់នៅក្នុងគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ ។ អត្ថបទគតិយុត្តពាក់ព័ន្ធនឹងមុខងារសាធាណៈដែលត្រូវបានចងក្រងឡើងនេះ មិនត្រឹមតែដើម្បីប្រើប្រាស់សម្រាប់ការគ្រប់គ្រងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែក៏អាចប្រើប្រាស់ជាប្រយោជន៍ទូទៅផងដែរដោយហេតុថា អត្ថបទទាំងនេះគឺជាអត្ថបទគតិយុត្តដែលមានវិសាលភាពទូទៅលើមុខងារសាធារណៈ។

ដើម្បីផ្ដល់ភាពងាយស្រួលដល់អ្នកអានឲ្យអាចចាប់បានដោយឆាប់រហ័សអំពីមុខងារសាធារណៈ អត្ថបទត្រូវបានចងក្រងផ្ដើមពីការបង្ហាញស្ថានភាពទូទៅ និងធ្វើការបង្ហាញលម្អិតជាបន្តបន្ទាប់លើទិដ្ឋភាពដោយឡែកៗជុំវិញអាជីពមន្ត្រីរាជការ ដោយត្រូវបានរៀបចំដូចខាងក្រោម÷

១. សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
២. ការរៀបចំក្របខ័ណ្ឌទូទៅក្នុងមុខងារសាធារណៈ
៣. លក្ខន្តិកៈគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
៤. ប្រព័ន្ធបៀវត្ស
៥. ប្រាក់ឧបត្ថម្ភផ្សេងៗ
៦. ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ
៧. នីតិវិធីនៃការតែងតាំងមន្ត្រីរាជការស៊ីវិល
៨. ការផ្ដល់គ្រឿងឥស្សរិយយស
៩. ការស្ថិតនៅក្រៅក្របខ័ណ្ឌដើម
១០. ស្ថានភាពទំនេរគ្មានបៀវត្ស
១១. ការឈប់សម្រាក
១២. ការគ្រប់វត្តមាននិងវិធានការវិន័យ
១៣. ការចូលនិវត្តន៍
១៤. ប្រាក់ឧបត្ថម្ភពេលបញ្ចប់អាជីព

៙៙

# ១. សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

១.១  ព្រះរាជក្រម លេខ ០៦.នស.៩៤ ចុះថ្ងៃទី៣០  ខែតុលា  ឆ្នាំ១៩៩៤

ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ

ព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០៦ ន.ស.៩៤

## ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស**

**អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើនៅថ្ងៃទី២៤-៩-១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១-១១-១៩៩៣
- គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

## ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា ដូចមានសេចក្តីទៅនេះ ៖

## ជំពូកទី ១
## បញ្ញត្តិទូទៅ

**មាត្រា ១**. -

អ្នករាជការក្របខ័ណ្ឌទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ក្រៅពីអ្នករាជការដែលស្ថិតនៅក្នុងក្រុមតុលាការ និង ក្រុមនីតិបញ្ញត្តិដែលមានលក្ខណៈពិសេសនោះត្រូវស្ថិតនៅក្នុងសហវិធាននេះ ។

**មាត្រា ២**. -

ច្បាប់នេះអនុវត្តចំពោះអ្នករាជការនៃព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខ័ណ្ឌទាំងពួង ដែលបានបង្កើតនិងរៀបចំឡើងតាមព្រះរាជក្រឹត្យ ហើយបានចូលធ្វើការនៅតាមក្រសួង ស្ថាប័ននានាដោយមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ ។

**មាត្រា ៣**.-

ក្របខ័ណ្ឌទាំងឡាយ នៃអ្នករាជការត្រូវកំណត់ដោយលក្ខន្តិកៈដោយឡែកតាមព្រះរាជក្រឹត្យ។

**មាត្រា ៤**. -

ប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សអ្នករាជការក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលក្ខន្តិកៈ ដោយឡែកនៃអង្គផ្សេងៗ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

**មាត្រា ៥** .-

ការតែងតាំង ការតំលើងថ្នាក់ ការផ្លាស់ប្តូរ ការដាក់ក្រៅតំណែង ឬការដាក់អោយនៅក្រៅក្របខ័ណ្ឌ ត្រូវសំរេចដោយ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ។

ការបញ្ឈប់លែងអោយធ្វើការដោយបង្ខំ ការដាក់អោយចូលនិវត្តន៍មុនកំណត់ និងការហូតងារនៃអ្នករាជការក្របខ័ណ្ឌ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ស្របតាមលក្ខន្តិកៈដោយឡែកនៃអ្នករាជការនេះ ។

**មាត្រា ៦** .-

អ្នករាជការម្នាក់ៗមានសិទ្ធិសុំមើលកំណត់ត្រា និងឯកសារផ្សេងៗដែលជាសំណុំរឿងផ្ទាល់ខ្លួន មុននឹងត្រូវទទួលទណ្ឌកម្មខាងវិន័យ ឬមុននឹងត្រូវផ្លាស់ដោយបង្ខំ ។ សិទ្ធិដដែលនេះត្រូវបានអនុញ្ញាតអោយដល់អ្នករាជការណាដែលយឺតយូរ មិនបានឡើងឋានន្តរស័ក្តិ ឬថ្នាក់តាមវេនអតីតភាព ។

**មាត្រា ៧** .-

អ្នករាជការក្របខ័ណ្ឌអាចដាក់ទៅបំរើការ ឬបំពេញមុខងារក្រៅពីក្របខ័ណ្ឌដើមរបស់ខ្លួនបាន ក្នុងករណីចាំបាច់និងមានការយល់ព្រមពីសាមីខ្លួន ។

អ្នករាជការក្របខ័ណ្ឌមានសិទ្ធិសុំផ្លាស់កន្លែងធ្វើការទៅតាមប្តី ឬប្រពន្ធបាន ។

**មាត្រា ៨** .-

នៅក្នុងក្របខ័ណ្ឌនីមួយៗ តាមគោលការណ៍ អ្នករាជការក្នុងឋានន្តរស័ក្តិ ឬថ្នាក់ណាមួយមិនអាចចាត់អោយទៅធ្វើការក្រោមបង្គាប់អ្នករាជការម្នាក់ទៀតដែលមានឋានន្តរស័ក្តិ ឬថ្នាក់ទាបជាងខ្លួនទេ លើកលែងក្នុងករណីចាំបាច់ហើយ សាមីខ្លួនដែលមានឋានន្តរស័ក្តិ ឬថ្នាក់ធំជាងនោះយល់ព្រម ។

**មាត្រា ៩** .-

របបស្ដីពីការសុំច្បាប់ និងការឈប់សំរាកប្រចាំឆ្នាំ ប្រាក់បំណាច់ បេសកកម្ម ប្រាក់បំណាច់ព្យាបាលរោគក្នុងមន្ទីរពេទ្យ និងប្រាក់សោធននិវត្តន៍ ។ ល ។ ត្រូវកំណត់តាមច្បាប់ដោយឡែក ។

**មាត្រា ១០** .-

បៀវត្សនិងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ដូចជាប្រាក់បំណាច់បន្ថែមនិងប្រាក់បំណាច់ទទួលខុសត្រូវ ប្រាក់តំបន់ ប្រាក់ឧបត្ថម្ភកូននិងប្រពន្ធ ប្រាក់ថ្លៃឈ្នួលផ្ទះ ថ្លៃសង្ហារឹមក្នុងផ្ទះ ថ្លៃជាវមធ្យោបាយការងារ ថ្លៃទឹក និងថ្លៃភ្លើង ។ ល ។ នៃអ្នករាជការត្រូវកំណត់តាមច្បាប់ដោយឡែក ។

## ជំពូកទី ២
## ការជ្រើសរើសអោយចូលធ្វើការ

**មាត្រា ១១** .-

បេក្ខជនទាំងពីរភេទអាចទទួលអោយចូលធ្វើការក្នុងក្របខ័ណ្ឌរាជការបាន លុះត្រាតែបេក្ខជននោះបានបំពេញនូវលក្ខខ័ណ្ឌដូចខាងក្រោម ÷

១- មានសញ្ជាតិជាខ្មែរ ។

២- មានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយមិនលើសពី ២៥ ឆ្នាំ ប៉ុន្តែមានករណីលើកលែងខ្លះដូចមានចែងខាងក្រោមនេះ ÷

ក- ចំពោះបេក្ខជនដែលមានសញ្ញាប័ត្រឧត្តមសិក្សា ការកំរិតអាយុ ត្រូវបានរំកិលពី ២៥ ឆ្នាំ ដល់ ៣០ ឆ្នាំ យ៉ាងច្រើនបំផុត ។

ខ-ចំពោះបេក្ខជនដែលបានរៀននៅគ្រឹះស្ថានឧត្តមសិក្សា មួយឆ្នាំ ឬច្រើនឆ្នាំ ហើយមិនបានសញ្ញាប័ត្រនោះ ការកំរិតអាយុ ២៥ ឆ្នាំ នឹងត្រូវរំកិលតាមចំនួនឆ្នាំដែលបានរៀនក្នុងគ្រឹះស្ថានឧត្តមសិក្សាទាំងនោះ តែមិនអោយលើសពី ៣០ ឆ្នាំ ។

គ-ចំពោះបេក្ខជនដែលបានបំពេញកាតព្វកិច្ចយោធា ការកំរិតអាយុត្រូវរំកិលតាមចំនួនឆ្នាំដែលបានបំពេញកាតព្វកិច្ចយោធានោះ ។

ឃ- ក្នុងពេលចាំបាច់ រាជរដ្ឋាភិបាល អាចចេញអនុក្រឹត្យលើកលែងការកំណត់អាយុនៃបេក្ខជនដើម្បីបំពេញសេចក្ដីត្រូវការជាអាទិភាព និងដើម្បីប្រយោជន៍ជាតិ ។

៣-មិនបានប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិជាពលរដ្ឋ សិទ្ធិខាងនយោបាយ ។

៤-មិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈឹមពីរឿងល្មើសប៉ះពាល់ដល់ទំនៀមទំលាប់ កិត្តិយស និងភាពសុចរិត ។

៥-ត្រូវមានកាយសម្បទាគ្រប់គ្រាន់ ក្នុងការបំពេញការងារដែលលក្ខណសម្បត្តិមានចែងទុកជាមុននៅក្នុងសេចក្ដីណែនាំ និងបទបញ្ជាជាធរមាន ។

៦-បងប្អូនជនជាតិភាគតិច បងប្អូននៅតំបន់ដាច់ស្រយាល និងបងប្អូននារីភេទអាចត្រូវបាន ផ្តល់អាទិភាព និងភាពងាយស្រួល ។

៧-ត្រូវបំពេញលក្ខខ័ណ្ឌខាងសមត្ថភាពគ្រប់គ្រាន់ ដូចមានចែងក្នុងបទបញ្ញាដោយឡែក នៃអង្គដែលខ្លួនមានបំណងសុំចូលបំរើការងារ ។

**មាត្រា ១២** .-

លក្ខខ័ណ្ឌស្តីពីសញ្ជាតិ និងអាយុត្រូវបញ្ជាក់តាមសំបុត្រអត្រានុកូលដ្ឋាន ឬតាមសាលក្រមជំនួសអត្រានុកូលដ្ឋាននោះ ។

សេចក្តីបញ្ជាក់ថាគ្មានទោសត្រូវកំណត់ក្នុងសំបុត្រថ្កោលទោសមួយមានសុពលភាព ៣ ខែ ដែលចេញអោយដោយក្រសួងយុត្តិធម៌ ។

**មាត្រា ១៣** .-

ជាគោលការណ៍ រាល់ការជ្រើសរើសបេក្ខជនអោយចូលក្នុងក្របខ័ណ្ឌ ត្រូវធ្វើឡើងតាមការប្រឡងប្រជែង លើកលែងតែមានការកំណត់ផ្សេងពីនេះដោយរាជរដ្ឋាភិបាល ។

**មាត្រា ១៤** .-

កាលបរិច្ឆេទ នៃការប្រឡងប្រជែងជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌរាជការ ត្រូវកំណត់ និងផ្សព្វផ្សាយយ៉ាងតិច ៣ ខែ មុនថ្ងៃដែលបើកអោយចូលប្រឡង ។ ក្នុងករណីដែលមានការប្រញាប់ការផ្សព្វផ្សាយត្រូវធ្វើយ៉ាងតិច ៣០ ថ្ងៃ ។

**មាត្រា ១៥** .-

ជាគោលការណ៍ រាល់ការប្រឡងប្រជែងជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌរាជការត្រូវមានតំណាងស្ថាប័នមុខងារសាធារណៈចូលរួម ។

## ជំពូកទី ៣
## ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ
## ការបញ្ចេញពីក្របខ័ណ្ឌ

**មាត្រា ១៦** .-

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការនឹងអាចសំរេចបានជាស្ថាពរ ក្រោយពីបានធ្វើកម្មសិក្សាសាកល្បងមួយ។ ផ្ទុយទៅវិញ អាចលើកលែងមិនបាច់ធ្វើកម្មសិក្សា ចំពោះបេក្ខជនទាំងឡាយដែលបានប្រឡងជាប់ទៅកាន់ប្រភេទក្របខ័ណ្ឌខ្ពស់ជាងនៃអង្គដែលខ្លួនធ្លាប់ជាមន្ត្រីរាជការចាស់តាំងស៊ប់ក្នុងក្របខ័ណ្ឌម្តងរួចហើយ ។

**មាត្រា ១៧** .-

បៀវត្សរបស់កម្មសិក្សាការីត្រូវកាត់ទុកប្រាក់សម្រាប់សោធននិវត្តន៍ ។ បើសិនជាកម្មសិក្សាការីនោះមិនបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការទេនោះ ប្រាក់ដែលបានកាត់ទុកសម្រាប់សោធននិវត្តន៍នេះត្រូវសងមកសាមីខ្លួនវិញ ។

**មាត្រា ១៨** .-

រយៈពេលកម្មសិក្សាត្រូវកំរិត ១២ ខែ ។ រយៈពេលកម្មសិក្សាត្រូវគិតពីថ្ងៃតែងតាំងកម្មសិក្សាការីនេះ។ កម្មសិក្សានេះមិនត្រូវយកជាការបានទេ បើកាលណាសាមីជនអាក់ខានមកធ្វើកម្មសិក្សាសរុបលើសពី ៣០ ថ្ងៃ ។ ក្នុងករណីនេះ សាមីជនត្រូវបន្តធ្វើកម្មសិក្សានៅឆ្នាំទី ២ ទៀត ។

- ការតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការនឹងធ្វើទៅបានលុះត្រាតែកម្មសិក្សាការីបានបំពេញកម្មសិក្សាចំនួន ១២ ខែជាពិតប្រាកដ ។ រយៈពេលកម្មសិក្សានេះត្រូវបន្ថយ ៦ ខែ ចំពោះមន្ត្រីរាជការក្របខ័ណ្ឌចាស់ដែលបាន ប្រឡងជាប់ចូលក្របខ័ណ្ឌថ្មីមួយទៀតដោយរក្សាអតីតភាពដែលមានពីមុន ។
- ការតាំងស៊ប់ក្នុងក្របខ័ណ្ឌត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចតែងតាំង តាមសំណើពីប្រធានអង្គភាព ។ ការតែងតាំងស៊ប់នៃកម្មសិក្សាការីត្រូវតែមានការរួមយោបល់ពីគណៈកម្មការមួយ ។

សមាសភាពគណៈកម្មការនេះមាន :

| | | |
|---|---|---|
| ១- | ប្រធានស្ថាប័ន ឬតំណាង | ប្រធាន |
| ២- | ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង | សមាជិក |
| ៣- | ប្រធានការិយាល័យបុគ្គលិក ឬតំណាង | សមាជិក |
| ៤- | អ្នករាជការមួយរូបដែលមានក្របខ័ណ្ឌជាមួយគ្នា | សមាជិក |

កម្មសិក្សាការីណាដែលមិនបានបង្ហាញអោយឃើញថាខ្លួនមានសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ ឬក៏ពិនិត្យឃើញថារបៀបធ្វើការងារមានការខ្ជីខ្ជា ឬក៏គ្មានកំលាំងពលំនឹងកាន់មុខតំណែងបានតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងសេចក្តីណែនាំជាធរមាន អាចបញ្ឈប់មិនអោយធ្វើការនេះពេលណាក៏បានក្នុងរយៈពេលកម្មសិក្សា ។ ត្រូវបញ្ឈប់មិនអោយធ្វើការ ដូចគ្នាដែរចំពោះអ្នករាជការណាដែលបានប្រព្រឹត្តិបទល្មើសស្មើនឹងមាត្រា ៣៣ និងមាត្រាបន្តបន្ទាប់ទៅមុខទៀតនៃច្បាប់នេះ ដែលចែងពីការដាក់វិន័យចំពោះមន្ត្រីរាជការ ។

ការបញ្ឈប់មិនអោយធ្វើការ ឬការតាំងស៊ប់ក្នុងក្របខ័ណ្ឌ តោងតែសំរេចជាដាច់ខាតក្នុងរយៈពេល៣ខែ ក្រោយថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា ១២ ខែកន្លងមក ។ ការតែងតាំងស៊ប់ក្នុងក្របខ័ណ្ឌចាប់ផ្តើមមានប្រសិទ្ធភាព ក្នុងផ្នែកបៀវត្សក៏ដូចជាអតីតភាពការងារសម្រាប់ឡើងឋានន្តរស័ក្ត ឬថ្នាក់ចាប់ពីថ្ងៃផុតកំណត់នៃកម្មសិក្សានេះ ។ ប៉ុន្តែអតីតភាពការងារសំរាប់ ចូលនិវត្តន៍ត្រូវបានគិតបញ្ចូលតាំងពីថ្ងៃចាប់ផ្តើមធ្វើកម្មសិក្សា ។

**មាត្រា ១៩**.-

អ្នករាជការណាដែលធ្វើការតទៅទៀតមិនបាន ដោយហេតុមកពីបាត់បង់សម្បទាវិជ្ជាជីវៈ ហើយដែលមិនបានបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់ ដើម្បីទទួលសោធននិវត្តន៍អាចនឹងត្រូវបញ្ឈប់មិនអោយធ្វើការតទៅទៀតនៅពេលណាក៏បាន ។

អ្នករាជការមានអតីតភាពការងារចាប់ពី ២០ ឆ្នាំឡើងទៅ ដែលតម្រូវអោយចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ មានសិទ្ធិទទួលប្រាក់សោធនសមាមាត្រ ។ បើអតីតភាពការងារក្រោម ២០ ឆ្នាំ អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ មានសិទ្ធិទទួលប្រាក់សោធនដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់រដ្ឋតែមួយលើក ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសំរេចដោយគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោមនេះ ៖

| | |
|---|---|
| ១-ប្រធានស្ថាប័ន ឬតំណាង | ប្រធាន |
| ២-ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង | សមាជិក |
| ៣-ប្រធានការិយាល័យបុគ្គលិក ឬតំណាង | សមាជិក |
| ៤-គ្រូពេទ្យដែលបានទទួលសច្ចាប្រណិធាន ហើយដែលចាត់តាំងឡើយ ដោយក្រសួងសុខាភិបាល | សមាជិក |
| ៥-អ្នករាជការដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នាពីរនាក់ ដែលមានឋានន្តរស័ក្តិយ៉ាងហោចណាស់ស្មើនឹងសាមីខ្លួន | សមាជិក |

## ជំពូកទី ៤
## ការឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់

**មាត្រា ២០**.-

ការឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់នៃអ្នករាជការត្រូវធ្វើតាមវេនជ្រើសរើសក៏បាន ឬតាមវេនជ្រើសរើស និងអតីតភាពជាមួយគ្នាក៏បាន ។

តាមធម្មតារយៈពេលអប្បបរមានៃការឡើងថ្នាក់ត្រូវកំរិត ២ ឆ្នាំ ។ ដើម្បីនឹងធ្វើអោយឡើងថ្នាក់តាម ការជ្រើសរើសយកនោះ ត្រូវមានចុះឈ្មោះក្នុងតារាងឡើងថ្នាក់ ។ ក្នុងករណីអ្នករាជការណាម្នាក់បំពេញការងារមានស្នាដៃល្អពិសេសត្រូវបានតំលើងថ្នាក់ជាស្វ័យប្រវត្តិ ដោយពុំគិតពីលក្ខខ័ណ្ឌអតីតភាពឡើយ។

ចំពោះក្របខ័ណ្ឌទាំងអស់ ការតម្លើងថ្នាក់ត្រូវមានការយល់ព្រមពីស្ថាប័នមានសមត្ថកិច្ចក្នុងការតែងតាំង ដែលសំរេចអោយតាមកំរិតនៃកន្លែងទំនេរក្នុងឋានន្តរស័ក្តិនីមួយៗ និងតាមកំរិតមុខចំណាយថវិកា ។

**មាត្រា ២១**.-

អ្នករាជការក្នុងឋានន្តរស័ក្តិតែមួយអាចឡើងថ្នាក់បានម្តងមួយថ្នាក់ បើដូរឋានន្តរស័ក្តិត្រូវឡើងទៅថ្នាក់ក្រោមបំផុតនៃស័ក្តិខ្ពស់ជាងនោះ ។ នៅពេលដែលអ្នករាជការត្រូវប្តូរប្រភេទក្របខ័ណ្ឌដោយសារបានប្រឡងជាប់ទៅប្រភេទក្របខ័ណ្ឌខ្ពស់ សន្ទស្សន៍បៀវត្សត្រូវគិតត្រឹមថ្នាក់ដែលមានកំរិតស្មើ ឬខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់នៃអ្នករាជការនោះ ។

ការតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ទាំងឡាយ ត្រូវគិតលើផ្នែកបៀវត្សនិងអតីតភាពចាប់ពីកាលបរិច្ឆេទដែលការតម្លើងឋានន្តរស័ក្តិនេះត្រូវបានប្រកាស ។

**មាត្រា ២២**.-

ជារៀងរាល់ឆ្នាំ នៅខែមករា អ្នករាជការទាំងអស់ដែលមានសិទ្ធិត្រូវតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ ត្រូវបំពេញព្រឹត្តិប័ត្រពិន្ទុសម្រាប់តម្លើងថ្នាក់របស់ខ្លួន ។ ព្រឹត្តិប័ត្រពិន្ទុនេះត្រូវបានប្រធានអង្គភាពធ្វើការកត់សម្គាល់ និងបញ្ជាក់បន្ថែមព្រមទាំងកំណត់ជាពិន្ទុ ។

អភិបាលខេត្ត ក្រុង មានភារៈផ្តល់យោបល់ទៅលើកិរិយាមារយាទ ការគោរពវិន័យ សាមគ្គីភាពរបស់ ប្រធានមន្ទីរនានានៅខេត្ត ក្រុង ។

តារាងពិន្ទុទាំងនេះត្រូវបញ្ជូនតាមលិខិតសំងាត់ទៅប្រធានស្ថាប័នសាមី ។

**មាត្រា ២៣**.-

ក្រោយពីបានចារលើព្រឹត្តិប័ត្រពិន្ទុ តាមក្របខ័ណ្ឌ និងលំដាប់លំដោយអតីតភាព ប្រធានអង្គភាព ឬប្រធានស្ថាប័នមានសមត្ថកិច្ចបញ្ឈប់បញ្ជីស្នើសុំឡើងថ្នាក់នោះ ។

បញ្ជីខាងលើនេះ ត្រូវចុះឈ្មោះអ្នករាជការដែលបានបំពេញលក្ខខ័ណ្ឌដូចខាងក្រោម ៖

១- តាមធម្មតា អតីតភាពការងារយ៉ាងតិចបាន ២ ឆ្នាំ ចំពោះឋានន្តរស័ក្តិ ឬថ្នាក់ដែលបានទទួល គិតចាប់ពីថ្ងៃចូលឆ្នាំខ្មែរដែលជាថ្ងៃធ្វើតារាងឡើងថ្នាក់ ។

២- ត្រូវមានសេចក្តីស្នើសុំអោយឡើងថ្នាក់ត្រឹមត្រូវតាមច្បាប់ ពីថ្នាក់គ្រប់គ្រងបន្តបន្ទាប់ដែលសាមីខ្លួននៅក្រោមបង្គាប់ ។

**មាត្រា ២៤**.-

ព្រឹត្តិប័ត្រកំណត់ពិន្ទុវិជ្ជាជីវៈ និងស្ថានភាពសេវាកម្មនៃរាជការម្នាក់ៗដែលស្នើសុំឡើងឋានន្តរស័ក្តិ ឬថ្នាក់ ត្រូវដាក់អោយគណៈកម្មការចំណាត់ថ្នាក់ពិនិត្យ ។

**មាត្រា ២៥**.-

តារាងតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ ត្រូវធ្វើដោយគណៈកម្មការចំណាត់ថ្នាក់តែងតាំងតាមសំណើប្រធានអង្គភាព ឬពីប្រធានស្ថាប័នសាមី ។

គណៈកម្មការនេះ ត្រូវតែងតាំងឡើងតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ តាមប្រកាសក្រសួងហើយត្រូវមានសមាសភាពដូចតទៅ ៖

១-ប្រធានស្ថាប័ន ឬតំណាង ប្រធាន

២-ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង សមាជិក

៣-ប្រធានការិយាល័យបុគ្គលិក ឬតំណាង សមាជិក

៤-អ្នករាជការពីរនាក់ ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នា តែមានឋានន្តរស័ក្តិនិងថ្នាក់ខ្ពស់ជាង ឬបើគ្មានទេ ត្រូវយកអ្នករាជការក្នុងក្របខ័ណ្ឌឯទៀតក៏បានដែរ ។ អ្នករាជការទាំងនេះត្រូវជ្រើសរើសឡើងដោយការបោះឆ្នោត សមាជិក

**មាត្រា ២៦**.-

តារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់ ត្រូវធ្វើឡើងក្នុងត្រីមាសទី ៤ នៃឆ្នាំនីមួយៗ(ត្រីមាស ទី ៤ នៃឆ្នាំខ្មែរ) ។ តារាងនេះប្រើការសំរាប់ឆ្នាំបន្ទាប់ និងមានតែឈ្មោះអ្នកដែលស្នើរឡើងតាមវេនជ្រើសរើស ។

គណៈកម្មការនេះចំណាត់ថ្នាក់ប្រជុំពេញអង្គ កំណត់មធ្យមភាគនៃពិន្ទុចំពោះបេក្ខជនម្នាក់ៗពីពិន្ទុ ០ ដល់ពិន្ទុ ២០ រួចគណៈកម្មការនេះស្រង់ឈ្មោះបេក្ខជនតាមលំដាប់ដោយពិន្ទុ ។

ការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់ ត្រូវធ្វើតាមចំនួនកន្លែងដែលមានសល់ទំនេរ ។

ចំនួនឈ្មោះដែលចុះក្នុងតារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់ប្រចាំឆ្នាំសំរាប់ក្របខ័ណ្ឌនីមួយៗនៅក្នុងឋានន្តរស័ក្តិ ឬ ថ្នាក់នីមួយៗ ត្រូវកំណត់ដោយ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស តាមចំនួនកន្លែងទំនេរនិងតាមមុខចំណាយដែលមានគ្រោងទុកក្នុងថវិកា ។

**មាត្រា ២៧**.-

ក្នុងករណីដែលមិនអាចចុះឈ្មោះបេក្ខជនទាំងអស់ក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬថ្នាក់នៃឆ្នាំនេះបានទេ សាមីជនត្រូវមានសិទ្ធិចុះឈ្មោះមុនគេបង្អស់តាមលេខរៀង ក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ឆ្នាំបន្ទាប់មកទៀត លើកលែងតែគណៈកម្មការសំរេចផ្ទុយពីនេះ ដោយមានសេចក្តីរាយការណ៍សមហេតុផលពីប្រធានគ្រប់គ្រងសាមី ។

**មាត្រា ២៨**.-

ដើម្បីចុះឈ្មោះក្នុងតារាងឡើងឋានន្តរស័ក្តិឬថ្នាក់បាន នៅ ថ្ងៃ១៣ ខែមេសា ក្នុងឆ្នាំនីមួយៗ បេក្ខជនត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃអង្គរបស់ខ្លួន ដើម្បីឡើងថ្នាក់ ។ ក្នុងករណីពិសេស គណៈកម្មការចំណាត់ថ្នាក់មានសិទ្ធិចុះឈ្មោះក្នុងតារាងតំលើងឋានន្តរស័ក្តិឬថ្នាក់បាននូវអ្នករាជការដែលអង្គភាពគ្រប់គ្រងមិនបានស្នើតម្លើងឋានន្តរស័ក្តិឬថ្នាក់ ។

**មាត្រា ២៩**.-

អតីតភាពការងារមន្រ្តីរាជការដែលធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាល តំបន់ប៉ះពាល់សុខភាពឬ គ្រោះថ្នាក់ត្រូវគិតបន្ថែមពាក់កណ្តាលនៃអតីតភាពនេះទៀត ក្នុងការចុះឈ្មោះលើតារាងរាយនាមសំរាប់ស្នើសុំតម្លើងឋានន្តរស័ក្តិឬថ្នាក់ ។

**មាត្រា ៣០**.-

ការតម្លើងឋានន្តរស័ក្តិឬថ្នាក់តាមវេនអតីតភាព ត្រូវឆ្លាស់គ្នាជាមួយការឡើងឋានន្តរស័ក្តិឬថ្នាក់តាមវេនជ្រើសរើស ទៅតាមសមាមាត្រដែលបានគ្រោងទុកក្នុងលក្ខន្តិកៈដោយឡែកសំរាប់អង្គនីមួយៗ ។

ការឡើងឋានន្តរស័ក្តិឬថ្នាក់តាមវេនអតីតភាព ត្រូវសំរេចតាមលំដាប់លំដោយអតីតភាពជាដាច់ខាតក្នុងបញ្ជីរាយនាមអ្នករាជការដែលត្រូវសុំអោយឡើងឋានន្តរស័ក្តិឬថ្នាក់នោះ ។

**មាត្រា ៣១**.-

សិទ្ធិត្រូវបានឡើងឋានន្តរស័ក្តិឬថ្នាក់ ដោយវេនជ្រើសរើស ក៏ដូចជាដោយវេនអតីតភាព ត្រូវផ្អាកចំពោះអ្នករាជការណាដែលជាប់ចោទជាបទវិន័យឬជាបទតុលាការ ។

**មាត្រា ៣២**.-

ឋានន្តរស័ក្តិកិត្តិយស អាចផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចតែងតាំងជូនមន្ត្រីរាជការចូលនិវត្តន៍ ឬលាលែង ឬដែលបានដាក់អោយឈប់ធ្វើការងារដោយបាត់បង់សមត្ថភាពការងារ ។

ឋានន្តរស័ក្តិកិត្តិយសជាកិច្ចបច្ឆាមរណៈអាចផ្តល់ជូនមន្ត្រីរាជការដែលបានទទួលមរណភាព ។

## ជំពូកទី ៥
## វិន័យ

**មាត្រា ៣៣**.-

អ្នករាជការរាល់រូប ត្រូវតែគោរពអនុវត្តច្បាប់និងបទបញ្ជា ហើយនិងការណែនាំថ្នាក់លើរបស់ខ្លួន ។

អ្នករាជការត្រូវទទួលខុសត្រូវចំពោះមុខថ្នាក់លើអំពីកិច្ចការរបស់ខ្លួន និងអំពើដែលអាចធ្វើអោយប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់ខ្លួន ។

អ្នករាជការក្នុងក្របខ័ណ្ឌទាំងអស់ ត្រូវតែគោពរបញ្ជាថ្នាក់លើដែលបានចាត់អោយទៅបំរើការងារ ទោះបីទីតំបន់ណាក៏ដោយ ទាំងក្នុងនិងក្រៅប្រទេស ។

**មាត្រា ៣៤**.-

អ្នករាជការទាំងឡាយមិនអាចឈប់ធ្វើការដោយគ្មានបានទទួលការអនុញ្ញាតជាមុនពីថ្នាក់លើរបស់ខ្លួន ឬដោយគ្មានមូលហេតុត្រឹមត្រូវ ។ ការឈប់ធ្វើការ ឬការខានទៅធ្វើការដោយគ្មានការអនុញ្ញាត ឬគ្មានមូលហេតុត្រឹមត្រូវ អាចបង្ខំអោយអ្នករាជការនោះនៅទំនេរគ្មានបៀវត្ស ឬត្រូវផ្អាកបៀវត្ស ។ អ្នករាជការនោះអាចនឹងត្រូវទទួលទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ។

**មាត្រា ៣៥**.-

ត្រូវហាមឃាត់ជាដាច់ខាតដល់អ្នករាជការនូវប្រការខាងក្រោម ÷

១-យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ។

២-យកឥទ្ធិពល និង អំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុត គំរាមកំហែង បំពានសិទ្ធិរបស់ពលរដ្ឋ ។

៣-ប្រកបមុខរបរណាដែលនាំអោយប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ ។

៤-ចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ឬដោយប្រយោល។

៥-បោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយពត៌មានដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួងដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ ។

៦-ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីដែលលក្ខន្តិកៈដោយឡែក នៃអង្គនីមួយៗហាមឃាត់ ។

អំពើបំពាននឹងបទបញ្ញត្តិនៃមាត្រានេះអាចបណ្តាលអោយទទួលទណ្ឌកម្មផ្នែកវិន័យណាមួយដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញាដែលអាចកើតមានឡើងទៀតផង ។

**មាត្រា ៣៦**.-

អ្នករាជការទាំងឡាយមានសិទ្ធិចូលជាសមាជិក ឬចូលរួមក្នុងការគ្រប់គ្រងសមាគមស្របច្បាប់ ។

**មាត្រា ៣៧**.-

មន្ត្រីរាជការត្រូវមានអព្យាក្រឹតភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋដើម្បីបំរើសកម្មភាពនយោបាយដូចខាងក្រោម ៖

១- ធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ ។

២- ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬ ប្រឆាំងនឹងគណបក្សនយោបាយណាមួយ ។

ការប្រព្រឹត្តិផ្ទុយនឹងមាត្រានេះចាត់ទុកជាកំហុសនិងការផ្តាំផ្តងក្នុងវិជ្ជាជីវៈ ។

**មាត្រា ៣៨**.-

អ្នករាជការទាំងអស់ត្រូវបង្ហាញអោយឃើញថា ខ្លួនសមត្ថភាពក្នុងវិជ្ជាជីវៈជាដរាបក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន ។ អ្នករាជការទាំងអស់ត្រូវទទួលខុសត្រូវពីកំហុស និងការផ្តាំផ្តងក្នុងវិជ្ជាជីវៈព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តិក្នុងមុខងាររបស់ខ្លួន ។

**មាត្រា ៣៩**.-

កំហុសនិងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ ត្រូវយកទណ្ឌកម្មខាងវិន័យទៅអនុវត្ត ។ ការខ្វះខាត ឬបាត់សម្បទាវិជ្ជាជីវៈអាចត្រូវដាក់អោយចូលនិវត្តន៍ បើសាមីខ្លួនបំពេញលក្ខខ័ណ្ឌដើម្បីទទួលប្រាក់សោធន និវត្តន៍ ឬបញ្ឈប់ពីការងាររាជការក្នុងករណីមិនគ្រប់លក្ខខ័ណ្ឌដើម្បីទទួលប្រាក់សោធននិវត្តន៍ ។

**មាត្រា ៤០**.-

ទណ្ឌកម្មខាងវិន័យមានដូចតទៅ ៖

**១- ទណ្ឌកម្មថ្នាក់ទី ១**

ក- ស្តីបន្ទោស

ខ- ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ- ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ

ឃ- លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិឬថ្នាក់

**២- ទណ្ឌកម្មថ្នាក់ទី ២**

ក- ស្តីបន្ទោសជាទម្ងន់បណ្តាលអោយលុបចេញពីតារាងឡើងឋានន្តរស័ក្តិ ឬ ថ្នាក់បើសិនជាមានចុះឈ្មោះហើយ ឬធ្វើឲ្យយឺតក្នុងការតម្លើងឋានន្តរស័ក្តិ ឬ ថ្នាក់ក្នុងថេរៈវេលាមួយមានកំណត់ តែមិនត្រូវឲ្យលើសពី ២ ឆ្នាំក្នុងការតម្លើងឋានន្តរស័ក្តិ ឬថ្នាក់តាមវេនជ្រើសរើសឬតាមវេនអតីតភាព ។

ខ- ដាក់អោយនៅទំនេរគ្មានបៀវត្សមិនអោយលើសពីមួយឆ្នាំ ។

គ- បន្ថយឋានន្តរស័ក្តិឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់ ។

ឃ- ដាក់អោយចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ

ង- បណ្តេញចេញពីមុខតំណែងរាជការ ។

**មាត្រា ៤១**.-

ការស្តីបន្ទោសត្រូវធ្វើជាលិខិតផ្ញើទៅសាមីខ្លួន ដោយប្រធានអង្គភាពឬប្រធានស្ថាប័ន។

ការស្តីបន្ទោសដែលមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ និងការលុបឈ្មោះចេញពីតារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស តាមសេចក្តីរាយការណ៍ពីប្រធានអង្គភាព និងក្រោយពីសាមីខ្លួនបានដោះសា ។

**មាត្រា ៤២**.-

រាល់ទណ្ឌកម្មខាងវិន័យថ្នាក់ទី ២ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ក្រោយពីមានយោបល់របស់ក្រុមប្រឹក្សាវិន័យ ។

**មាត្រា ៤៣**.-

អ្នករាជការដែលត្រូវបន្ថយថ្នាក់ ឬឋានន្តរស័ក្តិ ត្រូវបញ្ចូលទៅក្នុងថ្នាក់ឬឋានន្តរស័ក្តិថ្មី ចាប់គិតពីថ្ងៃដែល មានសេចក្តីសំរេចជាផ្លូវការ ។

**មាត្រា ៤៤**.-

ការបណ្តេញមន្ត្រីរាជការចេញពីមុខតំណែងគឺការដកមុខងារឬអំណាច និងឋានន្តរស័ក្តិដែលបានប្រគល់អោយពីមុនដល់មន្ត្រីរាជការនោះ ។ ក្នុងករណីដែលត្រូវលុបចោលនូវសិទ្ធិទទួលប្រាក់សោធននិវត្តន៍ ឬប្រាក់ដែលកាត់ទុកក្នុងបេឡាសោធននិវត្តន៍ នោះត្រូវមានសេចក្តីសំរេចជាលាយល័ក្ខណ៍អក្សរ។

**មាត្រា ៤៥**.-

ការចោទប្រកាន់អំពីកំហុសខាងវិន័យត្រូវធ្វើដោយសេចក្តីសម្រេចរបស់ថ្នាក់គ្រប់គ្រងដែលមានសមត្ថកិច្ចក្រោយពីមានសេចក្តីរាយការណ៍ពិស្តារពីប្រធានអង្គភាពឬប្រធានស្ថាប័ន ។

**មាត្រា ៤៦**.-

អនុក្រឹត្យ ឬប្រកាសដែលសម្រេចចោទប្រកាន់អំពីកំហុសខាងវិន័យនាំអោយមានការផ្អាកមុខងារនៃអ្នករាជការនោះជាបណ្តោះអាសន្ន តែមិនមានការបន្ថយបៀវត្សទេ ។ ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្រុមប្រឹក្សាវិន័យត្រូវកោះប្រជុំដើម្បីផ្តល់យោបល់ ។

សេចក្តីសម្រេចផ្អាកការងារអ្នករាជការអោយឈប់ពីតំណែងមានកំណត់ត្រឹម៣ខែ ប៉ុន្តែបើជាករណីពិសេសអាចសំរេចអោយបន្តជាថ្មីទៀតបានកំណត់ ០១ ខែ ម្តង ប៉ុន្តែការបន្តនោះមិនត្រូវលើសពី ៣ ដងឡើយ ។

**មាត្រា ៤៧**.-

ការចោទប្រកាន់អំពីកំហុសខាងវិន័យ ត្រូវធ្វើការអង្កេតជាមុនសិនចំពោះទណ្ឌកម្មខាងវិន័យថ្នាក់ទី ២ ។ ការអង្កេតត្រូវប្រគល់អោយតំណាងប្រធានស្ថាប័នសាមីមួយរូបឬច្រើនរូប ដែលមានឋានន្តរស័ក្តិ និងថ្នាក់ខ្ពស់ជាង ឬអតីតភាពច្រើនជាងអ្នករាជការដែលត្រូវជាប់ចោទ ។

សំណុំរឿងអង្កេតត្រូវបញ្ជូនទៅប្រធានស្ថាប័នដើម្បីពិនិត្យ និងសំរេចថាគួរបញ្ជូនអ្នករាជការជាប់ចោទនោះទៅអោយក្រុមប្រឹក្សាវិន័យ ឬក៏សម្រេចថាគួរបញ្ឈប់ការចោទប្រកាន់វិញ ។ ក្នុងករណីដែលប្រធានស្ថាប័នយល់ថាគួរបន្តការចោទប្រកាន់ សំណុំរឿងត្រូវបញ្ជូនទៅក្រុមប្រឹក្សាវិន័យដែលត្រូវអញ្ជើញអ្នករាជការជាប់ចោទមកពន្យល់ដោះសារដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរមុននឹងក្រុមប្រឹក្សាវិន័យធ្វើការសន្និដ្ឋានអំពីកំហុសនិងទណ្ឌកម្ម ដើម្បីជាយោបល់ដល់ថ្នាក់មានសមត្ថកិច្ចសម្រេច ។

**មាត្រា ៤៨**.-

ក្រុមប្រឹក្សាវិន័យ ត្រូវមានសមាជិក ៥ នាក់ ៖

- អ្នករាជការ ៣ នាក់ ចាត់តាំងដោយប្រធានស្ថាប័ន ដែលអ្នករាជការជាប់ចោទនោះនៅក្រោមឱវាទ ម្នាក់បំពេញមុខងារជាប្រធាន និងម្នាក់ទៀតបំពេញមុខងារជាអ្នកធ្វើរបាយការណ៍ ។
- អ្នករាជការ ២ នាក់ ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នានឹងអ្នករាជការជាប់ចោទក៏ប៉ុន្តែមាន ឋានន្តរស័ក្តិខ្ពស់ជាង ឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា ។

មិនអាចចាត់តាំងអោយចូលក្នុងក្រុមប្រឹក្សាវិន័យនេះបាន អ្នករាជការណាដែលជាអ្នកធ្វើពាក្យបណ្ដឹង ចំពោះអ្នករាជការជាប់ចោទ ឬជាក្រុមញាតិរហូតដល់ជួរទី៣របស់អ្នករាជការជាប់ចោទនោះ។

**មាត្រា ៤៩**.-

អ្នកធ្វើរបាយការណ៍មានកាតព្វកិច្ចប្រាប់ទៅអ្នករាជការជាប់ចោទនូវសិទ្ធិរបស់អ្នករាជការនោះដូចតទៅ ៖

១- សិទ្ធិសុំមើលសំណុំរឿងផ្ទាល់ខ្លួន

២- សិទ្ធិសំអាងសាក្សី

៣- សិទ្ធិជ្រើសរើសតំណាងការពារខ្លួន

៤- សិទ្ធិពន្យល់ដោះសាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

**មាត្រា ៥០**.-

ក្រោយពេលបានទទួលរបាយការណ៍ ក្រុមប្រឹក្សាវិន័យអាចបង្គាប់អោយអ្នកធ្វើរបាយការណ៍រកពត៌មានបន្ថែមទៀតបាន ។

ប្រធានអាចពន្យាពេលប្រជុំក្រុមប្រឹក្សាវិន័យទៅថ្ងៃក្រោយបាន ព្រមទាំងអាចចាត់វិធានការផ្សេងៗដែលមានសារប្រយោជន៍ដើម្បីរកការពិត និងកុំអោយប៉ះពាល់ដល់សេចក្ដីវិនិច្ឆ័យរបស់តុលាការក្នុងករណីដែលការបានសម្រេចជាមុនមកហើយ ។

នីតិវិធីនៃការអនុវត្តវិន័យនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៦
## ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា ៥១**.-

អ្នករាជការដែលជាប់បណ្ដឹងពីបទមជ្ឈិមឬបទឧក្រិដ្ឋចំពោះមុខតុលាការ អាចត្រូវចោទប្រកាន់បានលុះត្រាមានសេចក្ដីអនុញ្ញាតបើកអោយចោទប្រកាន់ជាមុនពីគណៈរដ្ឋមន្ត្រី តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចំពោះមន្ត្រី ដែលមានបៀវត្សស្មើឬលើសបៀវត្សឧត្តមមន្ត្រីថ្នាក់លេខ ៣ ឬមានឋានៈជាប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីនិងក្រុង អភិបាលខេត្ត ក្រុង ។ ចំពោះអ្នករាជការដែលមានបៀវត្សទាបជាងបៀវត្សឧត្តមមន្ត្រីថ្នាក់លេខ ៣ វិញ សេចក្ដីអនុញ្ញាតជាមុន អោយចោទប្រកាន់នោះត្រូវសម្រេចត្រឹមប្រធានស្ថាប័នសាមី។

ក្នុងករណីបទល្មើសជាក់ស្ដែង តុលាការអាចបង្គាប់អោយឃុំខ្លួនភ្លាមមិនចាំបាច់មានសេចក្ដីអនុញ្ញាតអោយចោទប្រកាន់ទេ ប៉ុន្តែត្រូវជូនដំណឹងអំពីរឿងនេះជាប្រញាប់ទៅប្រធានស្ថាប័នសាមី ។

**មាត្រា ៥២**.-

អ្នករាជការណាដែលកំពុងជាប់ការចោទប្រកាន់ទៅតុលាការជំនុំជំរះ អាចត្រូវបានផ្អាកពីមុខងារសិនក្នុងករណីចាំបាច់ ។

ក្នុងករណីដែលអ្នករាជការត្រូវផ្អាកពីការងារដោយផ្អាកបៀវត្ស អ្នករាជការនោះត្រូវបានទទួលអោយចូលធ្វើការវិញភ្លាមដោយគិតពីអតីតភាព ឋានន្តរស័ក្តិ សោធននិវត្តន៍ និងទទួលបៀវត្សប្រតិសកម្មផងបើតុលាការប្រកាសអោយរួចខ្លួនជាស្ថាពរ ។

**មាត្រា ៥៣**.-

ការផ្តន្ទាទោសជាបទឧក្រិដ្ឋ ឬជាបទមជ្ឈឹមដោយឥតព្យួរទោស បណ្តាលអោយមានការហូតងារអ្នករាជការនោះ គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

អ្នករាជការដែលតវ៉ាសុំឧទ្ធរណ៍ត្រូវដាក់អោយនៅទំនេរគ្មានបៀវត្សជាបណ្តោះអាសន្នដោយស្វ័យប្រវត្តិ។

## ជំពូកទី ៧
## ការចូលនិវត្តន៍

**មាត្រា ៥៤**.-

អ្នករាជការទាំងពីរប្រភេទត្រូវដាក់អោយចូលនិវត្តន៍ជាកំហិតពេលដល់អាយុ ៥៥ ឆ្នាំ។

អាយុកំហិតនេះអាចរំកិលឡើងដល់ ៦០ ឆ្នាំបើលក្ខន្តិកៈដោយឡែកបានកំណត់ ។

ដើម្បីមានសិទ្ធិទទួលសោធននិវត្តន៍អតីតភាពបាន អ្នករាជការត្រូវបំពេញលក្ខខ័ណ្ឌដូចតទៅ ៖

- មានអាយុ ៥៥ ឆ្នាំ
- មានអតីភាពការងារ ៣០ ឆ្នាំ

ប៉ុន្តែអ្នករាជការដែលបានបំរើការងារអស់រយៈពេល ៣០ ឆ្នាំហើយ អាចសុំចូលនិវត្តន៍មុនអាយុ ៥៥ ឆ្នាំ ដោយទទួលប្រាក់សោធននិវត្តន៍អតីតភាព ។

**មាត្រា ៥៥**.-

អ្នករាជការដែលបំពេញការងារបាន ៣០ ឆ្នាំយ៉ាងតិច ត្រូវទទួលប្រាក់សោធននិវត្តន៍អតីតភាព ។

អ្នករាជការដែលបានបំពេញការងារក្រោម ២០ ឆ្នាំ ត្រូវទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់រដ្ឋតែមួយលើក ។

អ្នករាជការដែលបានបំពេញការងារក្នុងចន្លោះរយៈពេលពី ២០ ឆ្នាំដល់ក្រោម ៣០ ឆ្នាំត្រូវបានទទួលប្រាក់សោធននិវត្តន៍សមាមាត្រ ។

**មាត្រា ៥៦**.-

ក្នុងរយៈពេលបន្តការងារក្រោយពេលដល់អាយុចូលនិវត្តន៍ ចំពោះអ្នករាជការដែលមាន អតីតភាពគ្រប់ ៣០ ឆ្នាំហើយ មិនត្រូវកាត់ទុកប្រាក់សោធននិវត្តន៍ឡើយ ប៉ុន្តែបើអតីតភាពការងារមិនទាន់គ្រប់ ៣០ ឆ្នាំនោះ ត្រូវកាត់ទុកប្រាក់សោធននិវត្តន៍ ហើយរាប់បញ្ចូលចំនួនឆ្នាំដែលបានបន្តការងារ ដើម្បីទទួលប្រាក់ សោធននិវត្តន៍ ។

**មាត្រា ៥៧**.-

អតីតភាពការងាររបស់អ្នករាជការត្រូវគិតតាំងពីថ្ងៃដែលសាមីខ្លួនបានចូលបំរើការងារ រដ្ឋទោះក្នុងសម័យណាក៏ដោយ ។

## ជំពូកទី ៨
## ការដោះស្រាយទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ

**មាត្រា ៥៨**.-

អ្នករាជការមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការ អំពីករណីដែលពាក់ព័ន្ធទៅនឹងកិច្ចការមុខងារ សាធារណៈ ។ ប៉ុន្តែជាការចាំបាច់ អ្នករាជការនោះត្រូវរកវិធីដោះស្រាយតាមផ្លូវរដ្ឋបាលជាមុនសិន ។

**មាត្រា ៥៩**.-

សមត្ថកិច្ចដើម្បីដោះស្រាយទំនាស់ខាងលើនេះ ត្រូវប្រគល់ជូនគណៈកម្មាធិការ អចិន្ត្រៃយ៍មួយមានឈ្មោះថា គណៈកម្មាធិការសំរុះសំរួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ដែល មានប្រធានស្ថាប័នមុខងារសាធារណៈ ជាប្រធាន ហើយនឹងមានសមាសភាពដែលកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៩
## បទបញ្ញត្តិដោយឡែក

**មាត្រា ៦០**.-

ការកែសម្រួលចំនួនអ្នករាជការចាំបាច់ជាក់ស្ដែងជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ ក្នុងករណីដែលត្រូវកាត់បន្ថយចំនួនអ្នករាជការជាការចាំបាច់ ជាគោលការណ៍ ការរំសាយត្រូវប៉ះពាល់ជាបឋម ចំពោះអ្នករាជការដែលជិតដល់អាយុចូលនិវត្តន៍ដែលមានសម្បទាវិជ្ជាជីវៈថមថយ និងអ្នកដែលស្ម័គ្រចិត្តឈប់ ពីការងារ ។

**មាត្រា ៦១**.-

ជាគោលការណ៍ អ្នករាជការក្របខ័ណ្ឌមានអាទិភាពក្នុងការទទួលមុខតំណែងណាមួយ។ តែក្នុងករណីពិសេស ផ្អែកលើការចាំបាច់ រាជរដ្ឋាភិបាលអាចតែងតាំងវរជនណាម្នាក់ ឬជនដែលមានសញ្ញាប័ត្រខ្ពស់ អោយកាន់មុខតំណែងអ្វីមួយ ក៏បាន ទោះវរជនឬជននោះពុំមែនជាមន្ត្រីក្របខ័ណ្ឌក៏ដោយ ។

ក្នុងលក្ខណៈនេះ សាមីខ្លួនមានសិទ្ធិទទួលបៀវត្សជាធម្មតា តែគ្មានសិទ្ធិទទួលសោធននិវត្តន៍ទេ ។

**មាត្រា ៦២**.-

រាជរដ្ឋាភិបាលអាចតែងតាំងឲ្យចូលក្របខ័ណ្ឌអ្នករាជការនៅពេលណាក៏បាន ចំពោះវរជន ឬជនដែលមានសញ្ញាប័ត្រខ្ពស់ ដែលមានផលប្រយោជន៍ដល់ការងាររដ្ឋ ដោយមិនគិតពីលក្ខខ័ណ្ឌអាយុ។

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ៦៣**.-

ចាប់តាំងពីច្បាប់នេះចូលជាធរមាន រហូតដល់ឆ្នាំ ២០០០ អ្នករាជការដែលមានអាយុលើសពី ៥៥ ឆ្នាំ អាចអនុញ្ញាតបន្តអោយធ្វើការងារបាន តាមការស្នើសុំរបស់សាមីខ្លួន និងតាមការសម្រេចដោយអនុក្រឹត្យផ្អែកលើយោបល់ឯកភាពពី ស្ថាប័នមុខងារសាធារណៈ និងប្រធានស្ថាប័នសាមី ។ ការបន្តនេះមានរយៈពេលមួយឆ្នាំម្តងៗ តែមិនអោយលើសពី ៥ ឆ្នាំទេ ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**មាត្រា ៦៤**.-

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ សុក្រ ទី ២១ ខែ តុលា ឆ្នាំ ១៩៩៤
នាសម័យប្រជុំសាមញ្ញលើកទី ៣ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤

**ប្រធានរដ្ឋសភាស្តីទី**

**ឡូយ ស៊ីមឈាង**

១.២ ព្រះរាជក្រម លេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

នស/រកម/០៩៩៩/១១

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង មាត្រាទាំងឡាយ នៃជំពូកទី ៨ ដល់ ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និង អំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការធ្វើវិសោធនកម្មមាត្រា ៥១ នៃច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៩ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ២ នៃរដ្ឋសភា និងដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាម លើទំរង់និងគតិនៃច្បាប់នេះទាំងស្រុង នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ១ ហើយដែលមាន សេចក្តីទាំងស្រុងដូចតទៅ:

# ច្បាប់
## ស្តីពី
## ការធ្វើវិសោធនកម្មមាត្រា ៥១
## នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

**មាត្រាតែមួយៈ**

មាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ត្រូវធ្វើវិសោធនកម្មដូចតទៅៈ

**មាត្រា ៥១ ថ្មីៈ**

ក្នុងករណីដែល មន្ត្រីរាជការណាម្នាក់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានព្រះរាជអាជ្ញាសំរេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះ ទៅប្រធានស្ថាប័នសាមី ក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ ។

បើមានការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនជាបណ្តោះអាសន្នលើមន្ត្រីរាជការណាមួយនោះ ព្រះរាជអាជ្ញាឬចៅក្រមមានសមត្ថកិច្ចត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធានស្ថាប័នសាមី។

ក្នុងករណីដែលបទល្មើសនោះកើតមានក្នុងក្របខ័ណ្ឌ នៃការបំរើការងារសាធារណៈ រដ្ឋត្រូវការពារមន្ត្រីរាជការនោះតាមផ្លូវច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រីស្តីទី**
**ហត្ថលេខា**

**ស ខេង**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ហត្ថលេខា**

**អ៊ុក វិធុន**

លេខៈ ១៩៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ២. ការរៀបចំក្របខ័ណ្ឌទូទៅក្នុង មុខងារសាធារណៈ

❖ ព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧ /២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧

ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:ជស/រកត/១២៩៧/២៧៣

# ព្រះរាជក្រឹត្យ

## ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ច្បាប់ស្តីពីសហលក្ខនិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រតត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ និងពីរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈស្របតាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ។

# គ្រាស់បទ្ទាប់
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១**.

មន្ត្រីរាជការស៊ីវិលទាំងអស់ត្រូវបានរៀបចំជាក្របខ័ណ្ឌ ដែលត្រូវបែងចែកជាឋានន្តរស័ក្តិ ។ ក្របខ័ណ្ឌត្រូវចាត់ថ្នាក់ទៅតាមប្រភេទ ។

# ជំពូកទី២
# អំពីប្រភេទ

**មាត្រា ២**.

ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលទាំងអស់ ត្រូវបែងចែកជា ៤ប្រភេទ **ក.ខ.គ**. និង **ឃ** ដែលកំណត់ឡើងដោយយោងទៅតាមល័ក្ខខ័ណ្ឌអប្បបរិមានៃការបណ្តុះបណ្តាលសំរាប់បញ្ចូលក្នុងក្របខ័ណ្ឌ និងកំរិតឋានានុក្រមនៃតំណែងរបស់ក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយៗចាំបាច់ត្រូវបញ្ចូលទៅក្នុងប្រភេទណាមួយនៃប្រភេទទាំង៤ តាមលក្ខន្តិកៈដោយឡែករបស់ខ្លួន ។

**មាត្រា ៣**.

មន្ត្រីរាជការប្រភេទ **ក** មានមុខងារក្នុងតំណែងដឹកនាំ អធិការកិច្ចសិក្សា និងផ្តល់យោបល់ និងមុខងារក្នុងរាល់តំណែងទទួលខុសត្រូវ ។ កំរិតអប្បបរិមានៃការបណ្តុះបណ្តាល ដើម្បីអាចបញ្ចូលក្របខ័ណ្ឌក្នុងប្រភេទ **ក** គឺសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ បូក ៤ឆ្នាំ នៃការសិក្សាដោយមានសញ្ញាប័ត្រ ។ លក្ខន្តិកៈដោយឡែកខ្លះអាចប្រសិនបើចាំបាច់តម្រូវនូវកំរិតអប្បរិមានៃការបណ្តុះបណ្តាលស្មើ ឬលើស សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ បូក៦ឆ្នាំ នៃការសិក្សាដោយមានសញ្ញាប័ត្រ ។ ក្នុងករណីនេះត្រូវមានផ្តល់នូវការបន្ថែមសន្ទស្សន៍បៀវត្ស ។

**មាត្រា ៤**.

ប្រភេទ **ខ** មានមុខងារក្នុងការរៀបចំការងារសំរាប់អ្នកទទួលខុសត្រូវសំរេចនិងដាក់ឱ្យអនុវត្ត ។ កំរិតអប្បបរិមា ដើម្បីបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទ **ខ** គឺសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ បូក២ឆ្នាំ នៃការសិក្សាដោយមានសញ្ញាប័ត្រ ។

**មាត្រា ៥**.

ប្រភេទ **គ** មានមុខងារក្នុងលេខាធិការដ្ឋាន និងមុខងារប្រតិបត្តិដែលតម្រូវឱ្យមានចំណេះបច្ចេកទេសឬចំណេះធ្វើការងារ ។ កំរិតអប្បបរិមាដើម្បីបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទ **គ** គឺសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ។

**មាត្រា ៦.**

ប្រភេទ **ឃ** មានមុខងារក្នុងការប្រតិបត្តិ ។ ការបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទនេះពុំតម្រូវឱ្យមានល័ក្ខខ័ណ្ឌអំពីសញ្ញាប័ត្រឡើយ ។

**មាត្រា ៧.**

កំរិតអប្បបរិមានៃការបណ្តុះបណ្តាលដែលបានកំណត់ក្នុងមាត្រា៣ ៤ និង ៥ នៃព្រះរាជក្រឹត្យនេះអនុវត្តចំពោះនិស្សិតទាំងឡាយណាដែលត្រូវបានជ្រើសរើសឱ្យចូលមុខងារសាធារណៈតាមការប្រឡងប្រជែងចាប់ពីការផ្សព្វផ្សាយព្រះរាជក្រឹត្យនេះ ។

**មាត្រា ៨.**

មន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញភារៈកិច្ចក្នុងមុខតំណែង តាមការតែងតាំងដែលមានរួចហើយ ត្រូវផ្ទេរបញ្ចូលក្នុងក្របខ័ណ្ឌថ្មី ។ គណៈកម្មការអន្តរក្រសួងមួយនឹងត្រូវបានតែងតាំងដោយអនុក្រឹត្យដើម្បីលើកគោលការណ៍សំរាប់ការចាត់ថ្នាក់ថ្មីជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

## ជំពូកទី៣
## អំពីក្របខ័ណ្ឌ

**មាត្រា ៩.**

ក្របខ័ណ្ឌនីមួយៗ នៃមន្ត្រីរាជការ គឺជាការប្រមូលផ្តុំភ្នាក់ងារដែលមានគុណសម្បត្តិ ឬការបណ្តុះបណ្តាលដូចគ្នា ហើយដែលមានឧបនិស្ស័យកាន់តំណែងដូចគ្នា ឬប្រភេទមុខតំណែងដូចគ្នាក្នុងអាជីពរបស់ខ្លួននៅក្នុងក្រសួងណាមួយ ។

**មាត្រា ១០.**

ក្របខ័ណ្ឌនីមួយៗត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកមួយ ដែលរៀបចំដោយក្រសួងសាមី និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ លក្ខន្តិកៈដោយឡែកត្រូវកំណត់ឡើងដោយព្រះរាជក្រឹត្យ និងដោយមានការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាល និងពីក្រុមប្រឹក្សាអ្នកច្បាប់ ។

**មាត្រា ១១.**

លក្ខន្តិកៈដោយឡែកបង្កើតក្របខ័ណ្ឌនីមួយៗ និងរៀបចំអាជីពត្រូវស្របទៅតាមបទប្បញ្ញត្តិសហលក្ខន្តិកៈនៃមន្ត្រីរាជការស៊ីវិល និងតាមអត្ថបទថ្មីនេះ ។ លក្ខន្តិកៈដោយឡែកត្រូវមានជាចាំបាច់នូវបទប្បញ្ញត្តិដូចតទៅ:

ក- ការភ្ជាប់ក្របខ័ណ្ឌក្នុងក្រសួងមួយ

ខ- ការចាត់ថ្នាក់ក្របខ័ណ្ឌទៅក្នុងប្រភេទមួយ

គ- ការកំណត់បេសកកម្មទូទៅរបស់ក្របខ័ណ្ឌ

ឃ- ការកំណត់មុខតំណែងដែលភ្នាក់ងារក្របខ័ណ្ឌត្រូវបំពេញ

ង- ការកំណត់លក្ខណសម្បត្តិអប្បបរិមា ដើម្បីបញ្ចូលក្នុងក្របខ័ណ្ឌ និងបែបបទនៃការប្រឡងប្រជែងផ្ទៃក្នុង និងការប្រឡងប្រជែងចូលក្របខ័ណ្ឌរាជការដោយនិស្សិតសុទ្ធសាធ

ច- របបកម្មសិក្សាសាកល្បង

ឆ- ការកំណត់ឋានានុក្រមក្របខ័ណ្ឌ"បែងចែកក្របខ័ណ្ឌជាឋានន្តរស័ក្តិ និង កំណត់មុខតំណែងសំរាប់ឋានន្តរស័ក្តិនីមួយៗ"

ជ- វិធានសំរាប់តំឡើងថ្នាក់ និងតំឡើងឋានន្តរស័ក្តិ ។

**មាត្រា ១២.**

អនុក្រឹត្យមួយនឹងកំណត់ខ្លឹមសារគំរូនៃលក្ខន្តិកៈដោយឡែក និងវិធីអនុវត្តដើម្បីបង្កើតក្របខ័ណ្ឌ ។

## ជំពូកទី៤
## អំពីឋានន្តរស័ក្តិ

**មាត្រា ១៣.**

ឋានន្តរស័ក្តិ គឺជាលំដាប់ឋានានុក្រមនៃក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយៗ ចាំបាច់ត្រូវបែងចែកជា ៣ ឋានន្តរស័ក្តិឋានានុក្រម ។ ឋានន្តរស័ក្តិនិមួយៗ ឆ្លើយតបទៅនឹងមុខតំណែងឬ សារព័ន្ធមុខតំណែងដែលមានការទទួលខុសត្រូវកាន់តែខ្ពស់ ។

**មាត្រា ១៤.**

និស្សិតដែលមិនមែនជាមន្ត្រីរាជការ ហើយដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងឱ្យចូលក្នុងមុខងារសាធារណៈចាំបាច់ត្រូវតាំងស៊ប់ក្នុងឋានន្តរស័ក្តិដំបូងនៃក្របខ័ណ្ឌ ។

**មាត្រា ១៥.**

ជាធម្មតាភ្នាក់ងារទាំងឡាយអាចមានឧបនិស្ស័យសំរាប់ដំណើរការអាជីពរហូតក្នុងវិជ្ជាជីវៈរបស់ខ្លួនក្នុងឋានន្តរស័ក្តិ ដំបូង ដោយមានការតម្លើងថ្នាក់ជាទៀងទាត់ទៅតាមបទប្បញ្ញត្តិ នៃសហលក្ខន្តិកៈនិងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌរបស់ខ្លួន ។

**មាត្រា ១៦.**

ការតម្លើងឋានន្តរស័ក្តិក្នុងឋានន្តរស័ក្តិទី២ ទី៣ គឺសំរាប់ភ្នាក់ងារណាដែលមានគុណសម្បត្តិជាងគេ ។ ការតម្លើងឋានន្តរស័ក្តិនេះ ផ្អែកទៅលើភាពទំនេរនៃតំណែង ហើយប្រព្រឹត្តទៅតាមការចុះឈ្មោះក្នុងតារាងតម្លើង

ឋានន្តរស័ក្តិ ឬតាមការទទួលបាននូវវិញ្ញាបនប័ត្រសិក្សារយៈពេលវែងនៅសាលាភូមិន្ទរដ្ឋបាល ឬ សាលាអនុវត្ត ដែលទទួលស្គាល់ដោយលក្ខន្តិកៈដោយឡែក ឬតាមការប្រឡងប្រជែង ។ អាចត្រូវបានតម្លើងឋានន្តរស័ក្តិទី២ នៃក្របខ័ណ្ឌមួយចំពោះភ្នាក់ងារទាំងឡាយណាដែលបាន ឡើងដល់ថ្នាក់ទី៤ នៃឋានន្តរស័ក្តិដំបូងរួចហើយ ។ អាចត្រូវបានតំម្លើងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមួយចំពោះភ្នាក់ងារ ទាំងឡាយណាដែលបានឡើងដល់ថ្នាក់ទី៤ នៃឋានន្តរស័ក្តិទី២រួចហើយ ។ ការឡើងឋានន្តរស័ក្តិទៅឋានន្តរស័ក្តិខ្ពស់ជាងមួយទៀត ផ្តល់ឧបនិស្ស័យដល់សាមីជន ដើម្បីទទួលមុខតំណែងស្របទៅតាមឋានន្តរស័ក្តិថ្មីដូចដែលបានកំណត់ក្នុងលក្ខន្តិកៈដោយឡែក ។

**មាត្រា ១៧**.

បែបបទនៃការដាក់ចំនួនភ្នាក់ងារបច្ចុប្បន្នបញ្ចូលក្នុងឋានន្តរស័ក្តិថ្មីនៃក្របខ័ណ្ឌ និងអន្តរប្បញ្ញត្តិត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៥
## អំពីថ្នាក់

**មាត្រា ១៨**.

ឋានន្តរស័ក្តិនីមួយៗ ត្រូវបានបែងចែកជាថ្នាក់ដែលមានសន្ទស្សន៍កំណត់អំពីកំរិតលាភការ ។

**មាត្រា ១៩**.

ឋានន្តរស័ក្តិទី១ត្រូវបានចែកចេញជា ១៤ថ្នាក់ ។ ឋានន្តរស័ក្តិទី២ ចែកចេញជា ១០ថ្នាក់ ។ ឋានន្តរស័ក្តិទី៣ ចែកចេញជា៦ថ្នាក់ ។

**មាត្រា ២០**.

ជាធម្មតាមន្ត្រីរាជការទាំងអស់ត្រូវបានតម្លើងថ្នាក់ក្នុង២ឆ្នាំម្តង វៀរលែងតែក្នុងករណីដែលត្រូវបានផ្តល់អត្ថប្រយោជន៍ស្តីអំពីអតីតភាព ដែលជាលទ្ធផលចេញមកពីស្នាដៃពិសេស ឬបើជាការចាំបាច់ពីភាពលំបាកពីកំរិតនៃការទទួលខុសត្រូវ ឬពីលក្ខណៈស្ថិតក្នុងតំបន់ដាច់ស្រយាលនៃមុខតំណែងខ្លះ ។ លក្ខន្តិកៈដោយឡែកត្រូវកំណត់ព្រំដែនជាក់លាក់នៃមុខតំណែងដែលអាចផ្តល់ប្រយោជន៍លើអតីតភាពថ្នាក់ ។

## ជំពូកទី៦
## អវសានបញ្ញត្តិ

**មាត្រា ២១**.

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ២២**.

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ហត្ថលេខា | ហត្ថលេខា |
| **អ៊ឹង ហួត** | **ហ៊ុន សែន** |

បានជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២
រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
ហត្ថលេខា

**ប្រាក់ សុខ**

# ៣. លក្ខន្តិកៈនៃក្របខ័ណ្ឌមន្ត្រីរាជការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ៣.១ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

- ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

# ព្រះរាជក្រឹត្យ

ជស/រកត/០៣០០/១១៦

## ស្តីពីលក្ខន្តិកៈដោយឡែក
## នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

## យើង

**ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០០

# ក្រាស់បញ្ជាប់
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**<u>មាត្រា១</u>**.

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ **ក** ដូចបានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**<u>មាត្រា២</u>**.

ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនេះស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាលសំរាប់បណ្តាក្រសួង-ស្ថាប័ននានា។ ឯការវិវត្តន៍របស់មន្ត្រីម្នាក់ៗគឺស្ថិតនៅក្រោមក្រសួង-ស្ថាប័នសាមី។

មិនត្រូវបានអនុញ្ញាតអោយបង្កើតក្របខ័ណ្ឌ សំរាប់ធ្វើការងារគ្រប់គ្រងរដ្ឋបាលផ្សេងពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលឡើយ លើកលែងតែក្រសួងមហាផ្ទៃ។

**<u>មាត្រា៣</u>**.

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មានឧបនិស្ស័យកាន់មុខតំណែងដឹកនាំ និងទទួលខុសត្រូវធ្វើអធិការកិច្ច ធ្វើការសិក្សា និងផ្តល់យោបល់ ក្នុងអង្គភាពរដ្ឋបាល គតិយុត្តិ សេដ្ឋកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស និងសង្គមកិច្ចនៃរដ្ឋបាលកណ្តាល និងខេត្តក្រុងស្របតាមមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។ មន្ត្រីក្នុងក្របខ័ណ្ឌនេះក៏មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងនៅក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ។

# ជំពូកទី២
# ឋានន្តរស័ក្តិ និង មុខតំណែង

**<u>មាត្រា៤</u>**.

ក្របខ័ណ្ឌមន្ត្រី គ្រប់គ្រងរដ្ឋបាល មាន ៣ ឋានន្តរស័ក្តិៈ

- -ឧត្តមមន្ត្រី មាន៦ថ្នាក់
- -វរៈមន្ត្រី មាន១០ថ្នាក់
- -អនុមន្ត្រី មាន១៤ថ្នាក់។

**មាត្រា៥.**

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជាៈ

-អគ្គនាយក

-អគ្គាធិការ

-និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិវរៈមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា

-អគ្គនាយករង

-អគ្គាធិការរង

-ប្រធាននាយកដ្ឋានក្នុងរដ្ឋបាលកណ្តាល

-និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិអនុមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជាៈ

- អនុប្រធាននាយកដ្ឋានក្នុងរដ្ឋបាលកណ្តាល

-ប្រធានមន្ទីរនៅខេត្ត ក្រុង

-និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន។

## ជំពូកទី៣
## ការជ្រើសរើស

**មាត្រា ៦.**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងក្នុងចំណោមបេក្ខជនជាមន្ត្រីរាជការ និង-ឬក្នុងចំណោមនិស្សិត។ ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជន ជាមន្ត្រីរាជការ និងសំរាប់បេក្ខជនជានិស្សិត ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ៧.**

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ៣០ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយដែលមានសញ្ញាប័ត្រទាបបំផុតសមមូលបរិញ្ញាប័ត្រ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបើកចំហចំពោះមន្ត្រីទាំងឡាយ ដែលស្ថិតយ៉ាងតិចបំផុតក្នុងថ្នាក់លេខ ១១ របស់ក្របខ័ណ្ឌប្រភេទ ខ និងមានអាយុច្រើនបំផុត ៤៥ ឆ្នាំ ។ ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌដែលមានសញ្ញាប័ត្រសមមូលនឹងបរិញ្ញាប័ត្រអាចប្រលងប្រជែងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតល័ក្ខខ័ណ្ឌ ឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៤៥ឆ្នាំ។

# ជំពូកទី៤
# ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨.**

បេក្ខជនដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែង ក្នុងចំណោមមន្ត្រីរាជការ និង-ឬក្នុងចំណោមនិស្សិតមានឋានៈជាសិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាល ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងនៅ សាលាភូមិន្ទរដ្ឋបាល។

**មាត្រា៩.**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវបានចាត់អោយទៅបំរើការងារតាមក្រសួង-ស្ថាប័ននានា ហើយត្រូវបានតែងតាំងជាមន្ត្រីគ្រប់គ្រងរដ្ឋបាលកម្មសិក្សា ដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មន្ត្រីគ្រប់គ្រងរដ្ឋបាលកម្មសិក្សាទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេលដូចខាងក្រោមនេះ

១- ១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីនិស្សិត។

២- ៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះពុំស្ថិតក្នុងក្របខ័ណ្ឌក្រមការ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះស្ថិតក្នុងក្របខ័ណ្ឌក្រមការពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បងមន្ត្រីដែលចែងក្នុងចំណុច ទី១ និងទី២ ខាងលើ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិអនុមន្ត្រី។ ក្នុងករណីពិសេសអាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម១២ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ១ និង ៦ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវលុបឈ្មោះចោលប្រសិនបើចេញមកពីនិស្សិត ឬ មួយបញ្ចូលទៅក្របខ័ណ្ឌដើមរបស់ខ្លួនវិញ ប្រសិនបើចេញមកពីមន្ត្រីរាជការដោយគិតបញ្ចូលសំរាប់អតីតភាពការងារ។ ករណីខាងលើទាំងនេះត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រោយពីមានសំណើរបស់ក្រសួង-ស្ថាប័នសាមីដោយបញ្ជាក់នូវមូលហេតុ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ខែ ក្រោយការបញ្ចប់កម្មសិក្សា។

មន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិតត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិអនុមន្ត្រី។

មន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។

## ជំពូកទី៥
## ការតែងតាំង

**មាត្រា១០.**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរួចហើយ មន្ត្រីគ្រប់គ្រងរដ្ឋបាលទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុងមាត្រា៥ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទដូចបានកំណត់ក្នុងមាត្រា ១៤ និងមាត្រាបន្តបន្ទាប់នៃព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី។

**មាត្រា១១.**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល អាចផ្លាស់ប្តូរពីក្រសួងស្ថាប័នមួយ ទៅក្រសួងស្ថាប័នមួយទៀតតាមការស្នើសុំរបស់សាមីខ្លួន ឬតាមតម្រូវការការងារដោយមានការឯកភាពរបស់ក្រសួងស្ថាប័នសាមីទាំងពីរ និងដោយមានការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ហើយត្រូវសំរេចដោយប្រកាស ឬអនុក្រឹត្យ ឬ ព្រះរាជក្រឹត្យ។

ការផ្លាស់ប្តូរនេះ ជាគោលការណ៍អាស្រ័យដោយតំណែងដែលមាននៅទំនេរក្នុងក្រសួង-ស្ថាប័នមួយទៀត ឬដោយសំណូមពរការងារចាំបាច់ ។

## ជំពូកទី៦
## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១២.**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និង មាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម៖

-មានគំនិតផ្តួចផ្តើម និងច្នៃប្រឌិត

-មានស្មារតីទទួលខុសត្រូវ

-យកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ

-មានប្រសិទ្ធភាពក្នុងការដឹកនាំ

-មានសីលធម៌ល្អ

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព។

ចំពោះការតម្លើងថ្នាក់៖

-ការតម្លើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីត្រូវសំរេចដោយព្រះរាជក្រឹត្យ

-ការតម្លើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិ វរៈមន្ត្រីត្រូវសំរេចដោយអនុក្រឹត្យ

-ការតម្លើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រីត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ១៣.**

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពី សន្ទស្សន៍ចាស់របស់មន្ត្រីសាមី។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលមានទំនេរនៅក្នុង ឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមរយៈការប្រឡងប្រជែង ឬមួយតាមរយៈការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុង ឬក្រៅប្រទេស។

ការតម្លើងឋានន្តរស័ក្តិពីអនុមន្ត្រីទៅវរៈមន្ត្រីត្រូវសំរេចដោយអនុក្រឹត្យ ហើយការតម្លើងឋានន្តរស័ក្តិ ពីវរៈមន្ត្រីទៅឧត្តមមន្ត្រីត្រូវសំរេចដោយព្រះរាជក្រឹត្យ។

**មាត្រា ១៤.**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃ ឋានន្តរស័ក្តិអនុមន្ត្រី។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់ លេខ ៧ នៃឋានន្តរស័ក្តិវរៈមន្ត្រី។

ការតម្លើងទៅក្នុងឋានន្តរស័ក្តិមួយខ្ពស់ជាង អាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមីសំរាប់កាន់មុខតំណែងស្របតាមឋានន្តរស័ក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា៥ នៃលក្ខន្តិកៈដោយឡែកនេះ។

**មាត្រា ១៥.**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងតំលៃឯកតានៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។

## ជំពូកទី៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦.**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលបំរើការងាររដ្ឋបាលរហូតដល់អាយុ ៦០ ឆ្នាំទើបចូលនិវត្តន៍។

ចំពោះការដាក់អោយចូលនិវត្តន៍៖

- ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ត្រូវសំរេចដោយព្រះរាជក្រឹត្យ
- ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី ត្រូវសំរេចដោយអនុក្រឹត្យ
- ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ១៧.**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលមានសញ្ញាប័ត្រខ្ពស់ជាងបរិញ្ញាប័ត្រត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ។

**មាត្រា ១៨.**

សញ្ញាស័ក្តិនិងឯកសណ្ឋានសំរាប់មន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយ ដោយឡែក។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា១៩.**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌក្នុងរដ្ឋបាលកណ្តាល និងខេត្តក្រុង។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២០.**

រាល់បទប្បញ្ញត្តិណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១.**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ ឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ:៤១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០០០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**ហត្ថលេខា**

**ពេជ្រ ប៊ុនធិន**

## ៣.២ ក្របខ័ណ្ឌមន្ត្រីក្រមការ

- ព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ

# ព្រះរាជក្រឹត្យ

នស/រកត/០៤០០/០៥៦

## ស្តីពីលក្ខន្តិកៈដោយឡែក

## នៃក្របខ័ណ្ឌមន្ត្រីក្រមការ

## យើង

## ព្រះបាទសម្តេចព្រះនរោត្តមសីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០០ ។

# គ្រាស់បន្ទាប់
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១.**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីក្រមការ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ខ ដូចបានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា២.**

ក្របខ័ណ្ឌមន្ត្រីក្រមការដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែក សំរាប់ក្របខ័ណ្ឌមន្ត្រីក្រមការនេះ ស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាលសំរាប់បណ្តាលក្រសួង ស្ថាប័ននានា។ ឯការវិវត្តន៍របស់មន្ត្រីម្នាក់ៗ គឺស្ថិតនៅក្រោមក្រសួងស្ថាប័នសាមី។

មិនត្រូវបានអនុញ្ញាតអោយបង្កើតក្របខ័ណ្ឌ សំរាប់ធ្វើការងារក្រមការផ្សេងពីក្របខ័ណ្ឌមន្ត្រី ក្រមការឡើយ លើកលែងតែក្រសួងមហាផ្ទៃ។

**មាត្រា៣.**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការ មានឧបនិស្ស័យសំរាប់ជាជំនួយក្នុងការងារដល់មន្ត្រីគ្រប់គ្រងរដ្ឋបាល ហើយអាចបំពេញមុខតំណែងដឹកនាំកំរិតមធ្យម ក្នុងអង្គភាពរដ្ឋបាល គតិយុត្តិ សេដ្ឋកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស និង សង្គមកិច្ចនៃរដ្ឋបាលកណ្តាល និងខេត្តក្រុងស្របតាមមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ របស់រដ្ឋ។

មន្ត្រីក្នុងក្របខ័ណ្ឌនេះ ក៏មានឧបនិស្ស័យសំរាប់បំពេញមុខតំណែង នៅក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ។

# ជំពូកទី២
# ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា៤.**

ក្របខ័ណ្ឌមន្ត្រីក្រមការមាន ៣ ឋានន្តរស័ក្តិះ

| | |
|---|---|
| -នាយក្រមការ | មាន០៦ថ្នាក់ |
| -ក្រមការដើមខ្សែ | មាន១០ថ្នាក់ |
| -ក្រមការ | មាន១៤ថ្នាក់។ |

**មាត្រា៥**.

មន្ត្រីក្នុងឋានន្តរស័ក្តិនាយក្រមការ មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា៖

-ប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល

-អនុប្រធានមន្ទីរនៅខេត្តក្រុង

-មុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន។

មន្ត្រីក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែ មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា៖

-អនុប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល

- ប្រធានការិយាល័យនៃមន្ទីរនៅខេត្ត ក្រុង

-មុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន។

មន្ត្រីក្នុងឋានន្តរស័ក្តិក្រមការ មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា៖

-អនុប្រធានការិយាល័យនៃមន្ទីរនៅខេត្តក្រុង

-មុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី៣
## ការជ្រើសរើស

**មាត្រា៦**.

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែង ក្នុងចំណោមបេក្ខជនជាមន្ត្រីរាជការ និង-ឬ ក្នុងចំណោមនិស្សិត។ ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជនជាមន្ត្រីរាជការ និង សំរាប់បេក្ខជនជានិស្សិត ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា៧**.

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុយ៉ាងច្រើន ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយមានសញ្ញាប័ត្រ ទាបបំផុតសមមូលមធ្យមសិក្សាប័ត្រភាគទី២+២ ឆ្នាំសិក្សា ក្នុងគ្រឹះស្ថានឧត្តមសិក្សា។ អាយុនេះអាចរំកិលពី ២៥ឆ្នាំ ឡើងដល់ ៣០ឆ្នាំ ស្របតាមមាត្រា១១ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបើកចំហចំពោះមន្ត្រីទាំងឡាយដែលស្ថិតយ៉ាងតិចបំផុតក្នុងថ្នាក់ លេខ ១១ របស់ក្របខ័ណ្ឌប្រភេទ គ និងមានអាយុយ៉ាងច្រើនបំផុត ៤០ឆ្នាំ។ ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌ

ដែលមានសញ្ញាប័ត្រសមមូលនឹងមធ្យមសិក្សាប័ត្រភាគទី ២+២ ឆ្នាំសិក្សា ក្នុងគ្រឹះស្ថានឧត្តមសិក្សាអាច ប្រឡងប្រជែងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតល័ក្ខខ័ណ្ឌ ឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៤០ឆ្នាំ។

## ជំពូកទី៤
## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨.**

បេក្ខជនដែលត្រូវបានជ្រើសរើស តាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និង-ឬ ក្នុងចំណោមនិស្សិត មានឋានៈជាសិស្សមន្ត្រីក្រមការ ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល។

**មាត្រា៩.**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីក្រមការ ត្រូវបានចាត់អោយទៅបំរើការងារតាមក្រសួង-ស្ថាប័ននានា ហើយត្រូវបានតែងតាំងជាមន្ត្រីក្រមការកម្មសិក្សា ដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

មន្ត្រីក្រមការកម្មសិក្សាទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេលដូចខាងក្រោម៖

១-១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីនិស្សិត។

២-៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុនពុំស្ថិតក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាល។

ចំពោះមន្ត្រី ដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុនស្ថិតក្នុងក្របខ័ណ្ឌ លេខាធិការរដ្ឋបាល ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បងមន្ត្រីដែលចែងក្នុងចំណុច ទី១ និងទី២ ខាងលើត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិក្រមការ ឬក្នុងករណីពិសេសអាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរិមា ត្រឹម១២ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ១ និង ៦ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវបានលុបឈ្មោះចោល ប្រសិនបើចេញមកពីនិស្សិត ឬ មួយបញ្ចូលទៅក្របខ័ណ្ឌដើមរបស់ខ្លួនវិញ ប្រសិនបើចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូលសំរាប់អតីតភាពការងារ។ ករណីខាងលើទាំងនេះត្រូវសំរេចដោយ ប្រកាសរបស់រដ្ឋលេខា ធិការដ្ឋានមុខងារសាធារណៈ តាមសំណើរបស់ក្រសួង-ស្ថាប័នសាមី ដោយបញ្ជាក់នូវមូលហេតុ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា។

មន្ត្រីក្រមការដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិក្រមការ។

មន្ត្រីក្រមការដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវធ្វើឡើងដោយអនុក្រឹត្យ។

## ជំពូកទី៥
## ការតែងតាំង

### មាត្រា១០.

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការរួចហើយ មន្ត្រីក្រមការទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុមាត្រា៥ ខាងលើស្របតាមឋានន្តរស័ក្តិ របស់ខ្លួនដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួង-ស្ថាប័នសាមីតាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី។

### មាត្រា១១.

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការអាចផ្លាស់ប្តូរពីក្រសួង ស្ថាប័នមួយ ទៅក្រសួង-ស្ថាប័នមួយទៀត តាមការស្នើសុំរបស់សាមីខ្លួន ឬតាមតំរូវការ ការងារដោយមានការឯកភាពរបស់ក្រសួងស្ថាប័នសាមីទាំងពីរ និងដោយមានការយល់ព្រម ពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

ការផ្លាស់ប្តូរនេះ ជាគោលការណ៍អាស្រ័យដោយតំណែងដែលមាននៅទំនេរក្នុងក្រសួង-ស្ថាប័ន មួយទៀត ឬដោយសំណូមពរការងារចាំបាច់។

## ជំពូកទី៦
## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

### មាត្រា ១២.

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោមនេះ៖

-គោរពវិន័យការងារបានត្រឹមត្រូវ

-មានស្មារតីទទួលខុសត្រូវ

-សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ

-មានសីលធម៌ល្អ

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ហើយត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ១៣**.

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលមានទំនេរនៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ តាមរយៈការប្រឡងប្រជែង ឬមួយតាមរយៈការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុង ឬក្រៅប្រទេស។

ការតម្លើងឋានន្តរស័ក្តិត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ១៤**.

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិក្រមការ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយក្រមការ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃ ឋានន្តរស័ក្តិក្រមការដើមខ្សែ។

ការតម្លើងទៅក្នុងឋានន្តរស័ក្តិមួយខ្ពស់ជាងអាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមី សំរាប់កាន់មុខតំណែងស្របតាមឋានន្តរស័ក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា៥ នៃលក្ខន្តិកៈដោយឡែកនេះ។

**មាត្រា ១៥**.

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីក្រមការ និងតម្លៃឯកតានៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។

## ជំពូកទី៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦**.

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវដាក់អោយចូលនិវត្តន៍នៅពេលដល់អាយុ ៥៨ ឆ្នាំ។

ដោយឡែក មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការដែលបំរើការងារក្នុងក្រសួងអប់រំ យុវជន និងកីឡា ការចូលនិវត្តន៍ត្រូវបានរំកិលដល់អាយុ ៦០ ឆ្នាំ ដូចក្របខ័ណ្ឌគ្រូបង្រៀននៃក្រសួងអប់រំ យុវជន និងកីឡា។

ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ១៧**.

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការ ដែលមានសញ្ញាប័ត្របរិញ្ញាប័ត្រ និងសញ្ញាប័ត្រសមមូលបរិញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ។

**មាត្រា ១៨**.

សញ្ញាស័ក្តិនិងឯកសណ្ឋានសំរាប់មន្ត្រីក្រមការ ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា១៩**.

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីទាំងឡាយ ដែលបច្ចុប្បន្ន កំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅរដ្ឋបាលកណ្តាល និងខេត្ត ក្រុង។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២០**.

រាល់បទប្បញ្ញត្តិណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១**.

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**ហត្ថលេខា**

**ពេជ្រ ប៊ុនធិន**

លេខៈ៥៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០០០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

## ៣.៣ ក្របខ័ណ្ឌមន្ត្រីលេខាធិការរដ្ឋបាល

❖ ព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/១០៣ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល

# ព្រះរាជក្រឹត្យ

នស/រកត/០៥០០/១០៣

## ស្តីពីលក្ខន្តិកៈដោយឡែក
## នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល

# យើង

## ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០០។

## គ្រាស់បន្ទាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.**

ត្រូវបានបង្កើតក្របខ័ណ្ឌលេខាធិការរដ្ឋបាល ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ **គ** ដូចបានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា២.**

ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែក សំរាប់ក្របខ័ណ្ឌលេខាធិការរដ្ឋបាលនេះ ស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាលសំរាប់បណ្តាក្រសួង-ស្ថាប័ននានា។ ឯការវិវត្តន៍របស់មន្ត្រីម្នាក់ៗគឺស្ថិតនៅក្រោមក្រសួងស្ថាប័នសាមី។

មិនត្រូវបានអនុញ្ញាតអោយបង្កើតក្របខ័ណ្ឌ សំរាប់ធ្វើការងារលេខាធិការរដ្ឋបាល ផ្សេងពីក្របខ័ណ្ឌលេខាធិការរដ្ឋបាលឡើយ លើកលែងតែក្រសួងមហាផ្ទៃ។

**មាត្រា៣.**

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលមានឧបនិស្ស័យសំរាប់បំពេញមុខតំណែងក្នុងលេខាធិការដ្ឋាន និងការទទួលភ្ញៀវព្រមទាំងមុខងារផ្នែករដ្ឋបាលធម្មតាទាំងឡាយដែលតម្រូវអោយមានទេពកោសល្យបច្ចេកទេស ឬការយល់ដឹងក្នុងការអនុវត្តន៍ជាក់ស្តែង។ មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក៏អាចមានឧបនិស្ស័យសំរាប់ត្រួតពិនិត្យលើការងាររបស់បុគ្គលិកនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលផងដែរ។ មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវដាក់អោយបំពេញមុខងារក្នុងអង្គភាពរដ្ឋបាលកណ្តាល ឬខេត្តក្រុងស្របតាមមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។ មន្ត្រីក្នុងក្របខ័ណ្ឌនេះក៏មានឧបនិស្ស័យសំរាប់ពេញមុខតំណែងនៅក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ។

## ជំពូកទី២
## ឋានន្តរស័ក្តិ

**មាត្រា៤.**

ក្របខ័ណ្ឌលេខាធិការរដ្ឋបាល មាន ៣ ឋានន្តរស័ក្តិ៖

- -នាយលេខាធិការរដ្ឋបាល មាន៦ថ្នាក់
- -លេខាធិការរដ្ឋបាលដើមខ្សែ មាន១០ថ្នាក់
- -លេខាធិការរដ្ឋបាល មាន១៤ថ្នាក់។

## ជំពូកទី៣
## ការជ្រើសរើស

**មាត្រា ៥.**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវធ្វើឡើងតាមរយៈប្រឡងប្រជែងដែលរៀបចំឡើងដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយមានការចូលរួមពីស្ថាប័នសាមី ក្នុងចំណោមបេក្ខជនជាមន្ត្រីរាជការ និង-ឬក្នុងចំណោមសិស្ស-និស្សិត។ ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជនជាមន្ត្រីរាជការ និងសំរាប់បេក្ខជនជាសិស្ស-និស្សិត ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ៦.**

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយដែលមានសញ្ញាប័ត្រទាបបំផុតសមមូលមធ្យមសិក្សាប័ត្រភាគទី២ ។ អាយុនេះអាចរំកិលពី ២៥ឆ្នាំ ឡើងដល់ ៣០ឆ្នាំ ស្របតាមមាត្រា ១១ នៃសហលក្ខនិកៈមន្ត្រីរាជការស៊ីវិល។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការត្រូវបើកចំហចំពោះមន្ត្រីទាំងឡាយ ដែលស្ថិតក្នុងក្របខ័ណ្ឌប្រភេទ **ឃ** ដែលបានបំពេញការងារ ៥ ឆ្នាំ ពេញលេញយ៉ាងតិចរួចមកហើយ។ ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌដែលមានសញ្ញាប័ត្រសមមូលនឹងមធ្យមសិក្សាប័ត្រភាគទី ២ អាចប្រឡងប្រជែងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតល័ក្ខខ័ណ្ឌអតីតភាពការងារ និងអាយុឡើយ។

## ជំពូកទី៤
## កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.**

បេក្ខជនដែលត្រូវបានជ្រើសរើស តាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និង-ឬ ក្នុងចំណោម សិស្ស-និស្សិតចាំបាច់ត្រូវឆ្លងកាត់រយៈពេលធ្វើកម្មសិក្សាមួយដែលមានរយៈពេលដូចខាងក្រោមនេះ៖

១-១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីសិស្ស-និស្សិត។

២-៦ ខែ ចំពោះមន្ត្រីដែលត្រូបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុនពុំស្ថិតក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុនស្ថិតក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលចែងក្នុងចំណុច ទី១ និងទី២ ខាងលើ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ឬ ក្នុងករណីចាំបាច់អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែមដែលមានរយៈពេលអតិបរិមា ត្រឹម ១២ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ១ និង ៦ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវបានលុប

ឈ្មោះចោលប្រសិនបើចេញមកពីសិស្ស-និស្សិត ឬ មួយបញ្ចូលទៅក្របខ័ណ្ឌដើមរបស់ខ្លួនវិញប្រសិនបើចេញមកពីមន្ត្រីរាជការដោយគិតបញ្ចូលសំរាប់អតីតភាពការងារ ។ ករណីខាងលើទាំងនេះត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមសំណើរបស់ក្រសួង-ស្ថាប័នសាមី ដោយបញ្ជាក់នូវមូលហេតុ។

មន្ត្រីលេខាធិការរដ្ឋបាល ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមសិស្ស-និស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិលេខាធិការរដ្ឋបាល។

មន្ត្រីលេខាធិការរដ្ឋបាល ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែង ក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន។

ការតាំងស៊ប់ជាមន្ត្រីលេខាធិការរដ្ឋបាលកម្មសិក្សា និងការតាំងស៊ប់ក្នុងឋានន្តរស័ក្តិលេខាធិការរដ្ឋបាល នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមសំណើរបស់ស្ថាប័នសាមី ។

## ជំពូកទី៥
## ការតែងតាំង

**មាត្រា៨**.

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាល រួចហើយ មន្ត្រីរាជការទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលស្របជាមួយឋានន្តរស័ក្តិរបស់ខ្លួន ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង-ស្ថាប័នសាមី តាមបែបបទដូចបានកំណត់ក្នុងមាត្រា២៨ នៃព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី។

**មាត្រា៩**.

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល អាចផ្លាស់ប្តូរពីក្រសួង ស្ថាប័នមួយ ទៅក្រសួងស្ថាប័នមួយទៀត តាមការស្នើសុំរបស់សាមីខ្លួន ឬតាមតំរូវការការងារដោយមានការឯកភាពរបស់ក្រសួងស្ថាប័នសាមីទាំងពីរ និងដោយមានការយល់ព្រម ពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

ការផ្លាស់ប្តូរនេះ ជាគោលការណ៍អាស្រ័យដោយតំណែងដែលមាននៅទំនេរក្នុងក្រសួង-ស្ថាប័នមួយទៀត ឬដោយសំណូមពរការងារចាំបាច់។

## ជំពូកទី៦
## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១០**.

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីលេខាធិការរដ្ឋបាល ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និង មាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម៖

-គោរពវិន័យការងារបានត្រឹមត្រូវ

-សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ

-មានសីលធម៌ល្អ

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ភាគ៤ តាមវេនជ្រើសរើសនិង ១ភាគ៤តាមវេនអតីតភាព ហើយត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ១១**.

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលមានទំនេរនៅក្នុង ឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ តាមរយៈការប្រឡងប្រជែងដោយរក្សាគោលការណ៍ភាគរយ។

-ឋានន្តរស័ក្តិនាយលេខាធិការរដ្ឋបាល ៥ភាគរយ

-ឋានន្តរស័ក្តិលេខាធិការរដ្ឋបាលដើមខ្សែ ២៥ភាគរយ

-ឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ៧០ភាគរយ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវសំរេចតាមប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ១២**.

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិលេខាធិការរដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិលេខាធិការរដ្ឋបាល។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយលេខាធិការរដ្ឋបាល គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃ ឋានន្តរស័ក្តិលេខាធិការរដ្ឋបាលដើមខ្សែ ។

**មាត្រា ១៣**.

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល និងតម្លៃឯកតានៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។

## ជំពូកទី៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៤**.

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលត្រូវដាក់អោយចូល និវត្តន៍ដល់ពេលអាយុ ៥៥ ឆ្នាំ ។

ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ១៥.**

មន្ត្រីនៃក្របខ័ណ្ឌ លេខាធិការរដ្ឋបាល ដែលមានសញ្ញាប័ត្រមធ្យមសិក្សាប័ត្រភាគទី២+២ ឆ្នាំ សិក្សា ដោយមានសញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា១៦.**

ចំនួនដំបូងនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវកសាងចេញពីសមាហរណកម្មនៃមន្ត្រីទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅរដ្ឋបាលកណ្តាល និងខេត្តក្រុង។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា១៧.**

រាល់បទប្បញ្ញត្តិណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨.**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ:១១២ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណ:**

**ហត្ថលេខា**

**ពេជ្រ ប៊ុនធិន**

# ៣.៤ ក្របខ័ណ្ឌមន្ត្រីរាជការរដ្ឋបាល

❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០០/១៣៥ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល

# ព្រះរាជក្រឹត្យ

នស/រកត/០៧០០/១៣៥

## ស្តីពីលក្ខន្តិកៈដោយឡែក

## នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០០

# ត្រាស់បង្គាប់
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១.**

ត្រូវបានបង្កើតក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ **ឃ** ដូចមានចែងក្នុងមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា២.**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែក សំរាប់ក្របខ័ណ្ឌភ្នាក់ងារ រដ្ឋបាលនេះ ស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាលសំរាប់បណ្តាក្រសួងស្ថាប័ននានា។ ឯការវិវត្តន៍របស់ភ្នាក់ងារម្នាក់ៗគឺស្ថិតនៅក្រោមក្រសួងស្ថាប័នសាមី។

មិនត្រូវបានអនុញ្ញាតអោយបង្កើតក្របខ័ណ្ឌ សំរាប់ធ្វើការងារភ្នាក់ងាររដ្ឋបាលផ្សេងពីក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលឡើយ លើកលែងតែក្រសួងមហាផ្ទៃ។

**មាត្រា៣.**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងក្នុងកិច្ចការប្រតិបត្តិនៅក្នុងអង្គភាពរដ្ឋបាលកណ្តាល និងខេត្ត ក្រុងហើយ និងក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ។

# ជំពូកទី២
# ឋានន្តរស័ក្តិនៃក្របខ័ណ្ឌ

**មាត្រា៤.**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល មាន ៣ ឋានន្តរស័ក្តិៈ

- នាយភ្នាក់ងាររដ្ឋបាល មាន៦ថ្នាក់
- ភ្នាក់ងាររដ្ឋបាលដើមខ្សែ មាន១០ថ្នាក់
- ភ្នាក់ងាររដ្ឋបាល មាន១៤ថ្នាក់។

# ជំពូកទី៣
# ការជ្រើសរើស

**មាត្រា ៥.**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែង ដែលរៀបចំឡើងដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។ ចំនួនតំណែងក្នុងការជ្រើសរើស ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ៦.**

ការប្រឡងប្រជែងជ្រើសរើសត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុច្រើន២៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ។ អាយុនេះអាចរំកិលពី ២៥ឆ្នាំ ឡើងដល់ ៣០ឆ្នាំ ស្របតាមមាត្រា ១១ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

## ជំពូកទី៤
## កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.**

បេក្ខជនដែលត្រូវបានជ្រើសរើសចាំបាច់ត្រូវឆ្លងកាត់រយៈពេលធ្វើកម្មសិក្សាមួយ ដែលប្រព្រឹត្តទៅស្របតាមបទប្បញ្ញត្តិ មាត្រា ១៦ និងមាត្រាបន្តបន្ទាប់ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បងមន្ត្រីនេះត្រូវបានតាំងស៊ប់ក្នុង ឋានន្តរស័ក្តិភ្នាក់ងារ ឬ ក្នុងករណីចាំបាច់អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម ១២ខែ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះត្រូវបានលុបឈ្មោះចោល។ ករណីខាងលើទាំងនេះ ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមសំណើររបស់ក្រសួងស្ថាប័ន សាមីដោយបញ្ជាក់នូវមូលហេតុ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា។ ការតែងតាំងជាភ្នាក់ងាររដ្ឋបាលកម្មសិក្សា និង ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

## ជំពូកទី៥
## ការតែងតាំង

**មាត្រា៨.**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិមួយរួចមក ភ្នាក់ងាររដ្ឋបាលទាំងនេះត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរមួយដែល ស្របជាមួយឋានន្តរស័ក្តិរបស់ខ្លួនដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងស្ថាប័នសាមីតាមបែបបទដូចបានកំណត់ក្នុងមាត្រា២៨ នៃព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី។

## ជំពូកទី៦
## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ៩.**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម៖

-គោរពវិន័យការងារបានត្រឹមត្រូវ

-សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ

-មានសីលធម៌ល្អ

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ភាគ៤ តាមវេនជ្រើសរើសនិង ១ ភាគ ៤ ក្នុងវេនអតីតភាព។

**មាត្រា ១០.**

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលមានទំនេរនៅក្នុង ឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ តាមរយៈការប្រឡងប្រជែងដោយរក្សាគោលការណ៍គិតជាភាគរយ

-ឋានន្តរស័ក្តិនាយភ្នាក់ងាររដ្ឋបាល = ៥ភាគរយ

-ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ = ២៥ភាគរយ

-ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល = ៧០ភាគរយ

ការតម្លើងថ្នាក់ និង តម្លើងឋានន្តរស័ក្តិ ត្រូវសំរេចតាមប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ១១.**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយភ្នាក់ងាររដ្ឋបាល គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃ ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ។

**មាត្រា ១២.**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល និងតម្លៃឯកតានៃសន្ទស្សន៍ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។

## ជំពូកទី៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៣.**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវដាក់អោយចូលនិវត្តន៍ពេលដល់អាយុ ៥៥ ឆ្នាំ។

ចំពោះការដាក់អោយចូនិវត្តន៍សំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា១៤.**

ចំនួនដំបូងនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅរដ្ឋបាលកណ្តាល និងខេត្ត ក្រុង។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា១៥.**

រាល់បទប្បញ្ញត្តិណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦.**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**ហត្ថលេខា**

**ពេជ្រ ប៊ុនធិន**

លេខៈ១៤៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

## ៣.៥ ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២

ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៥១

## ស្តីពីលក្ខន្តិកៈដោយឡែក
## នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

## យើង

**ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០០២

# ត្រាស់បង្គាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ **ក** ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា២.**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ប្រមូលផ្តុំមន្ត្រីបច្ចេកទេសកំរិតឧត្តម បំរើការងារបច្ចេកទេសតាមជំនាញផ្សេងៗ នៅក្នុងក្រសួង ស្ថាប័នរដ្ឋ។

**មាត្រា៣.**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងស្ថាប័នសាមីនីមួយៗ និង ក្រោមការគ្រប់គ្រងរួមរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ មានឧបនិស្ស័យ សំរាប់កាន់មុខតំណែងដឹកនាំ គ្រប់គ្រង សិក្សាស្រាវជ្រាវ លើកយោបល់ ធ្វើអធិការកិច្ចនិងទទួលខុសត្រូវលើការងារបច្ចេកទេសក្នុងអង្គភាពបច្ចេកទេសជំនាញនៅថ្នាក់កណ្តាល និងខេត្ត ក្រុង និងតាមគ្រឹះស្ថានសាធារណៈនានារបស់ក្រសួង ស្ថាប័នរដ្ឋ។

## ជំពូកទី២
## ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា៤.**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ មាន ៣ ឋានន្តរស័ក្តិៈ

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែពិសេស មាន ៦ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ មាន ១០ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ មាន ១៤ថ្នាក់

**មាត្រា៥.**

មន្ត្រីនៃក្របខ័ណ្ឌ មន្ត្រីបច្ចេកទេសជាន់ខ្ពស់អាចកាន់មុខតំណែងដឹកនាំគ្រប់គ្រង រួមជាមួយនិងមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅតាមអង្គភាពបច្ចេកទេសជំនាញនានា របស់ក្រសួង ស្ថាប័ននៅថ្នាក់កណ្តាល និងខេត្ត ក្រុង និងតាមគ្រឹះស្ថានសាធារណៈដូចតទៅៈ

+ ឋានន្តរស័ក្តិទី១ :

    -អគ្គលេខាធិការ

    -អគ្គនាយក អគ្គាធិការ

+ ឋានន្តរស័ក្តិទី២ :

-អគ្គលេខាធិការរង

- អគ្គនាយករង អគ្គាធិការរង

-ប្រធាននាយកដ្ឋាន អធិការ

+ ឋានន្តរស័ក្តិទី៣ :

- អធិការរង

-អនុប្រធាននាយកដ្ឋាន

-ប្រធានមន្ទីរខេត្ត ក្រុង

និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ក្នុងឋានន្តរស័ក្តិនីមួយៗ ក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី៣
## ការជ្រើសរើស

**មាត្រា ៦.**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវធ្វើឡើងតាមការប្រឡង ជ្រើសរើសក្នុងចំណោមបេក្ខជនជានិស្សិត និងជាមន្ត្រីរាជការ។ ចំនួនមុខតំណែងក្នុងការជ្រើសរើសតាមជំនាញនិងតាមក្រសួងស្ថាប័ន ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី។

**មាត្រា ៧.**

ការប្រឡងជ្រើសរើសក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ៣០ឆ្នាំ គិតមកដល់ថ្ងៃប្រលង និងយ៉ាងទាបមានសញ្ញាប័ត្រវិស្វករ បរិញ្ញាប័ត្រ ឬសញ្ញាប័ត្រសមមូល ។

លក្ខខណ្ឌក្នុងការប្រលងចូលក្របខ័ណ្ឌមន្ត្រី បច្ចេកទេសជាន់ខ្ពស់ សំរាប់បេក្ខជនជាមន្ត្រីរាជការ ត្រូវកំណត់យ៉ាងទាបត្រឹមថ្នាក់លេខ ១១ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម និងមានអាយុយ៉ាងច្រើន ៤៥ ឆ្នាំ។ មន្ត្រីរាជការ ដែលមានសញ្ញាប័ត្រដូចកំណត់ខាងលើ មិនតម្រូវលក្ខខណ្ឌក្របខ័ណ្ឌឡើយ។

## ជំពូកទី៤
## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨.**

បេក្ខជនដែលបានជ្រើសរើសចូលក្របខ័ណ្ឌ តាមរយៈការប្រលងជ្រើសរើសក្នុងចំណោមនិស្សិត និងក្នុងចំណោមមន្ត្រីរាជការ ត្រូវទទួលការបណ្តុះបណ្តាលដំបូងរៀបចំដោយក្រសួង ស្ថាប័នសាមី ហើយមានឋានៈជានិស្សិត មន្ត្រីបច្ចេកទេសជាន់ខ្ពស់។

ការបណ្តុះបណ្តាលដំបូង អាចប្រព្រឹត្តទៅតាមលក្ខណៈប្រមូលផ្តុំ ឬតាមការកំណត់ណាមួយផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

**មាត្រា៩.**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលប្រលងជាប់ ត្រូវបានបែងចែកអោយទៅបំរើការនៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុង និងថ្នាក់កណ្តាលរបស់ក្រសួង ស្ថាប័នសាមី ដោយផ្អែកលើលទ្ធផលនៃការបញ្ចប់វគ្គបណ្តុះបណ្តាល និងទៅតាមជំនាញដែលបានជ្រើសរើស ក្នុងពេលប្រលងចូលហើយត្រូវបានតែងតាំងជាមន្ត្រី បច្ចេកទេសជាន់ខ្ពស់កម្មសិក្សា ដោយប្រកាសរបស់ប្រធានស្ថាប័នទទួលបន្ទុក ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា១០.**

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលជ្រើសរើសចេញពីនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ខែ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី ៣។

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលជ្រើសរើសចេញពីមន្ត្រីបច្ចេកទេសមធ្យម ពុំចាំបាច់ធ្វើកម្មសិក្សាសាកល្បងឡើយ។ ក្រោយពីបានទទួលការបណ្តុះបណ្តាលដំបូង មន្ត្រីទាំងនេះ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់មន្ត្រីសាមី។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវសំរេចដោយព្រះរាជក្រឹត្យ។

**មាត្រា១១.**

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅឆ្នាំទី២ ទៀត។ ក្នុងករណីធ្លាក់នៅឆ្នាំទី២នេះ កម្មសិក្សាការីដែលជ្រើសរើសពីនិស្សិត ត្រូវលុបឈ្មោះចេញ។

## ជំពូកទី៥
## ការតែងតាំង

**មាត្រា១២.**

ក្រោយពេលតែងតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់អាចត្រូវ តែងតាំងក្នុងមុខតំណែងទំនេរណាមួយដែលមានកំណត់ក្នុងមាត្រា៣ និងមាត្រា៥ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួនតាមបែបបទដូចបានកំណត់ក្នុងមាត្រា១៤និងមាត្រាបន្តបន្ទាប់នៃព្រះរាជក្រម០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី។

# ជំពូកទី៦
# ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា១៣.**

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ អាចត្រូវដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែង ដើម្បីទៅបំរើការនៅក្រសួង ស្ថាប័ន ឬអង្គភាពណាមួយផ្សេងតាមតំរូវការ និងតាមការយល់ព្រមពីសាមីខ្លួន។

# ជំពូកទី៧
# ការតំឡើងថ្នាក់ និង ការតំឡើងឋានន្តរស័ក្តិ

**មាត្រា ១៤.**

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ត្រូវដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និង មាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យដំឡើងថ្នាក់មានដូចខាងក្រោមនេះ

-គំនិតផ្តួចផ្តើមច្នៃប្រឌិត និងលទ្ធផលនៃការងារ

-ស្មារតីទទួលខុសត្រូវក្នុងការងារនិងមនសិការវិជ្ជាជីវៈ

-ការយកចិត្តទុកដាក់ចំពោះផលប្រយោជន៍ជាតិ

-ប្រសិទ្ធភាពនៃការដឹកនាំគ្រប់គ្រងចាត់ចែងអនុវត្តការងារ

-សាមគ្គីធម៌និង សីលធម៌រស់នៅល្អ

ការដំឡើងថ្នាក់មន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ភាគ៤ តាមវេនជ្រើសរើសនិង ១ ភាគ ៤ តាមវេនអតីតភាព។

-ការដំឡើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិទី១ ត្រូវសំរេចដោយព្រះរាជក្រឹត្យ

-ការដំឡើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិទី២ ត្រូវសំរេចដោយអនុក្រឹត្យ

-ការដំឡើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិទី៣ ត្រូវសំរេចដោយប្រកាសរបស់ ក្រសួង ស្ថាប័នសាមី។

**មាត្រា ១៥.**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិតាមធម្មតាត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ត្រូវដំឡើងទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់មន្ត្រីសាមី។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចតទៅៈ

-៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី១

-២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២

-៧០% ឡើងទៅសំរាប់ឋានន្តរស័ក្តិទី៣។

ការដំឡើងឋានន្តរស័ក្តិ ត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិ និង តាមការវាយតម្លៃរបស់ឋានានុក្រមគ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាលរយៈពេលវែងក្នុងឬក្រៅប្រទេស។

ការដំឡើងឋានន្តរស័ក្តិ ទី៣ទៅទី២ ត្រូវសំរេចដោយអនុក្រឹត្យ។

ការដំឡើងឋានន្តរស័ក្តិ ទី២ទៅទី១ ត្រូវសំរេចដោយព្រះរាជក្រឹត្យ។

**មាត្រា ១៦**.

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី២ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ ៧ នៃ ឋានន្តរស័ក្តិទី២ ។

**មាត្រា ១៧**.

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតម្លៃឯកតានៃសន្ទស្សន៍ ត្រូវកំណត់ស្របតាមមាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការ។

## ជំពូកទី៨
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៨**.

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៦០ឆ្នាំ។

ការដាក់អោយចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិទី១ ត្រូវសំរេចដោយព្រះរាជក្រឹត្យ។

ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរសក្តិទី២ ត្រូវសំរេចដោយអនុក្រឹត្យ។

ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរសក្តិទី៣ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី។

**មាត្រា ១៩**.

មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលក្រសួង ស្ថាប័ន ចាត់អោយទៅទទួលការបំប៉ន ឬ ការបណ្តុះបណ្តាលជំនាញបន្ត ដែលមានរយៈពេលសរុបចាប់ពី ០១ ឆ្នាំឡើងទៅដោយមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា ត្រូវទទួលការដំឡើងថ្នាក់ ០១ថ្នាក់ ជាស្វ័យប្រវត្តិតាមវេនជ្រើសរើស។

មន្ត្រីដែលមានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រវិស្វករ ត្រូវដំឡើងថ្នាក់ ០១ ថ្នាក់ជាស្វ័យប្រវត្តិ។

**មាត្រា ២០**.

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវទទួលប្រាក់បំណាច់មុខងារ ប្រាក់ហានិភ័យ និងប្រាក់បំណាច់ផ្សេងៗទៀត ស្របតាមការកំណត់នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ។

**មាត្រា ២១**.

សញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា២២.**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រី បច្ចេកទេសជាន់ខ្ពស់ ត្រូវកសាងចេញពីការធ្វើសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌតាមជំនាញផ្សេងៗ នៅតាមអង្គភាពបច្ចេកទេសជំនាញថ្នាក់កណ្តាល និងខេត្ត ក្រុងរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា២៣.**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៤.**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ។

**មាត្រា២៥.**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ១៣៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**

## ៣.៦ ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម

❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៥២

## ស្តីពី
## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម

## យើង
## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍ រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពី សម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុង សម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០០២

# គ្រាស់បន្ទាប់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ **ខ** ដូចមានចែងក្នុងមាត្រា នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា២.**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ប្រមូលផ្តុំមន្ត្រីបច្ចេកទេសកំរិតមធ្យម បំរើការងារបច្ចេកទេសតាមជំនាញផ្សេងៗនៅក្នុងក្រសួង ស្ថាប័នរដ្ឋ។

**មាត្រា៣.**

ក្របខណ្ឌ័មន្ត្រីបច្ចេកទេសមធ្យម ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ របស់ក្រសួងស្ថាប័ន សាមីនីមួយៗ និងក្រោមការគ្រប់គ្រងរួមរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។ មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម មានឧបនិស្ស័យសំរាប់ជាជំនួយ ដល់មន្ត្រីបច្ចេកទេសជាន់ខ្ពស់ក្នុងការសំរេច និងអនុវត្តការងារ និងអាចបំពេញមុខតំណែងដឹកនាំកំរិតមធ្យម ក្នុងអង្គភាពបច្ចេកទេសជំនាញនៅថ្នាក់កណ្តាល និងខេត្ត ក្រុង និងតាមគ្រឹះស្ថានសាធារណៈនានា របស់ក្រសួង ស្ថាប័នរដ្ឋ។

## ជំពូកទី ២
## ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា៤-**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមមាន ៣ ឋានន្តរស័ក្តិៈ

-ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម ដើមខ្សែពិសេស មាន៦ ថ្នាក់

-ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម ដើមខ្សែ មាន ១០ ថ្នាក់

-ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម មាន ១៤ ថ្នាក់។

**មាត្រា៥-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម អាចកាន់មុខតំណែងគ្រប់គ្រង រួមជាមួយនឹងមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅតាមអង្គភាពជំនាញបច្ចេកទេសនានារបស់ក្រសួង ស្ថាប័ននៅថ្នាក់កណ្តាល និង ខេត្ត ក្រុង ដូចតទៅៈ

- ឋានន្តរស័ក្តិទី១ :

  -ប្រធានការិយាល័យនៅរដ្ឋបាលកណ្តាល

  -អនុប្រធានមន្ទីរខេត្ត ក្រុង

- ឋានន្តរស័ក្តិទី២

-អនុប្រធានការិយាល័យនៅរដ្ឋបាលកណ្តាល

-ប្រធានការិយាល័យមន្ទីរខេត្ត ក្រុង

- ឋានន្តរស័ក្តិទី៣

-អនុប្រធានការិយាល័យមន្ទីរខេត្ត ក្រុង

-ប្រធានការិយាល័យស្រុក ខ័ណ្ឌ

និងមុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ក្នុងឋានន្តរស័ក្តិនីមួយៗ ក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី ៣
## ការជ្រើសរើស

**មាត្រា៦**-

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជានិស្សិត និងជាមន្ត្រីរាជការ។

ចំនួនមុខតំណែងជ្រើសរើសតាមជំនាញ និងតាមក្រសួង ស្ថាប័ន ត្រូវកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយយោងតាមការស្នើសុំពី ក្រសួង ស្ថាប័នសាមី។

**មាត្រា៧**-

ការប្រលងជ្រើសរើសក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជន ដែលមាន អាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រលង និងយ៉ាងទាប មានសញ្ញាប័ត្រមធ្យមបច្ចេកទេស ឬ សញ្ញាប័ត្រសមមូល។

លក្ខខណ្ឌក្នុងការប្រលងចូលក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម សំរាប់បេក្ខជនជាមន្ត្រីរាជការ ត្រូវកំណត់យ៉ាងទាបត្រឹមថ្នាក់លេខ ១១ នៃក្របខ័ណ្ឌ មន្ត្រីបច្ចេកទេសបឋម និងមានអាយុយ៉ាងច្រើន៤០ឆ្នាំ។ មន្ត្រីរាជការដែលមានសញ្ញាប័ត្រដូចកំណត់ខាងលើមិនតម្រូវលក្ខខណ្ឌក្របខ័ណ្ឌឡើយ។

## ជំពូកទី ៤
## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និងការតាំងស៊ប់

**មាត្រា៨**-

បេក្ខជនដែលបានជ្រើសរើសចូលក្របខ័ណ្ឌ តាមរយៈការប្រលងជ្រើសរើសក្នុងចំណោមនិស្សិត និងក្នុងចំណោមមន្ត្រីរាជការ ត្រូវទទួលការបណ្តុះបណ្តាល ដំបូងរៀបចំដោយក្រសួង ស្ថាប័នសាមី ហើយមានឋានៈជានិស្សិតមន្ត្រីបច្ចេកទេសមធ្យម ។

ការបណ្តុះបណ្តាលដំបូង អាចប្រព្រឹត្តទៅតាមលក្ខណៈប្រមូលផ្តុំ ឬតាមការកំណត់ណាមួយផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

**មាត្រា៩**-

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីបច្ចេកទេសមធ្យម ដែលប្រឡងជាប់ត្រូវបានបែងចែកទៅបំរើការនៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុង និងថ្នាក់កណ្តាលរបស់ក្រសួង ស្ថាប័នសាមី ដោយផ្អែកលើលទ្ធផលនៃការបញ្ចប់វគ្គបណ្តុះបណ្តាល និងទៅតាមជំនាញ ដែលបានជ្រើសរើសក្នុងពេលប្រលងចូល ហើយត្រូវបានតែងតាំងជាមន្ត្រី បច្ចេកទេសមធ្យមកម្មសិក្សា ដោយប្រកាសរបស់ប្រធានស្ថាប័នទទួលបន្ទុក ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា១០**-

មន្ត្រីបច្ចេកទេសមធ្យម ដែលជ្រើសរើសចេញពីនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុង ថ្នាក់ លេខ ១៤ នៃឋាននន្តរស័ក្តិទី៣ ។

មន្ត្រីបច្ចេកទេសមធ្យមដែលជ្រើសរើសចេញពីមន្ត្រីបច្ចេកទេសបឋម ពុំចាំបាច់ធ្វើកម្មសិក្សាសាកល្បងឡើយ ។ ក្រោយពីបានទទួលការបណ្តុះបណ្តាលដំបូង មន្ត្រីទាំងនេះត្រូវតាំងស៊ប់ក្នុងឋាននន្តរស័ក្តិទី៣ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់មន្ត្រីសាមី ។

ការតាំងស៊ប់ក្នុង ឋាននន្តរស័ក្តិទី៣ នៃក្របខណ្ឌមន្ត្រីបច្ចេកទេសមធ្យមត្រូវសំរេចដោយអនុក្រឹត្យ ។

**មាត្រា១១**-

មន្ត្រីបច្ចេកទេសមធ្យម ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវបានអនុញ្ញាតឲ្យ បន្តកម្មសិក្សានៅឆ្នាំទី២ទៀត។ ក្នុងករណីធ្លាក់នៅឆ្នាំទី២នេះកម្មសិក្សាការីដែលជ្រើសរើសពីនិស្សិតត្រូវលុបឈ្មោះចេញ។

## ជំពូកទី៥
## ការតែងតាំង

**មាត្រា១២**-

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីបច្ចេកទេសមធ្យមអាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលមានកំណត់ក្នុងមាត្រា ៣ និងមាត្រា ៥ ខាងលើស្របតាម ឋាននន្តរស័ក្តិ របស់ខ្លួន តាមបែបបទដូចមានកំណត់ក្នុងមាត្រា២៨ នៃព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃគណៈរដ្ឋមន្ត្រី។

# ជំពូកទី៦
# ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា១៣**-

មន្ត្រីបច្ចេកទេសមធ្យមអាចត្រូវដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែង ដើម្បីបំរើការនៅក្រសួងស្ថាប័ន ឬអង្គភាពណាមួយផ្សេងតាមតំរូវការ និងតាមការយល់ព្រមពីសាមីខ្លួន។

# ជំពូកទី៧
# ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

**មាត្រា១៤**-

មន្ត្រីបច្ចេកទេសមធ្យម ត្រូវបានដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

លក្ខណៈសម្បត្តិជាមូលដ្ឋាន សំរាប់ការពិនិត្យដំឡើងថ្នាក់មានដូចខាងក្រោម៖

-វិន័យនិងលទ្ធផលនៃការងារ

-ស្មារតីទទួលខុសត្រូវក្នុងការងារ និងមនសិការវិជ្ជាជីវៈ

-សាមគ្គីធម៌ និងសីលធម៌រស់នៅល្អ។

ការដំឡើងថ្នាក់មន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ភាគ ៤ តាមវេនជ្រើសរើស តាម១ភាគ៤ តាមវេនអតីតភាព។ ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

**មាត្រា១៥**-

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ឬក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ ដែលមានសន្ទស្សន៍ខ្ពស់ បន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចតទៅៈ

-៥% ជាអតិបរមាសំរាប់ឋានន្តរសក្តិទី១

-២៥%ជាអតិបរមាសំរាប់ឋានន្តរសក្តិទី២

-៧០%ឡើងទៅសំរាប់ឋានន្តសក្តិទី៣។

ការដំឡើងឋានន្តរស័ក្តិត្រូវធ្វើតាមរយៈការចុះឈ្មោះ ក្នុងតារាងដំឡើងឋានន្តរស័ក្តិ និងតាមការវាយតម្លៃរបស់ឋានានុក្រមគ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាលរយៈពេលវែងក្នុង ឬក្រៅប្រទេស។

ការដំឡើងឋានន្តរស័ក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី។

**មាត្រា១៦**-

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី២គឺមន្ត្រី ដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី៣។

អាចដំឡើងឋានន្តិរស័ក្តិទី១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី៧ នៃឋានន្តរស័ក្តិទី២។

**មាត្រា១៧**-

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតម្លៃឯកតានៃសន្ទស្សន៍ ត្រូវកំណត់ស្រប តាមមាត្រា ៣និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០១ស្តីពី បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការ។

## ជំពូកទី ៨
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៨**-

មន្ត្រីបច្ចេកទេសមធ្យមត្រូវដាក់អោយចូលនិវត្តិន៍ ពេលដល់អាយុ ៥៨ឆ្នាំ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី។

**មាត្រា១៩**-

មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដែលក្រសួង ស្ថាប័ន ចាត់អោយទៅទទួលការបំប៉ន ឬការបណ្តុះបណ្តាលជំនាញបន្ត ដែលមានរយៈពេលសរុបចាប់ពី ០១ ឆ្នាំ ឡើងទៅដោយមានវិញ្ញាប័នប័ត្របញ្ជាក់ ការសិក្សា ត្រូវបានទទួលការតម្លើងថ្នាក់ ០១ ថ្នាក់ ជាស្វ័យប្រវត្តិតាមវេនជ្រើសរើស។

មន្ត្រីដែលមានសញ្ញាប័ត្រ ខ្ពស់ជាងសញ្ញាប័ត្រមធ្យមបច្ចេកទេស ត្រូវបានដំឡើងថ្នាក់ ០១ ថ្នាក់ជាស្វ័យ ប្រវត្តិ។

**មាត្រា២០**-

មន្ត្រីបច្ចេកទេសមធ្យម ត្រូវបានទទួលប្រាក់បំណាច់មុខងារ ប្រាក់ហានិភ័យ និងប្រាក់បំណាច់ផ្សេងៗ ស្របតាមការកំណត់នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្ស មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ។

**មាត្រា២១**-

សញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់មន្ត្រីបច្ចេកទេសមធ្យម ត្រូវកំណត់ដោយព្រះរាជក្រឹត្យ មួយដោយឡែក។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា២២-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ត្រូវកសាងចេញពីការធ្វើសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ តាមជំនាញផ្សេងៗ នៅតាមអង្គភាពបច្ចេកទេសជំនាញ ថ្នាក់កណ្តាល និងខេត្ត ក្រុងរបស់ ក្រសួង ស្ថាប័ន។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា២៣-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៤-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ។

**មាត្រា២៥-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០២

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រសូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ១៣៩ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ៣.៧ ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម

❖ ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០២/១៥៣ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២

ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៥៣

## ស្តីពី
## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម
## យើង
## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០០២

# គ្រាស់បន្ទាប់
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១**.

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ **គ** ដូចមានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា២**.

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ប្រមូលផ្តុំមន្ត្រីដែលមានទេពកោសល្យបច្ចេកទេសឬការយល់ដឹងក្នុងការអនុវត្តជាក់ស្តែង សំរាប់ប្រតិបត្តិការងារជំនាញផ្សេងៗ នៅក្នុងអង្គភាពបច្ចេកទេសជំនាញ នៅថ្នាក់កណ្តាល និងខេត្ត ក្រុង និង គ្រឹះស្ថានសាធារណៈរបស់ក្រសួងស្ថាប័ន។

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម មានឧបនិស្ស័យអាចបំពេញមុខតំណែងត្រួតពិនិត្យ លើការងាររបស់មន្ត្រីក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេសផងដែរ។

**មាត្រា៣**.

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ស្ថាប័នសាមីនីមួយៗ និងក្រោមការគ្រប់គ្រងរួម របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា៤**.

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋមមាន ៣ ឋានន្តរស័ក្តិៈ

-ឋានន្តរស័ក្តិទី១ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម ដើមខ្សែពិសេស មាន ៦ថ្នាក់

-ឋានន្តរស័ក្តិទី២ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម ដើមខ្សែ មាន ១០ថ្នាក់

-ឋានន្តរស័ក្តិទី៣ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម មាន១៤ថ្នាក់។

# ជំពូកទី២
# ការជ្រើសរើស

**មាត្រា ៥**.

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជាសិស្ស និស្សិត និងជាមន្ត្រីរាជការ។

ចំនួនមុខតំណែងជ្រើសរើសតាមជំនាញនិងតាមក្រសួង ស្ថាប័ន ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី។

**មាត្រា ៦.**

ការប្រលងជ្រើសរើស ក្នុងចំណោមសិស្ស និស្សិត ត្រូវបើកចំហចំពោះបេក្ខជន ដែលមានអាយុច្រើនបំផុត ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រលង និងយ៉ាងទាបមានសញ្ញាប័ត្រមធ្យមសិក្សាភាគទី២ ឬសញ្ញាប័ត្រសមមូល។

លក្ខខណ្ឌក្នុងការប្រលងចូលក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម សំរាប់បេក្ខជនជាមន្ត្រីរាជការ ត្រូវកំណត់យ៉ាងទាបត្រឹមថ្នាក់លេខ ១១ នៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ឬមានសញ្ញាប័ត្រដូចកំណត់ខាងលើ។

## ជំពូកទី៣
## កម្មសិក្សាសាកល្បង ការតាំងស៊ប់ និងការតែងតាំង

**មាត្រា៧.**

បេក្ខជនដែលប្រលងជាប់ ត្រូវបែងចែកអោយទៅបំរើការនៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុងនិងថ្នាក់កណ្តាល របស់ក្រសួង ស្ថាប័នសាមី ទៅតាមជំនាញ ដែលជ្រើសរើសក្នុងពេលប្រលងចូលហើយ ត្រូវតែងតាំងជាមន្ត្រីបច្ចេទេសបឋមកម្មសិក្សា ដោយប្រកាស របស់ប្រធានស្ថាប័នទទួលបន្ទុក។

**មាត្រា៨.**

មន្ត្រីបច្ចេកទេសបឋមដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃ ឋានន្តរស័ក្តទី ៣។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ត្រូវសំរេចដោយប្រកាស របស់ក្រសួងស្ថាប័នសាមី ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសារធារណៈ។

**មាត្រា៩.**

មន្ត្រីបច្ចេទេសបឋម ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សា នៅឆ្នាំទី២ទៀត។ ក្នុងករណីធ្លាក់នៅឆ្នាំទី២នេះ កម្មសិក្សាការីដែលជ្រើសរើសពីសិស្ស និស្សិត ត្រូវលុបឈ្មោះ ចេញ។

**មាត្រា១០.**

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម អាចត្រូវតែងតាំងក្នុងមុខតំណែងទំនេរ ណាមួយដែលមានកំណត់ក្នុងមាត្រា២ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួនតាមបែបបទ ដូចមានកំណត់ក្នុង មាត្រា ២៨ នៃព្រះរាជក្រមលេខ០០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

**មាត្រា១១.**

មន្ត្រីបច្ចេទេសបឋម អាចត្រូវដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែងដើម្បីទៅបំរើការនៅក្រសួងស្ថាប័ន ឬអង្គភាពណាមួយផ្សេងតាមតំរូវការនិងតាមការយល់ព្រមពីសាមីខ្លួន។

## ជំពូកទី៤
## ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

**មាត្រា ១២.**

មន្ត្រីបច្ចេកទេសបឋម ត្រូវបានដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

លក្ខណៈសម្បត្តិជាមូលដ្ឋានសំរាប់ការពិនិត្យដំឡើងថ្នាក់ មានដូចខាងក្រោមៈ

-វិន័យ និងលទ្ធផលការងារ

-ស្មារតីទទួលខុសត្រូវក្នុងការងារ និងមនសិការវិជ្ជាជីវៈ

-សាមគ្គីធម៌ និងសីលធម៌រស់នៅល្អ។

ការដំឡើងថ្នាក់នៃមន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ភាគ ៤ តាមវេនអតីតភាព។

ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួងស្ថាប័នសាមី។

**មាត្រា ១៣.**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតាត្រូវដំឡើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ឬ ក្នុងករណីចាំបាច់ត្រូវដំឡើងទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បន្ទាប់ពីសន្ទស្សន៍ បៀវត្សចាស់របស់មន្ត្រីសាមី។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចខាងក្រោមៈ

-៥%ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី១

-២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២

-៧០%ឡើងទៅសំរាប់ឋានន្តរស័ក្តិទី៣។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី២គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ១១ នៃឋានន្តរស័ក្តិទី៣។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី១គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី៧ នៃឋានន្តរស័ក្តិទី២។

ការដំឡើងឋានន្តរស័ក្តិត្រូវសំរេចដោយប្រកាសរបស់ក្រសួងស្ថាប័នសាមី។

**មាត្រា ១៤.**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតំលៃឯកតានៃសន្ទស្សន៍ត្រូវកំណត់ស្របតាមមាត្រា៣ និងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ។

## ជំពូកទី៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៥.**

មន្ត្រីបច្ចេកទេសបឋមត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៥៥ ឆ្នាំ។

ការដាក់អោយចូលនិវត្តន៍ត្រូវសំរេចដោយប្រកាសរបស់ក្រសួងស្ថាប័នសាមី។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៦.**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ត្រូវកសាងចេញពីការធ្វើសមាហរណកម្មមន្ត្រីរាជការដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ តាមជំនាញផ្សេងៗ នៅតាមអង្គភាពបច្ចេកទេសជំនាញថ្នាក់កណ្តាល និងខេត្តក្រុងរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៧.**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨.**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

**មាត្រា១៩.**

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ:១៤០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឱ តាន់**

## ៣.៨ ក្របខ័ណ្ឌមន្ត្រីភ្នាក់ងារបច្ចេកទេស

- ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០២/១៥៤ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៥៤

## ស្តីពី
## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស

## យើង
## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០០២

## ត្រាស់បង្គាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.**

ត្រូវបានបង្កើតក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ **ឃ** ដូចមានចែងក្នុងមាត្រា ៦នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា២.**

ក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ប្រមូលផ្តុំមន្ត្រីដែលមានមុខងារក្នុងការប្រតិបត្តិផ្សេងៗ នៅក្នុងអង្គភាពបច្ចេកទេសជំនាញនៅថ្នាក់កណ្តាល និងខេត្ត ក្រុងនៃក្រសួងស្ថាប័ន។

**មាត្រា៣.**

ក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងស្ថាប័នសាមីនីមួយៗ និងក្រោមការគ្រប់គ្រងរួម របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា៤.**

ក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេសមាន ៣ ឋានន្តរស័ក្តិៈ

-ឋានន្តរស័ក្តិទី១ ឬ ឋានន្តរស័ក្តិនាយភ្នាក់ងារបច្ចេកទេស មាន ៦ថ្នាក់
-ឋានន្តរស័ក្តិទី២ ឬ ឋានន្តរស័ក្តិនាយភ្នាក់ងារបច្ចេកទេសដើមខ្សែ មាន ១០ថ្នាក់
-ឋានន្តរស័ក្តិទី៣ ឬ ឋានន្តរស័ក្តិនាយភ្នាក់ងារបច្ចេកទេស មាន ១៤ថ្នាក់។

## ជំពូកទី ២
## ការជ្រើសរើស

**មាត្រា ៥.**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស រៀបចំដោយក្រសួង ស្ថាប័នសាមី។

ចំនួនមុខតំណែងជ្រើសរើស ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់មុខងារសាធារណៈ ដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី។

**មាត្រា ៦.**

ការប្រឡងជ្រើសរើស ត្រូវបើកចំហចំពោះបេក្ខជន ដែលមានកាយសម្បទាសមស្របតាមការងារ និងមានអាយុច្រើនបំផុត ២៥ ឆ្នាំគិតមកដល់ថ្ងៃប្រលង ដោយពុំតំរូវនូវលក្ខខណ្ឌសញ្ញាប័ត្រអ្វីឡើយ។

## ជំពូកទី ៣
## កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.**

បេក្ខជនដែលប្រលងជាប់ ត្រូវបែងចែកអោយទៅបំរើការនៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុងនិងថ្នាក់កណ្តាល របស់ក្រសួង ស្ថាប័ន ហើយត្រូវបានតែងតាំងជាភ្នាក់ងារបច្ចេកទេស កម្មសិក្សាដោយប្រកាសរបស់ប្រធានស្ថាប័នទទួលបន្ទុក។

កម្មសិក្សានេះមានរយៈពេល ១២ខែ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី៣ ដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ៨.**

ភ្នាក់ងារបច្ចេកទេស ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សា នៅឆ្នាំទី២ទៀត។ ក្នុងករណីធ្លាក់នៅឆ្នាំទី២ នេះ ភ្នាក់ងារនោះត្រូវលុបឈ្មោះចេញ។

## ជំពូកទី ៤
## ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

**មាត្រា ៩.**

ភ្នាក់ងារបច្ចេកទេស ត្រូវបានដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

លក្ខណៈសម្បត្តិជាមូលដ្ឋានសំរាប់ការពិនិត្យតម្លើងថ្នាក់ មានដូចខាងក្រោមៈ

-វិន័យ និងលទ្ធផលការងារ

-ស្មារតីទទួលខុសត្រូវក្នុងការងារ និងមនសិការវិជ្ជាជីវៈ

-សាមគ្គីធម៌ និងសីលធម៌រស់នៅល្អ។

ការដំឡើងថ្នាក់នៃមន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព។

ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួងស្ថាប័នសាមី។

**មាត្រា ១០.**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចខាងក្រោមៈ

-៥%ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី១

-២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២

-៧០%ឡើងទៅសំរាប់ឋានន្តរស័ក្តិទី៣។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី២ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ១១ នៃឋានន្តរស័ក្តិទី៣។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី៧ នៃឋានន្តរស័ក្តិទី២។

ការដំឡើងឋានន្តរស័ក្តិត្រូវសំរេចដោយប្រកាសរបស់ក្រសួងស្ថាប័នសាមី។

## ជំពូកទី៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១១.**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌនិងតំលៃឯកតានៃសន្ទស្សន៍ត្រូវកំណត់ ស្របតាមមាត្រា ៣ និង មាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ។

**មាត្រា ១២.**

ភ្នាក់ងារបច្ចេកទេសត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៥៥ ឆ្នាំ។

ការដាក់អោយចូលនិវត្តន៍ត្រូវសំរេចដោយប្រកាសរបស់ក្រសួងស្ថាប័នសាមី។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៣.**

ចំនួនដំបូងនៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ត្រូវកសាងចេញពីការធ្វើសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ តាមអង្គភាពបច្ចេកទេសជំនាញ ថ្នាក់កណ្តាល និងខេត្ត ក្រុងរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៤.**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥**.

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ។

**មាត្រា១៦**.

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ១៤១ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ៤. ប្រព័ន្ធបៀវត្ស

## ៤.១ បៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្ស

❖ ព្រះរាជក្រឹត្យ លេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១

ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

# ព្រះរាជក្រឹត្យ

នស/រកត/១២០១/៤៥០

**ស្តីពី**
**បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស**
**របស់មន្ត្រីរាជការស៊ីវិល**

**យើង**
**ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.**

បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស គឺជាកំរៃជីវភាពប្រចាំខែ ដែលរដ្ឋត្រូវផ្តល់ជូនដល់មន្ត្រីរាជការស្ថិតនៅក្រោមការគ្រប់គ្រង នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ក្នុងការបំពេញការងារ។

បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស រួមមានៈ

-បៀវត្សមូលដ្ឋាន
-ប្រាក់បំណាច់មុខងារ
-ប្រាក់ហានិភ័យ និង ប្រាក់វិភាជន៍គ្រួសារ។

## ជំពូកទី ១
## បៀវត្សមូលដ្ឋាន

**មាត្រា ២.**

បៀវត្សមូលដ្ឋាន គឺជាប្រាក់ប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីរាជការសំរាប់ជីវភាពរស់នៅក្នុងនោះមានៈ គ្រឿងឧបភោគ បរិភោគ ការស្នាក់នៅ សំលៀកបំពាក់ ការព្យាបាលជំងឺ ។ល។

**មាត្រា ៣.**

បៀវត្សមូលដ្ឋាននៃមន្ត្រីរាជការ ត្រូវបែងចែកទៅតាមប្រភេទ ឋានន្តរស័ក្តិ និងថ្នាក់ដែលត្រូវបានកំណត់ទៅតាមកំរិតនៃសន្ទស្សន៍ដូចខាងក្រោមៈ

| **ប្រ.ភ** | **ឋានន្តរស័ក្តិ** | **ថ្នាក់** | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១៤ | ១៣ | ១២ | ១១ | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| **ក** | ក១ | | | | | | | | | ៤៣៦ | ៤៥៧ | ៤៨២ | ៥០៦ | ៥២៨ | ៥៥០ |
| | ក២ | | | | | ៣៦១ | ៣៧៣ | ៣៨៧ | ៤០២ | ៤១៩ | ៤៣៧ | ៤៥៤ | ៤៦៧ | ៤៧៨ | ៤៨៧ |
| | ក៣ | ៣១៥ | ៣២៣ | ៣៣១ | ៣៤០ | ៣៤៩ | ៣៥៩ | ៣៦៩ | ៣៨០ | ៣៩០ | ៣៩៩ | ៤០៧ | ៤១៤ | ៤២០ | ៤២៥ |
| **ខ** | ខ១ | | | | | | | | | ៣០៨ | ៣២៤ | ៣៤៤ | ៣៦០ | ៣៧៤ | ៣៨៥ |
| | ខ២ | | | | | ២៥២ | ២៦២ | ២៧២ | ២៨៣ | ២៩៥ | ៣០៦ | ៣១៦ | ៣២៥ | ៣៣៣ | ៣៤០ |
| | ខ៣ | ២២០ | ២២៥ | ២៣០ | ២៣៦ | ២៤៣ | ២៥១ | ២៥៩ | ២៦៦ | ២៧៣ | ២៧៩ | ២៨៤ | ២៨៩ | ២៩៣ | ២៩៧ |
| **គ** | គ១ | | | | | | | | | ២១២ | ២២៣ | ២៣៥ | ២៤៥ | ២៥៤ | ២៦២ |
| | គ២ | | | | | ១៧៣ | ១៧៨ | ១៨៥ | ១៩៣ | ២០១ | ២០៨ | ២១៥ | ២២២ | ២២៨ | ២៣៣ |
| | គ៣ | ១៥០ | ១៥៤ | ១៥៨ | ១៦៣ | ១៦៨ | ១៧៤ | ១៧៩ | ១៨៤ | ១៨៨ | ១៩២ | ១៩៥ | ១៩៨ | ២០០ | ២០២ |
| **ឃ** | ឃ១ | | | | | | | | | ១៤១ | ១៤៩ | ១៥៧ | ១៦៤ | ១៧០ | ១៧៥ |
| | ឃ២ | | | | | ១១៣ | ១១៧ | ១២២ | ១២៨ | ១៣៤ | ១៣៩ | ១៤៤ | ១៤៨ | ១៥២ | ១៥៥ |
| | ឃ៣ | ១០០ | ១០២ | ១០៤ | ១០៦ | ១០៩ | ១១២ | ១១៦ | ១២០ | ១២៣ | ១២៦ | ១២៩ | ១៣១ | ១៣៣ | ១៣៥ |

**មាត្រា៤.**

តំលៃឯកតា នៃសន្ទស្សន៍សំរាប់អនុវត្តក្នុងតារាងបៀវត្សមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈមានចំនួន៣០០រៀល ។

ការកែប្រែតំលៃឯកតានៃសន្ទស្សន៍នេះ ត្រូវធ្វើឡើងដោយអនុក្រឹត្យ។

**មាត្រា៥.**

មន្ត្រីកម្មសិក្សាដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវបានផ្តល់សន្ទស្សន៍បៀវត្សក្នុងថ្នាក់ទី ១៤ នៃឋានន្តរស័ក្តិទី ៣ របស់ក្របខ័ណ្ឌនីមួយៗ។ ចំពោះមន្ត្រីដែលជ្រើសរើសចេញពីមន្ត្រីមានក្របខ័ណ្ឌស្រាប់ ត្រូវបានផ្តល់សន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន។

ក្នុងរយៈពេលកម្មសិក្សានេះ មន្ត្រីកម្មសិក្សាដែលជ្រើសរើសចេញពីសិស្ស និស្សិត មិនត្រូវបានផ្តល់ប្រាក់បំណាច់មុខងារ និង ប្រាក់វិភាជន៍គ្រួសារនោះទេ។

រយៈពេលធ្វើកម្មសិក្សា មិនបានគិតក្នុងអតីតភាព សំរាប់តំឡើងថ្នាក់ទេ ប៉ុន្តែគិតក្នុងអតីតភាព សំរាប់សោធននិវត្តន៍។

**មាត្រា ៦.**

មន្ត្រីរាជការមានសិទ្ធិទទួលបៀវត្សមូលដ្ឋានបាន តែក្នុងលក្ខខ័ណ្ឌដូចខាងក្រោមៈ

១-កំពុងបំពេញសកម្មភាពការងារ

២-កំពុងផ្លាស់ប្តូរកន្លែងធ្វើការនៅក្នុង ឬក្រៅប្រទេស

៣- កំពុងធ្វើដំណើរទៅកាន់មុខតំណែង ឬ កំពុងវិលត្រឡប់មកវិញ

៤- កំពុងបំពេញកម្មសិក្សាវិជ្ជាជីវៈ ឬបច្ចេកទេសតាមតំរូវការរបស់រដ្ឋ

៥- កំពុងបំពេញកម្មសិក្សាជាដំបូង ដើម្បីតាំងស៊ប់ក្នុងក្របខ័ណ្ឌ។

**មាត្រា ៧.**

សិទ្ធិទទួលនូវបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ត្រូវគិតចាប់ផ្តើមពីថ្ងៃចូលបំរើការងារជាស្ថាពរ ដែលទទួលស្គាល់ដោយក្រសួងសាមី ហើយត្រូវជូនដំណឹងជាលាយល័ក្ខអក្សរ ដល់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា ៨.**

មន្ត្រីរាជការដែលឈប់សំរាកស្របតាមបទប្បញ្ញត្តិនៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងបទបញ្ញត្តិផ្សេងៗដែលមានជាធរមាន មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន។

**មាត្រា ៩.**

បៀវត្សមូលដ្ឋាន ត្រូវផ្តល់ជូនដល់មន្ត្រីរាជការដែលត្រូវចាត់អោយចូលរៀនវគ្គបណ្តុះបណ្តាល បំពាក់បំប៉នវិជ្ជាជីវៈ ឬបច្ចេកទេសតាមតំរូវការរបស់រដ្ឋស្របតាមក្របខ័ណ្ឌរបស់សាមីខ្លួន។

**មាត្រា ១០.**

ការបញ្ឈប់ផ្តល់បៀវត្សមូលដ្ឋាន ត្រូវធ្វើទៅតាមថ្ងៃកំណត់នៃប្រកាស របស់ប្រធានស្ថាប័នក្នុងករណីខាងក្រោមនេះ៖

-មន្ត្រីរាជការដែលសុំលាឈប់ពីការងារ ដោយមានការអនុញ្ញាត

-មន្ត្រីរាជការដែលត្រូវបណ្តេញចេញពីមុខតំណែង

-មន្ត្រីរាជការដែលពលី ឬទទួលមរណៈភាព

-មន្ត្រីរាជការដែលអវត្តមានគ្មានការអនុញ្ញាត ឬហួសរយៈពេលកំណត់

-មន្ត្រីរាជការដែលវិលត្រឡប់មកកាន់ការងារវិញហួសរយៈពេលដែលកំណត់ដោយលិខិតបង្គាប់ការ លើកលែងតែករណីស្របច្បាប់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច

-មន្ត្រីរាជការដែលអវត្តមានហួសកាលកំណត់របស់បេសកកម្ម ឬការឈប់សំរាក លើលែងតែករណីប្រធានស័ក្តិ ឬដោយជម្ងឺ ដែលមានលិខិតបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬពីសមត្ថកិច្ច សុខាភិបាល

-មន្ត្រីរាជការដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថា ជាទណ្ឌិត

**មាត្រា ១១**.

មន្ត្រីរាជការ ដែលត្រូវដាក់អោយស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស គ្មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ចាប់ពីថ្ងៃកំណត់ ដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស។

**មាត្រា ១២**.

មន្ត្រីរាជការ ដែលត្រូវដាក់អោយចូលនិវត្តន៍ គ្មានសិទ្ធិទទួលបៀវត្សមូលដ្ឋានៈ

-នៅពេលសាមីខ្លួនដល់អាយុចូលនិវត្តន៍

-តាមសំណើសុំរបស់សាមីខ្លួន ចំពោះមន្ត្រីរាជការដែលគ្រប់អតីតភាពការងារសំរាប់ចូលនិវត្តន៍។

## ជំពូកទី ២
## ប្រាក់បំណាច់មុខងារ

**មាត្រា ១៣**.

ប្រាក់បំណាច់មុខងារ គឺជាប្រាក់បន្ថែមទៅលើបៀវត្សមូលដ្ឋានប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការនៅក្នុងប្រភេទ **ក**,**ខ** និង **គ** ហើយដែលកំពុងបំពេញមុខងារក្នុងក្រសួង ស្ថាប័ន។

**មាត្រា ១៤**.

ប្រាក់បំណាច់មុខងារ ត្រូវបានបែងចែកជា ០៥ កំរិត ទៅតាមរយៈពេល និងបទពិសោធន៍ការងារក្នុងមុខតំណែងនីមួយៗដូចខាងក្រោមៈ

-កំរិតទី៥ សំរាប់បទពិសោធន៍រយៈពេលក្រោម ០៣ឆ្នាំ

-កំរិតទី៤ សំរាប់បទពិសោធន៍រយៈពេលពី ០៣ ទៅ ០៦ឆ្នាំ

-កំរិតទី៣ សំរាប់បទពិសោធន៍រយៈពេលពី ០៦ ទៅ ១០ឆ្នាំ

-កំរិតទី២ សំរាប់បទពិសោធន៍រយៈពេលពី ១០ ទៅ ១៦ឆ្នាំ

-កំរិតទី១ សំរាប់បទពិសោធន៍រយៈពេលលើសពី ១៦ឆ្នាំ

**មាត្រា ១៥.**

ការផ្លាស់ប្តូរកំរិត និងការផ្តល់ប្រាក់បំណាច់មុខងារ មិនអាចអនុវត្តន៍ទៅតាមឆ្នាំកំណត់ ដូចមានចែង នៅក្នុងមាត្រា ១៤ ជាស្វ័យប្រវត្តិបានទេ ក៏ប៉ុន្តែត្រូវធ្វើឡើងដោយមានការវាយតំលៃពីប្រធានស្ថាប័ន។

**មាត្រា ១៦.**

មន្ត្រីរាជការដែលមានមុខតំណែង ដូចខាងក្រោម ត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ ដូចមាន ចែងនៅក្នុងតារាងភ្ជាប់ជាមួយនេះ៖

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | អគ្គលេខាធិការ រាជរដ្ឋាភិបាល | ៧៨០ ០០០៛ | ៨២៧ ០០០៛ | ៨៧៧ ០០០៛ | ៩៣០ ០០០៛ | ៩៨៦ ០០០៛ |
| ២ | អគ្គលេខាធិការរង រាជរដ្ឋាភិបាល | ៧៦៥ ០០០៛ | ៨១១ ០០០៛ | ៨៦០ ០០០៛ | ៩១២ ០០០៛ | ៩៦៧ ០០០៛ |
| ៣ | អគ្គលេខាធិការ | ៧៥០ ០០០៛ | ៧៩៥ ០០០៛ | ៨៤៣ ០០០៛ | ៨៩៤ ០០០៛ | ៩៤៨ ០០០៛ |
| ៤ | អគ្គនាយក | ៧៣៥ ០០០៛ | ៧៧៩ ០០០៛ | ៨២៦ ០០០៛ | ៨៧៦ ០០០៛ | ៩២៩ ០០០៛ |
| ៥ | អគ្គាធិការ | ៧២០ ០០០៛ | ៧៦៣ ០០០៛ | ៨០៩ ០០០៛ | ៨៥៨ ០០០៛ | ៩១០ ០០០៛ |
| ៦ | អភិបាល ខេត្តក្រុង | ៧០៥ ០០០៛ | ៧៤៧ ០០០៛ | ៧៩២ ០០០៛ | ៨៤០ ០០០៛ | ៨៩១ ០០០៛ |
| ៧ | សកលវិទ្យាធិការ | ៦៩០ ០០០៛ | ៧៣២ ០០០៛ | ៧៧៦ ០០០៛ | ៨២៣ ០០០៛ | ៨៧៣ ០០០៛ |
| ៨ | សាស្ត្រាចារ្យមហាបរិញ្ញា | ៦៧៥ ០០០៛ | ៧១៦ ០០០៛ | ៧៥៩ ០០០៛ | ៨០៥ ០០០៛ | ៨៥៣ ០០០៛ |
| ៩ | អគ្គលេខាធិការរង | ៦៦០ ០០០៛ | ៧០០ ០០០៛ | ៧៤២ ០០០៛ | ៧៨៧ ០០០៛ | ៨៣៤ ០០០៛ |
| ១០ | អគ្គនាយករង | ៦៤៥ ០០០៛ | ៦៨៤ ០០០៛ | ៧២៥ ០០០៛ | ៧៦៩ ០០០៛ | ៨១៥ ០០០៛ |
| ១១ | អគ្គាធិការរង | ៦៣០ ០០០៛ | ៦៦៨ ០០០៛ | ៧០៨ ០០០៛ | ៧៥១ ០០០៛ | ៧៩៦ ០០០៛ |
| ១២ | សកលវិទ្យាធិការរង | ៦៣០ ០០០៛ | ៦៦៨ ០០០៛ | ៧០៨ ០០០៛ | ៧២១ ០០០៛ | ៧៩៦ ០០០៛ |

**មាត្រា ១៧.**

ប្រាក់បំណាច់មុខងារប្រចាំខែ របស់មន្ត្រីរដ្ឋបាលទូទៅ ត្រូវផ្តល់ជូនចំពោះមន្ត្រីរាជការ ដែលកំពុងបំពេញ មុខងារក្នុងមុខតំណែង ដែលមានចែងនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន ដូចខាងក្រោមនេះ៖

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ប្រធាន នាយកដ្ឋាន | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ២ | អធិការ | ៥៧ ៥០០៛ | ៦២ ១០០៛ | ៦៧ ១០០៛ | ៧២ ៥០០៛ | ៧៨ ៣០០៛ |
| ៣ | អនុប្រធាន នាយកដ្ឋាន | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ៤ | អធិការរង | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ៥ | ប្រធានមន្ទីរខេត្តក្រុង | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ | ៦៦ ១០០៛ | ៧១ ៤០០៛ |
| ៦ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ៧ | ប្រធានការិយាល័យ ថ្នាក់កណ្តាល | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ៨ | អនុប្រធានមន្ទីរខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៩ | អនុប្រធានការិយាល័យ ថ្នាក់កណ្តាល | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ១០ | ប្រធានការិយាល័យ មន្ទីរខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១១ | អនុប្រធានការិយាល័យ មន្ទីរខេត្តក្រុង | ៣៥ ០០០៛ | ៣៧ ៨០០៛ | ៤០ ៨០០៛ | ៤៤ ១០០៛ | ៤៧ ៦០០៛ |
| ១២ | ប្រធានការិយាល័យ ស្រុកខ័ណ្ឌ | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៣ | មន្ត្រីក្រមការ | ៣០ ០០០៛ | ៣២ ៤០០៛ | ៣៥ ០០០៛ | ៣៧ ៨០០៛ | ៤០ ៨០០៛ |
| ១៤ | អនុប្រធានការិយាល័យ ស្រុកខ័ណ្ឌ | ២៥ ០០០៛ | ២៧ ០០០៛ | ២៩ ២០០៛ | ៣១ ៥០០៛ | ៣៤ ០០០៛ |
| ១៥ | លេខាធិការដើមខ្សែ | ២២ ៥០០៛ | ២៤ ៣០០៛ | ២៦ ៣០០៛ | ២៨ ៤០០៛ | ៣០ ៧០០៛ |
| ១៦ | លេខាធិការ | ២០ ០០០៛ | ២១ ៦០០៛ | ២៣ ៣០០៛ | ២៥ ២០០៛ | ២៧ ២០០៛ |

**មាត្រា១៨.**

ប្រាក់បំណាច់មុខងារប្រចាំខែ របស់មន្ត្រីរដ្ឋបាលដែនដី ត្រូវផ្តល់ជូនចំពោះមន្ត្រីរាជការ ក្រសួង មហាផ្ទៃ ដែលកំពុងបំពេញមុខងារ ក្នុងមុខតំណែង ដែលមានចែងនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ដូចខាងក្រោមនេះ៖

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | អភិបាលរង ខេត្តក្រុង | ៦០ ០០០៛ | ៦១ ៩០០៛ | ៦៦ ៩០០៛ | ៧២ ៣០០៛ | ៧៨ ១០០៛ |
| ២ | អភិបាលស្រុកខ័ណ្ឌ | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ៣ | នាយខុទ្ទកាល័យ សាលាខេត្តក្រុង | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ | ៦៦ ១០០៛ | ៧១ ៤០០៛ |
| ៤ | អគ្គលេខាធិការ សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៥ | ប្រធានក្រុមហិរញ្ញវត្ថុ សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៦ | ប្រធានក្រុមអធិការកិច្ច សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៧ | នាយរងខុទ្ទកាល័យ សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៨ | អភិបាលរង ស្រុខ័ណ្ឌ | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៩ | អគ្គ លេខាធិការរង សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១០ | អនុប្រធានក្រុមហិរញ្ញវត្ថុ សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១១ | អនុប្រធានក្រុមអធិការកិច្ច សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១២ | ប្រធានការិយាល័យសាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១៣ | ប្រធានមន្ទីរ-សាលាស្រុកខ័ណ្ឌ | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៤ | អនុប្រធានការិយាល័យសាលាខេត្តក្រុង | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៥ | ប្រធានការិយាល័យសាលាស្រុកខ័ណ្ឌ | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៦ | អនុប្រធានមន្ទីរ-សាលាស្រុកខ័ណ្ឌ | ២៥ ០០០៛ | ២៧ ០០០៛ | ២៩ ២០០៛ | ៣១ ៥០០៛ | ៣៤ ០០០៛ |
| ១៧ | អនុប្រធានការិយាល័យសាលាស្រុកខ័ណ្ឌ | ២៥ ០០០៛ | ២៧ ០០០៛ | ២៩ ២០០៛ | ៣១ ៥០០៛ | ៣៤ ០០០៛ |
| ១៨ | លេខាធិការ ថ្នាក់ខេត្តក្រុងស្រុកខ័ណ្ឌ | ២០ ០០០៛ | ២១ ៦០០៛ | ២៣ ៣០០៛ | ២៥ ២០០៛ | ២៧ ២០០៛ |
| ១៩ | ស្មៀនឃុំសង្កាត់ | ២០ ០០០៛ | ២១ ៦០០៛ | ២៣ ៣០០៛ | ២៥ ២០០៛ | ២៧ ២០០៛ |
| ២០ | ប្រធានពន្ធនាគារកណ្តាល | ៧៦ ៧០០៛ | ៨២ ៨០០៛ | ៨៩ ៤០០៛ | ៩៦ ៦០០៛ | ១០៤៣០០៛ |
| ២១ | អនុប្រធានពន្ធនាគារកណ្តាល | ៧៤ ២០០៛ | ៨០ ១០០៛ | ៨៦ ៥០០៛ | ៩៣ ៤០០៛ | ១០០៩០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ២២ | ប្រធានពន្ធនាគារខេត្តក្រុង | ៧១ ៧០០៛ | ៧៧ ៤០០៛ | ៨៣ ៦០០៛ | ៩០ ៣០០៛ | ៩៧ ៥០០៛ |
| ២៣ | អនុប្រធានពន្ធនាគារខេត្តក្រុង | ៦៩ ២០០៛ | ៧៤ ៧០០៛ | ៨០ ៧០០៛ | ៨៧ ២០០៛ | ៩៤ ២០០៛ |
| ២៤ | នាយផ្នែករដ្ឋបាលពន្ធនាគារ | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ២៥ | នាយរងផ្នែករដ្ឋបាលពន្ធនាគារ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ | ៦៦ ១០០៛ | ៧១ ៤០០៛ |
| ២៦ | អ្នកគ្រប់គ្រងអ្នកទោសក្នុងពន្ធនាគារ | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |

**មាត្រា១៩.**

ប្រាក់បំណាច់មុខងារប្រចាំខែ ក្នុងវិស័យអប់រំ មានដូចខាងក្រោមនេះ៖

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរស មហាវិទ្យាល័យ | ៨០ ០០០៛ | ៨៤ ០០០៛ | ៨៨ ២០០៛ | ៩២៦០០៛ | ៩៧ ២០០៛ |
| ២ | ព្រឹទ្ធបុរសរង មហាវិទ្យាល័យ | ៧៨ ០០០៛ | ៨១ ៩០០៛ | ៨៦ ០០០៛ | ៩០៣០០៛ | ៩៤ ៨០០៛ |
| ៣ | សាស្ត្រាចារ្យ ឧត្តមសិក្សា | ៧៧ ០០០៛ | ៨០ ៩០០៛ | ៨៥ ០០០៛ | ៨៩៣០០៛ | ៩៣ ៨០០៛ |
| ៤ | នាយក វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៥ | នាយក វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៦ | នាយក វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៧ | គ្រូបង្រៀន ឧត្តមសិក្សា | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៤០០៛ | ៨៧០០០៛ | ៩១ ៤០០៛ |
| ៨ | នាយករង វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៧៤ ០០០៛ | ៧៧៧០០៛ | ៨១ ៦០០៛ | ៨៥៧០០៛ | ៩០ ០០០៛ |
| ៩ | នាយករង វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៧៤ ០០០៛ | ៧៧៧០០៛ | ៨១ ៦០០៛ | ៨៥៧០០៛ | ៩០ ០០០៛ |
| ១០ | នាយករង វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៧៤ ០០០៛ | ៧៧៧០០៛ | ៨១ ៦០០៛ | ៨៥៧០០៛ | ៩០ ០០០៛ |
| ១១ | អធិការ មធ្យមសិក្សា | ៧៤ ០០០៛ | ៧៧៧០០៛ | ៨១ ៦០០៛ | ៨៥៧០០៛ | ៩០ ០០០៛ |
| ១២ | នាយក នាយកវិទ្យាល័យ | ៧៣ ០០០៛ | ៧៦៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៣ | នាយក មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៧៣ ០០០៛ | ៧៦៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៤ | នាយក មជ្ឈមណ្ឌលគរុកោសល្យខេត្តក្រុង | ៧៣ ០០០៛ | ៧៦៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៥ | នាយក មជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ | ៧៣ ០០០៛ | ៧៦៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៦ | នាយក សាលាមធ្យមសិក្សាបច្ចេកទេសឬស្សីកែវ | ៧៣ ០០០៛ | ៧៦៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៧ | នាយក សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា | ៧៣ ០០០៛ | ៧៦៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៨ | នាយក សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម | ៧៣ ០០០៛ | ៧៦៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៩ | នាយករង វិទ្យាល័យ | ៧២ ០០០៛ | ៧៥៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២០ | នាយករង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៧២ ០០០៛ | ៧៥៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២១ | នាយករង សាលាគរុកោសល្យខេត្តក្រុង | ៧២ ០០០៛ | ៧៥៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២២ | នាយករង មជ្ឈមណ្ឌលបច្ចេកទេសវិជ្ជាជីវៈ | ៧២ ០០០៛ | ៧៥៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៣ | នាយករង សាលាមធ្យមសិក្សាបច្ចេកទេសឬស្សីកែវ | ៧២ ០០០៛ | ៧៥៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៤ | នាយករង សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា | ៧២ ០០០៛ | ៧៥៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៥ | នាយករង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម | ៧២ ០០០៛ | ៧៥៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៦ | គ្រូបង្រៀន មធ្យម ទុតិយភូមិ | ៧១ ០០០៛ | ៧៤៦០០៛ | ៧៨៣០០៛ | ៨២ ២០០៛ | ៨៦ ៣០០៛ |
| ២៧ | អធិការ បឋមសិក្សា | ៦៩ ០០០៛ | ៧២៥០០៛ | ៧៦១០០៛ | ៧៩ ៩០០៛ | ៨៣ ៩០០៛ |
| ២៨ | នាយក អនុវិទ្យាល័យ | ៦៨ ០០០៛ | ៧១៤០០៛ | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ |
| ២៩ | នាយក មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង | ៦៨ ០០០៛ | ៧១៤០០៛ | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ |
| ៣០ | នាយករង អនុវិទ្យាល័យ | ៦៧ ០០០៛ | ៧០៤០០៛ | ៧៣៩០០៛ | ៧៧ ៦០០៛ | ៨១ ៥០០៛ |
| ៣១ | នាយករង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង | ៦៧ ០០០៛ | ៧០៤០០៛ | ៧៣៩០០៛ | ៧៧ ៦០០៛ | ៨១ ៥០០៛ |
| ៣២ | គ្រូបង្រៀន មធ្យមសិក្សា បឋមភូមិ | ៦៦ ០០០៛ | ៦៩៣០០៛ | ៧២៨០០៛ | ៧៦ ៥០០៛ | ៨០ ៣០០៛ |
| ៣៣ | នាយក សាលាបឋមសិក្សា | ៦៤ ០០០៛ | ៦៧២០០៛ | ៧០ ៦០០៛ | ៧៤ ១០០៛ | ៧៧ ៨០០៛ |
| ៣៤ | នាយក សាលាមត្តេយ្យ | ៦៤ ០០០៛ | ៦៧២០០៛ | ៧០ ៦០០៛ | ៧៤ ១០០៛ | ៧៧ ៨០០៛ |
| ៣៥ | នាយករង សាលាបឋមសិក្សា | ៦៣ ០០០៛ | ៦៦២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ | ៧៦ ៧០០៛ |
| ៣៦ | នាយករង សាលាមតេយ្យ | ៦៣ ០០០៛ | ៦៦២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ | ៧៦ ៧០០៛ |
| ៣៧ | គ្រូបង្រៀន មធ្យមសិក្សា -មត្តេយ្យសិក្សា | ៦២ ០០០៛ | ៦៥១០០៛ | ៦៨ ៤០០៛ | ៨១ ៨០០៛ | ៧៥ ៤០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣៨ | គ្រូបង្រៀន កំរិតបឋម | ៦០ ០០០៛ | ៦៣០០០៛ | ៦៦ ២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ |

**មាត្រា២០**.

ប្រាក់បំណាច់មុខងារប្រចាំខែ ក្នុងវិស័យសុខាភិបាលមានដូចខាងក្រោមនេះ

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរស មហាវិទ្យាល័យ | ៨០០០០៛ | ៨៤០០០៛ | ៨៨២០០៛ | ៩២៦០០៛ | ៩៧២០០៛ |
| ២ | ព្រឹទ្ធបុរសរង មហាវិទ្យាល័យ | ៧៨០០០៛ | ៨១៩០០៛ | ៨៦០០០៛ | ៩០៣០០៛ | ៩៤៨០០៛ |
| ៣ | នាយក សាលាបច្ចេកទេសថែទាំវេជ្ជសាស្រ្តថ្នាក់កណ្តាល | ៧៨០០០៛ | ៨១៩០០៛ | ៨៦០០០៛ | ៩០៣០០៛ | ៩៤៨០០៛ |
| ៤ | នាយករង សាលាបច្ចេកទេសថែទាំវេជ្ជសាស្រ្តថ្នាក់កណ្តាល | ៧៥០០០៛ | ៧៨៨០០៛ | ៨២៨០០៛ | ៨៧០០០៛ | ៩១៤០០៛ |
| ៥ | នាយក មន្ទីរពេទ្យជាតិ | ៦៥០០០៛ | ៧០២០០៛ | ៧៥៨០០៛ | ៨១៩០០៛ | ៨៨៥០០៛ |
| ៦ | នាយក មជ្ឈមណ្ឌលជាតិ | ៦៥០០០៛ | ៧០២០០៛ | ៧៥៨០០៛ | ៨១៩០០៛ | ៨៨៥០០៛ |
| ៧ | នាយក វិទ្យាស្ថានជាតិ | ៦៥០០០៛ | ៧០២០០៛ | ៧៥៨០០៛ | ៨១៩០០៛ | ៨៨៥០០៛ |
| ៨ | នាយក មន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពឱសថ | ៦៥០០០៛ | ៧០២០០៛ | ៧៥៨០០៛ | ៨១៩០០៛ | ៨៨៥០០៛ |
| ៩ | នាយកឃ្លាំងឱសថកណ្តាល | ៦៥០០០៛ | ៧០២០០៛ | ៧៥៨០០៛ | ៨១៩០០៛ | ៨៨៥០០៛ |
| ១០ | នាយករង មន្ទីរពេទ្យជាតិ | ៦០០០០៛ | ៦៤៨០០៛ | ៧០០០០៛ | ៧៥៦០០៛ | ៨១៧០០៛ |
| ១១ | នាយករង មជ្ឈមណ្ឌលជាតិ | ៦០០០០៛ | ៦៤៨០០៛ | ៧០០០០៛ | ៧៥៦០០៛ | ៨១៧០០៛ |
| ១២ | នាយករង វិទ្យាស្ថានជាតិ | ៦០០០០៛ | ៦៤៨០០៛ | ៧០០០០៛ | ៧៥៦០០៛ | ៨១៧០០៛ |
| ១៣ | នាយករង មន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពឱសថ | ៦០០០០៛ | ៦៤៨០០៛ | ៧០០០០៛ | ៧៥៦០០៛ | ៨១៧០០៛ |
| ១៤ | នាយករងឃ្លាំងឱសថកណ្តាល | ៦០០០០៛ | ៦៤៨០០៛ | ៧០០០០៛ | ៧៥៦០០៛ | ៨១៧០០៛ |
| ១៥ | ប្រធានការិយាល័យ ស្រុកប្រតិបត្តិ | ៥០០០០៛ | ៥៤០០០៛ | ៥៨៣០០៛ | ៦៣០០០៛ | ៦៨១០០៛ |
| ១៦ | អនុប្រធានការិយាល័យ ស្រុកប្រតិបត្តិ | ៤៧៥០០៛ | ៥១៣០០៛ | ៥៥៤០០៛ | ៥៩៨០០៛ | ៦៤៦០០៛ |
| ១៧ | ប្រធាន មន្ទីរពេទ្យបង្អែក | ៤៧៥០០៛ | ៥១៣០០៛ | ៥៥៤០០៛ | ៥៩៨០០៛ | ៦៤៦០០៛ |
| ១៨ | អនុប្រធាន មន្ទីរពេទ្យបង្អែក | ៤៥០០០៛ | ៤៨៦០០៛ | ៥២៥០០៛ | ៥៦៧០០៛ | ៦១២០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៩ | ប្រធានមណ្ឌលសុខភាព | ៤៥០០០៛ | ៤៨៦០០៛ | ៥២៥០០៛ | ៥៦៧០០៛ | ៦១២០០៛ |
| ២០ | អនុប្រធានមណ្ឌលសុខភាព | ៤២៥០០៛ | ៤៥៩០០៛ | ៤៩៦០០៛ | ៥៣៦០០៛ | ៥៧៩០០៛ |
| ២១ | គ្រូពេទ្យ ឯកទេស | ៦៥០០០៛ | ៧០២០០៛ | ៧៥៨០០៛ | ៨១៩០០៛ | ៨៨៥០០៛ |
| ២២ | គ្រូពេទ្យ អនុបណ្ឌិត | ៦៥០០០៛ | ៧០២០០៛ | ៧៥៨០០៛ | ៨១៩០០៛ | ៨៨៥០០៛ |
| ២៣ | ឱសថបណ្ឌិត | ៦០០០០៛ | ៦៤៨០០៛ | ៧០០០០៛ | ៧៥៦០០៛ | ៨១៧០០៛ |
| ២៤ | គ្រូពេទ្យ ការពារ | ៥៥០០០៛ | ៥៩៤០០៛ | ៦៤២០០៛ | ៦៩៣០០៛ | ៧៤៩០០៛ |
| ២៥ | ឱសថការី ការពារ | ៥៥០០០៛ | ៥៩៤០០៛ | ៦៤២០០៛ | ៦៩៣០០៛ | ៧៤៩០០៛ |
| ២៦ | គ្រូពេទ្យ ព្យាបាល | ៥០០០០៛ | ៥៤០០០៛ | ៥៨៣០០៛ | ៦៣០០០៛ | ៦៨១០០៛ |
| ២៧ | ឱសថការី ព្យាបាល | ៥០០០០៛ | ៥៤០០០៛ | ៥៨៣០០៛ | ៦៣០០០៛ | ៦៨១០០៛ |
| ២៨ | ទន្តបណ្ឌិត | ៥០០០០៛ | ៥៤០០០៛ | ៥៨៣០០៛ | ៦៣០០០៛ | ៦៨១០០៛ |
| ២៩ | គ្រូពេទ្យ មធ្យម | ៤៥០០០៛ | ៤៨៦០០៛ | ៥២៥០០៛ | ៥៦៧០០៛ | ៦១២០០៛ |
| ៣០ | ទន្តពេទ្យ មធ្យម | ៤៥០០០៛ | ៤៨៦០០៛ | ៥២៥០០៛ | ៥៦៧០០៛ | ៦១២០០៛ |
| ៣១ | ឱសថការី មធ្យម | ៤៥០០០៛ | ៤៨៦០០៛ | ៥២៥០០៛ | ៥៦៧០០៛ | ៦១២០០៛ |
| ៣២ | ឆ្មប មធ្យម | ៤០០០០៛ | ៤៣២០០៛ | ៤៦៧០០៛ | ៥០៤០០៛ | ៥៤៤០០៛ |
| ៣៣ | គិលានុបដ្ឋាក មធ្យម | ៤០០០០៛ | ៤៣២០០៛ | ៤៦៧០០៛ | ៥០៤០០៛ | ៥៤៤០០៛ |
| ៣៤ | អ្នកព្យាបាលដោយចលនា មធ្យម | ៤០០០០៛ | ៤៣២០០៛ | ៤៦៧០០៛ | ៥០៤០០៛ | ៥៤៤០០៛ |
| ៣៥ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍ មធ្យម | ៤០០០០៛ | ៤៣២០០៛ | ៤៦៧០០៛ | ៥០៤០០៛ | ៥៤៤០០៛ |

**មាត្រា២១**.

មន្ត្រីរាជការដែលស្ថិតនៅក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងនោះ។ មន្ត្រីរាជការដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតអោយជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយទេ។

**មាត្រា២២**.

ការកែប្រែប្រាក់បំណាច់មុខងារ ត្រូវធ្វើឡើង ដោយអនុក្រឹត្យ។

## ជំពូកទី៣
## ប្រាក់ហានិភ័យ

**មាត្រា២៣.**

ប្រាក់ហានិភ័យគឺជាប្រាក់ប្រចាំខែសំរាប់ផ្តល់ជូនដល់មន្ត្រីរាជការទាំងឡាយណា ដែលត្រូវចាត់ឱ្យទៅបំរើការងារ ឬបំរើការងារ នៅក្នុងមុខងារ ឬទីកន្លែង ដែលមានគ្រោះថ្នាក់ ជំងឺឆ្លង ការងារប៉ះពាល់សុខភាព ការងារដែលបណ្តាលឱ្យខូចសុខភាព ដូចជា កន្លែងក្តៅ សើម មានធូលីច្រើន ឬពុល ចំហាយជាតិពុល ឬជាតិគីមី សំលេងខ្ទរខ្លាំង ក្លិនស្អុយ និងតំបន់គ្រុនចាញ់។

**មាត្រា២៤.**

ប្រាក់ហានិភ័យមានពីរ គឺ:

១-ប្រាក់ប៉ះពាល់សុខភាព

២-ប្រាក់តំបន់

មុខងារដែលប៉ះពាល់សុខភាពនិងតំបន់ហានិភ័យ ព្រមទាំងប្រាក់ហានិភ័យនឹងត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក។

## ជំពូកទី៤
## ប្រាក់វិភាជន៍គ្រួសារ

**មាត្រា ២៥.**

ប្រាក់វិភាជន៍គ្រួសារ គឺជាប្រាក់ប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការជាមេគ្រួសារ សំរាប់ប្រពន្ធ កូន និងកូនចិញ្ចឹមស្របច្បាប់ នៅក្នុងបន្ទុក។

ប្រាក់វិភាជន៍សំរាប់កូនអាចបន្តផ្តល់ជូន រហូតដល់អាយុ២១ឆ្នាំ ក្នុងករណីមានលិខិតបញ្ជាក់ការសិក្សា។

**មាត្រា ២៦.-**

ប្រាក់វិភាជន៍គ្រួសារ ត្រូវផ្តល់មន្ត្រីរាជការនៅក្នុងគ្រប់ករណីដែលសាមីខ្លួន នៅមានសិទ្ធិទទួលបៀវត្សមូលដ្ឋាន។

មន្ត្រីរាជការដែលជាមេគ្រួសារ ត្រូវទទួលខុសត្រូវចំពោះពត៌មានស្តីពីស្ថានភាពគ្រួសារទាក់ទងនឹងប្រាក់វិភាជន៍គ្រួសារ។

**មាត្រា ២៧.**

ប្រាក់វិភាជន៍គ្រួសារប្រចាំខែត្រូវផ្តល់ជូន ដូចខាងក្រោម:

| ប្រាក់វិភាជន៍គ្រួសារ | ចំនួនទឹកប្រាក់ |
|---|---|
| ប្រពន្ធ | ៣០០០រៀល |
| កូន | ២៥០០រៀល |

**មាត្រា ២៨**.-

ការកែប្រែប្រាក់វិភាជន៍គ្រួសារ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ២៩**.-

មន្ត្រីរាជការក្នុងក្របខ័ណ្ឌ **ក ខ គ** ដែលពុំមានមុខតំណែងចែងក្នុងព្រះរាជក្រឹត្យនេះ នឹងត្រូវទទួលប្រាក់បំណាច់មុខងារសមមូលនឹងប្រាក់បំណាច់មុខងារ របស់មន្ត្រីរដ្ឋបាលទូទៅ ដែលមានចែងក្នុងមាត្រាទី ១៧។

**មាត្រា ៣០**.-

ប្រាក់ប៉ះពាល់សុខភាព និងប្រាក់តំបន់ ដែលកំពុងអនុវត្តបច្ចុប្បន្ន នៅមានសុពលភាព រហូតដល់ពេលដែល អនុក្រឹត្យថ្មីស្តីពី មុខងារដែលប៉ះពាល់សុខភាព និងតំបន់ហានិភ័យ ព្រមទាំងប្រាក់ហានិភ័យ ត្រូវបានដាក់ឱ្យចូលជាធរមានជំនួស។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ៣១**.-

រាល់បទបញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣២**.-

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

**មាត្រា ៣៣**.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ តទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១

ព រ ល.០១.១២.០០៤៦

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

**ហ៊ុន សែន**

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

- សេចក្តីណែនាំលេខ ០០៣ សណនមស ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០១ ស្តីពីការអនុវត្តន៍គោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**
លេខ ០០៣ សណនមស

# សេចក្តីណែនាំ
# ស្តីពី
# ការអនុវត្តន៍គោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

-យោងអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល ស្តីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ។

-យោងសារាចរលេខ ១៤ សរណន ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើជំរឿនមន្ត្រីរាជការ និង វិភាគមុខងារ ។

-យោងស្មារតីអង្គប្រជុំអន្តរក្រសួងនាថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០០

រាជរដ្ឋាភិបាលបានប្រកាសផ្សាយជាផ្លូវការ នូវអនុក្រឹត្យស្តីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល សំដៅឈានទៅគ្រប់គ្រងមន្ត្រីរាជការស៊ីវិលអោយបានល្អប្រសើរទាំងបរិមាណ និង គុណភាព ។ តាមនីតិវិធីថ្មីនេះ ការគ្រប់គ្រងរដ្ឋបាល និង ហិរញ្ញវត្ថុរបស់មន្ត្រីរាជការស៊ីវិលមាន ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និង ការផ្លាស់ប្តូរស្ថានភាពគ្រួសារ ត្រូវធ្វើឡើងដោយប្រព័ន្ធព័ត៌មានវិទ្យា ។ ក្នុងរយៈពេលអន្តរកាលផ្អែកតាមខ្លឹមសារជំពូក ៣ នៃ អនុក្រឹត្យនេះ និងផ្អែកតាមលទ្ធផលនៃការធ្វើជំរឿនមន្ត្រីរាជការស៊ីវិលកន្លងមក គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ត្រូវប្រើប្រាស់តារាងទូទាត់បៀវត្សថ្មី ។ ដើម្បីអនុវត្តតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាដែលបានបោះពុម្ពខាងលើនេះអោយមានប្រសិទ្ធិភាព រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សូមធ្វើការណែនាំដូចតទៅៈ

គ្រប់ក្រសួង ស្ថាប័ន និង អង្គភាព ដែលបានធ្វើសុពលភាពទិន្នន័យមន្ត្រីរាជការស៊ីវិលរបស់ខ្លួន ជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ព្រមទាំងបានបោះពុម្ពតារាងទូទាត់ បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាត្រឹមត្រូវរួចហើយនោះ ត្រូវយកតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យានេះប្រើប្រាស់ជាផ្លូវការជំនួសតារាងទូទាត់បៀវត្សដែលបានធ្វើដោយដៃកន្លងមក ។

## I-<u>នីតិវិធីនៃការពិនិត្យ ផ្តល់ទិដ្ឋាការ និងការបោះពុម្ពឯកសារសំរាប់បើកបៀវត្សៈ</u>

ជារៀងរាល់ខែ គ្រប់ក្រសួង ស្ថាប័ន ដែលអនុវត្តតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា ត្រូវធ្វើសំណើមករដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីសុំពិនិត្យ និង ផ្តល់ទិដ្ឋាការលើសំណុំឯកសារនៃការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និង ការផ្លាស់ប្តូរស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល ។ ក្រោយពីបានពិនិត្យ និងផ្តល់ទិដ្ឋាការរួច រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈនឹងរាយការណ៍ពីស្ថានភាពនៃការផ្លាស់ប្តូរទាំងនោះ

ជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើសមទិនលើទិន្នន័យមន្ត្រីរាជការស៊ីវិលក្នុងប្រព័ន្ធពត៌មានវិទ្យា នឹងបោះពុម្ពឯកសារយកទៅប្រើប្រាស់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការស៊ីវិល

ឯកសារដែលត្រូវបោះពុម្ពរួមមានៈ

១-តារាងទូទាត់បៀវត្ស ចំនួន ២ ច្បាប់

២-តារាងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមប្រភេទបៀវត្ស ចំនួន ២ ច្បាប់

តារាងទូទាត់បៀវត្សដែលបានបោះពុម្ពខាងលើនេះ នឹងត្រូវចុះហត្ថលេខាដោយក្រសួង ស្ថាប័ន សាមីនិងបញ្ជាក់ពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ ឯកសារមួយច្បាប់រក្សាទុកនៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងមួយច្បាប់សំរាប់យកទៅប្រើប្រាស់ក្នុងការបើកបៀវត្សជូនមន្ត្រីរាជការស៊ីវិល ។

## II-**សំណុំលិខិតដែលត្រូវបំពេញ:**

សំណុំលិខិតដែលក្រសួង ស្ថាប័ន ត្រូវបំពេញសំរាប់ស្នើសុំទិដ្ឋាការលើសំណុំឯកសារនៃការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល ដើម្បីទទួលបានឯកសារបើកបៀវត្សតាមប្រព័ន្ធពត៌មានវិទ្យា សំរាប់យកទៅប្រើក្នុងការបើកបៀវត្សមានៈ

១-លិខិតស្នើសុំទិដ្ឋាការ (មានគំរូ) ចំនួន ២ ច្បាប់

២-របាយការណ៍ស្តីពីការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល
និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល (មានគំរូ) ចំនួន ២ ច្បាប់

៣-សំណុំឯកសារបញ្ជាក់មួយមុខៗ ចំនួន ២ ច្បាប់

## III-**កាលបរិច្ឆេទនៃការបញ្ជូនឯកសារ:**

-ក្រសួង ស្ថាប័ន ត្រូវបញ្ជូនសំណុំលិខិតមកដល់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណុំឯកសារនៃការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល អោយបានមុន ថ្ងៃទី ០៥ នៃខែនីមួយៗ ។

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ផ្ញើរបាយការណ៍នៃការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលជូនទីស្តីការគណៈរដ្ឋមន្ត្រី អោយបានមុន ថ្ងៃទី ១២ នៃខែនីមួយៗ ។

-ត្រូវបោះពុម្ពឯកសារសំរាប់បើកបៀវត្សជូនក្រសួង ស្ថាប័នអោយបានមុន ថ្ងៃទី ២០ នៃខែនីមួយៗ ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវសហការ និង ចាត់តាំងអនុវត្តតារាងទូទាត់បៀវត្សតាមប្រព័ន្ធពត៌មានវិទ្យាក្នុងរយៈពេលអន្តរកាលអោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០១

**រដ្ឋលេខាធិការ**

**ពេជ្រ ប៊ុនធិន**

**<u>ចម្លងជូន</u>**

-ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល "ដើម្បីជូនជ្រាប"

-គ្រប់ក្រសួង-ស្ថាប័ន "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈរដ្ឋមន្ត្រី**
**ក្រសួង**........................
**លេខ**........................

រាជធានីភ្នំពេញ ថ្ងៃទី ..........ខែ .........ឆ្នាំ ២០០....

## រដ្ឋមន្ត្រី ....................................................

## សូមជំរាបជូន
## ឯកឧត្តមរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

**កម្មវត្ថុ** - សំណើសុំពិនិត្យនិងផ្តល់ទិដ្ឋាការលើសំណុំឯកសារនៃការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល នៃក្រសួង...........................សំរាប់ខែ........................ឆ្នាំ២០០.............។

**យោង** - សេចក្តីណែនាំលេខ...............ចុះថ្ងៃទី.............ខែ...........ឆ្នាំ ២០០.....របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

ខ្ញុំមានកិត្តិយសសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា ក្នុងខែនេះក្រសួងមានស្ថានភាព មន្ត្រីរាជការស៊ីវិល និងបៀវត្សដូចតទៅៈ

| បរិយាយ | ខែ(មុន)......ឆ្នាំ ២០០... | | ខែ(មុន)......ឆ្នាំ ២០០... | | ប្រៀបធៀប | |
|---|---|---|---|---|---|---|
| | ចំនួនបុគ្គលិក | ទឹកប្រាក់ | ចំនួនបុគ្គលិក | ទឹកប្រាក់ | ចំនួនបុគ្គលិក | ទឹកប្រាក់ |
| I-បៀវត្ស | | | | | | |
| -បៀវត្សសុទ្ធសាធ | | | | | | |
| -ប្រាក់ឧបត្ថម្ភ ៦០% | | | | | | |
| II-ប្រាក់ឧបត្ថម្ភ | | | | | | |
| -គរុកោសល្យ | | | | | | |
| -តំបន់ | | | | | | |
| -បំណាច់ភារកិច្ច | | | | | | |
| -សុខភាព | | | | | | |
| -បំណាច់បន្ថែម | | | | | | |
| III- ប្រាក់ឧបត្ថម្ភគ្រួសារ | | | | | | |
| -កូន | | | | | | |
| -ប្រពន្ធ | | | | | | |
| IV-ប្រាក់រំលឹក | | | | | | |
| សរុបរួម | | | | | | |
| បញ្ឈប់បញ្ជីត្រឹមទឹកប្រាក់ចំនួន...................................................... "....................................................រៀលគត់។ | | | | | | |

សូមឯកឧត្តមមេត្តាពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណុំឯកសារនៃការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលដូចមានរាយជូនខាងលើដោយអនុគ្រោះ ។

**<u>ចម្លងជូន</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈរដ្ឋមន្ត្រី**

**ក្រសួង**........................

**លេខ**.........................

### របាយការណ៍ស្តីពីការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល
**សំរាប់ខែ**..................... **ឆ្នាំ ២០០**............

| លរ | អត្តលេខ | ឈ្មោះ ខ្មែរ | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | មុខងារ | កាំប្រាក់ | ប្រាក់ឧបត្ថម្ភ | | | | | ចំនួន | | ប្រាក់រំលឹក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | គរុកោសល្យ | តំបន់ | បំណាច់ភារកិច្ច | សុខភាព | | កូន | ប្រពន្ធ | |
| ១-ការជ្រើសរើសថ្មី | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២-ការចូលបំរើការងារជាថ្មី | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៣-ការផ្ទេរចូល | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤-ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៥-ការតែងតាំងក្នុងមុខតំណែង | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៦-ការកែសំរួលបៀវត្ស | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៧-ការតំឡើងឋានន្តរស័ក្តិឬថ្នាក់ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៨-ការកែសំរួលឬផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗមានៈគរុកោសល្យ-តំបន់-បំណាច់ភារកិច្ច-សុខភាព-បំណាច់បន្ថែម | | | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៩-ការបន្ថយឋានន្តរស័ក្តិឬថ្នាក់ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ១០-ការដាក់អោយនៅក្រៅតំណែង | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ១១-ការដាក់អោយនៅក្រៅក្របខ័ណ្ឌដើម | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ១២-ការដាក់អោយស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ១៣-ការបញ្ឈប់ពីការងារឬលុបឈ្មោះ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ១៤-ការផ្ទេរចេញ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ១៥-ការដាក់អោយចូលនិវត្តន៍ឬបាត់បង់សម្បទាវិជ្ជាជីវៈ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ១៦-ការបន្ថែមឬបន្ថយកូន | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ១៧-ការបន្ថែមឬបន្ថយប្រពន្ធ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

លេខ...........................................................................
បានឃើញនិងឯកភាពចំនួន...............................ករណី
មិនឯកភាពចំនួន.............................................ករណីគឺ
...................................................................................
...................................................................................
រាជធានីភ្នំពេញ ថ្ងៃទី...........ខែ..................ឆ្នាំ២០០.......
រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី...........ខែ........ឆ្នាំ២០០...
រដ្ឋមន្ត្រី ឬ តំណាង

បានពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី...........ខែ........ឆ្នាំ២០០...
ប្រធាននាយកដ្ឋានបុគ្គលិក

## ៤.២ ការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការ

❖ អនុក្រឹត្យ លេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ ស្ដីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិលនិងប្រាក់កម្រៃគរុកោសល្យក្នុងវិស័យអប់រំ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:៣៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល

## និង ប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍ រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្ស មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

# សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១** -

អនុក្រឹត្យនេះ មានគោលដៅបំពេញបន្ថែមព្រះរាជក្រឹត្យ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សដូចមានចែងក្នុងជំពូកទី២ ស្តីពីប្រាក់បំណាច់មុខងារ។

**មាត្រា ២** -

អនុក្រឹត្យនេះ កំណត់ការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការដែលមានមុខតំណែងជាប្រធាននាយកដ្ឋាន អភិបាលរងខេត្ត-ក្រុង អធិការថ្នាក់កណ្តាល ព្រឹទ្ធបុរសមហាវិទ្យាល័យ អភិបាលស្រុក-ខ័ណ្ឌ ហើយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន និងកំណត់បន្ថែម ប្រាក់កំរៃគរុកោសល្យរបស់មន្ត្រីរាជការក្នុងវិស័យអប់រំ។

## ជំពូកទី២

## ប្រាក់បំណាច់មុខងារ

**មាត្រា ៣** -

មន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងជា ប្រធាននាយកដ្ឋាន អភិបាលរងខេត្ត-ក្រុង អធិការថ្នាក់កណ្តាល ព្រឹទ្ធបុរសមហាវិទ្យាល័យ អភិបាលស្រុក-ខ័ណ្ឌ ហើយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័នថ្នាក់កណ្តាលត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ
ដូចមានចែងនៅក្នុងតារាងខាងក្រោមនេះ៖

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | **កំរិត ទី១** |
|---|---|---|---|---|---|---|
| ១ | ប្រធាននាយកដ្ឋាន | ៦២០ ០០០៛ | ៦៥៨ ០០០៛ | ៦៩៨ ០០០៛ | ៧៤១ ០០០៛ | ៧៨៦ ០០០៛ |
| ២ | អភិបាលរងខេត្ត-ក្រុង | ៦១៥ ០០០៛ | ៦៥៣ ០០០៛ | ៦៩៣ ០០០៛ | ៧៣៦ ០០០៛ | ៧៨១ ០០០៛ |
| ៣ | អធិការថ្នាក់កណ្តាល | ៦១០ ០០០៛ | ៦៤៨ ០០០៛ | ៦៨៨ ០០០៛ | ៧៣១ ០០០៛ | ៧៧៦ ០០០៛ |
| ៤ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៦០៥ ០០០៛ | ៦៤៣ ០០០៛ | ៦៨៣ ០០០៛ | ៧២៦ ០០០៛ | ៧៧១ ០០០៛ |
| ៥ | អភិបាលស្រុក-ខ័ណ្ឌ | ៥០០ ០០០៛ | ៥៣៨ ០០០៛ | ៥៧៨ ០០០៛ | ៦២១ ០០០៛ | ៦៦៦ ០០០៛ |

**មាត្រា ៤** -

ប្រធានអង្គភាព ដែលមានរចនាសម្ព័ន្ធក្នុងក្រសួង-ស្ថាប័ន និងស្មើនាយកដ្ឋាន ត្រូវទទួលបាន ប្រាក់បំណាច់មុខងារជាប្រធាននាយកដ្ឋាន ដូចមានចែងនៅក្នុងមាត្រា ៣ ។

## ជំពូកទី៣
## ប្រាក់កំរៃគរុកោសល្យ

**មាត្រា ៥** -

ប្រាក់កំរៃគរុកោសល្យ គឺជាប្រាក់បន្ថែមលើប្រាក់បំណាច់មុខងារប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការក្នុងវិស័យអប់រំ ហើយដែលបានឆ្លងកាត់ វគ្គបណ្តុះបណ្តាលគុរកោសល្យ។

**មាត្រា ៦** :

ប្រាក់កំរៃគរុកោសល្យ ត្រូវផ្តល់ជូនទៅតាមក្របខ័ណ្ឌប្រភេទមន្ត្រីរាជការ ដូចខាងក្រោមៈ

| **ល.រ** | **ក្របខ័ណ្ឌ** | **ប្រាក់កំរៃគរុកោសល្យ** |
|---|---|---|
| ១ | ប្រភេទ **ក** | ១២ ០០០៛ |
| ២ | ប្រភេទ **ខ** | ១០ ០០០៛ |
| ៣ | ប្រភេទ **គ** | ៨ ០០០៛ |
| ៤ | ប្រភេទ **ឃ** | ៦ ០០០៛ |

**មាត្រា ៧** :

ការកែប្រែប្រាក់កំរៃគរុកោសល្យ ត្រូវធ្វើឡើងដោយអនុក្រឹត្យ។

**មាត្រា៨** :

មន្ត្រីរាជការឯកទេសផ្សេងៗ ដែលត្រូវបានឧទ្ទេសនាមដោយក្រសួងស្ថាប័នអោយបង្ហាត់បង្រៀន ពេញពេលនៅតាមគ្រឹះស្ថានសិក្សានានា រយៈពេលពេញ១ឆ្នាំ ត្រូវទទួលបានប្រាក់កំរៃគរុកោសល្យ។

លិខិតឧទ្ទេសនាមត្រូវធ្វើឡើង១ឆ្នាំម្តងៗ។

## ជំពូកទី៤
## ប្រាក់បង្គ្រប់

**មាត្រា ៩** -

មន្ត្រីរាជការដែលទទួលបានប្រាក់បៀវត្សថ្មី(បៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារ) ទាបជាងប្រាក់បៀវត្សចាស់ត្រូវទទួលបានប្រាក់បង្គ្រប់ដែលធានាមិនអោយទាបជាងប្រាក់បៀវត្សចាស់។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០** -

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា ១២** -

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០២ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** **ហ៊ុន សែន**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១១
-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ៩៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៥

ស្តីពីការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ៩៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ

-យោងតាមការចាំរបស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១**.-

អនុក្រឹត្យនេះ មានគោលដៅបំពេញបន្ថែម និង កែប្រែប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ស្របតាមមាត្រា ២២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ដោយចាប់អនុវត្តពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៥ តទៅ។

**មាត្រា ២**.-

ប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ដែលមានចែងក្នុងមាត្រា ១៧. ១៨. ១៩ និង មាត្រា ២០ ជំពូកទី ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពី បៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល និង មាត្រា ៣ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងារ របស់ មន្ត្រីរាជការស៊ីវិល និង ប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ ត្រូវកែប្រែដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យ នេះ។

**មាត្រា ៣**.-

ប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញមុខងារនៅក្នុងមុខតំណែង ដូចមានកំណត់នៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ត្រូវបានកំណត់ទៅតាមវិស័យដូចខាងក្រោមៈ

១-តារាងប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការរដ្ឋបាលទូទៅ

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ១ | អនុប្រធាននាយកដ្ឋាន | ៥៤០ ០០០៛ | ៥៧៨ ០០០៛ | ៦១៨ ០០០៛ | ៦៦១ ០០០៛ | ៧០៦ ០០០៛ |
| ២ | ប្រធានមន្ទីរជំនាញ ខេត្ត-ក្រុង | ៥២៥ ០០០៛ | ៥៦៣ ០០០៛ | ៦០៣ ០០០៛ | ៦៤៦ ០០០៛ | ៦៩១ ០០០៛ |
| ៣ | អធិការរង ថ្នាក់កណ្តាល | ៥២៥ ០០០៛ | ៥៦៣ ០០០៛ | ៦០៣ ០០០៛ | ៦៤៦ ០០០៛ | ៦៩១ ០០០៛ |
| ៤ | ប្រធានការិយាល័យ ថ្នាក់កណ្តាល | ៧៨ ១០០៛ | ៨៩ ៨០០៛ | ១០៣ ៣០០៛ | ១១៨ ៨០០៛ | ១៣៦ ៦០០៛ |
| ៥ | អនុប្រធាន មន្ទីរជំនាញខេត្ត ក្រុង | ៧១ ០០០៛ | ៨១ ៧០០៛ | ៩៤ ០០០៛ | ១០៨ ១០០៛ | ១២៤ ៣០០៛ |
| ៦ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ៦៥ ០០០៛ | ៧៤ ៨០០៛ | ៨៦ ០០០៛ | ៩៨ ៩០០៛ | ១១៣ ៧០០៛ |
| ៧ | អនុប្រធាន ការិយាល័យ ថ្នាក់កណ្តាល | ៦១ ៤០០៛ | ៧០ ៦០០៛ | ៨១ ២០០៛ | ៩៣ ៤០០៛ | ១០៧ ៤០០៛ |
| ៨ | ប្រធានការិយាល័យ មន្ទីរជំនាញខេត្តក្រុង | ៥៥ ៨០០៛ | ៦៤ ២០០៛ | ៧៣ ៨០០៛ | ៨៤ ៩០០៛ | ៩៧ ៦០០៛ |
| ៩ | អនុប្រធានការិយាល័យមន្ទីរជំនាញខេត្តក្រុង | ៤៤ ១០០៛ | ៥០ ៧០០៛ | ៥៨ ៣០០៛ | ៦៧ ១០០៛ | ៧៧ ២០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ១០ | ប្រធានការិយាល័យជំនាញស្រុកខណ្ឌ | ៤២ ០០០៛ | ៤៨ ៣០០៛ | ៥៥ ៦០០៛ | ៦៤ ០០០៛ | ៧៣ ៦០០៛ |
| ១១ | មន្ត្រីក្រមការ | ៣៦ ៥០០៛ | ៤២ ០០០៛ | ៤៨ ៣០០៛ | ៥៥ ៦០០៛ | ៦៤ ០០០៛ |
| ១២ | អនុប្រធាន ការិយាល័យ ជំនាញស្រុកខណ្ឌ | ៣១ ៧០០៛ | ៣៦ ៥០០៛ | ៤២ ០០០៛ | ៤៨ ៣០០៛ | ៥៥ ៦០០៛ |
| ១៣ | មន្ត្រីលេខាធិការ | ២៤ ០០០៛ | ២៧ ៦០០៛ | ៣១ ៨០០៛ | ៣៦ ៦០០៛ | ៤២ ១០០៛ |

២-តារាងប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការរដ្ឋបាលមហាផ្ទៃ

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ១ | អភិបាល ស្រុកខ័ណ្ឌ | ៥៣០ ០០០៛ | ៥៦៨ ០០០៛ | ៦០៨ ០០០៛ | ៦៥១ ០០០៛ | ៦៩៦ ០០០៛ |
| ២ | នាយ ខុទ្ទកាល័យសាលាខេត្តក្រុង | ៥២៥ ០០០៛ | ៥៦៣ ០០០៛ | ៦០៣ ០០០៛ | ៦៤៦ ០០០៛ | ៦៩១ ០០០៛ |
| ៣ | អភិបាលរង ស្រុកខ័ណ្ឌ | ៧១ ០០០៛ | ៨១ ៧០០៛ | ៩៤ ០០០៛ | ១០៨ ១០០៛ | ១២៤ ៣០០៛ |
| ៤ | នាយរង ខុទ្ទកាល័យសាលាខេត្តក្រុង | ៧១ ០០០៛ | ៨១ ៧០០៛ | ៩៤ ០០០៛ | ១០៨ ១០០៛ | ១២៤ ៣០០៛ |
| ៥ | អគ្គលេខាធិការសាលាខេត្តក្រុង | ៦៧ ៦០០៛ | ៧៧ ៨០០៛ | ៨៩ ៥០០៛ | ១០២ ៩០០៛ | ១១៨ ៣០០៛ |
| ៦ | ប្រធានក្រុមហិរញ្ញវត្ថុ សាលាខេត្តក្រុង | ៦៧ ៦០០៛ | ៧៧ ៨០០៛ | ៨៩ ៥០០៛ | ១០២ ៩០០៛ | ១១៨ ៣០០៛ |
| ៧ | ប្រធានក្រុមអធិការកិច្ច សាលាខេត្តក្រុង | ៦៧ ៦០០៛ | ៧៧ ៨០០៛ | ៨៩ ៥០០៛ | ១០២ ៩០០៛ | ១១៨ ៣០០៛ |
| ៨ | អគ្គលេខាធិការរង សាលាខេត្តក្រុង | ៥៥ ៨០០៛ | ៦៤ ២០០៛ | ៧៣ ៨០០៛ | ៨៤ ៩០០៛ | ៩៧ ៦០០៛ |
| ៩ | អនុប្រធានក្រុមហិរញ្ញវត្ថុ សាលាខេត្តក្រុង | ៥៥ ៨០០៛ | ៦៤ ២០០៛ | ៧៣ ៨០០៛ | ៨៤ ៩០០៛ | ៩៧ ៦០០៛ |
| ១០ | អនុប្រធានក្រុមអធិការកិច្ច សាលាខេត្តក្រុង | ៥៥ ៨០០៛ | ៦៤ ២០០៛ | ៧៣ ៨០០៛ | ៨៤ ៩០០៛ | ៩៧ ៦០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ១១ | ប្រធាន ការិយាល័យសាលាខេត្តក្រុង | ៥៥ ៨០០រ | ៦៤ ២០០រ | ៧៣ ៨០០រ | ៨៤ ៩០០រ | ៩៧ ៦០០រ |
| ១២ | ប្រធាន មន្ទីរ សាលាស្រុកខណ្ឌ | ៤៨ ៥០០រ | ៥៥ ៨០០រ | ៦៤ ២០០រ | ៧៣ ៨០០រ | ៨៤ ៩០០រ |
| ១៣ | អនុប្រធាន ការិយាល័យសាលាខេត្តក្រុង | ៤៤ ១០០រ | ៥០ ៧០០រ | ៥៨ ៣០០រ | ៦៧ ១០០រ | ៧៧ ២០០រ |
| ១៤ | អនុប្រធាន មន្ទីរ សាលាស្រុកខណ្ឌ | ៤៤ ១០០រ | ៥០ ៧០០រ | ៥៨ ៣០០រ | ៦៧ ១០០រ | ៧៧ ២០០រ |
| ១៥ | ប្រធាន ការិយាល័យសាលាស្រុកខណ្ឌ | ៤២ ០០០រ | ៤៨ ៣០០រ | ៥៥ ៦០០រ | ៦៤ ០០០រ | ៧៣ ៦០០រ |
| ១៦ | អនុប្រធានការិយាល័យសាលាស្រុកខណ្ឌ | ៣១ ៧០០រ | ៣៦ ៥០០រ | ៤២ ០០០រ | ៤៨ ៣០០រ | ៥៥ ៦០០រ |
| ១៧ | ស្មៀនឃុំសង្កាត់ | ៣១ ៧០០រ | ៣៦ ៥០០រ | ៤២ ០០០រ | ៤៨ ៣០០រ | ៥៥ ៦០០រ |

### ៣-តារាងប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីពន្ធនាគាររដ្ឋបាលមហាផ្ទៃ

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ១ | ប្រធានពន្ធនាគារកណ្តាល | ១២៦ ៥០០រ | ១៤៥ ៥០០រ | ១៦៧ ៣០០រ | ១៩២ ៤០០រ | ២២១ ៣០០រ |
| ២ | អនុប្រធានពន្ធនាគារកណ្តាល | ១១៥ ០០០រ | ១៣២ ៣០០រ | ១៥២ ២០០រ | ១៧៥ ០០០រ | ២០១ ៣០០រ |
| ៣ | ប្រធានពន្ធនាគារខេត្តក្រុង | ៩៥ ៨០០រ | ១១០ ២០០រ | ១២៦ ៧០០រ | ១៤៥ ៧០០រ | ១៦៧ ៦០០រ |
| ៤ | អនុប្រធានពន្ធនាគារខេត្តក្រុង | ៨៧ ១០០រ | ១០០ ២០០រ | ១១៥ ២០០រ | ១៣២ ៥០០រ | ១៥២ ៤០០រ |
| ៥ | នាយផ្នែករដ្ឋបាលពន្ធនាគារ | ៧២ ៦០០រ | ៨៣ ៥០០រ | ៩៦ ០០០រ | ១១០ ៤០០រ | ១២៧ ០០០រ |
| ៦ | នាយរង ផ្នែករដ្ឋបាលពន្ធនាគារ | ៦៦ ០០០រ | ៧៥ ៩០០រ | ៨៧ ៣០០រ | ១០០ ៤០០រ | ១១៥ ៥០០រ |
| ៧ | អ្នកគ្រប់គ្រងអ្នកទោសក្នុងពន្ធនាគារ | ៦០ ០០០រ | ៦៩ ០០០រ | ៧៩ ៤០០រ | ៩១ ៣០០រ | ១០៥ ០០០រ |

## ៤-តារាងប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការវិស័យអប់រំ

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ២ | នាយករង វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៣ | នាយករងវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៤ | នាយករងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៥ | នាយកសាលាមធ្យមសិក្សាបច្ចេកទេសឬស្សីកែវ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៦ | សាស្ត្រាចារ្យ ឧត្តមសិក្សា | ២១៥ ៧០០៛ | ២៤៨ ១០០៛ | ២៨៥ ៣០០៛ | ៣២៨ ១០០៛ | ៣៧៧ ៣០០៛ |
| ៧ | អធិការ មធ្យមសិក្សា | ១៩៦ ១០០៛ | ២២៥ ៥០០៛ | ២៥៩ ៣០០៛ | ២៩៨ ២០០៛ | ៣៤២ ៩០០៛ |
| ៨ | គ្រូបង្រៀន ឧត្តមសិក្សា | ១៧៨ ៣០០៛ | ២០៥ ១០០៛ | ២៣៥ ៩០០៛ | ២៧១ ៣០០៛ | ៣១២ ០០០៛ |
| ៩ | នាយក វិទ្យាល័យ | ១៣២ ១០០៛ | ១៥១ ៩០០៛ | ១៧៤ ៧០០៛ | ២០០ ៩០០៛ | ២៣១ ០០០៛ |
| ១០ | នាយករង វិទ្យាល័យ | ១២៥ ៨០០៛ | ១៤៤ ៧០០៛ | ១៦៦ ៤០០៛ | ១៩១ ៤០០៛ | ២២០ ១០០៛ |
| ១១ | គ្រូបង្រៀន មធ្យមសិក្សាទុតិយភូមិ | ១២៥ ៨០០៛ | ១៤៤ ៧០០៛ | ១៦៦ ៤០០៛ | ១៩១ ៤០០៛ | ២២០ ១០០៛ |
| ១២ | នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ១១៩ ៨០០៛ | ១៣៧ ៨០០៛ | ១៥៨ ៥០០៛ | ១៨២ ៣០០៛ | ២០៩ ៧០០៛ |
| ១៣ | នាយក សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា | ១១៤ ១០០៛ | ១៣១ ២០០៛ | ១៥០ ៩០០៛ | ១៧៣ ៥០០៛ | ១៩៩ ៥០០៛ |
| ១៤ | នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម | ១១៤ ១០០៛ | ១៣១ ២០០៛ | ១៥០ ៩០០៛ | ១៧៣ ៥០០៛ | ១៩៩ ៥០០៛ |
| ១៥ | នាយក សាលាគរុកោសល្យខេត្តក្រុង | ១១៤ ១០០៛ | ១៣១ ២០០៛ | ១៥០ ៩០០៛ | ១៧៣ ៥០០៛ | ១៩៩ ៥០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៦ | នាយក មជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ | ១១៤ ១០០៛ | ១៣១ ២០០៛ | ១៥០ ៩០០៛ | ១៧៣ ៥០០៛ | ១៩៩ ៥០០៛ |
| ១៧ | នាយក មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ១០៨ ៧០០៛ | ១២៥ ០០០៛ | ១៤៣ ៨០០៛ | ១៦៥ ៤០០៛ | ១៩០ ២០០៛ |
| ១៨ | នាយករងសាលាមធ្យមសិក្សាបច្ចេកទេសឬស្សីកែវ | ១០៣ ៥០០៛ | ១១៩ ០០០៛ | ១៣៦ ៩០០៛ | ១៥៧ ៤០០៛ | ១៨១ ០០០៛ |
| ១៩ | នាយករង សាលាគរុកោសល្យខេត្តក្រុង | ១០៣ ៥០០៛ | ១១៩ ០០០៛ | ១៣៦ ៩០០៛ | ១៥៧ ៤០០៛ | ១៨១ ០០០៛ |
| ២០ | នាយករង សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា | ១០៣ ៥០០៛ | ១១៩ ០០០៛ | ១៣៦ ៩០០៛ | ១៥៧ ៤០០៛ | ១៨១ ០០០៛ |
| ២១ | នាយករងសាលាមធ្យមសិក្សាគរុកោសល្យឧត្តមយ្យឈ្លឹម | ១០៣ ៥០០៛ | ១១៩ ០០០៛ | ១៣៦ ៩០០៛ | ១៥៧ ៤០០៛ | ១៨១ ០០០៛ |
| ២២ | នាយករង មជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ | ១០៣ ៥០០៛ | ១១៩ ០០០៛ | ១៣៦ ៩០០៛ | ១៥៧ ៤០០៛ | ១៨១ ០០០៛ |
| ២៣ | អធិការ បឋមសិក្សា | ៩៨ ៦០០៛ | ១១៣ ៤០០៛ | ១៣០ ៤០០៛ | ១៥០ ០០០៛ | ១៧២ ៥០០៛ |
| ២៤ | នាយក អនុវិទ្យាល័យ | ៩៣ ៩០០៛ | ១០៨ ០០០៛ | ១២៤ ២០០៛ | ១៤២ ៨០០៛ | ១៦៤ ២០០៛ |
| ២៥ | នាយកមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តក្រុង | ៩៣ ៩០០៛ | ១០៨ ០០០៛ | ១២៤ ២០០៛ | ១៤២ ៨០០៛ | ១៦៤ ២០០៛ |
| ២៦ | នាយករង អនុវិទ្យាល័យ | ៨៩ ៤០០៛ | ១០២ ៨០០៛ | ១១៨ ២០០៛ | ១៣៥ ៩០០៛ | ១៥៦ ៣០០៛ |
| ២៧ | នាយករងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តក្រុង | ៨៩ ៤០០៛ | ១០២ ៨០០៛ | ១១៨ ២០០៛ | ១៣៥ ៩០០៛ | ១៥៦ ៣០០៛ |
| ២៨ | គ្រូបង្រៀន មធ្យមសិក្សា បឋមភូមិ | ៨៥ ១០០៛ | ៩៧ ៩០០៛ | ១១២ ៦០០៛ | ១២៩ ៥០០៛ | ១៤៨ ៩០០៛ |
| ២៩ | នាយក សាលាបឋមសិក្សា-មត្តេយ្យសិក្សា | ៨១ ០០០៛ | ៩៣ ២០០៛ | ១០៧ ២០០៛ | ១២៣ ៣០០៛ | ១៤១ ៨០០៛ |
| ៣០ | នាយករង សាលាបឋមសិក្សា-មត្តេយ្យសិក្សា | ៧៣ ៦០០៛ | ៨៤ ៧០០៛ | ៩៧ ៤០០៛ | ១១២ ០០០៛ | ១២៨ ៨០០៛ |
| ៣១ | គ្រូបង្រៀន បឋមសិក្សា-មត្តេយ្យសិក្សា | ៧០ ១០០៛ | ៨០ ៦០០៛ | ៩២ ៧០០៛ | ១០៦ ៦០០៛ | ១២២ ៦០០៛ |
| ៣២ | គ្រូបង្រៀន កំរិត បឋម | ៦៨ ០០០៛ | ៧៨ ២០០៛ | ៨៩ ៩០០៛ | ១០៣ ៤០០៛ | ១១៨ ៩០០៛ |

### ៥-តារាងប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការវិស័យសុខាភិបាល

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរសរង មហាវិទ្យាល័យ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ២ | នាយករងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រថ្នាក់កណ្តាល | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៣ | នាយករង មន្ទីរពេទ្យជាតិ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៤ | នាយករង មជ្ឈមណ្ឌលជាតិ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៥ | នាយករង វិទ្យាស្ថានជាតិ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៦ | នាយករង មន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពឱសថ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៧ | នាយករង ឃ្លាំងឱសថកណ្តាល | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៨ | នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៩ | គ្រូពេទ្យ ឯកទេស | ២០៣ ៨០០៛ | ២៣៤ ៤០០៛ | ២៦៩ ៦០០៛ | ៣១០ ១០០៛ | ៣៥៦ ៦០០៛ |
| ១០ | គ្រូពេទ្យ អនុបណ្ឌិត | ១៨៥ ៣០០៛ | ២១៣ ១០០៛ | ២៤៥ ១០០៛ | ២៨១ ៩០០៛ | ៣២៤ ២០០៛ |
| ១១ | ទន្តបណ្ឌិតឯកទេស | ១៧៦ ៥០០៛ | ២០៣ ០០០៛ | ២៣៣ ៥០០៛ | ២៦៨ ៥០០៛ | ៣០៨ ៨០០៛ |
| ១២ | ឱសថបណ្ឌិត | ១៧៦ ៥០០៛ | ២០៣ ០០០៛ | ២៣៣ ៥០០៛ | ២៦៨ ៥០០៛ | ៣០៨ ៨០០៛ |

**មាត្រា ៥**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន។

**មាត្រា ៧**.-

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៦

-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភសម្រាប់មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ៥៣ អនក្រ.បក

**<u>អនុក្រឹត្យ</u>**

**ស្តីពី**

**ការកំណត់ប្រាក់បំណាច់ឧបត្ថម្ភសម្រាប់មន្ត្រីរាជការស៊ីវិល**

**ដែលបានបញ្ចប់ការបណ្តុះបណ្តាលជំនួងនៅសាលាភូមិន្ទរដ្ឋបាល**

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សមន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែប្រែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ

-បានឃើញអនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល

-យោងតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលរបស់សាលាភូមិន្ទរដ្ឋបាល កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៦

-យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាលរបស់សាលាភូមិន្ទរដ្ឋបាល

# សំរេច

**មាត្រា ១.**

អនុក្រឹត្យនេះ មានគោលដៅកំណត់ឲ្យបានសមស្របនូវប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ សម្រាប់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល បន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន ដោយគិតចាប់តាំងពី ខែកក្កដា ឆ្នាំ២០០៧ តទៅ ។

**មាត្រា ២.**

ប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ របស់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល ហើយដែលកំពុងបម្រើការងារស៊ប់ក្នុងក្របខ័ណ្ឌរដ្ឋនៅតាមក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាលត្រូវបានកំណត់ដូចខាងក្រោមៈ

១. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីជាន់ខ្ពស់ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ស្មើនឹងប្រាក់បំណាច់មុខងារប្រចាំខែរបស់អនុប្រធាននាយកដ្ឋាន ។

២. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាលវគ្គសិស្សមន្ត្រីក្រមការ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ស្មើនឹងប្រាក់បំណាច់មុខងារប្រចាំខែរបស់អនុប្រធានការិយាល័យថ្នាក់កណ្តាល ។

ប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូង នៅសាលាភូមិន្ទរដ្ឋបាល ហើយដែលស្ថិតនៅក្នុងកម្មសិក្សាក្នុងក្របខ័ណ្ឌរដ្ឋនៅតាមក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាលត្រូវបានកំណត់ដូចខាងក្រោមៈ

១. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីជាន់ខ្ពស់ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ចំនួន ៣០០ ០០០ រៀល (សាមសិបម៉ឺនរៀល) ។

២. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីក្រមការ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ចំនួន ៦០ ០០០ រៀល (ប្រាំមួយម៉ឺនរៀល)។

**មាត្រា ៣.**

ប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ សម្រាប់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល ដូចមានចែងក្នុងមាត្រា ២ ត្រូវបានជំនួសដោយប្រាក់បំណាច់មុខងារនៅពេលដែលមន្ត្រីនោះ ទទួលបានការតែងតាំងក្នុងមុខតំណែង ដែលមានប្រាក់បំណាច់ឧបត្ថម្ភនេះ ។

**មាត្រា ៤.**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

<u>កន្លែងទទួលៈ</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៥

-ឯកសារ-កាលប្បវត្តិ

# ៤.៣ ប្រាក់បំណាច់មុខងារសម្រាប់មុខដំណែង ក្រៅក្របខ័ណ្ឌមន្ត្រីរាជការ

- អនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ ស្ដីពីប្រាក់បំណាច់របស់សមាជិក រាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ទីប្រឹក្សាព្រមទាំងមន្ត្រីរាជការ ស៊ីវិល និងកងកម្លាំងប្រដាប់អាវុធចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ៦២ អនក្រ.បក

# <u>អនុក្រឹត្យ</u>

## ស្តីពី

## ប្រាក់បំណាច់របស់សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ទីប្រឹក្សា ព្រមទាំង មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៅតាមក្រសួង ស្ថាប័ន និងរដ្ឋលេខាធិការដ្ឋាន

-យោងសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១** -

អនុវត្តការផ្តល់ប្រាក់បំណាច់បន្ថែមលើប្រាក់បៀវត្សប្រចាំខែតាមស្មារតីអនុក្រឹត្យ លេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥ ចាប់ពី ខែ មករា ឆ្នាំ ២០០៥ តទៅ ចំពោះ សមាជិក សមាជិកា រាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ទីប្រឹក្សា រាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី-ឧបនាយករដ្ឋមន្ត្រី ព្រមទាំងមន្ត្រីរាជការស៊ីវិល និង កងកម្លាំង ប្រដាប់អាវុធ ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការឡើងទៅ។

**មាត្រា ២** -

ប្រាក់បំណាច់បន្ថែមលើប្រាក់បៀវត្សប្រចាំខែនេះ ត្រូវបានកំណត់ក្នុងតារាងជូនខាងក្រោមៈ

| ប្រភេទប្រាក់បំណាច់ → មុខតំណែង ↓ | ប្រាក់បំណាច់តំណាង | ប្រាក់បំណាច់បដិសណ្ឋារកិច្ច | ប្រាក់បំណាច់បេសកកម្ម | ប្រាក់ឈ្នួលផ្ទះ ទឹក ភ្លើង | សរុប |
|---|---|---|---|---|---|
| នាយករដ្ឋមន្ត្រី | ១.១៣៧.៥០០៛ | ៩៦២.៥០០៛ | ៦១២.៥០០៛ | ៩៦២.៥០០៛ | ៣.៦៧៥.០០០៛ |
| ឧបនាយករដ្ឋមន្ត្រី | ៩១៨.៧៥០៛ | ៧៤៣.៧៥០៛ | ៤៨១.២៥០៛ | ៦៥៦.២៥០៛ | ២.៨០០.០០០៛ |
| ទេសរដ្ឋមន្ត្រី | ៨៣១.២៥០៛ | ៦៥៦.២៥០៛ | ៣៩៣.៧៥០៛ | ៥៦៨.៧៥០៛ | ២.៤៥០.០០០៛ |
| រដ្ឋមន្ត្រី | ៧៤៣.៧៥០៛ | ៥៦៨.៧៥០៛ | ៣០៦.២៥០៛ | ៤៨១.២៥០៛ | ២.១០០.០០០៛ |
| រដ្ឋលេខាធិការ | ៧០០.០០០៛ | ៤៨១.២៥០៛ | ២៦២.៥០០៛ | ៣០៦.២៥០៛ | ១.៧៥០.០០០៛ |
| អនុរដ្ឋលេខាធិការ | ៥២៥.០០០៛ | ៣៥០.០០០៛ | ២៦២.៥០០៛ | ២៦២.៥០០៛ | ១.៤០០.០០០៛ |

**មាត្រា ៣** -

មន្ត្រីជាន់ខ្ពស់ដូចកំណត់ក្នុងមាត្រា ១ ដែលមានមុខតំណែងពីរ ឬ បី មានសិទ្ធិទទួលប្រាក់បំណាច់ខាងលើបានតែមួយមុខតំណែង ក្នុងតំណែងណាមួយក៏បាន ។

**មាត្រា ៤** -

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួលៈ</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-ឯកសារ-កាលប្បវត្តិ

## ៤.៤ ការបន្ថែមប្រាក់បៀវត្សជូនមន្ត្រីរាជការ

❖ អនុក្រឹត្យ លេខ ២៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការបន្ថែមប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និវត្តជន និងមន្ត្រីបាត់បង់សមត្ថភាពពលកម្ម

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ២៨ អនក្រ. បក

## អនុក្រឹត្យ
## ស្តីពីការបន្ថែមប្រាក់បៀវត្ស ជូនមន្ត្រីរាជការ
## ស៊ីវិល យោធា នគរបាលជាតិ
## និវត្តជន និង មន្ត្រីបាត់បង់សមត្ថភាពពលកម្ម

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម នរ/រកម/០១.៩៩/០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩

-បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី

-យោងការសំរេចរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៩

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សំរេច

**មាត្រា ១.**

ត្រូវបានអនុញ្ញាតិអោយបន្ថែមប្រាក់បៀវត្ស ចំនួន ៣០ ភាគរយ លើបៀវត្សសុទ្ធសាធ ជូនមន្ត្រីរាជការ ស៊ីវិល យោធា នគរបាលជាតិ និវត្តជន និង មន្ត្រីបាត់បង់សមត្ថភាពពលកម្ម។

**មាត្រា ២.**

ប្រាក់បៀវត្សដែលបន្ថែម ៣០ ភាគរយនេះ ត្រូវចាប់អនុវត្តពី ខែឧសភា ឆ្នាំ ១៩៩៩ តទៅ ។

**មាត្រា ៣.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣

-កាលប្បវត្តិ-ឯកសារ

**បានជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- ❖ អនុក្រឹត្យ លេខ ០៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល កែប្រែពីចំនួន៣០០រៀល ទៅ ចំនួន ៣៤៥ រៀល

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ០៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជលេខក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជលេខក្រម ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.**

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ត្រូវកែប្រែពីចំនួន ៣០០ រៀល ទៅចំនួន ៣៤៥ រៀល ក្នុងមួយសន្ទស្សន៍ស្មើនឹងចំនួន ១៥ភាគរយ លើបៀវត្សមូលដ្ឋាន។

**មាត្រា ២.**

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ដូចមានកំណត់ក្នុងមាត្រា១ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ តទៅ ។

**មាត្រា ៣.**

អនុក្រឹត្យនេះ មានប្រសិទ្ធភាពអនុវត្តផងដែរចំពោះនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។

**មាត្រា ៤.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសារធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន។

**មាត្រា៥.**

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ មករា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

<u>កន្លែងទទួលៈ</u>

**សុខ អាន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ១៤០ អនក្រ.បក  ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៥   ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលៈ កែប្រែពីចំនួន ៣៨៥ រៀល ទៅចំនួន ៤០០ រៀល

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១៤០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-យោងតាមសេចក្តីជូនដំណឹងលេខ១៧៥៩ សជណ ចុះថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការសម្រាប់ឆ្នាំ២០០៦ និងយោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.**

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ត្រូវកែប្រែពីចំនួន៣៤៥ រៀលទៅចំនួន៤០០ រៀល ក្នុងមួយសន្ទស្សន៍។

**មាត្រា២.**

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ដូចមានកំណត់ក្នុងមាត្រា១ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ តទៅ។

**មាត្រា៣.**

អនុក្រឹត្យនេះ មានប្រសិទ្ធភាពអនុវត្តផងដែរចំពោះនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។

**មាត្រា៤.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា៥.**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៤

-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ១៥១ អនក្រ.បក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦ ស្តីពី ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល កែប្រែពីចំនួន ៤០០ រៀល ទៅចំនួន ៤៦០ រៀល

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១៥១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា១**.

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ត្រូវកែប្រែពីចំនួន៤០០ រៀលទៅចំនួន៤៦០ រៀលក្នុងមួយសន្ទស្សន៍។

**មាត្រា២**.

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ដូចមានកំណត់ក្នុងមាត្រា១ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ តទៅ ។

**មាត្រា៣.**

អនុក្រឹត្យនេះ មានប្រសិទ្ធភាពអនុវត្តផងដែរចំពោះនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។

**មាត្រា៤.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា៥.**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

<u>កន្លែងទទួលៈ</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ៤៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល កែប្រែពីចំនួន៤៦០រៀល ទៅ ចំនួន ៥០០ រៀល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ៨៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន របស់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា១**.

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ត្រូវកែប្រែពីចំនួន៤០០រៀល ទៅចំនួន ៥០០រៀល ក្នុងមួយសន្ទស្សន៍។

**មាត្រា២.**

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ដូចមានកំណត់ក្នុងមាត្រា១ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ តទៅ ។

**មាត្រា៣.**

អនុក្រឹត្យនេះ មានប្រសិទ្ធភាពអនុវត្តផងដែរចំពោះនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។

**មាត្រា៤.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសារធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា៥.**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

<u>កន្លែងទទួលៈ</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ១៩៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល កែប្រែពី ចំនួន ៥០០ រៀល ទៅចំនួន ៦០០ រៀល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១៩៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល
# រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សំរេច

**មាត្រា១.**

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ត្រូវកែប្រែពីចំនួន ៥០០ រៀល ទៅចំនួន ៦០០ រៀល ក្នុងមួយសន្ទស្សន៍។

**មាត្រា២.**

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ដូចមានកំណត់ក្នុងមាត្រា១ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៨ តទៅ ។

**មាត្រា៣.**

អនុក្រឹត្យនេះ មានប្រសិទ្ធភាពអនុវត្តផងដែរចំពោះកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និង និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។

**មាត្រា៤.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសារធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន។

**មាត្រា៥.**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

<u>កន្លែងទទួលៈ</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពី ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល កែប្រែពី ចំនួន៦០០ រៀល ទៅ ចំនួន ៧២០ រៀល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ២១ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា១.**

តម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលដូចមានចែងក្នុងមាត្រា ៤ វាក្យខណ្ឌទី១នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល ត្រូវកែប្រែពីចំនួន ៦០០ រៀល ទៅ ៧២០ រៀល ក្នុងមួយសន្ទស្សន៍។

**មាត្រា២.**

តម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន ដូចមានកំណត់មាត្រា ១ ខាងលើ ត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ តទៅ ។

**មាត្រា៣.**

អនុក្រឹត្យនេះមានប្រសិទ្ធភាពអនុវត្តផងដែរចំពោះកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និង និវត្តន៍ជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ។

**មាត្រា៤.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសារធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា៤

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលៈ កែប្រែពីចំនួន ៧២០ រៀល ទៅ ចំនួន ៨៧០ រៀល

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ២០៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន និងការបង្កើតបៀវត្សរ៍សុទ្ធសាធរបស់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-បានឃើញព្រះក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

-បានឃើញអនុក្រឹត្យលេខ ១៨៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ

-បានឃើញក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩ ស្ដីពីការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មន្ត្រីរាជការស៊ីវិល
-បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ស្ដីពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា ១.**

អនុក្រឹត្យនេះ មានគោលដៅកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន ពី ៧២០ (ប្រាំពីររយម្ភៃ) រៀលទៅ ៨៧០ (ប្រាំបីរយចិតសិប) រៀល របស់មន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបង្កើន ២០ (ម្ភៃ) ភាគរយ នៃបៀវត្សរ៍សុទ្ធសាធរបស់និវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនបាត់បងសមត្ថភាពពលកម្ម ជនពិការ ដែលជាអតីតយុទ្ធជន។

**មាត្រា ២.**

តម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន និងការបង្កើតបៀវត្សរ៍សុទ្ធសាធដូចមានចែងក្នុងមាត្រា ១ ខាងលើត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ តទៅ ។

**មាត្រា ៣.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

បានយកសេចក្ដីជម្រាបជូន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

<u>កន្លែងទទួល:</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

❖ សារាចរណែនាំ លេខ ០០១ សរណន.សអយ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០០៦ របស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការកែប្រែតម្លៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**
លេខៈ០០១ សរណន ស.អ.យ

# សារាចរណែនាំ
## ស្តីពី
## ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

ដើម្បីអនុវត្តអោយមានប្រសិទ្ធភាពតាមខ្លឹមសារ នៃអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សូមធ្វើការណែនាំអនុវត្តដូចតទៅៈ

**I-របៀបគណនាប្រាក់សោធនរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ**

ការគណនាប្រាក់សោធនរបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោមៈ

ប្រាក់សោធនសរុបប្រចាំខែថ្មី=ប្រាក់សោធនសុទ្ធសាធ+ប្រាក់បង្គ្រប់+ប្រាក់បន្ថែមអោយស្មើប្រាក់សោធនចាស់+ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងៗ ប្រសិនបើមាន

ប្រាក់សោធនសុទ្ធសាធ = (សន្ទស្សន៍បៀវត្សមូលដ្ឋាន × តម្លៃឯកតានៃសន្ទស្សន៍ × អត្រាភាគរយប្រាក់សោធន

<u>ឧទាហរណ៍ទី១</u>

និវត្តជនម្នាក់មានកាំប្រាក់ ក ៣.៥ មានសន្ទស្សន៍បៀវត្សមូលដ្ឋាន = ៣៩៩ តម្លៃឯកតានៃសន្ទស្សន៍ = ៤០០៛០០ និង អត្រាភាគរយប្រាក់សោធន = ៨០% នៃបៀវត្សមូលដ្ឋាន។ មុនពេលធ្វើសមាហរណកម្មនិវត្តជននោះមានប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែចំនួន ១១០.១២៤៛០០ ។ ដូច្នេះការគណនាប្រាក់សោធននិវត្តន៍ថ្មីរបស់គាត់គឺៈ

ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ = ៣៩៩ × ៤០០ × ៨០% = ១២៧.៦៨០៛០០

១/ចំពោះនិវត្តជនដែលមានប្រាក់សោធនសុទ្ធសាធ ទាបជាងប្រាក់បៀវត្សមូលដ្ឋានអប្បបរមាត្រូវគណនាតាមរូបមន្តដូចខាងក្រោមៈ

ប្រាក់សោធននិវត្តន៍សរុបប្រចាំខែ = ប្រាក់សោធនសុទ្ធសាធ + ប្រាក់តំឡើងអោយស្មើបៀវត្សមូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមអោយស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងៗ ប្រសិនបើមាន

ឧទាហរណ៍ទី២

និវត្តជនម្នាក់មានកាំប្រាក់ ឃ១.១ សន្ទស្សន៍បៀវត្សមូលដ្ឋាន = ១៧៥ តម្លៃឯកតានៃសន្ទស្សន៍ = ៤០០៛០០ អត្រាភាគរយប្រាក់សោធន = ៨០% នៃបៀវត្សមូលដ្ឋាន។ មុនពេលធ្វើសមាហរណកម្ម និវត្តជនគាត់មានប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែចំនួន ៦៤.០៩៥៛០០ ។ ដូច្នេះការគណនាប្រាក់សោធននិវត្តន៍របស់គាត់គឺ:

-ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ឃ១.១ =១៧៥ × ៤០០ × ៨០% = ៥៦.០០០៛០០
-ប្រាក់បៀវត្សមូលដ្ឋានអប្បបរមា ឃ១.៦ = ៥៦.៤០០៛០០
-ប្រាក់បន្ថែមឱ្យស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = (៥៦.៤០០ - ៥៦.០០០)= ៤០០៛០០
-ប្រាក់បង្គ្រប់ = ១៥.០០០៛០០
-ប្រាក់បន្ថែមឱ្យស្មើសោធនចាស់ = ៤៥០៛០០
ដូច្នេះប្រាក់សោធននិវត្តន៍សរុបប្រចាំខែថ្មីគឺ = ៥៦ ០០០៛០០ + ៤០០៛០០ + ១៥ ០០០៛០០ + ៤៥០៛០០
= ៧១.៨៥០៛០០

២/ចំពោះជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលមានប្រាក់សោធនទាបជាង ៩០% នៃបៀវត្សមូលដ្ឋានអប្បបរមាត្រូវគណនា តាមរូបមន្តដូចខាងក្រោមៈ

| |
|---|
| ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសរុបប្រចាំខែ = ប្រាក់សោធនសុទ្ធសាធ + ប្រាក់តំឡើងអោយស្មើ៩០%នៃបៀវត្សមូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមអោយស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងៗទៀតប្រសិនបើមាន |

ឧទាហរណ៍ទី៣

ជនបាត់បង់សម្បទាវិជ្ជាជីវៈ ម្នាក់មានកាំប្រាក់ គ៣.១៤ សន្ទស្សន៍បៀវត្សមូលដ្ឋាន = ១៥០ តម្លៃឯកតានៃសន្ទស្សន៍ = ៤០០៛០០ អត្រាភាគរយប្រាក់សោធន = ៦៥% នៃបៀវត្សមូលដ្ឋាន។ មុនពេលធ្វើ សមាហរណកម្ម គាត់មានប្រាក់សោធន និវត្តន៍សុទ្ធសាធប្រចាំខែចំនួន ៤៦.៥៧៥៛០០ ។ ដូចច្នេះការគណនាប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈរបស់គាត់គឺ:

-ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធប្រចាំខែ គ៣.១៤=១៥០×៤០០ × ៦៥%= ៣៩.០០០៛០០
-៩០%នៃប្រាក់បៀវត្សមូលដ្ឋានអប្បបរមា គ៣.១៤ = ៦០.០០០៛០០ × ៩០% = ៥៤.០០០៛០០
-ប្រាក់បន្ថែមឱ្យស្មើនឹង៩០%នៃបៀវត្សមូលដ្ឋានអប្បបរមា = (៥៤.០០០ - ៣៩.០០០)=១៥.០០០៛០០
ដូចច្នេះប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសរុបប្រចាំខែថ្មីគឺ = ៣៩.០០០៛០០+១៥.០០០៛០០= ៥៤.០០០៛០០

គណនាការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន នៃប្រាក់សោធនសុទ្ធសាធរបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តចាប់ពីខែ មករា ឆ្នាំ ២០០៦ តទៅ ។

## II-របៀបគណនាប្រាក់សោធនរបស់មន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍ និង ចូលបាត់បង់សម្បទាវិជ្ជាជីវៈ

មន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍និងចូលបាត់បង់សម្បទាវិជ្ជាជីវៈក៏ត្រូវគណនាប្រាក់សោធន ដូចរូបមន្តខាងលើដែរ ។

ប្រាក់សោធនរបស់មន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៦ តទៅ ។

សំណុំលិខិតស្នើសុំប្រាក់សោធនថ្មីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រប់ខេត្ត/ក្រុងមានដូច ខាងក្រោម៖

-តារាងបើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែចុងក្រោយ ០១ ច្បាប់

-តារាងបើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែថ្មី ០៣ ច្បាប់

បន្ទាប់ពីមានការយល់ព្រមជាគោលការណ៍ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា លើតារាងប្រាក់សោធន ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រប់ខេត្ត/ក្រុង មានសិទ្ធិចុះហត្ថលេខានៅលើទំព័រត្រង់ (ប្តូរប្រាក់បៀវត្ស គិតពីថ្ងៃទី ខែ ឆ្នាំ ) របស់សៀវភៅនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សង្ឃឹមយ៉ាងមុតមាំថា ក្រសួង/ស្ថាប័ន និង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រប់ខេត្ត/ក្រុង នឹងអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះអោយទទួលបានប្រសិទ្ធភាពខ្ពស់ជាក់ជាមិនខានឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិនា ២០០៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

<u>ចម្លងជូន</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
-គ្រប់សាលាខេត្ត/ក្រុង
(ដើម្បីជូនជ្រាបជាព័ត៌មាន)
-គ្រប់ក្រសួង/ស្ថាប័ននៃរាជរដ្ឋាភិបាល
-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រប់ខេត្ត/ក្រុង
(ដើម្បីសហការអនុវត្ត)
-ឯកសារ-កាលប្បវត្តិ

# តារាងបៀវត្សមូលដ្ឋានថ្មីនៃមន្ត្រីរាជការស៊ីវិល

| ឋានន្តរសក្តិ | ថ្នាក់ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 14 | 13 | 12 | 11 | 10 | 9 | 8 | 7 | 6 | 5 | 4 | 3 | 2 | 1 |
| ក១ | | | | | | | | | 174,400 | 182,800 | 192,800 | 202,400 | 211,200 | 220,000 |
| ក២ | | | | | 144,400 | 149,200 | 154,800 | 160,800 | 167,600 | 174,800 | 181,600 | 186,800 | 191,200 | 194,800 |
| ក៣ | 126,000 | 129,200 | 132,400 | 136,000 | 139,600 | 143,600 | 147,600 | 152,000 | 156,000 | 159,600 | 162,800 | 165,600 | 168,000 | 170,000 |
| ខ១ | | | | | | | | | 123,200 | 129,600 | 137,600 | 144,000 | 149,600 | 154,000 |
| ខ២ | | | | | 100,800 | 104,800 | 108,800 | 113,200 | 118,000 | 122,400 | 126,400 | 130,000 | 133,200 | 136,000 |
| ខ៣ | 88,000 | 90,000 | 92,000 | 94,400 | 97,200 | 100,400 | 103,600 | 106,400 | 109,200 | 111,600 | 113,600 | 115,600 | 117,200 | 118,800 |
| គ១ | | | | | | | | | 84,800 | 89,200 | 94,000 | 98,000 | 101,600 | 104,800 |
| គ២ | | | | | 69,200 | 71,200 | 74,000 | 77,200 | 80,400 | 83,200 | 86,000 | 88,800 | 91,200 | 93,200 |
| គ៣ | 60,000 | 61,600 | 63,200 | 65,200 | 67,200 | 69,600 | 71,600 | 73,600 | 75,200 | 76,800 | 78,000 | 79,200 | 80,000 | 80,800 |
| ឃ១ | | | | | | | | | 56,400 | 59,600 | 62,800 | 65,600 | 68,000 | 70,000 |
| ឃ២ | | | | | 45,200 | 46,800 | 48,800 | 51,200 | 53,600 | 55,600 | 57,600 | 59,200 | 60,800 | 62,000 |
| ឃ៣ | 40,000 | 40,800 | 41,600 | 42,400 | 43,600 | 44,800 | 46,400 | 48,000 | 49,200 | 50,400 | 51,600 | 52,400 | 53,200 | 54,000 |

# ៥. ប្រាក់ឧបត្ថម្ភផ្សេងៗ

## ៥.១ ប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស

❖ អនុក្រឹត្យ លេខ១០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ ស្តីពី ការកំណត់ប្រាក់របបបេសកកម្មក្នុង និងក្រៅប្រទេស

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១០អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពីការកំណត់ប្រាក់របបបេសកកម្មក្នុង និង ក្រៅប្រទេស

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/ រកម / ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០១/ នស /៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្ដីពីការកំណត់ប្រាក់របបបេសកកម្មក្នុងប្រទេស

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១** : អនុក្រឹត្យនេះ មានទិសដៅកំណត់នូវប្រាក់របបឧបត្ថម្ភជីវភាពដល់មន្ត្រីរាជការដែលមានភារៈកិច្ចបំពេញការងារបេសកកម្មក្នុង និងក្រៅប្រទេស ។

## ជំពូកទី២

## ក្របខ័ណ្ឌមន្ត្រីរាជការដែលត្រូវបានទទួលប្រាក់របបបេសកកម្ម

**មាត្រា២** : មន្ត្រីរាជការដែលត្រូវបានទទួលរបបបេសកកម្មក្នុង និង ក្រៅប្រទេស គឺជាមន្ត្រីរាជការដែលកំពុងកាន់មុខតំណែងពិតប្រាកដនៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង និង ស្ថាប័នរដ្ឋ។

**មាត្រា៣** : មន្ត្រីរាជការទាំងឡាយដូចមាត្រា២ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភជីវភាពក្នុងពេលបំពេញការងារបេសកកម្មទៅតាមឋានន្តរស័ក្តិនៃមុខតំណែង និង ទីកន្លែងបំពេញការងារ។

## ជំពូកទី៣

## អំពីប្រាក់របបឧបត្ថម្ភ

### I-បេសកកម្មក្នុងប្រទេស

**មាត្រា ៤** : ប្រាក់របបឧបត្ថម្ភជីវភាពក្នុងកិច្ចបំពេញការងារបេសកកម្មត្រូវបានកំណត់ដូចតទៅ:

ក: ប្រាក់របបពិសេសសំរាប់មន្ត្រីជាន់ខ្ពស់មានឋានៈចាប់ពីថ្នាក់អគ្គលេខាធិការ អគ្គនាយក ឬ មន្ត្រីថ្នាក់ស្មើនឹងមុខតំណែងនេះឡើងទៅ:

| សោហ៊ុយចំណាយបេសកកម្ម | របបឧបត្ថម្ភក្នុងម្នាក់/ថ្ងៃឬយប់ | ផ្សេងៗ |
|---|---|---|
| -ប្រាក់ហោប៉ៅ<br>-ហូបចុក<br>-ស្នាក់នៅ | ១៦.000៛00<br>៣0.000៛00<br>៨0.000៛00 | ✷ក្នុងទីក្រុងភ្នំពេញ ឬ ក្នុងទីក្រុង តាមខេត្តក្រុងនានា មិនផ្តល់ជូនទេ<br>✷បេសកកម្មរយៈពេលខ្លី: ធ្វើដំណើរដោយមធ្យោបាយរបស់រដ្ឋ និងមិនសំរាកពេលយប់ ផ្តល់ជូនតែប្រាក់បេសកកម្ម និងប្រាក់ហូបចុក។ |

ខៈប្រាក់របបបេសកម្មសំរាប់មន្ត្រីរាជការទូទៅ មានឋានៈចាប់ពីថ្នាក់អគ្គលេខាធិការរង អគ្គនាយករង ឬ មន្ត្រីថ្នាក់ស្មើនឹងមុខតំណែងនេះចុះក្រោមៈ

| សោហ៊ុយ ចំណាយ បេសកកម្ម | របបឧបត្ថម្ភក្នុងម្នាក់ | | | | | | | រយៈ ពេល |
|---|---|---|---|---|---|---|---|---|
| | ក្នុងទីក្រុង ភ្នំពេញ ឬ ក្នុងទីក្រុង តាមខេត្ត នានា | សំរាប់ក្នុងទឹកដីខេត្ត-ក្រុងដែលមានចំងាយផ្លូវ | | សំរាប់ក្នុងទឹកដីខេត្តភូមិភាគឥសាន្តដែលមាន ចំងាយផ្លូវ | | បេសកកម្មឆ្លងខេត្តក្រុងដែលមានចំងាយផ្លូវ | | |
| | | ពី១០ ដល់ ៤០គម | លើសពី ៤០គម | ពី៥ដល់ ៣០គម | លើសពី ៣០គម | ពី១០ដល់ ៤០គម | លើសពី៤០ គម | |
| -ប្រាក់ហោប៉ៅ | មិនផ្តល់ជូនទេ | ៨.000៛00 | ៨.000៛00 | ៨.000៛00 | ៨.000៛00 | ៨.000៛00 | ៨.000៛00 | ១ថ្ងៃ |
| -ហូបចុក | -ដ- | ១៥.000៛00 | ១៥.000៛00 | ១៥.000៛00 | ១៥.000៛00 | ១៥.000៛00 | ១៥.000៛00 | ១ថ្ងៃ |
| -ស្នាក់នៅ | -ដ- | មិនផ្តល់ជូនទេ | ៤0.000៛00 | មិនផ្តល់ជូនទេ | ៤0.000៛00 | មិនផ្តល់ជូនទេ | ៤0.000៛00 | ១យប់ |

គៈប្រាក់របបបេសកកម្មដោយឡែកសំរាប់ការប្រជុំថ្នាក់អន្តរជាតិស្ថិតនៅក្នុងខេត្ត-ក្រុង ក្រៅពីខ្លួនរស់នៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ៈ

| សោហ៊ុយ ចំណាយ បេសកកម្ម | របបឧបត្ថម្ភក្នុងម្នាក់ | | រយៈពេល | ផ្សេងៗ |
|---|---|---|---|---|
| | មន្ត្រីជាន់ខ្ពស់(១) | មន្ត្រីរាជការទូទៅ(២) | | |
| -ប្រាក់ហោប៉ៅ | ៣២.000៛00 | ១៦.000៛00 | ១ថ្ងៃ | *ប្រាក់បេសកកម្មនេះមិនគិតចូលក្នុងគំរោងចំណាយនៃកម្មវិធីប្រជុំទេ។ |
| -ហូបចុក | ៦0.000៛00 | ៣0.000៛00 | ១ថ្ងៃ | (១)ឋានៈដូចមាត្រា៤-ក |
| -ស្នាក់នៅ | ៣00.000៛00 | ២00.000៛00 | ១យប់ | (២)ឋានៈដូចមាត្រា៤-ខ |

## II-បេសកកម្មនៅបរទេស

**មាត្រា ៥** : គណៈប្រតិភូកម្ពុជា ឬ មន្ត្រីរាជការដែលត្រូវបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ឬពីក្រសួង ស្ថាប័នសាមី តាមការអញ្ជើញរបស់ប្រទេសភាគីមិត្ត ត្រូវកំណត់ជូនតាមឋានន្តរស័ក្តិនៃមុខដំណែង ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័នជា៤ប្រភេទ ដូចខាងក្រោមៈ

**ប្រភេទកៈ** សមាជិករាជរដ្ឋាភិបាល

**ប្រភេទខ:** មន្ត្រីជាន់ខ្ពស់រួមមាន ថ្នាក់អនុរដ្ឋលេខាធិការ អគ្គលេខាធិការរាជរដ្ឋាភិបាល អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គលេខាធិការ អគ្គនាយក ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង ឬ ថ្នាក់ស្មើនឹងមុខដំណែងនេះ។

**ប្រភេទគ:** មន្ត្រីមានឋានៈជាវរៈមន្ត្រី អនុមន្ត្រី នាយក្រមការ រួមមាន ថ្នាក់អគ្គលេខាធិការរង ឬអគ្គនាយករង ចុះមកត្រឹមថ្នាក់ប្រធានការិយាល័យនៅរដ្ឋបាលកណ្តាល និងអនុប្រធានមន្ទីរខេត្ត-ក្រុង ឬ ថ្នាក់ស្មើមុខតំណែងនេះ។

**ប្រភេទឃ:** មន្ត្រីថ្នាក់ក្រមការដើមខ្សែនិង មន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋចាប់ពីថ្នាក់អនុប្រធានការិយាល័យនៅរដ្ឋបាលកណ្តាល និង ប្រធានការិយាល័យនៅមន្ទីរខេត្ត-ក្រុង ឬ ថ្នាក់ស្មើនឹងមុខដំណែងនេះចុះក្រោម។

**មាត្រា៦** : ប្រាក់របបបេសកកម្មសំរាប់ចំណាយក្នុងកិច្ចបំពេញការងារក្រៅប្រទេស ត្រូវកំណត់ជូនជារូបិយប័ណ្ណ(ប្រាក់ដុល្លារអាមេរិក)តាមប្រភេទដូចខាងក្រោម:

ឯកត្តាគិត:ដុល្លារអាមេរិក

| ប្រភេទនៃមុខដំណែង មន្ត្រីរាជការ | របបឧបត្ថម្ភក្នុងម្នាក់-ថ្ងៃ | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រាក់ហោប៉ៅ | ប្រាក់ហូបចុក | | | ប្រាក់ស្នាក់នៅ | | |
| | | អាស៊ី | អឺរ៉ុប-អាហ្វ្រិក | អាមេរិក-អូស្ត្រាលី-ជប៉ុន | អាស៊ី | អឺរ៉ុប-អាហ្វ្រិក | អាមេរិក-អូស្ត្រាលី-ជប៉ុន |
| -ប្រភេទក | ៥០ | ៨០ | ១០០ | ១២០ | ២៥០ | ៣៥០ | ៤០០ |
| -ប្រភេទខ | ៤០ | ៧០ | ៨០ | ១០០ | ២០០ | ២៥០ | ៣០០ |
| -ប្រភេទគ | ៣០ | ៦០ | ៧០ | ៨០ | ១៥០ | ២០០ | ២០០ |
| -ប្រភេទឃ | ២០ | ៦០ | ៧០ | ៨០ | ១៥០ | ២០០ | ២០០ |

**មាត្រា៧** : ចំណាយផ្សេងៗដោះស្រាយ ជូនក្នុងកំរិតមួយសមស្របដោយផ្អែកតាមគំរោងរបស់ក្រសួងនិងស្ថាប័នស្នើសុំចំណាយ។

**មាត្រា៨**: វត្ថុអនុស្សាវរីយ៍ដោះស្រាយជូនតែប្រតិភូដែលមានប្រធានដឹកនាំមានឋានៈចាប់ពីឧត្តមមន្ត្រី ឡើងលើដូចក្នុងមាត្រា៥ ត្រង់ប្រភេទ ក និងប្រភេទ ខ ។

**មាត្រា៩**: សហព័ទ្ធអមដំណើរ(បើមាន)សោហ៊ុយចំណាយទាំងអស់ជាបន្ទុករបស់សាមីជន។ រដ្ឋទទួលបន្ទុកតែចំណាយរបស់សហព័ទ្ធអមដំណើរដែលជាភរិយារបស់នាយករដ្ឋមន្ត្រី ឬឧបនាយករដ្ឋមន្ត្រីដែលបំពេញទស្សនកិច្ចផ្លូវរដ្ឋក្នុងនាមនាយករដ្ឋមន្ត្រី ។

## ជំពូកទី៤

## អំពីទិដ្ឋាការនៃការសន្យាចំណាយនិងការទូទាត់

**មាត្រា ១០** : ទិដ្ឋាការនៃការសន្យាចំណាយ ចាំបាច់ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបរិបថចំណាយហិរញ្ញវត្ថុសាធារណៈ ដូចមានខ្លឹមសារចែងក្នុងជំពូកទី១ មាត្រា៣ នៃអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។ ដូចនេះចំណាយលើរបបបេសកកម្មក្នុងឬក្រៅប្រទេស ទោះបីជាមានភាពចាំបាច់និងបន្ទាន់ ឬមួយក៏ប្រតិភូបានវិលត្រឡប់ដោយមិនបានសុំទិដ្ឋាការនៃការសន្យាចំណាយជាមុន អាណាប័កមិនមានសិទ្ធិបោះផ្សាយអាណត្តិបើកប្រាក់ (សន្យាចំណាយ ទាំងស្រុង) តែម្តងបានទេ បើគ្មានការស្នើសុំជាលាយល័ក្ខអក្សរ និង មានទិដ្ឋាការនៃការសន្យាចំណាយ (យល់ព្រម)ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនទេនោះ។

**មាត្រា ១១** : ការទូទាត់ចំណាយបេសកកម្មក្នុងប្រទេសៈ

ការទូទាត់ចំណាយបេសកកម្មក្នុងប្រទេសត្រូវអនុវត្តជាប្រាក់រៀលតាមរបបបានកំណត់នៅក្នុងមាត្រា៤ ខាងលើ ទោះបីមានសក្ខីប័ត្រចំណាយខ្លះជារូបិយប័ណ្ណបរទេសក៏ដោយ ។ សោហ៊ុយធ្វើដំណើរ (ក្នុងករណីគ្មានមធ្យោបាយរបស់រដ្ឋ) ដោះស្រាយជូនតាមវិក័យប័ត្រជាក់ស្តែង។ ប្រាក់បេសកកម្ម កំណត់ខ្ពស់បំផុតត្រឹម១០ថ្ងៃ ។ បើលើសពីនេះចាំបាច់ត្រូវមានបញ្ជាបេសកកម្មបន្តតែក៏មិនឱ្យលើស ពី២០ថ្ងៃក្នុង១ខែ។ ប្រាក់ហូបចុកឬក៏មានចំណាយផ្សេងៗបន្ថែមទៀត ត្រូវកត់ត្រាក្នុងខ្ទង់ថវិកាជំពូក ១១.០២.០១.០៣ សោហ៊ុយស្នាក់នៅ ។ ក្នុងករណីចំណាយបេសកកម្មនេះមានចំនួនទឹកប្រាក់មិនលើសពីកំរិតកំណត់នៃរជ្ជទេយ្យបុរេប្រទានទេនោះ ត្រូវប្រើប្រាស់ឥណទានថវិកា ក្នុងរជ្ជទេយ្យ បុរេប្រទាន។

**មាត្រា១២** : ការទូទាត់ចំណាយបេសកកម្មនៅបរទេសៈ

-សោហ៊ុយធ្វើដំណើរដោះស្រាយជូនតាមតម្លៃក្នុងវិក័យប័ត្រ ឬវិក័យប័ត្របណ្ដោះអាសន្ន ( Proforma Invoice ) ដោយគិតរួមបញ្ចូលទាំងថ្លៃបង់ពន្ធព្រលានយន្តហោះ។ ថ្លៃសំបុត្រយន្តហោះ ត្រូវបែងចែកជាបីប្រភេទតាមឋានៈដូចខាងក្រោមៈ

១-នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី កំណត់ថ្លៃសំបុត្រយន្តហោះថ្នាក់ទី ១ (First Class )។

២-រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមន្ត្រីមានមុខដំណែងណាមួយក្នុងប្រភេទ ខ កំណត់ថ្លៃសំបុត្រយន្តហោះ ថ្នាក់ជំនួញ( Business Class )។

៣-ប្រធានប្រតិភូនិងសមាជិករួមដំណើរដូចក្នុងប្រភេទ គ-ឃ កំណត់ថ្លៃសំបុត្រយន្តហោះថ្នាក់ធម្មតា ( Economic Class )។ បើសិនរយៈពេល ហោះហើរចាប់ពីប្រាំមួយ(០៦)ម៉ោងឡើង ថ្លៃសំបុត្រយន្តហោះសំរាប់ប្រធានប្រតិភូកំណត់ជូនថ្នាក់ជំនួញ (Business Class )។

-ប្រាក់បេសកកម្មកំណត់ខ្ពស់បំផុតត្រឹម ១០ថ្ងៃ។

-ប្រាក់បេសកកម្ម បើរយៈផ្លូវឆ្ងាយត្រូវឆ្លងកាត់ច្រើនដំណាក់ចាប់ពីពីរ(០២)ថ្ងៃឡើង ប្រាក់ឧបត្ថម្ភលើសោហ៊ុយស្នាក់នៅហូបចុក និងប្រាក់ហោប៉ៅត្រូវកំណត់ជូនបន្ថែមត្រឹម មួយថ្ងៃទៅ-មួយថ្ងៃមក។

-សោហ៊ុយចំណាយសំរាប់សហព័ទ្ធអមដំណើរដូចក្នុងមាត្រា៩(បើមាន) ដោះស្រាយជូនតែសោហ៊ុយធ្វើដំណើរ និងប្រាក់ហូបចុកប៉ុណ្ណោះ។

-ដោយឡែក សោហ៊ុយបេសកកម្មសំរាប់នាយករដ្ឋមន្ត្រីរួមទាំងសោហ៊ុយចំណាយផ្សេងៗ ដោះស្រាយជូនតាមគំរោងសមស្រប។

-សរុបទឹកប្រាក់ចំណាយបេសកកម្មដែលទទួលបានទិដ្ឋាការសន្យាចំណាយរួចហើយ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ជារបបកំណត់សំរាប់ផ្តល់ថវិកាជូនតែម្តង។

**<u>មាត្រា១៣</u>** : ករណីមុខចំណាយមួយចំនួនត្រូវបានទទួលការរាប់រងពីភាគីអញ្ជើញ មុខចំណាយនោះនឹងត្រូវកាត់ចេញ ពីរបបឧបត្ថម្ភលើសោហ៊ុយបេសកកម្មក្នុងឬក្រៅប្រទេស។

ការទូទាត់ចំណាយសំរាប់ប្រាក់ហោប៉ៅ ពន្ធព្រលានយន្តហោះ និងចំណាយផ្សេងៗ(បើមាន) ត្រូវប្រើថវិការដ្ឋទេយ្យបុរេប្រទាន។

**<u>មាត្រា១៤</u>** : ករណីដោយឡែកដែលកម្មវិធីបេសកកម្មឬទស្សនៈកិច្ចនៅបរទេសមានការប្រែប្រួលដោយថាហេតុ ថវិកាផ្ដល់បន្ថែមចាំបាច់ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ប៉ុន្តែទោះយ៉ាងនេះក្ដី អាណាប័កត្រូវពិនិត្យនិងទទួលស្គាល់ជាមុនពីភាពត្រឹមត្រូវនូវរាល់លិខិតយុត្តិការចំណាយដែលប្រតិភូបេសកកម្មបានបង្ហាញតាមរយៈរបាយការណ៍។

**<u>មាត្រា ១៥</u>** : បេសកកម្មក្នុងឬក្រៅប្រទេសដែលក្រសួងនិងស្ថាប័នមិនបានសុំទិដ្ឋាការធានា ចំណាយជាមុនដូចក្នុង មាត្រា៩ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាននីតិសម្បទាគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យតាមគ្រប់រូបភាពស្របច្បាប់នូវ ចំណាយថវិកាដែលមិនត្រឹមត្រូវតាមបរិបថហិរញ្ញវត្ថុនេះ។

ក្រោយការពិនិត្យ ឃើញពីភាពត្រឹមត្រូវនៃលិខិតយុត្តិការពាក់ព័ន្ធព្រមទាំងមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចហើយ ការទូទាត់ចំណាយបេសកកម្មក្នុងនិងក្រៅប្រទេសរបៀបនេះនឹងប្រព្រឹត្តទៅតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន តែត្រូវធ្វើជាប្រាក់រៀលចំពោះបេសកកម្មក្រៅប្រទេស។

## <u>ជំពូកទី៥</u>

## <u>អវសានប្បញ្ញត្តិ</u>

**<u>មាត្រា១៦</u>** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**<u>មាត្រា១៧</u>** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល:</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អាជ្ញាធរសវនកម្មជាតិ
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១៧ ដើម្បីអនុវត្ត
-ឯកសារនិងកាលប្បវត្តិ

## ៥.២ ប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម

- សេចក្តីសម្រេច លេខ ៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលស្តីពីការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ សស ៥២ :

❖❖❖❖❖

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសំរាប់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-បានឃើញសេចក្តីសំរេចលេខ ២៤៥ សសរ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម

-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

# សម្រេច

**ប្រការ១.**

សេចក្តីសំរេចនេះ មានគោលដៅកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់មន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព និងសំរាលកូន ដែលបានកំណត់ក្នុងសេចក្តីសំរេចលេខ២៤៥ សសរ ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម ។

**ប្រការ២.**

ត្រូវបានឧបត្ថម្ភជាថវិកា ដើម្បីរួមចំណែក និង ជួយដល់គ្រួសារសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព សំរាប់ធ្វើបុណ្យតាមប្រពៃណីក្នុងម្នាក់ៗដូចខាងក្រោមៈ

- ទទួលមរណភាពដោយជំងឺធម្មតា ចំនួនពី ១ ២០០ ០០០ រៀល (មួយលាន ពីរសែន រៀល)
- ទទួលមរណភាពក្នុងពេលបំពេញបេសកកម្ម ឬ គ្រោះថ្នាក់ការងារ ចំនួន ១ ៥០០ ០០០រៀល (មួយលាន ប្រាំសែន រៀល)។

**ប្រការ៣.**

មន្ត្រីរាជការស៊ីវិលជាស្ត្រីភេទដែលសំរាលកូន និងសំរាកលំហែមាតុភាព ត្រូវបានទទួលថវិកាឧបត្ថម្ភ ក្នុងម្នាក់ៗចំនួន ៦០០ ០០០ រៀល (ប្រាំមួយរយពាន់រៀល) ។

**ប្រការ៤.**

ផលប្រយោជន៍ផ្សេងៗទៀតរបស់មន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព និង សំរាលកូននឹងមានកំណត់ដោយឡែក ។

**ប្រការ៥.**

នីតិវិធី និងបែបបទ នៃការអនុវត្តសេចក្តីសម្រេចនេះ នឹងកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**ប្រការ៦.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធានក្រុមក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៧**.

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចបានយកសេក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា
ឧបនាយកដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

**សុខ អាន**

**កន្លែងទទួល**:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-អគ្គស្នងការដ្ឋានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
-ដូចប្រការ ៦
-ឯកសារ -កាលប្បវត្តិ

## ៥.៣ ប្រាក់ឧបត្ថម្ភមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត

- សារាចរណែនាំ លេខ ០០១ សហវ ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១០ ស្តីពីការប្រើប្រាស់និងការផ្តល់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខៈ០០១ សហវ

រាជធានីភ្នំពេញថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១០

# សារាចរណែនាំ
## ស្តីពី
## ការប្រើប្រាស់ និងការផ្តល់ប្រាក់កម្រៃ សម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត

### ១-សេចក្តីផ្តើម

កន្លងមកការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត នៅតាម ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពុំទាន់មានសង្គតិភាព និងសមធម៌ ដែលអាចនាំឱ្យមានការបាត់ប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិការដ្ឋ ។ ជាពិសេសការកំណត់តម្រូវការ និងការកំណត់ប្រាក់កម្រៃ ដែលត្រូវចំណាយសម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត នៅពុំទាន់មានមូលដ្ឋាន និងគោលការណ៍ប្រកបដោយសង្គតិភាព និងតម្លាភាពនៅឡើយ ។ លើសពីនេះ ដោយមានការណែនាំរបស់រាជរដ្ឋាភិបាលតាមរយៈលិខិតលេខ ១៣៣៤ សជណ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំដៅពង្រឹងការគ្រប់គ្រងចំណាយលើបន្ទុកបុគ្គលិកផងនោះ ទើបក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំសារាចរណែនាំនេះឡើង ។

គោលបំណងនៃសារាចរណែនាំនេះ គឺដើម្បីកំណត់គោលការណ៍នៃការប្រើប្រាស់ និងកំណត់ប្រាក់កម្រៃ ដែលត្រូវចំណាយ ព្រមទាំងនីតិវិធី និងការទទួលខុសត្រូវក្នុងការប្រើប្រាស់ថវិការដ្ឋ សម្រាប់ចំណាយលើមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត នៅតាមក្រសួង ស្ថាប័ន និងអង្គភាពចំណាយទាំងអស់របស់រាជរដ្ឋាភិបាល ក្នុងគោលដៅធានាឱ្យបាននូវសង្គតិភាព សមធម៌ តម្លាភាព ភាពសក្តិសិទ្ធិ និងប្រសិទ្ធភាព ក្នុងការប្រើប្រាស់ថវិការដ្ឋ ។

### ២-គោលការណ៍នៃការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត

មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត គឺជាមន្ត្រីក្រៅក្របខ័ណ្ឌដែលត្រូវបានជ្រើសរើសទៅតាមនីតិវិធីត្រឹមត្រូវ ដើម្បីបំពេញតម្រូវការជាក់ស្តែង និងចាំបាច់របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើមុខងារបន្ទាប់បន្សំ និងមិនអចិន្ត្រៃយ៍មួយចំនួន ដែលការ

ប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតនេះ មានប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ ជាងការប្រើប្រាស់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ ។ ម្យ៉ាងទៀតមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត គឺជាប្រភេទមន្ត្រីក្រៅក្របខ័ណ្ឌ ដែលត្រូវផ្តល់កិច្ចសន្យាប្រចាំឆ្នាំ ហើយការចុះកិច្ចសន្យាការងារម្តងមិនឱ្យលើសពី ១ ឆ្នាំទេ ។

ដូច្នេះ ជានីតិវិធីក្រសួង ស្ថាប័ននិងមន្ទីរជំនាញរាជធានី ខេត្ត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានតម្រូវការក្នុងការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតត្រូវ៖

១-គ្រោងចំនួនមន្ត្រីក្រៅក្របខ័ណ្ឌប្រចាំឆ្នាំ ទៅតាមមុខងារ និងអង្គភាពដែលត្រូវបំពេញការងារទៅតាមការណែនាំ និងគំរូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២-គ្រោងចំណាយលើមន្ត្រីក្រៅក្របខ័ណ្ឌ ទៅតាមចំនួន និងទៅតាមមុខងារដែលត្រូវការជាក់ស្តែង ដោយបើកកម្រៃតាមមុខងារនីមួយៗ ដែលបានកំណត់ដោយសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**៣-ការកំណត់ប្រាក់កម្រៃប្រចាំខែ និងប្រចាំថ្ងៃ សម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត**

ការផ្តល់ប្រាក់កម្រៃប្រចាំខែ ឬ ប្រចាំថ្ងៃ ដល់មន្ត្រីជាប់កិច្ចសន្យាឬ បុគ្គលិកអណ្តែត ត្រូវអនុវត្តទៅតាមប្រភេទមុខងារដូចមានកំណត់ក្នុងតារាងខាងក្រោម៖

**ក-តារាងមុខងារ និង ប្រាក់កម្រៃប្រចាំខែ សម្រាប់មន្ត្រីជាប់កិច្ចសន្យា**

| **ចំណាត់ថ្នាក់មុខងារ** | **បរិយាយមុខងារ** | **ប្រាក់កម្រៃប្រចាំខែ** |
|---|---|---|
| I-**ជំនួយការរដ្ឋបាល** | -ពិធីការ (រៀបចំសាលប្រជុំ, បម្រើភេសជ្ជៈ........)<br>-អ្នកគ្រប់គ្រងឯកសារ (រៀបចំឯកសារ, រត់សំបុត្រ, បណ្ណាល័យ.............)<br>-ទទួលបន្ទុករដ្ឋបាល (ចុះលេខ, ទទួលទូរស័ព្ទ, កាន់បញ្ជីវត្តមាន........)<br>-ហៅឈ្មោះអ្នកជំងឺ | ១២០ ០០០ **រៀល** |
| II-**ជំនួយការបច្ចេកទេស** | -គ្រប់គ្រងគេហទំព័រ កុំព្យូទ័រ ព័ត៌មានវិទ្យា<br>-សរសេរព័ត៌មាន ផ្សាយព័ត៌មាន<br>-ថតរូប ថតវីដេអូ<br>-តម្លើង ចងក្រង និងពិនិត្យអត្ថបទ ថែរក្សាហ្វីល | ១៤០ ០០០ **រៀល** |

| | | |
|---|---|---|
| | -សិល្បៈករ សិល្បៈការិនី<br>-ផ្នែកទិដ្ឋាការ<br>-អ្នកចិញ្ចឹមសត្វពិសោធន៍<br>-ផ្នែកស្ថិតិ<br>-ជំនួយការ (អយ្យការ ចៅក្រម ព្រះរាជអាជ្ញា)<br>-ស្រង់ថ្លៃទំនិញ ត្រួតពិនិត្យទំនិញ<br>-មន្ទីរពិសោធន៍<br>-បសុព្យាបាល (ពេទ្យសត្វ ថៃសត្វ)<br>-ឧទ្យានុរក្ស ឆ្មាំឆ្នេរសមុទ្រ ឆ្មាំប្រាសាទ<br>-ជំនួយការអ្នកបច្ចេកទេសវាស់វែងផ្លូវ<br>-សម្របសម្រួលគម្រោង<br>-រៀបចំរបាយការណ៍<br>-ជាងទឹក ជាងអគ្គិសនី<br>-ជាងគំនូរ<br>-ជំនួយការឧតុនិយម(ព្យាករណ៍ទឹកជំនន់ វាស់កំពស់ទឹកតាមស្ថានីយ៍ ប្រមូលទិន្នន័យបរិមាណទឹកភ្លៀង សីតុណ្ហភាព រំហួតសំណើម ល្បឿនខ្យល់...)<br>-បុគ្គលិកពន្លត់អគ្គីភ័យ<br>-ជំនួយការសហគមន៍<br>-ជំនួយការ (ផ្លូវអាកាស ផ្លូវទឹក)<br>-បុគ្គលិកលក់តែមប្រៃសណីយ៍ | |

| | | |
|---|---|---|
| | -បុគ្គលិកកាន់វិទ្យុទាក់ទង<br>-ចុះបញ្ជីពាណិជ្ជកម្មខ្នាតតូច<br>-សេវាកម្មទេសចរណ៍ មគ្គុទេសន៍ភ្ញៀវ<br>-ចុះបញ្ជីយានយន្ត<br>-ជំនួយការផ្នែកវិវាទ<br>-អ្នកផ្តល់ព័ត៌មាន<br>-អ្នករៀបចំប្លង់ដីធ្លី<br>-ការងារបណ្តុះបណ្តាល<br>-ការងារអភិវឌ្ឍន៍<br>-ការងារបច្ចេកទេសរលកអាកាស វិទ្យុ ជំនាញប្រៃសណីយ៍<br>-គ្រូបង្រៀនអក្ខរកម្ម<br>-គ្រូបង្រៀនចំណេះទូទៅ និងពុទ្ធិកសិក្សា | |
| III-**ជំនួយការថ្នាក់ដឹកនាំ** | -ជំនួយការថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័ន | ១៦០ ០០០ **រៀល** |
| IV-**អ្នកបច្ចេកទេសជំនាញ** | -បកប្រែភាសាបរទេស<br>-បកប្រែភាសាបាលី សំស្រ្កឹត<br>-គ្រូជំនាញ (គ្រូសិល្បៈ គ្រូជំនាញផ្សេងៗ)<br>-អ្នកស្រាវជ្រាវផ្នែកចារកម្ម<br>-អ្នកស្រាវជ្រាវវប្បធម៌<br>-ឆ្មប គ្រូពេទ្យ យន្តការី ឱសថបុរាណ | ២០០ ០០០ **រៀល** |

## ខ-តារាងមុខងារ និង ប្រាក់កម្រៃប្រចាំខែ សម្រាប់បុគ្គលិកអណ្តែត

| **ចំណាត់ថ្នាក់មុខងារ** | **បរិយាយមុខងារ** | **ប្រាក់កម្រៃប្រចាំថ្ងៃ** |
| --- | --- | --- |
| I-**កម្មករ** | -អ្នកយាមយានជំនិះ<br>-សន្តិសុខ (យាមឃ្លាំង យាមក្រសួង...)<br>-ថែសួន កាប់ច្ការ<br>-អ្នកធ្វើអនាម័យ<br>-កម្មករដាំដុះ<br>-កម្មករប្រព័ន្ធធារាសាស្ត្រ បិទបើកទ្វារទឹក ចែកចាយទឹក...<br>-អ្នកធ្វើអនាម័យ និងបោកគក់នៅតាមមន្ទីរពេទ្យ<br>-ចុងភៅ<br>-អ្នកសែងសព | ៦ ០០០ រៀល |
| II-**កម្មករជំនាញ** | -កម្មករ (ដាំដុះ ចិញ្ចឹមសត្វ វារីវប្បកម្ម...)<br>-កម្មករជួសជុលនិងថែទាំ(ផ្លូវ ស្ពាន លូទឹកស្អុយ...)<br>-អ្នកបើកបរ (រថយន្ត អេស្កាវ៉ាទ័រ រ៉ូឡូ នីវីឡឺ និងគ្រឿងចក្រធំៗផ្សេងទៀត) | ៨ ០០០ រៀល |

ទទួលបានសារាចរនេះ សូមសម្តេច ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី ខេត្ត និងប្រធានមន្ទីរជំនាញរាជធានី ខេត្ត គ្រប់រាជធានី ខេត្ត ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានម៉ឺងម៉ាត់ និង មានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>ចម្លងជូន</u>
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋធម្មនុញ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់សាលារាជធានី ខេត្ត
-គ្រប់មន្ទីរហិរញ្ញវត្ថុរាជធានី ខេត្ត
-ឯកសារ កាលប្បវត្តិ

# ៦.ការដាំឡើងផ្កាក់និងបានន្តរសក្ដិ

❖ អនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកាឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យទាំងឡាយស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បកចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៣

# សំរេច

**មាត្រា ១**.-

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្ដូរក្របខ័ណ្ឌឋានន្តរស័ក្តិ និងថ្នាក់ទៅតាមកំរិតសញ្ញាប័ត្រ និងមុខតំណែងរបស់មន្ត្រីរាជការស៊ីវិល។

**មាត្រា ២**.-

ការផ្លាស់ប្ដូរក្របខ័ណ្ឌ ឋានន្តរស័ក្តិតាមកំរិតសញ្ញាប័ត្រមិនត្រូវបានអនុញ្ញាតបានឡើយ លើកលែងតែករណីដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ។

**មាត្រា ៣**.-

ការផ្លាស់ប្ដូរក្របខ័ណ្ឌទៅតាមកំរិតសញ្ញាប័ត្រធ្វើទៅបាន តែតាមរយៈការប្រឡងប្រជែងផ្ទៃក្នុង របស់ក្រសួងស្ថាប័នដែលគ្រប់គ្រងក្របខ័ណ្ឌនោះ។

ការផ្លាស់ប្ដូរក្របខ័ណ្ឌឋានន្តរស័ក្ត និងថ្នាក់ទៅតាមកំរិតសញ្ញាប័ត្រក៏អាចធ្វើទៅបានដែរចំពោះករណីដែលមន្ត្រីរាជការនោះធ្លាប់ទទួលបៀវត្សទៅតាមកំរិតសញ្ញាប័ត្រ ហើយដែលតែងតាំងអោយកាន់មុខតំណែងណាមួយដែលមុខដំណែងថ្មីនេះទាបជាងក្របខ័ណ្ឌដោយគិតតាមសញ្ញាប័ត្រ។

**មាត្រា ៤**.-

ការកំណត់ល័ក្ខខ័ណ្ឌប្រឡងប្រជែងផ្ទៃក្នុង ដើម្បីប្ដូរក្របខ័ណ្ឌត្រូវកំណត់ដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈទីស្ដីការគណៈរដ្ឋមន្ត្រីនិង ក្រសួងស្ថាប័នពាក់ព័ន្ធ។

**មាត្រា ៥**.-

ក្នុងករណីចាំបាច់ ដោយសារក្របខ័ណ្ឌឋានន្តរស័ក្តិ មន្ត្រីដែលត្រូវស្នើតែងតាំងនោះមិនសមស្របនឹងតំណែងដែលត្រូវទទួលអាចត្រូវចាត់ឱ្យមន្ត្រីនោះបំពេញមុខងារក្នុងតំណែងនោះតែប៉ុណ្ណោះ ។ ករណីនេះមន្ត្រីដែលទទួលបំពេញមុខងារមានសិទ្ធិទទួលប្រាក់បំណាច់ទាំងឡាយ ដែលមុខតំណែងនោះត្រូវបាន ហើយមន្ត្រីរូបនោះត្រូវបន្តការឡើងថ្នាក់ក្នុងក្របខ័ណ្ឌនិងឋានន្តរស័ក្តិរបស់ខ្លួនដែលមានមុនការចាត់អោយបំពេញមុខងារថ្មីនេះ។ ក្របខ័ណ្ឌ និង ឋានន្តរស័ក្តិមិនត្រូវបានកែសំរួលតាមមុខតំណែងថ្មីនេះឡើយ។

**មាត្រា ៦**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៧**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>**កន្លែងទទួល**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៧
-ឯកសារ-កាលប្បវត្តិ

❖ លិខិត លេខ ២០៦ ម.ស.ប.រ ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ១៩៩៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្តីពីការតម្លើងថ្នាក់ ឬ កាំប្រាក់ប្រចាំឆ្នាំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**
លេខៈ២០៦ ម.ស.ប.រ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិនា ឆ្នាំ១៩៩៥

**រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ**

## សូមគោរពជូន

**ឯកឧត្តមរដ្ឋមន្ត្រី គ្រប់ក្រសួង**
**ឯកឧត្តមរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន**

**កម្មវត្ថុៈ** ការតម្លើងថ្នាក់ ឬកាំបៀវត្សប្រចាំឆ្នាំ
**យោងៈ** ព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤

ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ដោយផ្អែកតាមខ្លឹមសារមាត្រាទី ២០ និង មាត្រាបន្តបន្ទាប់ នៃសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ស្តីអំពីដំណើរការតម្លើងថ្នាក់ ឬកាំបៀវត្សប្រចាំឆ្នាំ និងយោលទៅតាមដំណាក់កាលដែលលក្ខន្តិកៈដោយឡែករបស់អង្គនីមួយៗ កំពុងតែរៀបរៀងចងក្រងនៅឡើយនោះ ខ្ញុំសូមឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ មេត្តាជ្រាបអំពីចំណុចអនុវត្តដូចខាងក្រោមៈ

-គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវជូនដំណឹងដល់អង្គភាពក្រោមឱវាទអោយធ្វើបញ្ជីរាយនាម ព្រមទាំងដាក់ពិន្ទុពី ០ ដល់ ២០ ដល់បេក្ខជនដែលត្រូវស្នើតម្លើងថ្នាក់ ឬកាំបៀវត្សមកក្រសួង ឬរដ្ឋលេខាធិការដ្ឋានផ្ទាល់តែម្តង ក្នុងខែមករារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ ១៩៩៦ ដើម្បីពិនិត្យ និងសំរេចតាមយោបល់របស់គណៈកម្មការតម្លើងថ្នាក់ដោយយកតាមវេនជ្រើសរើស ឬតាមវេនជ្រើសរើស និងតាមវេនអតីតភាពជាមួយគ្នាក៏បាន វៀរលែងតែប្រធានមន្ទីរនានា ជុំវិញខេត្ត-ក្រុង ដែលត្រូវមានមូលវិចាររបស់អភិបាលខេត្ត-ក្រុង។ រយៈពេលតម្លើងថ្នាក់ ឬកាំបៀវត្ស គិតជាអប្បបរមាមានរយៈពេល ២ឆ្នាំ។

សាម៉ីក្រសួងនីមួយៗ ត្រូវគិតលើកំរិតកំណត់តម្លើងថ្នាក់ ឬកាំបៀវត្សជាបណ្តោះអាសន្នពី ៥០ ទៅ៧០ ភាគរយ លើចំនួនមន្ត្រីរាជការដែលត្រូវស្នើឡើងថ្នាក់។

-ចំពោះមន្ត្រីថ្នាក់ដឹកនាំដែលស្ថិតក្នុងតារាង **ក** ពី កII.11 ទៅ កII.5 ការពិនិត្យ និងសំរេចតម្លើងថ្នាក់ ឬកាំបៀវត្ស ប្រចាំឆ្នាំ ពីកាំទី ១ ទៅកាំទី ២ អាស្រ័យលើរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ដែលគ្រប់គ្រងផ្ទាល់តាមសំណើរបស់សាមីអង្គភាព និងតាមយោបល់របស់គណៈកម្មការតម្លើងថ្នាក់ដោយពុំចាំបាច់

គិតអត្រាភាគរយទេ។ មន្ត្រីប្រភេទ **ភ** នេះមានចំនួនពុំច្រើនទេ ហើយមួយភាគធំបានឡើងកាំទី ២ ជាកាំខ្ពស់បំផុតទៅហើយ។

-ចំពោះមន្ត្រីថ្នាក់ដឹកនាំដែលស្ថិតក្នុងតារាង ក II.4 ដែលជាក្របខ័ណ្ឌដឹកនាំខ្ពស់ ការតម្លើងថ្នាក់គឺជាសមត្ថកិច្ច សំរេចរបស់គណៈរដ្ឋមន្ត្រី។

ការអនុវត្តការតម្លើងថ្នាក់ ឬកាំបៀវត្សនេះ គិតចាប់ពីថ្ងៃទី ១៣ ខែ មេសា រៀងរាល់ឆ្នាំ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងអនុវត្តតាមការគួរ។

**ប្រាក់ សុខ**

ចម្លងជូន

-ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
-ឯកសារ-កាលប្បវត្តិ

❖ លិខិត លេខ ៦០០ម.ស.ន.ក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្តីពីនីតិវិធីក្នុងការបំពេញបែបបទមួយចំនួនលើការដំឡើងថ្នាក់ជូនមន្ត្រី រាជការស៊ីវិល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

លេខៈ៦០០ មស.ន.ក                                        រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ**

## សូមទូលថ្វាយ និង គោរពជូន

**សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី**
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុៈ** អំពីនីតិវិធីក្នុងការបំពេញបែបបទមួយចំនួនលើការដំឡើងថ្នាក់ ជូនមន្ត្រីរាជការស៊ីវិល។

**យោងៈ** -ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។
-ព្រះរាជក្រឹត្យទាំងឡាយស្តីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។

ខ្ញុំមានកិត្តិយសសូមទូលថ្វាយ និងជម្រាបជូន សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន សូមទ្រង់ជ្រាប និងជ្រាបថា ដោយកន្លងមកនៅពេលពុំទាន់មានព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនានានោះ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ធ្លាប់បានចេញ លិខិតលេខ ២០៦ ម.ស ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការដំឡើងថ្នាក់ ឬកាំបៀវត្សប្រចាំឆ្នាំ ដែលគ្រប់ក្រសួង ស្ថាប័នបានអនុវត្តរហូតមក។ បច្ចុប្បន្ន យើងមានព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ ហើយមន្ត្រីរាជការទាំងអស់ត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌថ្មីហើយនោះ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សូមធ្វើការណែនាំអំពីនីតិវិធីក្នុងការបំពេញបែបបទមួយចំនួនលើការដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការ ស៊ីវិលគ្រប់ក្របខ័ណ្ឌនៅក្រសួង ស្ថាប័ន ដូចខាងក្រោមៈ

**១-ការបង្កើតគណៈកម្មការចំណាត់ថ្នាក់**

ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតគណៈកម្មការចំណាត់ថ្នាក់ ដែលមានសមាសភាពដូចមានចែងក្នុងមាត្រា ២៥ ជំពូកទី ៤ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំធ្វើតារាងដំឡើងថ្នាក់ប្រចាំឆ្នាំ (ដូចមានគំរូតារាងដំឡើងថ្នាក់ជូនភ្ជាប់មកជាមួយ) និងពិនិត្យ

ពិភាក្សាវាយតម្លៃសម្រេចក្នុងការដំឡើងថ្នាក់ឱ្យបានត្រឹមត្រូវ និងសម្រាប់កាលបរិច្ឆេទកំណត់ គឺថ្ងៃទី ១៣ ខែមេសា រៀងរាល់ឆ្នាំ។

**២-ការដំឡើងថ្នាក់ប្រចាំឆ្នាំ**

ដោយអនុវត្តតាមខ្លឹមសារមាត្រា ២០ និង មាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា គ្រប់ក្រសួង-ស្ថាប័នត្រូវជូនដំណឹងទៅដល់អង្គភាពក្រោមឱវាទ ឱ្យធ្វើការពិនិត្យវាយតម្លៃ និងដាក់ពិន្ទុពី ០ ដល់ ២០ ដល់បេក្ខជនដែលត្រូវស្នើឡើងថ្នាក់ក្នុងព្រឹត្តិបត្រពិន្ទុ (ដូចមានគំរូព្រឹត្តិបត្រពិន្ទុជូនភ្ជាប់ជាមួយ) តាមលក្ខណៈ សម្បត្តិជាមូលដ្ឋានសម្រាប់ពិនិត្យដំឡើងថ្នាក់ ដូចមានចែងនៅក្នុងព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកនានារបស់ក្របខ័ណ្ឌនីមួយៗ រួចធ្វើបញ្ជីរាយនាមបេក្ខជនទាំងនោះ ផ្ញើមកគណៈកម្មការចំណាត់ថ្នាក់របស់ក្រសួង ស្ថាប័ន រៀងរាល់ខែមករា ដើម្បីឱ្យគណៈកម្មការចំណាត់ថ្នាក់របស់ក្រសួង ស្ថាប័នធ្វើការពិនិត្យ និងសម្រេច។

គណៈកម្មការចំណាត់ថ្នាក់របស់ក្រសួង ស្ថាប័ន ត្រូវធ្វើការពិនិត្យនិងសំរេចដំឡើងថ្នាក់មន្ត្រីរាជការតាមប្រភេទ ក្របខ័ណ្ឌនីមួយៗ ដូចខាងក្រោមៈ

-តាមវេនជ្រើសរើសៈ មន្ត្រីរាជការដែលមានអតីតភាពពី ២ឆ្នាំ ជិតដល់ ៣ឆ្នាំ ជ្រើសរើសយក ៧៥% នៃចំនួនមន្ត្រីរាជការដែលត្រូវស្នើឡើងថ្នាក់ទាំងអស់។

-តាមវេនអតីតភាពៈ មន្ត្រីរាជការដែលមានអតីតភាពពី ៣ឆ្នាំ ត្រូវបានឡើងថ្នាក់ជាស្វ័យប្រវត្តិ
បើគ្មានករណីទទួលវិន័យដូចមានចែងក្នុងមាត្រា៤០នៃច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

**៣-ការដំឡើងថ្នាក់ករណីពិសេស**

-មន្ត្រីរាជការស៊ីវិលដែលបានដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើមទៅបំពេញមុខងារជាសមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ត្រូវបានដំឡើងថ្នាក់ជាស្វ័យប្រវត្តិ ២ឆ្នាំម្តង។

-មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការសិក្សាដោយទទួលបានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រដែលកំណត់ក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌរបស់ខ្លួន និងមន្ត្រីដែលបានបញ្ចប់វគ្គវិក្រឹត្យការ សុក្រឹតការនៅសាលាភូមិន្ទរដ្ឋបាលនោះ ត្រូវបានដំឡើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ដោយរក្សាការដំឡើងថ្នាក់ប្រចាំឆ្នាំទៅតាមអតីតភាពការងារដដែល។

**៤-បែបបទនៃការដំឡើងថ្នាក់**

គ្រប់ក្រសួង-ស្ថាប័ន ត្រូវបំពេញបែបបទក្នុងការដំឡើងថ្នាក់ប្រចាំឆ្នាំ និងការដំឡើងថ្នាក់ករណីពិសេសរួមមាន៖

១-លិខិតស្នើសុំដំឡើងថ្នាក់របស់ក្រសួងស្ថាប័នសាមី ចំនួន ០១ ច្បាប់

២-បញ្ជីរាយនាមមន្ត្រីរាជការស៊ីវិលស្នើសុំដំឡើងថ្នាក់ (បេក្ខជន) តាមប្រភេទក្របខ័ណ្ឌ ចំនួន ០១ ច្បាប់

៣-តារាងដំឡើងថ្នាក់របស់មន្ត្រីរាជការស៊ីវិលដែលស្នើសុំឡើងថ្នាក់តាមប្រភេទក្របខ័ណ្ឌ ចំនួន ០១ ច្បាប់

៤-ប្រកាសឬអនុក្រឹត្យឬព្រះរាជក្រឹត្យស្តីពីការតែងតាំងគណៈកម្មការចំណាត់ថ្នាក់ ចំនួន ០១ ច្បាប់
៥-កំណត់ហេតុស្តីពីការប្រជុំពិភាក្សា វាយតម្លៃរបស់គណៈកម្មការចំណាត់ថ្នាក់ ចំនួន ០១ ច្បាប់
៦-ឯកសារពាក់ព័ន្ធផ្សេងៗតាមការចាំបាច់ ដូចជា សញ្ញាប័ត្រ វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា...។

សំណុំបែបបទខាងលើនេះ ត្រូវបញ្ជូនមករដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈឱ្យបានមុនដំណាច់ខែមករា នៃឆ្នាំ ដើម្បីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ៖

-ពិនិត្យ ស្នើសុំដំឡើងថ្នាក់ដោយអនុក្រឹត្យ ព្រះរាជក្រឹត្យសម្រាប់មន្ត្រីគ្រប់ក្របខ័ណ្ឌប្រភេទ "ក" ក្នុងឋានន្តរស័ក្តិទី ២ និងទី ១។
-ចេញប្រកាសសម្រាប់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឋានន្តរស័ក្តិអនុមន្ត្រី ក្របខ័ណ្ឌមន្ត្រីក្រមការ ក្របខ័ណ្ឌលេខាធិការ និងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល (រដ្ឋបាលអន្តរក្រសួង)។
-ផ្តល់ទិដ្ឋាការជូនក្រសួង ស្ថាប័នចេញប្រកាស សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ឋានន្តរស័ក្តិ ទី ៣ មន្ត្រីបច្ចេកទេសមធ្យម មន្ត្រីបច្ចេកទេសបឋម និងភ្នាក់ងារបច្ចេកទេស។
-ផ្តល់ទិដ្ឋាការជូនក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ចេញប្រកាសដំឡើងថ្នាក់សម្រាប់ក្របខ័ណ្ឌប្រភេទ "ក" ឋានន្តរស័ក្តិទី ៣ និងក្របខ័ណ្ឌប្រភេទ "ខ" ប្រភេទ "គ" និងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ។

អាស្រ័យដូចបានទូលថ្វាយ និងជម្រាបជូនខាងលើ សូមសម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន សូមមេត្តាអនុវត្តតាមខ្លឹមសារខាងលើតាមការគួរ។

សូមសម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលបង្គំខ្ញុំ។

**ពេជ្រ ប៊ុនធិន**

**<u>ចម្លងជូន</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"ដើម្បីជូនជ្រាប"
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

<u>**គំរូព្រឹត្តិប័ត្រពិន្ទុ**</u>

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង ស្ថាប័ន:**...............................
**អង្គភាព:**........................................

<u>**ព្រឹត្តិប័ត្រពិន្ទុសំរាប់ដំឡើងថ្នាក់**</u>
<u>**នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល**</u>

| គិតត្រឹមថ្ងៃទី ១៣ ខែ មេសា ឆ្នាំ........................ | |
|---|---|
| រយៈពេលបំពេញការងារក្នុងឋានន្តរស័ក្តិ ថ្នាក់បច្ចុប្បន្ន | រយៈពេលសរុប បំពេញការងារ |
| | |

**១-ជីវប្រវត្តិផ្ទាល់ខ្លួន**

១.គោត្តនាមនិងនាមៈ..............................ជាអក្សរឡាតាំងៈ.....................................................ភេទៈ.................
២.អត្តលេខៈ...............................................ថ្ងៃ-ខែ-ឆ្នាំកំណើតៈ.......................................................................
៣.កំរិតវប្បធម៌ទូទៅៈ...................................................................កំរិតជំនាញៈ..................................................
៤.កាលបរិច្ឆេទចូលធ្វើការងាររដ្ឋៈ........................................................................................................................
៥.កាលបរិច្ឆេទដែលបានតាំងស៊ប់ក្នុងក្របខ័ណ្ឌៈ.........................................................................................
៦.ឋានន្តរស័ក្តិ ថ្នាក់បច្ចុប្បន្នៈ.......................អតីតភាពក្នុងឋានន្តរស័ក្តិ ថ្នាក់បច្ចុប្បន្នៈ........................................ឆ្នាំ
៧.កាលបរិច្ឆេទក្នុងការដំឡើងថ្នាក់បច្ចុប្បន្ន (ថ្ងៃ ខែ ឆ្នាំ ឡើងថ្នាក់ចុងក្រោយ).......................................................
៨.កាលឈប់ពីការងារក្នុងឋានន្តរស័ក្តិ ថ្នាក់បច្ចុប្បន្នៈ

-មូលហេតុៈ.............................................................................................................................

-រយៈពេលៈ.............................................................................................................................

ខ្ញុំសូមធានាខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានខាងលើនេះពិតជាត្រឹមត្រូវពិតប្រាកដមែន។

*ធ្វើនៅ........................ថ្ងៃទី .........ខែ...............ឆ្នាំ................*

**ហត្ថលេខានិងឈ្មោះសាមីខ្លួន**

បានឃើញ និងបញ្ជាក់ថាព័ត៌មានដែល
លោក/លោកស្រី.......................................
បានអះអាងខាងលើពិតជាត្រឹមត្រូវប្រាកដមែន។
ធ្វើនៅ.............ថ្ងៃទី .........ខែ.........ឆ្នាំ...........
ហត្ថលេខា (មន្ត្រីទទួលបន្ទុកការងារបុគ្គលិក)

## ២.ការវាយតម្លៃដាក់ពិន្ទុ

| | |
|---|---|
| ១-មានគំនិតផ្តួចផ្តើម និងច្នៃប្រឌិត:........................................................................................... | /20 |
| ២-មានស្មារតីទទួលខុសត្រូវ:....................................................................................................... | /20 |
| ៣-យកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ:................................................................................. | /20 |
| ៤-មានប្រសិទ្ធភាពក្នុងការដឹកនាំ:................................................................................................ | /20 |
| ៥-មានសីលធម៌ល្អ:..................................................................................................................... | /20 |

ពិន្ទុដែលត្រូវបាន: /20

និទ្ទេស:....................................

មូលវិចារណ៍ និងការវាយតម្លៃទូទៅ

.......................................................................

.......................................................................

.......................................................................

.......................................................................

សំណើរបស់:.........................................................

.......................................................................

*ធ្វើនៅ...............ថ្ងៃទី.......ខែ.............ឆ្នាំ.............*

**ហត្ថលេខា** (មន្ត្រីដែលមានសមត្ថកិច្ចក្នុងការដាក់ពិន្ទុ និងមូលវិចារណ៍)

កំណត់សំគាល់

-ពិន្ទុក្នុង១ចំណុច មានពី ០ ដល់ ២០

-បូកសរុបពិន្ទុដែលទទួលបានទាំង ៥ ចំណុច រួចចែកនឹង ៥ ដើម្បីរកមធ្យមភាគ។

-ការកំណត់ពិន្ទុសំរាប់និទ្ទេសមានដូចខាងក្រោម:

ក-និទ្ទេស ល្អណាស់ ចាប់ពី១៩ ដល់ ២០ ពិន្ទុ

ខ-និទ្ទេស ល្អ ចាប់ពី១៦ ដល់ក្រោម ១៩ ពិន្ទុ

គ-និទ្ទេស ល្អបង្គួរ ចាប់ពី១៣ ដល់ក្រោម ១៦ ពិន្ទុ

ឃ-និទ្ទេស មធ្យម ចាប់ពី១០ ដល់ក្រោម ១៣ ពិន្ទុ

ង- និទ្ទេស ខ្សោយ ចាប់ពី ០ ដល់ក្រោម ១០ ពិន្ទុ

បានឃើញ និងឯកភាព

*ធ្វើនៅ.....................ថ្ងៃទី.......ខែ.............ឆ្នាំ.............*

**ប្រធានស្ថាប័ន/ប្រធានអង្គភាព**

# ៧. នីតិវិធីនៃការតែងតាំងមន្ត្រីរាជការស៊ីវិល

- សារាចរណែនាំ លេខ ០២ សរណន ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការជ្រើសរើសនិងតែងតាំងមន្ត្រីរាជការស៊ីវិល

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ០២ សរណន                                        រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ១៩៩៩

## សារាចរណែនាំ
## ស្តីពីការជ្រើសរើស និង តែងតាំងមន្ត្រីរាជការស៊ីវិល

កន្លងមករាជរដ្ឋាភិបាលបានពិនិត្យឃើញថា មានក្រសួងស្ថាប័នមួយចំនួនបានធ្វើការជ្រើសរើស និង តែងតាំងមន្ត្រីរាជការក្រោមឱវាទពុំសមស្របទៅតាមគោលការណ៍ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និង ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី និងសារាចរលេខ ០១ សរ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល។ ចំពោះមុខដើម្បីពង្រឹងការអនុវត្តន៍ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និង លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ ជុំវិញការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលអោយកាន់តែមានប្រសិទ្ធិភាព ដើម្បីសំដៅបន្តរួមចំណែកក្នុងការអនុវត្តន៍អោយបានជោគជ័យជាស្ថាពរ នូវគោលនយោបាយកំណែទំរង់រដ្ឋបាលសាធារណៈ និង ពង្រឹងនិតិរដ្ឋនោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោមៈ

**១-<u>ការជ្រើសរើសៈ</u>**

ក្នុងការជ្រើសរើសមន្ត្រីរាជការស៊ីវិល ចូលក្នុងក្របខ័ណ្ឌរដ្ឋ ត្រូវអនុវត្តតាមបញ្ញត្តិដែលមានចែងក្នុងជំពូកទី II នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ជាពិសេសមាត្រា ១៣ បានចែងថា "ជាគោលការណ៍រាល់ការជ្រើសរើសបេក្ខជនអោយចូលក្នុងក្របខ័ណ្ឌ ត្រូវធ្វើឡើងតាមការប្រឡងប្រជែង លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយរាជរដ្ឋាភិបាល" ។ បែបបទនៃការជ្រើសរើសនេះមានចែងក្នុងសារាចរ លេខ ០១ សរ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ ។

**២-<u>ការតែងតាំងមុខតំណែងៈ</u>**

ជាគោលការណ៍ ការតែងតាំងអោយកាន់មុខតំណែងណាមួយ នៃមុខងារសាធារណៈ របស់ក្រសួងស្ថាប័នត្រូវអនុវត្តចំពោះអ្នករាជការក្របខ័ណ្ឌ នៃក្រសួងស្ថាប័ននោះ ។

ការតែងតាំងនោះត្រូវផ្អែកលើសំណូមពរ ភារកិច្ចជាក់ស្តែង សញ្ញាប័ត្រជំនាញ បទពិសោធន៍ការងាររបស់សាមីជន អោយសមស្របទៅតាមតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់ក្រសួងស្ថាប័ននីមួយៗ ។ ការតែងតាំងអោយកាន់មុខតំណែងណាមួយក្នុងមុខងារសាធារណៈ ត្រូវអនុវត្តអោយបានសមស្របទៅតាមច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រីដែលមានចែងជាពិសេស ក្នុងមាត្រា ២៨ ជំពូក III ស្តីពីសិទ្ធិក្នុងការតែងតាំង ។

**៣-<u>ការផ្ទេរ:</u>**

រាល់ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ពីក្រសួងស្ថាប័នមួយ ទៅក្រសួងស្ថាប័នមួយទៀត ជាគោលការណ៍ត្រូវមានការឯកភាពពី រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**៤-<u>ហាមឃាត់:</u>**

**<u>ក/</u>** តាមស្មារតីខាងលើនេះ មិនត្រូវបានអនុញ្ញាតអោយធ្វើការតែងតាំងមុខតំណែងមុខងារសាធារណៈ ក្នុងករណីដូចខាងក្រោមៈ

-អ្នកដែលគ្មានឈ្មោះក្នុងក្របខ័ណ្ឌមុខងារសាធារណៈ

-អ្នកដែលកំពុងបំពេញកម្មសិក្សា ពុំទាន់តាំងស៊ប់ក្នុងក្របខ័ណ្ឌ ។

-ការតែងតាំងថ្នាក់ស្មើ ក្នុងមុខតំណែងណាមួយ ដោយគ្មានក្នុងរចនាសម្ព័ន្ធ ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងស្ថាប័ន ។

-ការតែងតាំងបន្ថែមចំនួនមន្ត្រី ក្នុងមុខតំណែងអនុប្រធាននាយកដ្ឋាន អនុប្រធានការិយាល័យ អនុប្រធានមន្ទីរនៅខេត្ត ក្រុង ក្នុងករណីដែលនាយកដ្ឋាន ការិយាល័យ ឬមន្ទីរនោះ មានអនុប្រធានចាប់ពី ២នាក់ឡើងទៅរួចហើយ ។ ក្នុងករណីចាំបាច់ត្រូវពិគ្រោះជាមួយ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីពិនិត្យលើរចនាសម្ព័ន្ធជាមុន ។

**<u>ខ/</u>**ហាមផ្ទេរបញ្ចូលមកក្នុង ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល នូវមន្ត្រីបុគ្គលិកយោធា-នគរបាលជាតិ បុគ្គលិកស្ថិតក្នុងអង្គភាពម្ចាស់ការហិរញ្ញវត្ថុ ស្វ័យាភិបាលសេដ្ឋកិច្ច និង ក្របខ័ណ្ឌផ្សេងទៀត ដែលមិនស្ថិតនៅក្រោមច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ។ ក្នុងករណីពិសេសត្រូវមានការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ទីស្តីការគណៈរដ្ឋមន្ត្រី ។

ទទួលបានសារាចរនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង និងរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តតាមខ្លឹមសារខាងលើនេះ ដោយស្មារតីទទួលខុសត្រូវ និង អោយមានប្រសិទ្ធិភាពខ្ពស់ ។

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

❖ សារាចរណែនាំ លេខ ១០ សរណន  ចុះថ្ងៃទី២៨  ខែមិថុនា  ឆ្នាំ១៩៩៩

ស្តីពីនីតិវិធីនៃការ តែងតាំងមន្ត្រីរាជការស៊ីវិល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១០ សរណន**

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ១៩៩៩

# សារាចរណែនាំ
## ស្តីពី
## នីតិវិធី នៃការតែងតាំងមន្ត្រីរាជការស៊ីវិល

❋❋❋

ទោះបីជាច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ អនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល សារាចរលេខ ០១ សរ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍ជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌរដ្ឋ និង គោលការណ៍ជ្រើសរើសបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួង ស្ថាប័ន នានា សារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការជ្រើសរើស និង តែងតាំងមន្ត្រីរាជការស៊ីវិល និង លិខិតបទដ្ឋានផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់ ដើម្បីធ្វើអោយរដ្ឋបាលរបស់រដ្ឋមានលក្ខណៈ អព្យាក្រឹត្យ តម្លាភាព និង អភិបាលកិច្ចល្អ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ការអនុវត្តន៍របស់ក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង មួយចំនួនក្នុងការជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌរដ្ឋ និង ការតែងតាំងមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមុខងារសាធារណៈ នៅតែមានបាតុភាពមិនប្រក្រតីដែលផ្ទុយនឹងគោលការណ៍ និង នីតិវិធីដែលបានកំណត់ហើយមិនទាន់មានលក្ខណៈឯកភាពគ្នានៅឡើយ ។

ដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ លិខិតបទដ្ឋាន និងលុបបំបាត់បាតុភាពមិនប្រក្រតីខាងលើ រាជរដ្ឋាភិបាលសូមធ្វើការណែនាំបន្ថែមដូចខាងក្រោម ៖

***១- ការតែងតាំងមន្ត្រីរាជការស៊ីវិលនៅក្រសួង-ស្ថាប័ន:***

-ត្រូវបន្តអនុវត្តអោយបានត្រឹមត្រូវតាមចំណុចទី២ ស្តីអំពីការតែងតាំងមុខតំណែងដែលកំណត់ក្នុងសារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ពោលគឺ ៖

ក- ការតែងតាំងអោយកាន់មុខតំណែងណាមួយ នៃមុខងារសាធារណៈ របស់ក្រសួងស្ថាប័ន ជាគោលការណ៍ត្រូវអនុវត្តចំពោះមន្ត្រីរាជការក្របខ័ណ្ឌ នៃក្រសួងស្ថាប័ននោះ ។

ខ- ការតែងតាំងត្រូវផ្អែកលើសំណូមពរ ភារកិច្ចជាក់ស្តែង សញ្ញាប័ត្រជំនាញ បទពិសោធន៍ការងាររបស់សាមីជន ឲ្យសមស្របទៅតាមតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់ក្រសួងនីមួយៗ។

គ-ការតែងតាំងអោយកាន់មុខតំណែងណាមួយ ក្នុងមុខងារសាធារណៈ ត្រូវអនុវត្តអោយបានសមស្របទៅតាមច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលមានចែងក្នុងមាត្រា ២៨ ជំពូកទី ៣ ស្តីពីសិទ្ធិក្នុងការតែងតាំង ។

-ត្រូវធ្វើការពិគ្រោះយោបល់ឲ្យបានឯកភាពគ្នា ជៀសវាងដាច់ខាតមិនអោយមានបាតុភាពនៅក្នុងក្រសួងស្ថាប័នរបស់ខ្លួនមុននឹងលើកសំណើតែងតាំង ឬ ធ្វើសេចក្តីសំរេចជាស្ថាពរ ។

-រាល់លិខិតបទដ្ឋានឯកត្តជនស្តីពីការតែងតាំងមន្ត្រីរាជការស៊ីវិល ដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ និង ប្រកាសត្រូវដាក់ឆ្លងជាមុន ដើម្បីផ្ទៀងផ្ទាត់ផ្នែករដ្ឋបាលដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ផ្នែកថវិកាដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលត្រូវចុះទិដ្ឋាការរៀងៗខ្លួន ។

- លិខិតបទដ្ឋានឯកត្តជនណាដែលគ្មានទិដ្ឋាការនោះ ត្រូវទុកជានិរាករណ៍ ។

***២-ការតែងតាំងប្រធានមន្ទីរជំនាញខេត្ត-ក្រុង:***

- ការផ្តួចផ្តើមលិខិតតែងតាំងត្រូវធ្វើឡើងដោយក្រសួងស្ថាប័នជំនាញ ។
- ត្រូវធ្វើការពិគ្រោះយោបល់ អោយបានឯកភាពគ្នាក្រសួងស្ថាប័ន ដើម្បីកំណត់យកបេក្ខជនដែលត្រូវតែងតាំង។
- បន្ទាប់មកត្រូវពិគ្រោះយោបល់លើបេក្ខជនដែលត្រូវតែងតាំងនោះជាមួយអភិបាល ខេត្ត-ក្រុងសាមុី ហើយអភិបាលខេត្តក្រុងសាមុីនោះត្រូវធ្វើការពិគ្រោះយោបល់អោយមានការឯកភាពគ្នាក្នុងជួរថ្នាក់ដឹកនាំខេត្ត-ក្រុង មុននឹងផ្តល់យោបល់ឆ្លើយតប។
- ក្នុងករណីមិនទាន់មានការឯកភាពរវាងក្រសួងស្ថាប័នសាមុីជាមួយនឹងខេត្ត-ក្រុងនោះ អភិបាលខេត្តក្រុងនោះត្រូវលើកសំណើជូនក្រសួងមហាផ្ទៃ ដើម្បីជួយធ្វើការសំរបសំរួល ជាមួយក្រសួងស្ថាប័នសាមុី ។
- ក្នុងករណីមិនអាចសំរបសំរួលបាន ក្រសួងមហាផ្ទៃ ឬ ក្រសួងស្ថាប័នសាមុីត្រូវលើកសំណើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

***៣***- ក្នុងករណីពិនិត្យឃើញថា លិខិតបទដ្ឋាន ឯកត្តជន ស្តីពីការតែងតាំងមន្ត្រីរាជការ របស់ក្រសួងស្ថាប័ន ធ្វើឡើងផ្ទុយនឹងច្បាប់ ឬលិខិតបទដ្ឋានជាធរមាន ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការមុខងារសាធារណៈត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាល ដើម្បីសុំការអនុញ្ញាតិលុបចោល ហើយត្រូវធ្វើការណែនាំក្រសួងស្ថាប័ននោះធ្វើអោយបានត្រឹមត្រូវឡើងវិញ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួងស្ថាប័ន និងខេត្ត-ក្រុង ត្រូវខិតខំអនុវត្តតាមខ្លឹមសារខាងលើដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***<u>ចម្លងជូន</u>***

*-ខុទ្ទកាល័យព្រះមហាក្សត្រ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង-ស្ថាប័ន*
*-គ្រប់សាលាខេត្ត-ក្រុង*
*-ឯកសារ-កាលប្បវត្តិ*

❖ ប្រកាស លេខ ១៨៨ មស.ត្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ ស្តីពីការបំពេញបែបបទមួយចំនួនក្នុងការតែងតាំង ផ្ទេរ និងកែសម្រួលបៀវត្សជូនដល់មន្ត្រីរាជការស៊ីវិល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

លេខៈ១៨៨ មស.គ្ររ                                        ភ្នំពេញ ថ្ងៃទី ០២ ខែ មិនា ឆ្នាំ ២០០០

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

## សូមទូលថ្វាយ និង ជំរាបជូន

**សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន**

**<u>កម្មវត្ថុៈ</u>** -អំពីការបំពេញបែបបទមួយចំនួនក្នុងការតែងតាំង ផ្ទេរ និង កែសំរួលបៀវត្ស ជូនដល់មន្ត្រីរាជការស៊ីវិល។

**<u>យោងៈ</u>** -ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

-សារាចរណែនាំ លេខ ០២ សរណន ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការជ្រើសរើស និង តែងតាំងមន្ត្រីរាជការស៊ីវិល។

-សារាចរណែនាំ លេខ ១០ សរណន ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីនីតិវិធីនៃការតែងតាំងមន្ត្រីរាជការស៊ីវិល ។

ទូលបង្គំ ខ្ញុំមានកិត្តិយសសូមទូលថ្វាយ និង ជំរាបជូន សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ព្រះមេត្តា និង មេត្តាជ្រាបថា កន្លងមក រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈសង្កេតឃើញថា ក្រសួង ស្ថាប័នមួយចំនួនបានរៀបចំសំណុំលិខិតដើម្បីស្នើសុំយោបល់ និង ផ្តល់ទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈលើការតែងតាំង ផ្ទេរ និង ការស្នើសុំកែសំរួលបៀវត្ស ជូនដល់មន្ត្រីរាជការស៊ីវិលបានសមស្របជាបង្គួរ ។ ដើម្បីសម្រួលដល់ដំណើរការរៀបចំឯកសារទាំងនេះអោយកាន់តែល្អប្រសើរ គ្រប់គ្រាន់ និង បង្កលក្ខណៈងាយស្រួល ដល់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈក្នុងការពិនិត្យឯកសារទាំងនេះជូន រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សូមទូលថ្វាយនិងជំរាបជូន ពីបែបបទលើការបំពេញសុំណុំលិខិតដូចខាងក្រោមៈ

### I-អំពីការតែងតាំងមន្ត្រីរាជការស៊ីវិលៈ

-លិខិតស្នើសុំផ្ទៀងផ្ទាត់ផ្នែករដ្ឋបាលលើការតែងតាំងមន្ត្រីរាជការស៊ីវិល ចំនួន ២ ច្បាប់

-បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើសុំតែងតាំង (មានគំរូ) ចំនួន ២ ច្បាប់

-ជីវប្រវត្តិសង្ខេប (មានគំរូ) ចំនួន ១ ច្បាប់

-សញ្ញាប័ត្រ (បើមាន) ចំនួន ១ ច្បាប់

-កំណត់បង្ហាញ ឬ កំណត់ហេតុស្តីពីការប្រជុំពិភាក្សាឯកភាពគ្នាលើការតែងតាំងមន្ត្រីរាជការស៊ីវិលក្នុងជួរថ្នាក់ដឹកនាំ ចំនួន ១ ច្បាប់

-អនុក្រឹត្យស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃក្រសួង ស្ថាប័ន ចំនួន ១ ច្បាប់

-ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានក្នុងករណីតែងតាំងថ្នាក់ការិយាល័យចុះ ចំនួន ១ ច្បាប់

-យោបល់ឯកភាពរបស់អាជ្ញាធរដែនដី ក្នុងករណីតែងតាំងប្រធានមន្ទីរខេត្ត ក្រុង ចំនួន ១ ច្បាប់

**II -អំពីការផ្ទេរមន្ត្រីរាជការស៊ីវិល:**

-លិខិតស្នើសុំផ្ទេរមន្ត្រីរាជការស៊ីវិល ចំនួន ២ ច្បាប់

-ជីវប្រវត្តិសង្ខេប (មានគំរូ) ចំនួន ១ ច្បាប់

-សំណើរបស់សាមីជនក្នុងការផ្ទេរដោយមានការឯកភាពយល់ព្រមពីថ្នាក់ដឹកនាំតាមឋានានុក្រម ហើយបើជាប្រធានមន្ទីរខេត្ត ក្រុងត្រូវមានយោបល់ពីអាជ្ញាធរដែនដី ចំនួន ១ ច្បាប់

-យោបល់ឯកភាពលើសំណើនៃការផ្ទេរពីក្រសួង ស្ថាប័នផ្ទេរចូល ឬ ផ្ទេរចេញ ចំនួន ១ ច្បាប់

**III -អំពីការស្នើកែសំរួលបៀវត្សជូនមន្ត្រីរាជការស៊ីវិល:**

-លិខិតស្នើសុំកែសំរួលបៀវត្សជូនមន្ត្រីរាជការស៊ីវិល ចំនួន ២ ច្បាប់

-បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើសុំកែសំរួលបៀវត្ស (មានគំរូ) ចំនួន ២ ច្បាប់

-ឯកសារបញ្ជាក់ផ្សេងៗ -ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសតែងតាំង ចំនួន ១ ច្បាប់

-ឬ លិខិតឬ ឯកសារផ្លាស់ប្តូរភារកិច្ច ចំនួន ១ ច្បាប់

-ឬ សញ្ញាប័ត្រ -លិខិតបញ្ជាក់ការសិក្សា ។ល។ ចំនួន ១ ច្បាប់

អាស្រ័យហេតុនេះ សូមសម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ព្រះមេត្តា និង មេត្តា ជួយបំពេញបែបបទដូចបានជំរាបជូនខាងលើ ដើម្បីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈជួយពិនិត្យនិងផ្តល់យោបល់ជូនបានឆាប់រហ័ស ។

សូម សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ព្រះមេត្តា និង មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីទូលបង្គំ ខ្ញុំ ។

**រដ្ឋលេខាធិការ**

**ពេជ្រ ម៉ុនធិន**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-គ្រប់ខេត្ត ក្រុង

"ដើម្បីជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ

❖ ប្រកាស លេខ ៧៧៥ មស.គ្ររ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០០ ស្តីពីការពិនិត្យនិងផ្តល់ទិដ្ឋាការលើសំណុំលិខិតបៀវត្សប្រចាំខែ និងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

លេខៈ៧៧៥ មស.ត្ររ ភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០០

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**
**សូមជំរាបជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ក្រុងកែប ក្រុងប៉ៃលិន**
**ឯកឧត្តម អភិបាលគ្រប់ខេត្ត ក្រុង**
**លោកប្រធានមន្ទីរផែនការគ្រប់ខេត្ត ក្រុង**

**<u>កម្មវត្ថុ</u>:**-ស្តីពីការពិនិត្យ និង ផ្តល់ទិដ្ឋាការលើសំណុំលិខិតបៀវត្សប្រចាំខែ និង ការងារគ្រប់គ្រងមន្ត្រីរាជការស៊ីវិល។

**<u>យោង</u>:**- លិខិតលេខ ៥៥ មសណ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីការចុះទិដ្ឋាការលើសំណុំលិខិត បៀវត្សប្រចាំខែ របស់ក្រសួងមុខងារសាធារណៈ។

- ប្រកាសអន្តរក្រសួងលេខ ២៣១ ប្រក ផក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការប្រគល់ការងារបៀវត្ស ពលកម្មជូនមន្ទីរផែនការខេត្ត ក្រុង របស់ក្រសួងផែនការ និង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

ខ្ញុំមានកិត្តិយស សូមជំរាបជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តមអភិបាលគ្រប់ខេត្ត ក្រុង និងលោកប្រធានមន្ទីរផែនការគ្រប់ខេត្ត ក្រុងមេត្តាជ្រាបថា ផ្អែកតាមលិខិតលេខ ៥៥ មសណ និង ប្រកាសលេខ ២៣១ ប្រក ផក ដូចមានយោងខាងលើ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សូមរំលឹកអំពីភារកិច្ចរបស់ការិយាល័យបៀវត្ស ពលកម្មនៃមន្ទីរផែនការ លើការងារពិនិត្យនិងផ្តល់ទិដ្ឋាការលើសំណុំលិខិតបៀវត្សប្រចាំខែនិងការងារគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅតាម ខេត្ត ក្រុងដូចតទៅៈ

**<u>ក-អំពីការពិនិត្យនិងផ្តល់ទិដ្ឋាការលើសំណុំលិខិតបៀវត្សប្រចាំខែ</u>**

ការិយាល័យបៀវត្សពលកម្មនៃមន្ទីរផែនការ មានភារកិច្ចពិនិត្យផ្ទៀងផ្ទាត់និងផ្តល់ទិដ្ឋាការលើសំណុំលិខិតបៀវត្សមន្ត្រីរាជការស៊ីវិលរបស់មន្ទីរជំនាញនានា នៅតាមបណ្តាខេត្ត ក្រុង ជារៀងរាល់ខែ ។ សំណុំលិខិតបៀវត្សមន្ត្រីរាជការស៊ីវិលណាដែលពុំបានទទួលការពិនិត្យ និង ផ្តល់ទិដ្ឋាការពីការិយាល័យបៀវត្សពលកម្មនៃមន្ទីរផែនការទេ សំណុំលិខិតបៀវត្សនោះពុំមានសុពលភាពអាចយកទៅប្រើប្រាស់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការស៊ីវិលបានឡើយ ។

**ខ-អំពីការងារគ្រប់គ្រងមន្ត្រីរាជការស៊ីវិល:**

ទន្ទឹមនឹងការត្រួតពិនិត្យ និង ផ្តល់ទិដ្ឋាការលើសំណុំលិខិតបៀវត្សនោះ ការិយាល័យបៀវត្ស ពលកម្ម ត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅតាមខេត្ត ក្រុងនោះ ដោយពិនិត្យ និង ផ្ទៀងផ្ទាត់លើរាល់លិខិតបទដ្ឋានឯកត្តជនក្នុងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និង ស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល ។

ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិល ដែលត្រូវតែមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈមាន : ការជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌរដ្ឋ -ការតែងតាំងក្នុងមុខតំណែង -ការផ្ទេរពីស្ថាប័នមួយទៅស្ថាប័នមួយទៀត -ការរៀបបៀវត្ស -ការកែសំរួលបៀវត្ស ។

ក្នុងករណីការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និង ស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលណាដែលពុំគោរពតាមគោលការណ៍នៃការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលជាធរមាន ត្រូវតែកាត់ចេញពីតារាងទូទាត់បៀវត្ស។

**គ-អំពីការងារគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យា និងពលករអណ្តែត:**

ជាមួយនេះការិយាល័យបៀវត្ស ពលកម្មត្រូវពិនិត្យលើការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងពលករអណ្តែតនៅតាមមន្ទីរនានាផងដែរ ។ ការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងពលករអណ្តែតត្រូវតែបានការអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈជាមុន ។ ករណីដែលពិនិត្យឃើញការប្រើប្រាស់ពុំសមស្រប ត្រូវរាយការណ៍ពីស្ថានភាពនេះមករដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈដើម្បីមានវិធានការ ។

**ឃ-អំពីរបាយការណ៍**

ជារៀងរាល់ដំណាច់ត្រីមាស ការិយាល័យបៀវត្ស ពលកម្ម ត្រូវរាយការណ៍ពីស្ថានភាពនៃការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល នៅតាមខេត្ត ក្រុងនោះមករដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ របាយការណ៍រួមមាន:

| | | |
|---|---|---|
| ១-លិខិតរាយការណ៍ | (គំរូ រប ១) | ចំនួន ១ច្បាប់ |
| ២-របាយការណ៍ស្តីពីការអនុវត្តន៍ក្របខ័ណ្ឌ និងឥណទានបៀវត្ស | (គំរូ រប ២) | ចំនួន ១ច្បាប់ |
| ៣-របាយការណ៍ស្តីពីការអនុវត្តន៍ក្របខ័ណ្ឌមន្ត្រីជាប់កិច្ចសន្យានិងពលករអណ្តែត | (គំរូ រប ៣) | ចំនួន ១ច្បាប់ |
| ៤-តារាងប្រៀបធៀប (គ្រប់មន្ទីរនិងគ្រប់ខែ) | | ចំនួន ១ច្បាប់ |
| ៥-តារាងគ្រោងទុកមុខចំណាយបៀវត្ស (គ្រប់មន្ទីរនិងគ្រប់ខែ) | | ចំនួន ១ច្បាប់ |
| ៦-តារាងទូទាត់បៀវត្ស (គ្រប់មន្ទីរដោយយកខែ ០១ និង ០៧) | | ចំនួន ១ ច្បាប់ |

អាស្រ័យហេតុនេះសូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តមអភិបាលគ្រប់ខេត្ត ក្រុង និងលោកប្រធានមន្ទីរផែនការគ្រប់ខេត្ត ក្រុង មេត្តាមានវិធានការណែនាំអនុវត្តតាមការគួរ ។

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
-ក្រសួងផែនការ
-គ្រប់ក្រសួង ស្ថាប័ន
-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ខេត្ត ក្រុង
-រតនាគារគ្រប់ខេត្ត ក្រុង "ដើម្បីសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**កម្ពុជា**

៣៣❖៤៤

**ក្រសួងមុខងារសាធារណៈ**

**លេខ: ៥៥ មសណ**

ភ្នំពេញ ថ្ងៃទី ១៧ សីហា ឆ្នាំ ១៩៩៣

**រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ**

**ជំរាបមក**

**ឯកឧត្តម អភិបាលគ្រប់ខេត្ត ក្រុង**

**កម្មវត្ថុ:** -ការចុះទិដ្ឋាការលើសំណុំបៀវត្សប្រចាំខែ ។

**យោង:** -លិខិតលេខ ០៧៤ កហវ ចុះថ្ងៃទី ២៤ -០៧ -៩៣ របស់ក្រសួងហិរញ្ញវត្ថុ ។

ខ្ញុំសូមជំរាបឯកឧត្តមអភិបាលគ្រប់ខេត្ត ក្រុងមេត្តាជ្រាបថា កន្លងមកក្រសួងហិរញ្ញវត្ថុ បានធ្វើលិខិតដូចមានយោងខាងលើ ដើម្បីជូនដំណឹងដល់គ្រប់ខេត្ត ក្រុងអំពីទំរង់បែបបទក្នុងការធ្វើតារាងបៀវត្សពិសេសគ្រប់តារាងបៀវត្ស ត្រូវឆ្លងទិដ្ឋាការក្រសួងមុខងារសាធារណៈ ។

ក្រសួងមុខងារសាធារណៈ ដោយផ្អែកតាមលិខិតខាងលើ សូមឯកឧត្តមមេត្តាណែនាំដល់ការិយាល័យបៀវត្សពលកម្ម ខេត្ត ក្រុងដូចតទៅ:

១-បៀវត្សប្រចាំខែត្រូវចុះទិដ្ឋាការនៅការិយាល័យបៀវត្ស ខេត្ត ក្រុង ដូចធ្លាប់អនុវត្តកន្លងមក ។

២-ការិយាល័យបៀវត្ស ខេត្ត ក្រុង ត្រូវតែធ្វើតារាងគ្រោងទុកមុខចំណាយបៀវត្សប្រចាំខែនៃមន្ទីរនីមួយៗ ដែលបានចុះទិដ្ឋាការរួចហើយមកក្រសួងមុខងារសាធារណៈអោយបានទៀងទាត់ជារៀងរាល់ខែ ដើម្បីក្រសួងមុខងារសាធារណៈ ទំនាក់ទំនងជាមួយក្រសួងហិរញ្ញវត្ថុ សុំបើកបៀវត្សនៅខែបន្តបន្ទាប់ ។ ប្រសិនបើការិយាល័យបៀវត្សពលកម្មណាពុំបានធ្វើតារាងបៀវត្សមកក្រសួងមុខងារសាធារណៈទេ ការិយាល័យបៀវត្សពលកម្មនោះត្រូវទទួលខុសត្រូវចំពោះមុខក្រសួងមុខងារសាធារណៈ និងក្រសួងហិរញ្ញវត្ថុ អំពីការបើកបៀវត្សទៅថ្ងៃអនាគត ។

អាស្រ័យហេតុនេះ សូមឯកឧត្តមអភិបាលខេត្ត ក្រុង មេត្តាមានវិធានការណែនាំដូចខាងលើតាមការគួរ។

**<u>ចម្លងជូន</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាបជាព័ត៌មាន"

-ឯកសារ

ហត្ថលេខា និង ត្រា

**ប្រាក់ សុខ**

លេខ ៧៧៦ មសត្ររ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០០

រដ្ឋលេខាធិការ

**ពេជ្រ ប៊ុនធិន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
សាលាខេត្ត................
លេខ..........................

ធ្វើនៅ..............ថ្ងៃទី..............ខែ.............ឆ្នាំ២០០....

**អភិបាលខេត្ត ក្រុង**.................................
(គំរូ រប ១)

**គោរពជូន**

**ឯកឧត្តមរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**<u>កម្មវត្ថុៈ</u>** របាយការណ៍ស្តីពីការងារអនុវត្តន៍ក្របខ័ណ្ឌ និងឥណទានបៀវត្សប្រចាំត្រីមាសទី....ឆ្នាំ ២០០...។

**<u>យោងៈ</u>** លិខិតលេខ ៧៧៥ មសត្ររ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០០ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

ខ្ញុំមានកិត្តិយស សូមគោរពរាយការណ៍ជូនឯកឧត្តមអំពីការអនុវត្តន៍ក្របខ័ណ្ឌ និងឥណទានបៀវត្សប្រចាំត្រីមាស ទី........ឆ្នាំ ២០០..... របស់ខេត្តយើងខ្ញុំដូចតទៅៈ

**<u>១-អំពីស្ថានភាពក្របខ័ណ្ឌនិងឥណទានបៀវត្សៈ</u>**

| ត្រីមាសទី........ | ចំនួន បុគ្គលិក | | ឥណទានបៀវត្ស | ចំនួនមន្ត្រីជាប់កិច្ចសន្យា | ចំនួនពលករអណ្តែត | ផ្សេងៗ |
|---|---|---|---|---|---|---|
| | សរុប | ទំនេរគ្មានប.វ | | | | |
| ខែ................. | | | | | | |
| ខែ................. | | | | | | |
| ខែ................. | | | | | | |

**<u>២-អំពីសភាពការណ៍ផ្សេងៗជុំវិញការងារគ្រប់គ្រងមន្ត្រីរាជការស៊ីវិលៈ</u>**

.......................................................................................................................................................
.......................................................................................................................................

**<u>៣-អំពីសំណូមពរៈ</u>**

.......................................................................................................................................................
.......................................................................................................................................................
..........................................................................................

អាស្រ័យហេតុនេះសូមឯកឧត្តមមេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

**អភិបាលខេត្ត ក្រុង**

<u>ចម្លងជូន</u>
-ក្រសួងមហាផ្ទៃ
-ក្រសួងផែនការ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងផែនការ**
**មន្ទីរផែនការខេត្ត**.....................

### របាយការណ៍ស្តីពីការអនុវត្តក្របខ័ណ្ឌ និង ឥណទានបៀវត្ស
### ប្រចាំត្រីមាសទី......ឆ្នាំ ២០០......

(ចំនួនបុគ្គលិកគិតទាំងបុគ្គលិកនៅតាមស្រុក ខ័ណ្ឌ ផង) (គំរូ របៈ ២)

| ល.រ | ឈ្មោះមន្ទីរ | ខែ................. | | | ខែ................. | | | ខែ................. | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនបុគ្គលិក | | ឥណទានបៀវត្ស | ចំនួនបុគ្គលិក | | ឥណទានបៀវត្ស | ចំនួនបុគ្គលិក | | ឥណទានបៀវត្ស |
| | | សរុប | ទំនេរគ្មានប.វ | | សរុប | ទំនេរគ្មានប.វ | | សរុប | ទំនេរគ្មានប.វ | |
| ១ | សាលាខេត្ត ក្រុង | | | | | | | | | |
| ២ | ទំ.ព្រឹទ្ធ.រដ្ឋ.និងអធិ. | | | | | | | | | |
| ៣ | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | | | | | | | | |
| ៤ | ពត៌មាន | | | | | | | | | |
| ៥ | សុខាភិបាល | | | | | | | | | |
| ៦ | ឧស្សា.រ៉ែ និងថាមពល | | | | | | | | | |
| ៧ | ផែនការ | | | | | | | | | |
| ៨ | ពាណិជ្ជកម្ម | | | | | | | | | |
| ៩ | អប់រំ យុវ.និងកីឡា | | | | | | | | | |
| ១០ | កសិ.រុក្ខា.និងនេសាទ | | | | | | | | | |
| ១១ | វប្បធម៌ និងវិចិត្រ | | | | | | | | | |
| ១២ | បរិស្ថាន | | | | | | | | | |
| ១៣ | អភិវឌ្ឍន៍ជនបទ | | | | | | | | | |
| ១៤ | សង្គមការបណ្តុះនិងយុវ. | | | | | | | | | |
| ១៥ | ប្រៃស.និងទូរគមនា. | | | | | | | | | |
| ១៦ | ធម្មការ និងកិច្ចការ. | | | | | | | | | |
| ១៧ | សាធារ. និងដឹកជញ្ជូន | | | | | | | | | |
| ១៨ | តុលាការ | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១៩ | ទេសចរណ៍ | | | | | | | | | |
| ២០ | រៀប.នគ.សំណង់និងសុ. | | | | | | | | | |
| ២១ | ធនធាន.និងឧត្តុនិយម | | | | | | | | | |
| ២២ | កិច្ចការនារី និងអតីត. | | | | | | | | | |
| | សរុប | | | | | | | | | |

| | | |
|---|---|---|
| បានឃើញនិងឯកភាព | បានឃើញនិងឯកភាព | ថ្ងៃទី.......ខែ.......ឆ្នាំ២០០.... |
| ថ្ងៃទី.......ខែ.......ឆ្នាំ២០០.... | ថ្ងៃទី.......ខែ.......ឆ្នាំ២០០.... | ប្រធានការិយាល័យបៀវត្ស ពលកម្ម |
| អភិបាលខេត្ត ក្រុង | ប្រធានមន្ទីរផែនការ | |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងផែនការ**
**មន្ទីរផែនការខេត្ត**.....................

**របាយការណ៍ស្តីពីការអនុវត្តន៍ក្របខ័ណ្ឌមន្ត្រីជាប់កិច្ចសន្យា និងពលករអណ្តែត**
**ប្រចាំត្រីមាសទី......ឆ្នាំ ២០០......**

(គំរូ របP៣)

| ល.រ | ឈ្មោះមន្ទីរ | ខែ.................. | | ខែ.................. | | ខែ.................. | |
|---|---|---|---|---|---|---|---|
| | | មន្ត្រីជាប់កិច្ចសន្យា | ពលករអណ្តែត | មន្ត្រីជាប់កិច្ចសន្យា | ពលករអណ្តែត | មន្ត្រីជាប់កិច្ចសន្យា | ពលករអណ្តែត |
| ១ | សាលាខេត្ត ក្រុង | | | | | | |
| ២ | ទំ.ព្រឹទ្ធ.រដ្ឋ.និងអធិ. | | | | | | |
| ៣ | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | | | | | |
| ៤ | ពត៌មាន | | | | | | |
| ៥ | សុខាភិបាល | | | | | | |
| ៦ | ឧស្សា.រ៉ែ និងថាមពល | | | | | | |
| ៧ | ផែនការ | | | | | | |
| ៨ | ពាណិជ្ជកម្ម | | | | | | |
| ៩ | អប់រំ យុវ.និងកីឡា | | | | | | |
| ១០ | កសិ.រុក្ខា.និងនេសាទ | | | | | | |
| ១១ | វប្បធម៌ និងវិចិត្រ | | | | | | |
| ១២ | បរិស្ថាន | | | | | | |
| ១៣ | អភិវឌ្ឍន៍ជនបទ | | | | | | |
| ១៤ | សង្គមការបណ្តុះនិងយុវ. | | | | | | |
| ១៥ | ប្រៃស.និងទូរគមនា. | | | | | | |
| ១៦ | ធម្មការ និងកិច្ចការ. | | | | | | |
| ១៧ | សាធារ. និងដឹកជញ្ជូន | | | | | | |
| ១៨ | តុលាការ | | | | | | |
| ១៩ | ទេសចរណ៍ | | | | | | |
| ២០ | រៀប.នគ.សំណង់និងសុ. | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២១ | ធនធាន.និងឧត្តុនិយម | | | | | | |
| ២២ | កិច្ចការនារី និងអតីត. | | | | | | |
| | សរុប | | | | | | |

បានឃើញនិងឯកភាព
ថ្ងៃទី.......ខែ.......ឆ្នាំ២០០....
អភិបាលខេត្ត ក្រុង

បានឃើញនិងឯកភាព
ថ្ងៃទី.......ខែ.......ឆ្នាំ២០០....
ប្រធានមន្ទីរផែនការ

ថ្ងៃទី.......ខែ.......ឆ្នាំ២០០....
ប្រធានការិយាល័យបៀវត្ស ពលកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង**.....................

**បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើសុំតែងតាំង**

| ល.រ | នាម និង គោត្តនាម | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | ថ្ងៃ ខែ ឆ្នាំចូល បំរើក្របខ័ណ្ឌរដ្ឋ | កំរិត វប្បធម៌ | កំរិតមុខជំនាញ | ឋានៈតួនាទី និង អគ្គតាព បច្ចុប្បន្ន | ភាំ បៀវត្ស | ឋានៈតួនាទី និង អគ្គតាព ស្នើសុំតែងតាំង |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

បានឃើញ និង ឯកភាព

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០០

**រដ្ឋមន្ត្រី**

ភ្នំពេញ ថ្ងៃទី....... ខែ........... ឆ្នាំ ២០០០

**ប្រធាននាយកដ្ឋានបុគ្គលិក**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង.....................**

**<u>បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើសុំសម្រួលបៀវត្ស</u>**

| ល.រ | នាម និង គោត្តនាម | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | ថ្ងៃ ខែ ឆ្នាំចូល បំរើក្របខ័ណ្ឌរដ្ឋ | កំរិត វប្បធម៌ | ស្ថានភាព | | កាំបៀវត្ស | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ចាស់ | ថ្មី | ចាស់ | ស្នើកែសម្រួល | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

បានឃើញ និង ឯកភាព

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០០

**រដ្ឋមន្ត្រី**

ភ្នំពេញ ថ្ងៃទី....... ខែ........... ឆ្នាំ ២០០០

**ប្រធាននាយកដ្ឋានបុគ្គលិក**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត ៤X៦

**ក្រសួង**.....................
**អង្គភាព**..................

## ជីវប្រវត្តិសង្ខេប

**ក-ព័ត៌មានផ្ទាល់ខ្លួន**

-គោត្តនាម និង នាម.....................................................អក្សរពុម្ពឡាតាំង.............................................ភេទៈ ស្រី ☐ ប្រុស ☐

-កើតថ្ងៃទី.......ខែ.................ឆ្នាំ១៩.......សញ្ជាតិ..........កើតនៅភូមិ...........................................ឃុំ(សង្កាត់)

..................................................ស្រុក(ខណ្ឌ)..................................ខេត្តក្រុង..................................................................................

**ខ-ព័ត៌មានគ្រួសារ**

-ឈ្មោះប្រពន្ធ ឬ ប្តី...................... ................ ស្លាប់ ☐ រស់ ☐ កើតថ្ងៃទី......ខែ.............ឆ្នាំ១៩.....

មុខរបរ.......................... .........................អង្គភាព.......................................................................

-ចំនួនកូន.........................នាក់

**គ-អាសយដ្ឋានបច្ចុប្បន្នៈ**.............................................................................................................................................

**ឃ-ភាសាបរទេសៈ**.....................................................................................................................................................

**ង-កំរិតវប្បធម៌ទូទៅ បណ្តុះបណ្តាលវិជ្ជាជីវៈ និង បណ្តុះបណ្តាលបន្តៈ**

| វគ្គ ឬ ការសិក្សា | គ្រឹះស្ថានសិក្សា បណ្តុះបណ្តាល | ទីកន្លែងសិក្សា | សញ្ញាប័ត្រដែលទទួលបាន | ថ្ងៃខែឆ្នាំចូលសិក្សា | ថ្ងៃខែឆ្នាំ បញ្ចប់ការសិក្សា |
|---|---|---|---|---|---|
| -កំរិតវប្បធម៌ទូទៅ | | | | | |
| | | | | / / | / / |
| -កំរិតបណ្តុះបណ្តាលមុខវិជ្ជាជីវៈមូលដ្ឋាន និង ក្រោយមូលដ្ឋាន | | | | | |
| | | | | / / | / / |
| | | | | / / | / / |

**ច-ប្រវត្តិការងារៈ**

| ថ្ងៃខែឆ្នាំចូល បំរើការងារ | ថ្ងៃខែឆ្នាំ បញ្ចប់ការងារ | ក្រសួងស្ថាប័ន | នាយកដ្ឋាន ឬ អង្គភាព ឬ មន្ទីរ | ការិយាល័យ | មុខតំណែង |
|---|---|---|---|---|---|
| / / | | | | | |
| / / | | | | | |
| / / | | | | | |

ខ្ញុំសូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថាពត៌មានបំពេញខាងលើនេះពិតជាត្រឹមត្រូវពិតប្រាកដមែន។

បានឃើញ និង បញ្ជាក់ថា ពត៌មានដែល — ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ ២០០០

លោក............................................... — ហត្ថលេខា (សាមីខ្លួន)

បានអះអាងខាងលើពិតជាត្រឹមត្រូវប្រាកដមែន។

ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ ២០០០

ហត្ថលេខា (ប្រធាននាយកដ្ឋានបុគ្គលិក) — ឈ្មោះ.......................................

ឈ្មោះ.......................................

# ៨.ការផ្តល់គ្រឿងឥស្សរិយយស

❖ ព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ជស/រកត/១០៩៥/០១

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**
**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# ត្រាស់បង្គាប់

**មាត្រា ១** : គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើត និងរៀបរៀងតាមប្រភេទ និងតាមឋានានុក្រម ដូចខាងក្រោមនេះ ៖

ក- ប្រភេទមាតុប្រទេស ៖

១- មេដាយជាតូបការៈ

២- មេដាយព្រះរាជាណាក្រកម្ពុជា មាន ៥ ថ្នាក់ ៖ មហាសេរីវឌ្ឍន៍ មហាសេនា - ធិបឌិន្ទ - សេនា - អស្សឫទ្ធិ

៣- មេដាយឯករាជ្ជាតិ

គ្រឿងឥស្សរិយយសប្រភេទនេះ សំរាប់បំពាក់ជូនវរជនដែលមានគុណូបការៈដ៏ឧត្តុងឧត្តមក្នុងការបំរើមាតុប្រទេស ដើម្បីបុព្វហេតុឯករាជ្យ សាមគ្គីភាព ប្រជាធិបតេយ្យ និង សន្តិភាពជាតិ

តាមរយៈព្រះរាជក្រឹត្យក្រោយពីការសំរេចរបស់គណៈរដ្ឋមន្ត្រី ហើយត្រូវប្រទានដោយព្រះមហាក្សត្រ ឬ ដោយព្រះរាជតំណាង ។

ខ- ប្រភេទព្រះរាជបល្ល័ង្ក

១- មេដាយរាជសម្បត្តិ

២- មេដាយ រដ្ឋកាល មាន ៣ ថ្នាក់ : មាស , ប្រាក់ , សំរិទ្ធ

៣- មេដាយ អនុស្សរា

គ្រឿងឥស្សរិយយសប្រភេទនេះ សំរាប់បំពាក់ជូនវរជនដែលមានគុណបំណាច់ចំពោះព្រះរាជបល្ល័ង្ក ចំពោះព្រះមហាក្សត្រផ្ទាល់ ចំពោះព្រះរាជវង្សានុវង្ស ព្រះមហាក្សត្រ ឬជាអនុស្សរីយ៍របស់ព្រះមហាក្សត្រ ។

ការផ្តល់ និង បំពាក់គ្រឿងឥស្សរិយយសទាំងនេះ ត្រូវសំរេចដោយព្រះរាជតំរិះផ្ទាល់របស់ព្រះមហាក្សត្រ តាមរយៈក្រឹត្យបរមរាជវាំង ។

គ- ប្រភេទការពារជាតិ :

១- មេដាយសេនាជ័យសិទ្ធ

២- មេដាយការពារជាតិ មាន ៣ ថ្នាក់ : មាស , ប្រាក់ , សំរិទ្ធ

គ្រឿងឥស្សរិយយសទាំងនេះ សំរាប់បំពាក់ជូនដល់ពលទាហាន នាយទាហាន នៃ កងកម្លាំងប្រដាប់អាវុធ ឬ នគរបាលដែលមានស្នាដៃឆ្នើមពិសេសក្នុងសង្គ្រាម ឬកិច្ចការពារព្រំដែន និងការពារសន្តិសុខជូនជាតិមាតុភូមិតាមរយៈ ព្រះរាជក្រឹត្យ ក្រោយពីការសំរេចរបស់គណៈរដ្ឋមន្ត្រី ហើយ ត្រូវប្រទានដោយព្រះមហាក្សត្រ ឬ ព្រះរាជតំណាង ។

ឃ- ប្រភេទចំរុះ

១- មេដាយសហមេត្រី មាន ៣ ថ្នាក់ : ធិបឌិន្ទ, សេនា, អស្សឫទ្ធិ សំរាប់បំពាក់ជូនអង្គទូត ឬ តំណាងប្រទេសជាមិត្តដែលបានបំពេញការងារ ដើម្បីជាប្រយោជន៍ ដល់ចំណងមិត្តភាព ប្រទេសទាំងពីរ ។

២- មេដាយសុវត្ថារា មាន ៣ ថ្នាក់ : ធិបឌិន្ទ, សេនា, អស្សឫទ្ធិ សំរាប់បំពាក់ជូនបុគ្គលដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ក្នុងវិស័យ កសិកម្មនិងសេដ្ឋកិច្ច ។

៣- មេដាយមុនីសារាភ័ណ្ឌ មាន ៣ ថ្នាក់ : ធិបឌិន្ទ, សេនា, អស្សឫទ្ធិ សំរាប់បំពាក់ជូនបុគ្គលដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ ក្នុងវិស័យសិក្សាធិការ អក្សរសាស្ត្រវិទ្យាសាស្ត្រ វិចិត្រសិល្បៈ សង្គមកិច្ច ឬ វិស័យផ្សេង ៗទៀត ។

៤- មេដាយការងារមាន ៣ ថ្នាក់ : មាស , ប្រាក់ , សំរិទ្ធ សំរាប់បំពាក់ជូនបុគ្គលដែលមានថ្វីដៃ ក្នុងការងារផ្នែករដ្ឋបាល ឬ ក្នុងវិស័យឯកជន ។

៥- មេដាយស្ថាបនាជាតិមាន ៣ ថ្នាក់ : មាស , ប្រាក់, សំរិទ្ធ សំរាប់បំពាក់ជូនសប្បុរសជន ដែលបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនជួយកសាងជាតិ ឬស្ថាបនា សមិទ្ធិជាប្រយោជន៍សាធារណៈ ។

៦- មេដាយខេមរាកីឡាឫទ្ធិ មាន ៣ ថ្នាក់ : មាស , ប្រាក់, សំរិទ្ធ សំរាប់បំពាក់ជូនកីឡាករដែលមានស្នាដៃឆ្នើមក្នុងវិស័យកីឡាជាតិ ឬអន្តរជាតិ ដែលបាននាំមកនូវកិត្តិយសដល់ប្រទេសជាតិ ។

៧- មេដាយស្ត្រីវឌ្ឍនា មាន ៣ ថ្នាក់ : មាស , ប្រាក់, សំរិទ្ធ សំរាប់បំពាក់ជូនស្ត្រី ឬ បុរសដែលមានគុណូបការៈខ្ពង់ខ្ពស់ក្នុងការលើកតំកើងបុព្វហេតុស្ត្រី ។

គ្រឿងឥស្សរិយយសប្រភេទចំរុះនេះ ត្រូវសំរេចតាមរយៈអនុក្រឹត្យនិងបំពាក់ដោយនាយករដ្ឋមន្ត្រី ឬ តំណាង ។

**មាត្រា ២** : រូបភាពលក្ខណៈសញ្ញាផ្សេងៗ នៃឥស្សរិយយស និង ប្រកាសនីយប័ត្រគ្រឿងឥស្សរិយយសទាំងនេះ ត្រូវយកតាមគំរូដែលបានកំណត់ក្នុងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៦៣ ។

**មាត្រា ៣** : រៀងរាល់ដំណាច់ឆ្នាំ អាជ្ញាធរមានសមត្ថកិច្ចតាមក្រសួង ឬ តាមអង្គភាពនីមួយៗ មានភារកិច្ចស្រង់បញ្ជីឈ្មោះ វរជនដែលត្រូវស្នើរដ្ឋាភិបាល ដើម្បីសំរេចជូនមេដាយ ដោយមានបញ្ជាក់ផងដែរនូវ ទឡ្ហីករណ៍ចំពោះករណី ផ្ទាល់វរៈជនម្នាក់ ៗ ។

ក្នុងករណីពិសេស បន្ទាន់ និង ចាំបាច់ នាយករដ្ឋមន្ត្រីអាចនឹងស្នើរៀបចំពិធីបំពាក់ឥស្សរិយយសនេះជាមុន រួចរៀបចំសំណុំបែបបទ ស្នើសុំជាខាងក្រោយ ។

**មាត្រា ៤** : គ្រឿងឥស្សរិយយស ពុំអាចផ្តល់ជូនឥស្សរជនមួយរូបលើសពីមួយដង ក្នុងមួយឆ្នាំបានឡើយ ។ តែមេដាយ ការពារជាតិ ឬ មេដាយស្ថាបនាជាតិមិនត្រូវគិតបញ្ចូលទេ ។

**មាត្រា ៥** : រាជរដ្ឋាភិបាលត្រូវផលិតមេដាយ និង ត្រូវមានសារាចរលំអិតបន្ថែមទៀតដើម្បីណែនាំដល់អាជ្ញាធរមានសមត្ថកិច្ច គ្រប់ថ្នាក់ អំពីបែបបទ នៃការរៀបចំសំណើសុំគ្រឿងឥស្សរិយយស ។

**មាត្រា ៦** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧** : នាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៨** : ព្រះរាជក្រឹត្យនេះមានអានុភាពគតិយុត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា** | **ហត្ថលេខា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២
សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
**ហត្ថលេខា**
**សុខ អាន** **ម៉េង សិរីវុឌ្ឍ**

លេខ ៥៧ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាងី តាន់**

❖ អនុក្រឹត្យ លេខ ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៦ អនក្រ បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណូមពរចាំបាច់ក្នុងការលើកទឹកចិត្ត និង ដើម្បីឲ្យការជូនគ្រឿងឥស្សរិយយសរបស់ជាតិមានភាពសុក្រឹតល្អ

## សំរេច

**មាត្រា ១** .-

បង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន មន្ត្រីរាជការ ដែលត្រូវផ្តល់ជូនគ្រឿងឥស្សរិយយស ។

**មាត្រា ២** .-

សមាសភាពគណៈកម្មការនេះរួមមានៈ

| | | |
|---|---|---|
| ១-ឯកឧត្តម អគ្គលេខាធិការរាជរដ្ឋាភិបាល | | ប្រធាន |
| ២-ឯកឧត្តម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | | អនុប្រធាន |
| ៣-ឯកឧត្តម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | មួយរូប | សមាជិក |
| ៤-ឯកឧត្តម រដ្ឋលេខាធិការក្រសួងការពារជាតិ | មួយរូប | សមាជិក |
| ៥-លោកប្រធាននាយកដ្ឋានឥស្សរិយយស នៃទីស្តីការគណៈរដ្ឋមន្ត្រី | | លេខាធិការ |

**មាត្រា ៣ .-**

គណៈកម្មការនេះមានភារកិច្ចៈ

-រៀបចំលក្ខខណ្ឌ សំរាប់ការទទួលគ្រឿងឥស្សរិយយសចំពោះមន្ត្រីរាជការ

-ពិនិត្យលក្ខណសម្បត្តិវរជនដែលមានស្នាដៃ និង គុណបំណាច់ដ៏ខ្ពង់ខ្ពស់ក្នុងបុព្វហេតុការពារបូរណភាពទឹកដី ឯករាជ្យ សន្តិភាព ប្រជាធិបតេយ្យ និង ក្នុងការងារស្តារនឹងអភិវឌ្ឍន៍ប្រទេសជាតិ

-ពិនិត្យចំនួនលក្ខណសម្បត្តិ មន្ត្រីរាជការ ទាំងឡាយដែលក្រសួង ស្ថាប័នរដ្ឋនានា ស្នើមកសុំគ្រឿងឥស្សរិយយស

-ពិនិត្យសំរេច និង ធ្វើសំណើដាក់ជូនសម្តេចនាយករដ្ឋមន្ត្រី លើប្រភេទគ្រឿងឥស្សរិយយសតាមទំហំស្នាដៃ ដែលបានបំពេញការងារដើម្បីជាប្រយោជន៍ជាតិ

-ធ្វើសំណើសុំគ្រឿងឥស្សរិយយសជូន មន្ត្រីរាជការ រៀងរាល់ ២ ឆ្នាំម្តង។

**មាត្រា ៤.-**

គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតអោយមានគណៈកម្មការមួយ ដើម្បីពិនិត្យលក្ខណសម្បត្តិបេក្ខជនដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស ដែលមានថ្នាក់ដឹកនៃក្រសួង ស្ថាប័ន ផ្ទាល់ជាប្រធានគណៈកម្មការ និងថ្នាក់ដឹកនាំអង្គភាពសំខាន់ៗ ក្រោមឱវាទក្រសួង ស្ថាប័ន ជាសមាជិក ហើយបញ្ជូនបញ្ជីបេក្ខជនដែលស្នើសុំគ្រឿងឥស្សរិយយសទាំងនោះមកគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន មន្ត្រីរាជការ ដែលត្រូវផ្តល់ជូនគ្រឿងឥស្សរិយយស។

**មាត្រា ៥.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង សមាសភាពគណៈកម្មការ ដូចមានចែងក្នុងមាត្រា២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០០

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួលៈ</u>

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុង មាត្រា ៤

-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន

-រាជកិច្ច

-កាលប្បវត្តិ-ឯកសារ

❖ សារាចរណែនាំ លេខ០១ សរណន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំបែបបទស្នើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០១ សរណន

# សារាចរណែនាំ
# ស្តីពីការរៀបចំ បែបបទស្នើគ្រឿង
# ឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

ដើម្បីជាការលើកទឹកចិត្ត ព្រមទាំងចារឹកទុកនូវគុណបំណាច់ និងស្នាដៃដ៏ខ្ពង់ខ្ពស់ក្នុងការការពារ និងកសាងប្រទេស រាជរដ្ឋាភិបាលធ្លាប់បានបំពាក់នូវគ្រឿងឥស្សរិយយសរបស់ជាតិគ្រប់ប្រភេទ ជូនចំពោះជនរួមជាតិនិង មិត្តភក្តិបរទេស ស្របទៅតាមទំហំស្នាដៃ និង គុណបំណាច់របស់បុគ្គលម្នាក់ៗ ឬសមូហភាពនិមួយៗ។ គោលនយោបាយលើកទឹកចិត្ត និងផ្តល់កិត្តិយសខាងលើនេះ ត្រូវបានទទួលការអបអរសាទរគ្រប់មជ្ឈដ្ឋាន។ ទន្ទឹមនឹងលទ្ធផលដ៏ល្អខាងលើនេះ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា នៅមានការខ្វះចន្លោះមួយចំនួនដែលចាំបាច់ត្រូវមានការកែលំអរឡើងវិញ ដើម្បីអោយការផ្តល់គ្រឿងឥស្សរិយយស របស់ជាតិមានភាពត្រឹមត្រូវយុត្តិធម៌ និងរក្សាបាននូវមោទនភាពដ៏ខ្ពង់ខ្ពស់របស់ជាតិយើង ស្របតាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជានិងអនុក្រឹត្យលេខ ៦៦ អនក្រ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស រាជរដ្ឋាភិបាល សូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័នអំពីបែបបទនៃការស្នើសុំគ្រឿងឥស្សរិយយសគ្រប់ប្រភេទ ដូចមានខ្លឹមសារខាងក្រោមនេះ ៖

១- ដើម្បីរក្សាតម្លៃគ្រឿងឥស្សរិយយសរបស់ជាតិ និងដើម្បីអោយរបៀបរបបការងាររដ្ឋបាលដំណើរការបានល្អ រាល់សំណើសុំគ្រឿងឥស្សរិយយសទាំងអស់ ចាំបាច់ត្រូវឆ្លងតាមគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវស្នើគ្រឿងឥស្សរិយយសរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០ ក្រោយពីសារាចរណែនាំនេះចូលជាធរមាន ។

២- គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវបង្កើតអោយមាន " គណៈកម្មការពិនិត្យលក្ខណសម្បត្តិបេក្ខជន ដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស" មួយដែលមានថ្នាក់ដឹកនាំក្រសួងស្ថាប័នផ្ទាល់ ជាប្រធានគណៈកម្មការ និង ថ្នាក់ដឹកនាំអង្គភាពសំខាន់ៗ ក្រោមឱវាទក្រសួងស្ថាប័ន ជាសមាជិក ។ គណៈកម្មការនេះមានភារកិច្ចពិនិត្យលក្ខណសម្បត្តិវរជន មន្ត្រីរាជការក្រោមឱវាទ សំរាប់ជ្រើសរើសជាបេក្ខជនស្នើសុំគ្រឿងឥស្សរិយយសទៅតាមប្រភេទ និងវិស័យការងារ ដូចមានចែងក្នុងព្រះរាជក្រឹត្យ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ដែលមានជូនភ្ជាប់មកជាមួយនេះស្រាប់ ក្រោយពេលគណៈកម្មការពិនិត្យជ្រើសរើស និងមានការឯកភាពពីប្រធានស្ថាប័នរួចហើយក្រសួង ស្ថាប័នត្រូវធ្វើ

សំណើ និង បញ្ជីឈ្មោះបេក្ខជន ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុប្រជុំវាយតម្លៃរបស់គណៈកម្មការពិនិត្យលក្ខណសម្បត្តិផង រួចហើយផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និង ដាក់ជូនរាជរដ្ឋាភិបាលសំរេច ។

៣- វរជន មន្ត្រីរាជការ ដែលជ្រើសរើសជាបេក្ខជនត្រូវមានលក្ខណសម្បត្តិធំៗ០៥ ចំណុចដូចខាងក្រោម ៖

ក- សីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តអំពើពុករលួយ និងសកម្មភាពផ្ទុយពីច្បាប់រដ្ឋ។

ខ- គំនិតផ្តួចផ្តើម និងមនសិការវិជ្ជាជីវៈខ្ពស់ សកម្មភាពការងារ ឧស្សាហ៍ព្យាយាម ថ្នៃប្រឌិត និង ទទួលខុសត្រូវ ។

គ- ការដឹកនាំ និងគ្រប់គ្រងមានប្រសិទ្ធភាព ។

ឃ- ស្មារតីស្នេហាជាតិ គិតគូរដល់ផលប្រយោជន៍ជាតិ និងកិត្តិយសរបស់ក្រសួង ស្ថាប័ន ។

ង- សាមគ្គីភាព និងទំនាក់ទំនងល្អជាមួយមហាជន ។

ផ្អែកតាមលក្ខណសម្បត្តិធំៗខាងលើ គណៈកម្មការពិនិត្យលក្ខណសម្បត្តិរបស់ក្រសួង ស្ថាប័ននិមួយៗ ត្រូវបង្កើតលក្ខណៈវិនិច្ឆ័យជាក់ស្តែង ស្របតាមវិស័យការងាររបស់ស្ថាប័នរៀងៗខ្លួន ។

៤- វរជន មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ដែលបំរើការនៅតាមក្រសួង ស្ថាប័ន ហើយបានពិនិត្យជ្រើសរើសជាបេក្ខជនដើម្បីស្នើផ្តល់គ្រឿងឥស្សរិយយស ចាំបាច់ត្រូវគិតទៅតាមទំហំស្នាដៃ និង ឆ្លាស់វេនគ្នាយៈពេល០២ ឆ្នាំម្តង ។

៥- ចំនួនបេក្ខជនប្រចាំឆ្នាំនៃបណ្តាក្រសួងស្ថាប័ននិមួយៗ ដែលស្នើសុំគ្រឿងឥស្សរិយយស ត្រូវកំណត់មិនអោយលើសពី ១០ភាគរយ នៃចំនួនក្របខ័ណ្ឌសរុបរបស់ក្រសួងស្ថាប័នឡើយ ។ ក្នុងចំនួនសមាមាត្រ ១០ភាគរយនេះ ត្រូវជ្រើសរើសពីក្នុងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់០២ ភាគរយ មន្ត្រីក្របខ័ណ្ឌក្រមការ ០៣ ភាគរយ និងក្របខ័ណ្ឌលេខាធិការចំនួន ០៥ ភាគរយ ។

៦- ចំនួនបេក្ខជនដែលស្នើសុំគ្រឿងឥស្សរិយយសក្នុងលំដាប់ឋានានុក្រមខ្ពស់ ត្រូវអោយតិចជាងចំនួនបេក្ខជនដែលស្នើសុំគ្រឿងឥស្សរិយយសក្នុងលំដាប់ឋានានុក្រមទាបជាង។ ក្នុងជំហានដំបូងត្រូវស្នើសុំគ្រឿងឥស្សរិយយសថ្នាក់ទាបសិន មុននិងឈានទៅដល់ថ្នាក់ខ្ពស់ជាបន្តបន្ទាប់ ។ បេក្ខជនដែលជ្រើសរើសសំរាប់ស្នើសុំគ្រឿងឥស្សរិយយសក្នុងស្ថាប័ននិមួយៗគឺគិតតែក្នុងក្របខ័ណ្ឌមុខងារសាធារណៈតែប៉ុណ្ណោះ ។

ចំពោះមន្ត្រីថ្នាក់ដឹកនាំដែលជាសមាជិករាជរដ្ឋាភិបាល និង អនុរដ្ឋលេខាធិការ មិនត្រូវបញ្ចូលមកក្នុងបញ្ជីស្នើគ្រឿងឥស្សរិយយសរបស់មន្ត្រីរាជការមុខងារសាធារណៈនេះទេ គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស របស់រាជរដ្ឋាភិបាល នឹងរៀបចំជូនក្នុងបញ្ជីមួយដោយឡែក ។

៧- វរជន មន្ត្រីរាជការ ដែលបំពេញការងារក្នុងវិស័យនិមួយៗ អាចនឹងទទួលបានគ្រឿងឥស្សរិយយសផ្សេងខុសពីមុខជំនាញរបស់ខ្លួន ប្រសិនជាស្នាដៃ និង គុណបំណាច់នោះបំរើអោយវិស័យដទៃទៀត។ ក្នុងករណីនេះ ប្រធានស្ថាប័នជំនាញ ដែលទទួលបានផលប្រយោជន៍ពីស្នាដៃ និង គុណបំណាច់ខាងលើជាអ្នកធ្វើសំណើសុំមកទីស្តីការណៈរដ្ឋមន្ត្រី ក្រោយពីពិភាក្សាឯកភាពជាមួយស្ថាប័នដែលគ្រប់គ្រងបេក្ខជនផ្ទាល់ ។

- ក្រសួងការពារជាតិ ជាអ្នកធ្វើសំណើសុំគ្រឿងឥស្សរិយយស ជូននាយទាហាន នាយទាហានរង ពលទាហាន និងកងឯកភាពនៃកងយោធពលខេមរភូមិន្ទ ក្រោយពីបានទទួលសំណើតាមឋានានុក្រមពីអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទរួចមក ។

- ក្រសួងស្ថាប័នជំនាញថ្នាក់កណ្តាល និង អាជ្ញាធរមូលដ្ឋានត្រូវមានការឯកភាពគ្នា មុននឹងស្នើសុំគ្រឿងឥស្សរិយយសជូនបេក្ខជន ដែលជាមន្ត្រីរាជការជំនាញនៅមូលដ្ឋាន ដោយក្រសួងស្ថាប័នជាអ្នកធ្វើសំណើ។

- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចពិនិត្យវាយតម្លៃការងាររបស់បណ្តាបុគ្គលិក អង្គទូត និងតំណាងប្រទេសជាមិត្ត ព្រមទាំងតំណាងអង្គការអន្តរជាតិនានាដែលមកបំពេញភារកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមានស្នាដៃ និង គុណបំណាច់ល្អប្រសើរ បំរើអោយផលប្រយោជន៍ប្រជារាស្ត្រខ្មែរដើម្បីស្នើសុំបំពាក់មេដាយសហមេត្រីតាមលំដាប់ថ្នាក់ មុនពេលបញ្ចប់អណត្តិនិមួយៗ ដោយគិតចាប់ពី ៣ ឆ្នាំឡើងទៅ ហើយក៏ត្រូវឯកភាពយល់ព្រមពីភាគីមិត្តជាមុនសិនដែរ មុននឹងស្នើមកទីស្តីការគណៈរដ្ឋមន្ត្រី ។

៨- ដើម្បីអោយស្របតាមព្រះរាជក្រឹត្យ និងអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ១៩៩៤ ចំពោះបែបបទនៃការស្នើសុំមេដាយស្ថាបនាជាតិ ដែលបានអនុវត្តកន្លងមកត្រូវរក្សាការអនុវត្តដដែល ដោយគ្រាន់តែប្តូរឈ្មោះពី ៖

- មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ទៅជា មេដាយមាសស្ថាបនាជាតិ
- មេដាយស្ថាបនាជាតិថ្នាក់លេខ ២ ទៅជា មេដាយប្រាក់ស្ថាបនាជាតិ
- មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ទៅជា មេដាយសំរឹទ្ធស្ថាបនាជាតិ

មេដាយស្ថាបនាជាតិនេះ សំរាប់បំពាក់ជូនតែសប្បុរសជនដែលបានបរិច្ចាគធនធានរបស់ខ្លួនពិតប្រាកដតែប៉ុណ្ណោះ។ ចំពោះមន្ត្រីរាជការដែលបានពាក់ព័ន្ធជាមួយសប្បុរសជនជាអ្នកទាក់ទាញអំណោយពីសប្បុរសជនមិនត្រូវបានទទួលមេដាយខាងលើនេះឡើយ ។

៩- រាល់សំណើសុំគ្រឿងឥស្សរិយយសគ្រប់ប្រភេទ ក្រសួងស្ថាប័ន លុះត្រាតែប្រមុខរាជរដ្ឋាភិបាលចុះហត្ថលេខាលើអនុក្រឹត្យ ឬ ព្រះមហាក្សត្រទ្បាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ ទើបទីស្តីការណៈរដ្ឋមន្ត្រីបើកគ្រឿងឥស្សរិយយសជូនបាន លើកលែងតែក្នុងករណីពិសេស បន្ទាន់ និងចាំបាច់ នាយករដ្ឋមន្ត្រីស្នើរៀបចំពិធីបំពាក់ជាមុន ទើបធ្វើបែបបទស្នើសុំជាក្រោយ ។

១០- គ្រឿងឥស្សរិយយសគ្រប់ប្រភេទ គ្រប់លំដាប់ថ្នាក់ដែលវរជន មន្ត្រីរាជការម្នាក់ៗបានទទួលត្រូវកត់ចូលក្នុងសំណុំឯកសារផ្ទាល់ខ្លួន ហើយត្រូវបានយកមកថ្លឹងថ្លែងជាគុណសម្បត្តិ សំរាប់ការពិចារណាតម្លើងឋានន្តរស័ក្តិ ។

១១- គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវពិនិត្យវាយតម្លៃស្នាដៃឆ្នាំ ២០០០ ជូនមន្ត្រីរាជការក្រោមឱវាទរួចបញ្ជូនសំណើមកទីស្តីការគណៈរដ្ឋមន្ត្រីអោយបានមុនថ្ងៃទី១៥ ខែ មីនាឆ្នាំ ២០០១ដើម្បីបូកសរុបពិនិត្យ និង សំរេច ជូននាឱកាសចូលឆ្នាំខ្មែរប្រពៃណីជាតិ ។ សំណើណាដែលមកក្រោយការកំណត់ខាងលើនេះនឹងមិនត្រូវបានយកមកដោះស្រាយឡើយ ។

១២- បណ្តាក្រសួងស្ថាប័នមានសមត្ថកិច្ចដែលមានគំរោងស្នើសុំគ្រឿងឥស្សរិយយស ត្រូវបញ្ជូនសំណើ និង បញ្ជីឈ្មោះបេក្ខជនអោយមកដល់ទីស្តីការគណៈរដ្ឋមន្ត្រី យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ខែឆ្នាំនិមួយៗ ដើម្បីអាចបូកសរុប ពិនិត្យ និងសំរេច ជូនគ្រឿងឥស្សរិយយសនាឱកាសដំណាច់ឆ្នាំ ។

សារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ១៩៩៧ ត្រូវទុកជានិរាករណ៍ ។

រាជរដ្ឋាភិបាលសង្ឃឹមជឿជាក់ថា គ្រប់ក្រសួង ស្ថាប័ន គ្រប់ជាន់ថ្នាក់ នឹងចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះ ប្រកបដោយស្មារតីយកចិត្តទុកដាក់ យុត្តិធម៌ ត្រឹមត្រូវ ស្មើភាព សំដៅរក្សាអោយបាននូវសុក្រឹតភាព និង តម្លៃ នៃគ្រឿងឥស្សរិយយសរបស់ជាតិ ។

រាជធានីភ្នំពេញ. ថ្ងៃទី១៦ ខែ មករា ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល:

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-គ្រប់ស្ថាប័ន-ក្រសួង-រដ្ឋលេខាធិការដ្ឋាន
-គ្រប់ខេត្ត-ក្រុង
-នាយកដ្ឋានសរុប
-រាជកិច្ច
-កាលប្បវត្តិ -ឯកសារ

❖ សេចក្តីណែនាំ លេខ ៣៣៦ សហវ.ប ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីនីតិវិធីនិងបែបបទនៃការពិនិត្យ វាយតម្លៃលក្ខណសម្បត្តិផ្តល់គ្រឿងឥស្សរិយយស និងមេដាយការងារជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខៈ ៣៣៦ សហវ.ប

# សេចក្តីណែនាំ
# ស្តីពី
# នីតិវិធី និងបែបបទនៃការពិនិត្យ វាយតម្លៃលក្ខណសម្បត្តិផ្តល់គ្រឿងឥស្សរិយយស និងមេដាយការងារ ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បីជាការលើកទឹកចិត្ត ព្រមទាំងចារឹកទុកនូវគុណបំណាច់ និងស្នាដៃដ៏ខ្ពង់ខ្ពស់ របស់មន្ត្រីរាជការនៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរួមចំណែកកសាង និងអភិវឌ្ឍប្រទេស ស្របតាមទំហំស្នាដៃរបស់បុគ្គលម្នាក់ៗ និងដោយគោរពតាមខ្លឹមសារព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំបែបបទ ស្នើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា និងប្រកាសលេខ ១០៨ សហវ.ប្រកប ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស និង មេដាយការងារ ក្រសួងសូមធ្វើការណែនាំដល់គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រោមឱវាទ អំពីនីតិវិធី និងបែបបទ នៃការពិនិត្យ និងវាយតម្លៃ ផ្តល់គ្រឿងឥស្សរិយយស និងមេដាយការងារ ដូចខាងក្រោម ៖

**១-** គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រោមឱវាទក្រសួង ត្រូវបង្កើតឱ្យមានគណៈកម្មការពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិបេក្ខជន ដែលត្រូវរៀបចំ និងមានសមាសភាពដូចខាងក្រោម ៖

**ក- អគ្គនាយកដ្ឋាន** សមាសភាព រួមមាន:

- អគ្គនាយក ប្រធាន
- អគ្គនាយករង សមាជិក
- ប្រធាននាយកដ្ឋានទទួលបន្ទុកការងារបុគ្គលិក សមាជិកអចិន្ត្រៃយ៍

នាយកដ្ឋាន និងសាខា/អង្គភាពចំណុះអគ្គនាយកដ្ឋាន ត្រូវរៀបចំគណៈកម្មការពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិបេក្ខជន ដែលមានសមាសភាពដូចបានកំណត់ក្នុងចំណុច **ខ** និង **គ** ខាងក្រោម ។ បញ្ជីឈ្មោះបេក្ខជនរបស់នាយកដ្ឋាន និងសាខា/អង្គភាព ត្រូវបញ្ជូនមកនាយកដ្ឋានទទួលបន្ទុកកិច្ចការបុគ្គលិក របស់អគ្គនាយកដ្ឋានដើម្បីបូកសរុប និងធ្វើរបាយការណ៍ដាក់ជូនគណៈកម្មការអគ្គនាយកដ្ឋានពិនិត្យ និងសម្រេច មុននឹងបញ្ជូនមកនាយកដ្ឋានបុគ្គលិកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ខ- នាយកដ្ឋាន:** សមាសភាព រួមមាន:

| | |
|---|---|
| - ប្រធាននាយកដ្ឋាន | ប្រធាន |
| - អនុប្រធាននាយកដ្ឋាន | សមាជិក |
| - ប្រធានការិយាល័យ | សមាជិក |

**គ- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ /សាខា/អង្គភាពចំណុះអគ្គនាយកដ្ឋាននៅរាជធានី-ខេត្ត**

សមាសភាព រួមមាន:

| | |
|---|---|
| - ប្រធានមន្ទីរ/សាខា/អង្គភាព | ប្រធាន |
| - អនុប្រធានមន្ទីរ/សាខា/អង្គភាព | សមាជិក |
| - ប្រធានការិយាល័យ/ទីស្នាក់ការ | សមាជិក |

២- ការវាយតម្លៃបេក្ខជន ត្រូវផ្អែកលើលក្ខណសម្បត្តិដូចខាងក្រោម៖

- សីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តអំពើពុករលួយ និង សកម្មភាពផ្ទុយពីច្បាប់រដ្ឋ
- គំនិតផ្តួចផ្តើម និង មនសិការវិជ្ជាជីវៈខ្ពស់ សកម្មការងារ ឧស្សាហ៍ព្យាយាម ថ្មៃប្រឌិត និងទទួលខុសត្រូវខ្ពស់
- ការដឹកនាំ និងគ្រប់គ្រងមានប្រសិទ្ធភាព
- ស្មារតីស្នេហាជាតិ គិតគូរដល់ផលប្រយោជន៍ជាតិ និងកិត្តិយសរបស់អង្គភាពក្រសួង
- សាមគ្គីភាព និងទំនាក់ទំនងល្អជាមួយមហាជនទូទៅ ។

៣- គណៈកម្មការខាងលើ មានភារកិច្ចប្រជុំពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិមន្ត្រីរាជការក្រោមឱវាទសម្រាប់ជ្រើសរើសជាបេក្ខជន ដើម្បីស្នើសុំគ្រឿងឥស្សរិយយស និងមេដាយការងារ ទៅតាមប្រភេទ និងវិស័យការងារ ស្របតាមខ្លឹមសារដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមលំដាប់នៃគ្រឿងឥស្សរិយយស និងមេដាយការងារ ដែលធ្លាប់បានទទួលកន្លងមកក្នុងក្របខ័ណ្ឌការងារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំនួនបេក្ខជនប្រចាំឆ្នាំនៃបណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី-ខេត្ត ត្រូវកំណត់មិនឱ្យលើស ១០% នៃចំនួនក្របខ័ណ្ឌសរុបរបស់អង្គភាពនីមួយៗ និងឆ្លាស់វេនគ្នា រយៈពេល ២ ឆ្នាំម្តង ។

គណកម្មការ អាចធ្វើការពិនិត្យវាយតម្លៃ និងលើកសំណើ ជាករណីពិសេស ដើម្បីស្នើសុំគ្រឿងឥស្សរិយយស និងមេដាយការងារ ផ្តល់ជូនដល់មន្ត្រីរាជការដែលមានស្នាដៃឆ្នើមលេចធ្លោ មន្ត្រីទទួលមរណភាព ឬ បាត់បង់សម្បទាវិជ្ជាជីវៈក្នុងបេសកកម្មការងារ និងមន្ត្រីដែលមានស្នាដៃការងារជាច្រើនឆ្នាំហើយត្រូវដល់អាយុចូលនិវត្តន៍ ។

៤- អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជន មកនាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ៣១ ខែ កក្កដា នៃឆ្នាំនីមួយៗ ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុប្រជុំវាយតម្លៃរបស់គណៈកម្មការនិមួយៗ ។

៥- នាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការបូកសរុប និងធ្វើរបាយការណ៍ ដាក់ជូនគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវស្នើគ្រឿងឥស្សរិយយស និងមេដាយការងារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ៣១ ខែ សីហា នៃឆ្នាំនីមួយៗ ដើម្បីពិនិត្យ និងសម្រេច ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមថា គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រោមឱវាទក្រសួង នឹងចាត់ចែងអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ សំដៅរក្សាបាននូវសុក្រឹតភាព និង តម្លៃនៃគ្រឿងឥស្សរិយយស និងមេដាយការងាររបស់ជាតិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន:**

-ឯកឧត្តមរដ្ឋលេខាធិការ / អនុរដ្ឋលេខាធិការ
-ឯកឧត្តមអគ្គលេខាធិការ / អគ្គលេខាធិការរង
« ដើម្បីជូនជ្រាប »
-គ្រប់អគ្គនាយកដ្ឋាន ព្រមទាំងសាខាគយ និងរដ្ឋាករ សាខាពន្ធដារ រតនាគាររាជធានី ខេត្ត នាយកដ្ឋាន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងអង្គភាព ក្រោមឱវាទក្រសួង
« ដើម្បីផ្សព្វផ្សាយ និងអនុវត្ត »
- ឯកសារ-កាលប្បវត្តិ

# ៩.ការស្ថិតនៅក្រៅក្របខ័ណ្ឌដើម

❖ អនុក្រឹត្យ លេខ ៥០ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ១៩៩៩

# សំរេច

**មាត្រា១** : មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ ហើយត្រូវបានតែងតាំងជាសមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ និងទីប្រឹក្សាគ្រប់ឋានានុក្រមត្រូវដាក់ឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌ នៃក្រសួង ស្ថាប័នដើម។

**មាត្រា២** : មន្ត្រីសាមីត្រូវដាក់ពាក្យសុំតាមឋានានុក្រមទៅបំរើការងារនៅក្រៅក្របខ័ណ្ឌដើមនៅក្រសួង ស្ថាប័នដែលមន្ត្រីសាមីបំពេញការងារកន្លងមក ក្រោយពីពេលទទួលបានការតែងតាំងមុខតំណែង ថ្មីជាផ្លូវការ។

**មាត្រា៣** : មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលមាន ក្របខ័ណ្ឌទាំងអស់ហើយត្រូវបានតែងតាំងក្នុងមុខតំណែង ដូចមានចែងក្នុងមាត្រា១ ត្រូវផ្អាក បៀវត្សពីក្រសួងស្ថាប័នដើម ហើយផ្ទេរបៀវត្សទៅក្រសួង ស្ថាប័ន ដែលត្រូវទៅបំពេញភារកិច្ចក្នុង មុខដំណែង ដោយទទួលបៀវត្សទៅតាមប្រភេទបៀវត្សចុងក្រោយ ព្រមទាំងទទួលប្រាក់បំណាច់ ប្រចាំខែតាមការកំណត់របស់រាជរដ្ឋាភិបាល ។

**មាត្រា៤** : មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដូចមានចែង ក្នុងមាត្រា១ខាងលើ ក្នុងរយៈពេលស្ថិតនៅក្របខ័ណ្ឌដើមនេះ ត្រូវបានគិតអតីតភាពសំរាប់ តំឡើងឋានន្តរស័ក្តិ ឬថ្នាក់ និងគិតអតីតភាពការងារសំរាប់ទទួលសោធននិវត្តន៍ ។

**មាត្រា៥** : មន្ត្រីសាមីដូចមានចែងក្នុងមាត្រា១ ខាងលើត្រូវដាក់ពាក្យសុំចូលបំរើការងារក្នុងក្របខណ្ឌដើម វិញ នៅពេលចប់អាណត្តិ ឬនៅពេលលាឈប់ពីមុខតំណែង ។ ក្រសួងស្ថាប័នសាមីត្រូវទទួល អោយចូលបំរើការងារវិញដោយរក្សាឋានន្តរស័ក្តិនិងថ្នាក់ដែលក្រសួងស្ថាប័ន នៃក្របខ័ណ្ឌដើម បានបន្តរៀបចំជូនដូចមានចែងក្នុងមាត្រា៤ ខាងលើ ។

**មាត្រា៦** : ចំពោះមុខតំណែងជាទីប្រឹក្សា ឬជំនួយការដែលត្រូវបានតែងតាំងបន្ថែមលើមុខតំណែងក្នុងមុខ ងារសាធារណៈនោះ មន្ត្រីសាមីពុំចាំបាច់ដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើមឡើយ ។

**មាត្រា៧** : មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដូចមានចែង ក្នុងមាត្រា ១ ខាងលើដែលកំពុងកាន់មុខតំណែងបច្ចុប្បន្នត្រូវដាក់ពាក្យសុំស្ថិត ក្រៅក្របខ័ណ្ឌ ដើម ដើម្បីបំពេញទំរង់បែបបទអោយស្របតាមខ្លឹមសារនៃអនុក្រឹត្យនេះ។

**មាត្រា៨** : មន្ត្រីដែលកាន់មុខតំណែងដូចមានចែងក្នុងមាត្រា ១ ខាងលើ ពេលដល់អាយុចូលនិវត្តន៍ ត្រូវ បំពេញបែបបទចូលនិវត្តន៍ជូនទៅ ក្រសួង ស្ថាប័នដើម ដូចមន្ត្រីដែលកំពុងបំពេញមុខងារក្នុង ក្របខ័ណ្ឌមុខងារសាធារណៈដែរ ។ មន្ត្រីសាមី នៅតែបន្តការងារក្នុងមុខតំណែងនយោបាយ ដដែលដោយត្រូវទទួលប្រាក់សោធនិវត្តន៍ តាមគោលការណ៍របស់រដ្ឋ និង ទទួលប្រាក់បំណាច់ បន្ថែម នៅក្រសួង ស្ថាប័ន ដែលមន្ត្រីសាមីបំពេញភារកិច្ចក្នុងមុខតំណែង ។ ករណីនេះ ក្រសួង ស្ថាប័ន ត្រូវផ្តល់ជូននូវប្រាក់បន្ថែមនូវប្រាក់កំរៃដូចមន្ត្រីកិច្ចសន្យា ដោយមានទឹកប្រាក់ស្មើនឹង ប្រាក់បៀវត្សចុងក្រោយរបស់មន្ត្រីសាមី។

**មាត្រា៩** : មន្ត្រីដែលចូលនិវត្តន៍រួចហើយៗ ត្រូវបានតែងតាំងក្នុងមុខតំណែងដូចមានចែងក្នុងមាត្រា១ ត្រូវបានទទួលប្រាក់បំណាច់បន្ថែម ព្រមទាំងប្រាក់កំរៃជាមន្ត្រីជាប់កិច្ចសន្យា ដោយមានទឹកប្រាក់ស្មើនឹងប្រាក់បៀវត្សចុងក្រោយរបស់មន្ត្រីសាមី។

**មាត្រា១០** : មន្ត្រីដែលពីមុនពុំស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋ ហើយត្រូវបានតែងតាំងក្នុងមុខតំណែងដូចមានចែងក្នុងមាត្រា១ ត្រូវបានទទួលប្រាក់បំណាច់បន្ថែម និង ទទួលប្រាក់កំរៃជាមន្ត្រីជាប់កិច្ចសន្យាដោយមានទឹកប្រាក់ដែលកំណត់ដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា១១** : ចំពោះមន្ត្រីដែលបំរើការងារក្នុងខុទ្ទកាល័យរបស់ប្រធានស្ថាប័ន រួមមានៈ ទីប្រឹក្សា ជំនួយការនាយកខុទ្ទកាល័យ នាយខុទ្ទកាល័យ និងមន្ត្រីខុទ្ទកាល័យផ្សេងៗទៀត ដូចមានចែងក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាននោះ ត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំពោះមន្ត្រីពីមុនស្ថិតនៅក្រៅក្របខ័ណ្ឌមុខងារសាធារណៈ។ ក្រោយពេលបញ្ចប់ពីមុខតំណែងមន្ត្រីសាមីត្រូវដាក់ពាក្យសុំចូលបំរើការងារក្នុងក្របខ័ណ្ឌដើមវិញ ដោយផ្តល់ជូនឋានន្តរស័ក្តិ-ថ្នាក់ និងប្រភេទកាំបៀវត្សដូចមានចែងក្នុងមាត្រា៥។

ក្នុងរយៈពេលបំពេញការងារក្នុងខុទ្ទកាល័យនេះត្រូវបានគិតអតីតភាពសំរាប់ឡើងឋានន្តរស័ក្តិ ឬថ្នាក់ និងអតីតភាពសំរាប់ទទួលសោធននិវត្តន៍។

**មាត្រា១២** : មន្ត្រីបំរើការងារក្នុងខុទ្ទកាល័យរបស់ក្រសួង ស្ថាប័ន ដែលពីមុនពុំស្ថិតនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ក្រសួងស្ថាប័នសាមីត្រូវផ្តល់បៀវត្សជូនជាមន្ត្រីជាប់កិច្ចសន្យា។ ទឹកប្រាក់នេះអាស្រ័យដោយ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ជាអ្នកកំណត់។

**មាត្រា១៣** : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីជនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយសំរេចចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល:</u>
-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រសួងព្រះបរមរាជវាំង
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចមាត្រា១៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៩៨ ស្តីពីដាក់មន្ត្រីរាជការឲ្យនៅក្រៅក្របខ័ណ្ឌដើមក្នុងពេលទៅបំពេញការងាររៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីដាក់មន្ត្រីរាជការអោយនៅក្រៅក្របខ័ណ្ឌដើម ក្នុងពេលទៅបំពេញការងាររៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៤៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈ ទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ
- តាមសំណើររបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងពិគ្រោះយោបល់ជាមួយគណៈកម្មាធិ ការជាតិរៀបចំការបោះឆ្នោត
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ១៩៩៨

## សំរេច

**មាត្រា ១** : មន្ត្រីរាជការដែលត្រូវបានតែងតាំងជាប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់មានការតែងតាំងថ្មី ។ ក្នុងរយៈពេលនេះសាមីខ្លួន ត្រូវបានរក្សាអតីតភាពការងារសំរាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ។

**មាត្រា ២** : មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកនៃគណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោត មន្ត្រីបំរើអោយគណៈកម្មាធិការជាតិរៀបចំការរបោះឆ្នោត និង មន្ត្រីបំរើអោយគណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់ចប់ភារកិច្ច ។ ក្នុងរយៈពេលនេះសាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ការឡើងថ្នាក់នឹងទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា ៣** : មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់ ថ្ងៃប្រកាសលទ្ធផលបោះឆ្នោតជាស្ថាពរ ។

មន្ត្រីរាជការបំរើអោយគណៈកម្មការឃុំ សង្កាត់រៀបចំ ការបោះឆ្នោតត្រូវដាក់ពាក្យសុំឈប់ពិសេស ទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់ថ្ងៃចប់ភារកិច្ច ។

ក្នុងការឈប់ពិសេសនេះ មន្ត្រីរាជការត្រូវបានរក្សាបៀវត្សអតីតភាពការងារសំរាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ។

**មាត្រា ៤** : មន្ត្រីរាជការដែលត្រូវបានតែងតាំងដោយគណៈកម្មាធិការរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មានសិទ្ធទទួលការអនុញ្ញាតឲ្យឈប់ពីការងារដើម្បីបំរើការរៀបចំការបោះឆ្នោត និងចូលបំរើការងារនៅអង្គភាពដើមវិញក្រោយពីចប់ភារកិច្ច។

លិខិតអនុញ្ញាតឲ្យឈប់សំរាករបស់ក្រសួង ស្ថាប័ន ឬ អង្គភាព ត្រូវចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា៥** : មន្ត្រីរាជការមួយឬពីររូបដែលត្រូវនៅបន្តនិរន្តរ៍ភាពការងារបោះឆ្នោតនៅ គណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោតត្រូវសុំបន្តការងារនៅក្រៅក្របខ័ណ្ឌដើមចាប់ពី ៦០ថ្ងៃ ក្រោយការប្រកាសលទ្ធផលជាស្ថាពររហូតដល់ពេលរៀបចំការបោះឆ្នោតអាណត្តិក្រោយ ។ ក្នុងរយៈពេលនេះ សាមីខ្លួនមានសិទ្ធរក្សាអតីតភាពការងារសំរាប់ឡើងថ្នាក់ និងទទួលសោធន៍ និវត្តន៍។

**មាត្រា៦** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងមន្ត្រីរាជការដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឲ្យបានល្អចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ១៩៩៨

**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

***កន្លែងទទួល:*** **អ៊ឹង ហួត** **ហ៊ុន សែន**

*-ខុទ្ទកាល័យព្រះមហាក្សត្រ*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១*

*-ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី២*

*-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*

*-គ្រប់ក្រសួង - ស្ថាប័ន*

*-ឯកសារ-កាលប្បវត្តិ*

បានយកសេចក្តីសម្រេចជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ និងសម្តេចនាយរដ្ឋមន្ត្រីទី ២

ដើម្បីសូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រី**

ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស្តីទី

**សុខ អាន** **ណាឌី តាន់**

❖ អនុក្រឹត្យ លេខ ៧២ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០១

ស្តីពីការដាក់មន្ត្រីរាជការឱ្យនៅក្រៅក្របខ័ណ្ឌដើមក្នុងពេលបំពេញ

ការងាររៀបចំការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ សង្កាត់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់មន្ត្រីរាជការឱ្យនៅក្រៅក្របខ័ណ្ឌដើមក្នុងពេល បំពេញការងាររៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០៤២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## សំរេច

**មាត្រា ១**.-

មន្ត្រីរាជការដែលត្រូវបានតែងតាំងជាប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់មានការតែងតាំងថ្មី ។ ក្នុងរយៈពេលនេះសាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ។

**មាត្រា ២**.-

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកនៃគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត មន្ត្រីបំរើឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមន្ត្រីបំរើឱ្យ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ចប់ភារកិច្ច ។ ក្នុងរយៈពេលនេះសាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ការឡើងថ្នាក់ និង ទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា ៣**.-

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការ ។ ក្នុងការឈប់ពិសេសនេះសាមីខ្លួនត្រូវបានរក្សាបៀវត្ស អតីតភាពការងារសំរាប់ការឡើងថ្នាក់ និង ទទួលសោធននិវត្តន៍ ។

**មាត្រា៤** .-

មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសជាសមាសភាពការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ចប់ភារកិច្ច ។ ក្នុងការឈប់ពិសេសនេះមន្ត្រីរាជការត្រូវបានរក្សាបៀវត្ស អតីតភាពការងារសំរាប់ការឡើងថ្នាក់ និង ទទួលសោធននិវត្តន៍ ។

**មាត្រា ៥**.-

គ្រប់ក្រសួង ស្ថាប័ន មន្ទីរ ឬអង្គភាពរដ្ឋ ត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរាជការដែល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានជ្រើសរើស និងតែងតាំងឱ្យចូលរួមក្នុងការងារបោះឆ្នោត បានឈប់ពីការងារតាមសំណូមពរ និងបានចូលបំរើការងារនៅអង្គភាពដើមវិញក្រោយពេលចប់ភារកិច្ច។

មន្ត្រីរាជការដែលទទួលបានការជ្រើសរើស និងតែងតាំងដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំចូលបំរើការងារវិញតាមថានានុក្រមនៃក្រសួង ស្ថាប័នសាមី ។

លិខិតអនុញ្ញាតអោយឈប់ពិសេស និងលិខិតអនុញ្ញាតឱ្យចូលបំរើការងារវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ ឬអង្គភាពរដ្ឋ ត្រូវចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៦**.-

មន្ត្រីរាជការ ដែលត្រូវបានចាត់តាំងអោយបន្តនិរន្តរភាពការងារបោះឆ្នោត នៅគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត ត្រូវសុំបន្តការងារនៅក្រៅក្របខ័ណ្ឌដើមចាប់ពី មានសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតតែងតាំង អោយបន្តការងាររហូតដល់ចប់ភារកិច្ច ។ ក្នុងរយៈពេលនេះ សាមីខ្លួនត្រូវបានរក្សា អតីតភាពការងារសំរាប់ឡើងថ្នាក់ និង ទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា៧** .-

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៨** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការ ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្ដីជំរាបជូន**

**សម្ដេចនាយករដ្ឋមន្ត្រី**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**ឆេង ផុន**

***កន្លែងទទួល***

*- ក្រសួងព្រះបរមរាជវាំង*

*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*

*- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*

*- គ្រប់ក្រសួង ស្ថាប័ន*

*- ឯកសារ - កាលប្បវត្តិ*

# ១០.ស្ថានភាពទំនេរគ្មានបៀវត្ស

❖ អនុក្រឹត្យ លេខ ១១៦ អនក្រ.កត ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥

ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ១១៦ អនក្រ.កត

# អនុក្រឹត្យ

ស្តីពី

***ការដាក់មន្ត្រីរាជការស៊ីវិល***
***ឱ្យស្ថិតនៅក្នុងភាពទំនេរ គ្មានបៀវត្ស***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤

-តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គណៈរដ្ឋមន្ត្រីយល់ព្រមផង

# **សំរេច**

## **ជំពូកទី១**

## **បទបញ្ញត្តិទូទៅ**

**មាត្រា ១** : ភាពទំនេរគ្មានបៀវត្ស គឺជាស្ថានភាពរបស់មន្ត្រីរាជការ ដែលបាត់សិទ្ធិទទួលប្រាក់បៀវត្សឡើងឋានន្តរស័ក្តិ ឬថ្នាក់ និងអតីតភាពការងារសំរាប់ទទួលសោធននិវត្តន៍ ។

**មាត្រា ២**: ភាពទំនេរគ្មានបៀវត្សត្រូវប្រកាសដោយ បញ្ញត្តិ ឬត្រូវបានអនុញ្ញាតដោយស្ថាប័នមានសមត្ថកិច្ចក្នុងការ តែងតាំងតាមពាក្យ ស្នើសុំរបស់សាមីជន ។

ការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវសំរេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស ។

## **ជំពូកទី២**

## **ភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ**

**មាត្រា ៣** : ការដាក់មន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរ គ្មានបៀវត្សដោយបញ្ញត្តិ មានករណីដូចតទៅៈ

-មន្ត្រីរាជការដែលបោះបង់ការងារ ឬអវត្តមានដោយគ្មានច្បាប់អនុញ្ញាត រយៈពេល១៥ថ្ងៃជាប់គ្នា លើកលែងតែមន្ត្រីនោះមានករណីពិសេសណាមួយ ។ ក្នុងចន្លោះពេល១៥ថ្ងៃ ដែលអវត្តមាននេះ ប្រធានស្ថាប័ន ត្រូវរំលឹកសាមីខ្លួនយ៉ាងហោចណាស់ពីរដងដែរ ។

-មន្ត្រីរាជការស្ថិតក្នុងការជំនុំជំរះរបស់តុលាការថាមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមហើយដែលបានប្ដឹងឧទ្ធរណ៍ រហូតដល់ថ្ងៃមានសាលក្រមចុងក្រោយបង្អស់ ។

**មាត្រា៤**: រយៈពេលនៃការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ តាមករណីដែលបានបញ្ជាក់នៅក្នុងវាក្យខ័ណ្ឌទី២ នៃមាត្រា ៣ ខាងលើនេះ ពុំអាចលើសពី ៣ ខែ ឡើយ។ ផុតរយៈពេល ៣ ខែ នេះ មន្ត្រីរាជការដែលពុំបានត្រឡប់ទៅបំពេញការងារវិញ ក្រោយពីបានដាក់កំហិតឱ្យចូលធ្វើការតាមការកំណត់ពីរដង ត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌ តែនៅមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ ឬប្រាក់សំណងដែលបានកាត់ទុកពីបៀវត្សតាមករណីនីមួយៗ នៃល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៥៥ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

## **ជំពូកទី៣**

## **ភាពទំនេរគ្មានបៀវត្សដោយមានពាក្យសុំ**

**មាត្រា៥**: ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវបានអនុញ្ញាតតាមពាក្យស្នើសុំរបស់សាមីខ្លួនលើកលែងតែមានការចាំបាច់របស់ក្រសួង ឬស្ថាប័ន ។ ភាពទំនេរគ្មានបៀវត្សនេះមានរយៈពេលម្តងៗមិនតិចជាង ៦ខែ និងមិនលើសពី២ឆ្នាំ ហើយអាចបន្តជាថ្មីសរុបទាំងអស់មិនឱ្យហួសពី៤ឆ្នាំ។

ការដាក់ឱ្យនៅទំនេរគ្មានបៀវត្សនេះ ត្រូវអនុវត្តចំពោះករណីដូចខាងក្រោម

-ដើម្បីទៅធ្វើការនៅក្នុងផ្នែកឯកជន ឬ ធ្វើការងារជាប្រយោជន៍សាធារណៈ ។

-ដើម្បីធ្វើការសិក្សា និងស្រាវជ្រាវនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងទិសដៅបំរើផលប្រយោជន៍ទូទៅ ។

-ដើម្បីជាផលប្រយោជន៍ផ្ទាល់ខ្លួន ។

**មាត្រា៦**: ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវបានអនុញ្ញាតជាចាំបាច់ជូនមន្ត្រីរាជការ ដែលបានដាក់ពាក្យស្នើសុំត្រឹមត្រូវតាមច្បាប់សំរាប់រយៈពេល៣ខែ និងមិនលើសពី២ឆ្នាំ ហើយអាចបន្តជាថ្មីមិនឱ្យហួស ពី៤ឆ្នាំ ចំពោះករណីដូចតទៅ

-សុំទៅថែទាំសហព័ទ្ធ ឬកូនដែលមានជម្ងឺធ្ងន់ ។

-សុំទៅរួមរស់ជាមួយសហព័ទ្ធ ជាមន្ត្រីរាជការក្នុងករណីសុំផ្លាស់មិនទាន់បាន ។

## ជំពូកទី៤
## លក្ខខ័ណ្ឌនៃការចាប់ផ្តើមឈប់ និងការវិលចូលបំរើការងារវិញ

**មាត្រា៧**: ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស តាមពាក្យស្នើសុំរបស់មន្ត្រីរាជការ ចាប់មានប្រសិទ្ធិភាពនៅថ្ងៃទី០១ នៃខែបន្ទាប់ ដែលមានការយល់ព្រមពីថ្នាក់មានសមត្ថកិច្ចសំរេច ។

**មាត្រា៨**: មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ដោយមានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ត្រូវតែដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬចូលបំរើការងាររបស់ខ្លួនវិញឱ្យបាន២ខែ មុនពេលផុតកំណត់នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ឬពុំអាចចូលបំរើការងាររបស់ខ្លួនវិញ នៅថ្ងៃចុងក្រោយនៃភាពទំនេរគ្មានបៀវត្ស ចាត់ទុកថាបោះបង់ចោលការងារ និងត្រូវបានលុបឈ្មោះពីក្របខ័ណ្ឌចាប់ពីថ្ងៃនោះតទៅ ។

**មាត្រា៩**: មន្ត្រីរាជការស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ដែលបានដាក់ពាក្យស្នើសុំច្បាប់ចូលបំរើការងារឡើងវិញ នៅមុនពេលផុតកំណត់ ត្រូវស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស រហូតដល់ពេលណាមានកន្លែងទំនេរសំរាប់ធ្វើការវិញ ។

**មាត្រា១០**:ការចូលបំរើការងារឡើងវិញ គឺជាសិទ្ធិរបស់មន្ត្រីរាជការ ។ មន្ត្រីរាជការចូលបំរើការងារឡើងវិញមានអាទិភាពទទួលកន្លែងទំនេរសមស្រប និងឋានន្តរស័ក្តិរបស់ខ្លួន ។

**មាត្រា១១**: សេចក្តីសំរេចឱ្យចូលបំរើការងារឡើងវិញ ឬ បញ្ឈប់ពីការងាររបស់មន្ត្រីរាជការស្ថិតនៅក្នុងភាពទំនេរគ្មាន បៀវត្សត្រូវបានសំរេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស ។

## ជំពូកទី៥
## អវសានបញ្ញត្តិ

**មាត្រា១២**: ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសដែលដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវធ្វើជា ចាំបាច់ទៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ មួយច្បាប់ ។

**<u>មាត្រា ១៣</u>** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៤**: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

<u>កន្លែងទទួល</u>:
-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ **នរោត្តម រណឬទ្ធិ** **ហ៊ុន សែន**
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
-ដូចមាត្រា១៤

# ១១.ការឈប់សម្រាក

❖ សេចក្តីសំរេច លេខ ៧៣ ស រ ច ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៨២ ស្តីពីម៉ោងធ្វើការ និងពេលឈប់សម្រាករបស់កម្មាភិបាល បុគ្គលិក កម្មករ

**សាធារណរដ្ឋប្រជាមានិតកម្ពុជា**
**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រុមប្រឹក្សារដ្ឋមន្ត្រី**
លេខៈ៧៣ ស រ ច

# សេចក្តីសំរេច
# ស្តីពីពេលម៉ោងធ្វើការ និង ពេលឈប់សំរាករបស់ កម្មាភិបាល បុគ្គលិក កម្មករ

-បានឃើញអង្គការចាត់តាំង និង សកម្មភាព របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ប្រកាសផ្សាយតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០-០២-៨២ នៃ ក្រុមប្រឹក្សារដ្ឋ

-អនុលោមតាមសំណូមពរ របស់រដ្ឋមន្ត្រីក្រសួងផែនការ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី សំរេច

**I-ថេរៈវេលាធ្វើការៈ**

១-ក្នុងក្រសួងមន្ទីរ សហគ្រាសរដ្ឋ ថេរៈវេលាធ្វើការពេញលេញ នៃកម្មាភិបាល បុគ្គលិក កម្មករទាំងពីរភេទ គឺ ប្រាំបីម៉ោង "៨ម៉ោង" ក្នុងមួយថ្ងៃ។

ក-ចំពោះក្រសួង មន្ទីរ "រដ្ឋបាល" ពីមជ្ឈឹមរហូតដល់ក្រុង និង ខេត្តៈ

-ព្រឹក ពីម៉ោងប្រាំពី "៧" ដល់ម៉ោង ដប់មួយនិងសាមសិបនាទី "១១.៣០"។

-ល្ងាច ពីម៉ោង ដប់បួន "១៤" ដល់ម៉ោង ដប់ប្រាំពីរនិងសាមសិបនាទី "១៧.៣០"។

ខ-ចំពោះសហគ្រាស រោងចក្រ អាគារលក់ដូរ ដែលនៅចំណុះក្រសួងមជ្ឈឹម ឬ ចំណុះក្រុង និងខេត្ត របៀបចែកពេលវេលាធ្វើការ ត្រូវកំរិតដោយក្រសួង ក្រុង និងខេត្ត ដែលគ្រប់គ្រងសំរាប់កន្លែងធ្វើការផ្សេងៗ តាមប្រភេទនៃសកម្មភាព និងរបៀបរៀបចំរបស់ខ្លួន។

២-ក្នុងករណីពិសេស ដែលតម្រូវអោយកម្មាភិបាល បុគ្គលិក កម្មករ ធ្វើការខុសពីម៉ោងកំណត់ដូចខាងលើ កម្មាភិបាល បុគ្គលិក កម្មករ ទាំងអស់នោះត្រូវបានឈប់សំរាកនៅថ្ងៃបន្ទាប់ ដើម្បីទូទាត់ស្មើគ្នានឹងពេលសំរាកដែលបានអាក់ខាន។ ក្នុងករណីដែលការឈប់សំរាក ទូទាត់មិនអាចធ្វើបានកម្មាភិបាល បុគ្គលិក កម្មករ នឹងត្រូវបានប្រាក់បន្ថែមតាមអត្រា ដែលតំលើងមួយរយភាគរយ "១០០%" លើកំរិតប្រាក់បំណាច់ប្រចាំជីវភាពប្រចាំថ្ងៃ។

**II-ការឈប់សំរាកប្រចាំសប្តាហ៍ៈ**

១-ក្នុងមួយសប្តាហ៍ កម្មាភិបាល បុគ្គលិក កម្មករ ត្រូវបានសំរាកមួយថ្ងៃដោយមានប្រាក់បំណាច់ប្រចាំជីវភាព។ តាមធម្មតា ថ្ងៃឈប់សំរាកនេះ គឺ ថ្ងៃអាទិត្យ ។

ក្នុងករណីធ្វើផលិតកម្ម តម្រូវអោយធ្វើការថ្ងៃអាទិត្យ ថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ នឹងកំណត់ ថ្ងៃណាមួយក្នុងសប្តាហ៍នេះ។

ក្នុងករណីពិសេស បើថ្ងៃឈប់សំរាកនេះមិនអាចអនុវត្តន៍បានក្នុងសប្តាហ៍នេះទេនោះ កម្មាភិបាល បុគ្គលិក កម្មករ នឹងត្រូវបានប្រាក់បន្ថែមតាមអត្រាដែលតំលើងមួយរយភាគរយ "១០០%" លើកំរិតប្រាក់បំណាច់ប្រចាំជីវភាពប្រចាំថ្ងៃ។

២-ក្រសួង មន្ទីរ ខេត្ត ក្រុង អាចកំណត់អោយអង្គភាពទាំងឡាយដូចខាងក្រោមនេះឈប់សំរាកប្រចាំសប្តាហ៍ ក្រៅពីថ្ងៃអាទិត្យ។

-សណ្ឋាគារ ភោជនីយដ្ឋាន

-មន្ទីរពេទ្យ ឱសថាល័យ ឱសថស្ថាន

-សារពត៌មាន ឃោសនាការ និង ទស្សនីយភាព សារមន្ទីរ និង ពិពរណ៍

-សហគ្រាសដឹកជញ្ជូនជើងគោក ទឹក អាកាស

-ក្រុមហ៊ុនអគ្គីសនី , រដ្ឋាករទឹក

-រោងចក្រនានាដែលផលិតជាប់រហូត ។ល។

## III-ថ្ងៃឈប់បុណ្យ ដែលត្រូវមានប្រាក់បំណាច់ប្រចាំជីវភាព:

១-ថ្ងៃឈប់បុណ្យ ដែលមានប្រាក់បំណាច់ប្រចាំជីវភាពគឺ:

-បុណ្យជាតិ ៧ មករា គឺថ្ងៃទី ៦, ៧ មករា......ពីរថ្ងៃ "២ថ្ងៃ"

-បុណ្យចូលឆ្នាំ គឺ ថ្ងៃទី ១៣,១៤ និង១៥ មេសា......បីថ្ងៃ "៣ថ្ងៃ"

-បុណ្យជ័យជំនះ ១៧ មេសា......មួយថ្ងៃ "១ថ្ងៃ"

-បុណ្យទិវាពលកម្មអន្តរជាតិ គឺ ថ្ងៃទី ១ ឧសភា......មួយថ្ងៃ "១ថ្ងៃ"

-បុណ្យគោរពវិញ្ញាណក្ខ័ន្ធ គឺថ្ងៃទី ខែដាច់ ខែភទ្របទ ផ្នែកចន្ទគតិ

"ភ្ជុំបិណ្ឌ"........................................................មួយថ្ងៃ "១ថ្ងៃ"

ចំពោះកងទ័ព គេអាចរៀបចំពិធីបុណ្យរំលឹកកំណើតកងទ័ព នៅថ្ងៃទី ១៩ ខែ មិថុនា។

២-ថ្ងៃបុណ្យដែលត្រូវឈប់មានប្រាក់បំណាច់ប្រចាំជីវភាពទាំងឡាយខាងលើនេះ មិនត្រូវគិតដើម្បីផ្តាច់ពេលឈប់សំរាកប្រចាំឆ្នាំមានប្រាក់បំណាច់នោះទេ។ បើចាំបាច់ត្រូវធ្វើការក្នុងពេលថ្ងៃបុណ្យ គឺ ត្រូវបានឈប់សំរាកទូទាត់នៅថ្ងៃបន្ទាប់បើក្នុងករណីដែលមិនអាចគិតគូរ ទូទាត់បាន កម្មាភិបាល បុគ្គលិក កម្មករទាំងនោះត្រូវបានប្រាក់បន្ថែម តាមអត្រាតំលើង មួយរយភាគរយ "១០០%" លើកំរិតប្រាក់បំណាច់ប្រចាំជីវភាពប្រចាំថ្ងៃ។

## IV -ការឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់ បំណាច់ប្រចាំជីវភាព:

១-កម្មាភិបាល បុគ្គលិក កម្មករ ទាំងអស់ ត្រូវមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំ មានប្រាក់បំណាច់ប្រចាំជីវភាព ចំនួន ដប់ប្រាំថ្ងៃ "១៥ថ្ងៃ" ក្នុងមួយឆ្នាំ ក្រោយពីបានបំរើក្រសួងបានមួយឆ្នាំរួចមក។

ក្រោយពីបានបញ្ចប់កម្មវិធីសិក្សាក្នុងឆ្នាំនិមួយៗ គ្រូបង្រៀន និង សាស្រ្តាចារ្យត្រូវបានឈប់សំរាកចំនួន ពីរខែ "២ ខែ"។

២-ការឈប់សំរាកប្រចាំឆ្នាំ ដូចបានកំណត់ខាងលើ មិនត្រូវគិតការឈប់សំរាកដោយបណ្តាលមកពីជម្ងឺដែលមានរយៈពេលតិចជាងបីខែក្នុង ១ឆ្នាំ ឬការឈប់សំរាកដែលបានកំណត់រួចហើយ នៃស្រ្តីឆ្លងទន្លេជាកម្មាភិបាល បុគ្គលិក កម្មករ រដ្ឋនោះទេ។

V -**ការឈប់សំរាកពិសេស**

កម្មាភិបាល បុគ្គលិក កម្មករជ្ជ ដែលបានឈប់សំរាកប្រចាំឆ្នាំរួចហើយតែនៅមាន ករណីផ្ទាល់ខ្លួន ដូចជាស្លាប់ឪពុក ម្តាយ ប្រពន្ធ ប្តី កូន និងរៀបមង្គលការកូន ឬសាមីខ្លួនផ្ទាល់ អាចនឹងស្នើសុំឈប់សំរាក ពិសេស ដែលកំណត់ដូចខាងក្រោមនេះ

១-ពី ១ ថ្ងៃ ដល់ ៣ថ្ងៃ ត្រូវមានការយល់ព្រមពីប្រធាន ឬអនុប្រធាន នាយកដ្ឋាន ឬ មុខងារ ប្រហាក់ប្រហែលពីប្រធាននិង អនុប្រធាន មន្ទីរ ក្រុង ឬ ខេត្ត ឬ មុខងារប្រហាក់ប្រហែលពីប្រធាន និង អនុប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុក។

២-ពី ៤ ថ្ងៃ ដល់ ៧ថ្ងៃត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រី ឬ អនុរដ្ឋមន្ត្រីឬ ថ្នាក់ប្រហាក់ប្រហែល ពីប្រធាន ឬ អនុប្រធាន នៃគណៈកម្មាធិការប្រជាជនបដិវត្តនៃ ក្រុង និង ខេត្ត។

VI -**ការអនុវត្តន៍**

១-សេចក្តីសំរេចនេះមាន ប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ដើម្បីជំនួសបទបញ្ញា លើកមុន។

រដ្ឋមន្ត្រី និង ប្រធានមន្ទីរគ្រប់ក្រសួង គ្រប់គណៈកម្មាធិការប្រជាជនបដិវត្តន៍ ក្រុង និង ខេត្ត ត្រូវ ទទួលភារៈរៀងៗខ្លួន ដើម្បីអនុវត្តន៍តាម សេចក្តីសំរេចនេះ។

២-រដ្ឋមន្ត្រី ក្រសួង ផែនការ មានភារៈទទួលខុសត្រូវក្នុងការណែនាំ និង ត្រួតពិនិត្យ ការអនុវត្តន៍ សេចក្តីសំរេចនេះ នៅគ្រប់ក្រសួង មន្ទីរ គ្រប់ក្រុង និងខេត្ត។

ភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៨២
ជ- ក្រុមប្រឹក្សារដ្ឋមន្ត្រី
ប្រធាន
ហត្ថលេខា និង ត្រា
**ចាន់ ស៊ី**

**កន្លែងទទួលៈ**
- រដ្ឋសភា
-ក្រុមប្រឹក្សារដ្ឋ
-គ្រប់ក្រសួង មន្ទីរជុំវិញមជ្ឈឹម
-វិទ្យុសម្លេងប្រជាជនកម្ពុជា
"ដើម្បីផ្សព្វផ្សាយ"
-គ្រប់ក្រុងនិង ខេត្ត
-ឯកសារ

លេខៈ ៦០ ចល
បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ២១ ខែ ៥ ឆ្នាំ ១៩៨២
ជ.រដ្ឋមន្ត្រី ឧទ្ទកាល័យ ក្រុមប្រឹក្សារដ្ឋមន្ត្រី
ឧបការី
ហត្ថលេខា និង ត្រា

**ម្យាស់ លាស់**

ក្រុមប្រឹក្សារដ្ឋមន្ត្រី
ក្រសួងផែនការ
លេខៈ៤៦ ផក-៣១-៥-៨២
បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ជ.រដ្ឋមន្ត្រីក្រសួងផែនការ
**អនុរដ្ឋមន្ត្រី**

❖ សេចក្តីណែនាំលេខ១៣០០ ផក.បព ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៨២ នៃក្រសួងផែនការដើម្បីអនុវត្តសេចក្តីសម្រេច លេខ ៧៣ សរច ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៨២ នៃក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីពេលម៉ោងធ្វើការ និងពេលឈប់សំរាករបស់ កម្មាភិបាល បុគ្គលិក កម្មករ

**ព្រះរាជាណាចក្រកម្ពុជា**
**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រុមប្រឹក្សារដ្ឋមន្ត្រី**
**ក្រសួង ផែនការ**
លេខៈ១៣០០ ផក.បព

**សេចក្តីណែនាំ នៃក្រសួងផែនការ**
**ដើម្បីអនុវត្តន៍សេចក្តីសំរេចលេខ ៧៣ សរច ចុះ**
**ថ្ងៃទី ១៤-០៥-៨២ នៃក្រុមប្រឹក្សារដ្ឋមន្ត្រី**
**ស្តីពីពេលម៉ោងធ្វើការ និង ពេលឈប់សំរាករបស់**

**កម្មាភិបាល បុគ្គលិក កម្មករ ។**

សេចក្តីសំរេចលេខ ៧៣ សរច ចុះ ថ្ងៃទី ១៤-០៥-៨២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មានសារៈសំខាន់បំផុតសំរាប់កំណត់វិន័យធ្វើការងារអោយបានត្រឹមត្រូវ ហើយនិងបង្កលក្ខណៈដើម្បីអោយកម្មាភិបាល បុគ្គលិក កម្មករ អាចឈប់សំរាក និងរួមចំណែកកំសាន្តបុណ្យប្រពៃណីយ៍ជាតិ ។ ការឈប់សំរាកនេះ លើកទឹកចិត្ត និង ជំរុញអោយ កម្មាភិបាល បុគ្គលិក កម្មករខិតខំធ្វើការបន្ថែមទៀត ដើម្បីរួមចំណែកការស្តារ និង កសាងមាតុភូមិជាថ្មីឡើងវិញ ។

ក្រសួង ផែនការ សូមធ្វើសេចក្តីណែនាំបន្ថែម ចំពោះគ្រប់ក្រសួង មន្ទីរ ជុំវិញមជ្ឈឹម ខេត្ត និង ក្រុង ដូចតទៅៈ

<u>I-ថេរៈវេលាធ្វើការៈ</u>

១- ថេរៈវេលាធ្វើការដែលពេលមុននេះកំណត់ ព្រឹកពីម៉ោង ៦.៣០នាទី ដល់ម៉ោង ១១ និង ល្ងាចពីម៉ោង ១៣.៣០នាទី ដល់ម៉ោង ១៧ ត្រូវកែប្រែមកព្រឹកពីម៉ោង ៧ ដល់ម៉ោង ១១.៣០នាទី និងល្ងាច ពីម៉ោង ១៤ ដល់ម៉ោង ១៧.៣០នាទី ហើយថេរៈវេលាធ្វើការនេះតម្រូវអោយក្រសួង មន្ទីរ អង្គភាពរដ្ឋបាល ទាំងអស់អនុវត្តន៍អោយបានល្អត្រឹមត្រូវ ពីមជ្ឈឹមរហូតដល់ស្រុក។

២- ចំពោះអង្គភាពផលិតកម្ម ឬ ជំនួញដូចជារោងចក្រសហគ្រាស ក្រុមហ៊ុនដឹកជញ្ជូន។ល។ ដែលការងារតម្រូវអោយធ្វើជាប់រហូត ពេលវេលាធ្វើការនេះត្រូវរៀបចំទៅតាមប្រភេទសកម្មភាព និង លក្ខណៈជាក់ស្តែងនៃអង្គភាពនីមួយៗ គឺរៀបចំយ៉ាងណាអោយដំណើរប្រព្រឹត្តទៅនៃការងារនេះបានធម្មតា គ្មានដាច់ពេល ។ គំរោងរៀបចំពេលម៉ោងធ្វើការរបស់អង្គភាពនីមួយៗ ក្រសួងសាមីត្រូវផ្ញើមកក្រសួង ផែនការដើម្បីពិនិត្យ និង ឯកភាពគ្នាសំរាប់ណែនាំអនុវត្តន៍បានល្អប្រសើរ ។ ការរៀបចំនោះត្រូវធ្វើយ៉ាងណា អោយរយៈពេលធ្វើការបាន ៤៨ ម៉ោង និងបានសំរាក ២៤ ម៉ោង ក្នុង ១សប្តាហ៍ ។ ថ្ងៃឈប់សំរាកនេះអាច ជាថ្ងៃអាទិត្យ ឬ ថ្ងៃណាមួយ ក្នុងសប្តាហ៍នេះក៏បាន ។

៣- ក្នុងពេលបច្ចុប្បន្ននេះ សារៈសំខាន់បំផុតគឺ យើងត្រូវចេះរៀបចំប្រើប្រាស់ពេលវេលាធ្វើការអោយ បានល្អ និង មានប្រសិទ្ធិភាពដោយយើងចេះបែងចែកនិងចាត់ចែងការងារចំពោះ កម្មាភិបាល បុគ្គលិក កម្មករ អោយបានគ្រប់ៗគ្នា និងធ្វើអោយអ្នកទាំងអស់នោះបំពេញការងារបានលទ្ធផលខ្ពស់ក្នុងក្របខ័ណ្ឌថេរៈវេលា ៨ ម៉ោង ក្នុង ១ ថ្ងៃ ។ ក្នុងករណីដែលគេធ្វើការលើសម៉ោងកំណត់ គេត្រូវបានឈប់សំរាកជំនួសស្មើគ្នានៅ ថ្ងៃបន្ទាប់ ឬ ថ្ងៃណាមួយក្នុងសប្តាហ៍នេះ ។ ប្រាក់ម៉ោងបន្ថែមនឹងអាចអនុញ្ញាតជូន កម្មាភិបាល បុគ្គលិក កម្មករ ដែលធ្វើការលើសម៉ោងកំណត់នេះបានក្នុងករណីដែលមានការងារពិសេសដោយឡែកចាំបាច់បន្ទាន់

ឥតព្រាងទុកជាមុនមិនអាចធ្វើបន្តទៅថ្ងៃក្រោយបាន និង ក្នុងករណីដែលមានកង្វះខាត កម្មាភិបាល បុគ្គលិក កម្មករ ក្រោយពីបានធ្វើការបែងចែកកិច្ចការគ្រប់ៗគ្នាអស់ហើយ។

ប្រាក់ម៉ោងបន្ថែមនេះត្រូវគិតតាមរូបមន្តដូចខាងក្រោមនេះ

$$\text{ប្រាក់បន្ថែមក្នុង ១ ម៉ោង} = \frac{(\text{ប្រាក់បំណាច់ប្រចាំខែ} - \text{ប្រាក់តំបន់})}{\text{២៦ ថ្ងៃ} \times \text{៨ ម៉ោង}} \times ២$$

<u>ឧទាហរណ៍:</u> ១-បុគ្គលិកម្នាក់មានប្រាក់ប្រចាំខែ ខ៤-២=១០០៛ ប្រាក់តំបន់ ៤០ភាគរយ ធ្វើការលើសម៉ោង ៥ម៉ោងក្នុង ១ ខែ ប្រាក់ម៉ោងបន្ថែមរបស់គាត់គឺ: $\left[\frac{(១០០៛ : ៤០)\ ៥}{២៦ \times ៨}\right] \times ២ = ៦៛៧៣$

២-កម្មករម្នាក់មានប្រាក់ប្រចាំខែ គ២-២=១១៥៛ ប្រាក់ ៤០ ភាគរយ ធ្វើការលើសម៉ោង ៧ ម៉ោង ក្នុង ១ ខែ ប្រាក់ម៉ោងបន្ថែមរបស់គាត់គឺ: $\left[\frac{(១១៥៛ : ៤៦)\ ៧}{២៦ \times ៨}\right] \times ២ = ១០៛៨៣$

៤-នៅក្នុងពេលធ្វើការប្រចាំថ្ងៃ ស្ត្រីដែលមានកូនតូចអាយុ ១២ ខែ ចុះ ត្រូវមានសិទ្ធិសំរាក ១ ម៉ោង ក្នុង ១ ថ្ងៃ ដើម្បីបំបៅកូន ។

<u>**II-ការឈប់សំរាកប្រចាំសប្តាហ៍:**</u> តាមគោលការណ៍ ក្រោយពីបានធ្វើការងារអស់រយៈពេល ៤៨ ម៉ោង កម្មាភិបាល បុគ្គលិក កម្មករ ត្រូវបានឈប់សំរាក ១ ថ្ងៃ "២៤ ម៉ោង "ក្នុង ១ សប្តាហ៍ ។

១-ចំពោះក្រសួង មន្ទីរ រដ្ឋបាល តាមធម្មតា ថ្ងៃឈប់សំរាកនេះ គឺ ថ្ងៃអាទិត្យ ។

២-ចំពោះអង្គភាពផលិតកម្ម ឬជំនួញ ។ល។ ក្នុងករណីពិសេស ដោយឡែកឥតព្រាងទុកមុនហើយមិនអាចទូទាត់ជំនួសបាន គឺត្រូវគិតរបបប្រាក់ម៉ោងបន្ថែមដូចចែងខាងលើ ។

<u>**III-ថ្ងៃឈប់បុណ្យ មានប្រាក់បំណាច់ប្រចាំជីវភាព:**</u> ថ្ងៃឈប់បុណ្យទាំង ៨ថ្ងៃដោយមានប្រាក់បំណាច់ប្រចាំជីវភាពក្នុងមួយឆ្នាំនេះ មិនគិតដើម្បីកាត់រយៈពេលឈប់សំរាកប្រចាំឆ្នាំចំនួន ១៥ ថ្ងៃនោះទេ ។

បើសិនជា កម្មាភិបាល បុគ្គលិក កម្មករ ត្រូវបានចាត់តាំងជាផ្លូវការ របស់ក្រសួង ខេត្ត ឬ ក្រុងអោយធ្វើការងារនៅថ្ងៃបុណ្យ ដើម្បីបំរើផលប្រយោជន៍សាធារណៈ កម្មាភិបាល បុគ្គលិក កម្មករ ទាំងនោះត្រូវបានទទួលការឈប់សំរាក ដើម្បីទូទាត់ស្មើគ្នានិង ថ្ងៃដែលបានធ្វើការនៅពេលនោះ ក្នុងសប្តាហ៍បន្ទាប់ ។

បើសិនជាមានករណីចាំបាច់ រហូតមិនអាចឈប់ទូទាត់បាន កម្មាភិបាល បុគ្គលិក កម្មករទាំងនោះត្រូវបានអនុវត្តន៍ប្រាក់បន្ថែមម៉ោងតាមរូបបន្ត ក្នុងជំពូកទី ១ ដែរ ។

<u>**IV -ការឈប់សំរាកប្រចាំឆ្នាំ ដោយមានប្រាក់ បំណាច់ប្រចាំជីវភាព:**</u>

-ការឈប់សំរាក់ប្រចាំឆ្នាំដោយមានប្រាក់បំណាច់ប្រចាំជីវភាពចំនួន ១៥ ថ្ងៃ អាចធ្វើទៅបានលុះត្រាតែ កម្មាភិបាល បុគ្គលិក កម្មករ ទាំងអស់នោះបានចូលបំរើការងារក្នុងក្រសួង ខេត្ត ឬ ក្រុងជាប់រហូតក្នុងរយៈពេលម៉ោងតិច ១២ ខែ ។

-រយៈពេល ១៥ ថ្ងៃ ដែលឈប់សំរាកនេះ មិនរាប់បញ្ចូលថ្ងៃដែលត្រូវឈប់សំរាកប្រចាំសប្តាហ៍ ឬ ថ្ងៃឈប់បុណ្យ មានប្រាក់បំណាច់ប្រចាំជីវភាពដែលមានកំណត់ហើយនោះទេ ហើយក៏មិនរាប់ថ្ងៃធ្វើដំណើរទៅសំរាកដែលមានរយៈពេលលើសពី ១ ថ្ងៃ ឡើងទៅនោះដែរ ។

-កម្មាភិបាល បុគ្គលិក កម្មករ ដែលទៅរៀនមានរយៈពេលវែងមានវិស្សមកាលហើយ មិនត្រូវអនុវត្តន៍ការឈប់សំរាក ១៥ ថ្ងៃនេះទេ។

-ចំពោះអ្នកឈឺ ដែលរយៈពេលឈប់សំរាកព្យាបាលលើសពី ៣ខែ និងស្ត្រីសំរាលកូនដែលឈប់លើសពី ៣ខែ ក៏មិនត្រូវអនុវត្តន៍ការសំរាកប្រចាំឆ្នាំនេះដែរ ។ ក្រសួង មន្ទីរ អង្គភាពនិមួយៗដែលរៀបចំដោះស្រាយការឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់បំណាច់ប្រចាំជីវភាព ត្រូវមានកម្មវិធីប្រចាំឆ្នាំត្រឹមត្រូវចំពោះកម្មាភិបាល បុគ្គលិក កម្មករទាំងអស់ ធ្វើយ៉ាងណាអោយដំណើរសកម្មភាពការងារបានប្រព្រឹត្តទៅជាធម្មតា ជៀសវាងអនុញ្ញាត្តអោយបុគ្គលិក ១ ចំនួន សុំឈប់សំរាកក្នុងពេលជាមួយគ្នាបណ្តាលអោយដំណើរការងារប្រព្រឹត្តទៅរអាក់រអួល ផលិតផលនិងទិន្នផលថយចុះ និង ជៀសវាងទុកអោយបាន ២ ឬ ៣ ឆ្នាំទើបឈប់សំរាក ម្តង ដើម្បីអោយពេលឈប់សំរាកបានយូរ ។

សេចក្តីសំរេចនេះមានគោលដៅអោយ កម្មាភិបាល បុគ្គលិក កម្មករទាំងអស់ដែលបានខិតខំធ្វើការបានឈប់សំរាក ដូច្នេះក្នុងពេលសព្វថ្ងៃនេះ ដែលសភាពការណ៍ប្រទេសយើងកំពុងកសាងឡើងវិញ ការធ្វើដំណើរមិនទាន់បានស្រួលដោយខ្វះមធ្យោបាយដឹកនាំ កម្មាភិបាល បុគ្គលិក កម្មករ គួរតែឈប់សំរាកនៅនឹងកន្លែង ឬ ជិតៗទីកន្លែងស្នាក់នៅ ។ តែក្នុងករណីខ្លះដែល កម្មាភិបាល បុគ្គលិក កម្មករ បានធ្វើការ ១២ ខែ ហើយប្រាថ្នាចង់ទៅលេងជាមួយគ្រួសារឯស្រុកកំណើតដែលនៅឆ្ងាយៗ រដ្ឋនឹងគិតគូរប្រាក់បំណាច់ក្នុងការធ្វើដំណើរនេះ នៅពេលដែលមានសំបុត្រស្នាមបញ្ជាក់ត្រឹមត្រូវ ។

**V -ការឈប់សំរាកពិសេស**

កិច្ចការផ្ទាល់ខ្លួនរបស់ កម្មាភិបាល បុគ្គលិក កម្មករ មានច្រើនជាធម្មតា ដូច្នេះហើយកិច្ចការណាដែលមានគំរោងច្បាស់លាស់ កម្មាភិបាល បុគ្គលិក កម្មករ ម្នាក់ៗត្រូវចេះប្រើប្រាស់ការឈប់សំរាកប្រចាំឆ្នាំនេះដើម្បីដោះស្រាយកិច្ចការផ្ទាល់ខ្លួនទាំងនេះ ។

ពេលដែល កម្មាភិបាល បុគ្គលិក កម្មករ បានឈប់សំរាកប្រចាំឆ្នាំរួចហើយ ហើយមានករណីពិសេសឥតព្រាងទុកជាមុនដែលមានបញ្ជាក់ក្នុងសេចក្តីសំរេចលេខ ៧៣ សរច ចុះថ្ងៃទី ១៤-០៥-៨២ កម្មាភិបាល បុគ្គលិក កម្មករនោះត្រូវបានអនុញ្ញាត្តអោយឈប់សំរាកពិសេសនេះអោយបានត្រឹមត្រូវតាមការកំណត់ នៃសេចក្តីសំរេច ។

**VI -ការអនុវត្តន៍**

សេចក្តីណែនាំបន្ថែមលើសេចក្តីសំរេចលេខ ៧៣ សរច ចុះថ្ងៃទី ១៤-០៥-៨២ ត្រូវអនុវត្តន៍ពីមជ្ឈឹមរហូតដល់ស្រុក ។ ចំពោះយោធា និង នគរបាលវិញ ការអនុវត្តន៍សេចក្តីសំរេចនេះ នឹងមានការណែនាំបន្ថែមជាក់ស្តែង ពីក្រសួងការពារប្រទេស និង ក្រសួងមហាផ្ទៃ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៨២
ជ- រដ្ឋមន្ត្រី ក្រសួង ផែនការ
**អនុរដ្ឋមន្ត្រី**

**ទី យ៉ាវ**

**ចម្លងជូន**
-ខុទ្ទកាល័យ រដ្ឋសភា
-ខុទ្ទកាល័យ ក្រុមប្រឹក្សារដ្ឋ
-ខុទ្ទកាល័យ ក្រុមប្រឹក្សារដ្ឋមន្ត្រី
-គ្រប់ក្រសួងមន្ទីរ ជុំវិញមជ្ឈឹម
-គ្រប់ខេត្ត - ក្រុង
"ដើម្បីផ្សព្វផ្សាយ និង អនុវត្តន៍"
-ឯកសារ

❖ អនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកំណត់រយៈពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ២១ អនក្រ. បក

## អនុក្រឹត្យ
## ស្តីពីការកំណត់រយៈពេលបំពេញការងារប្រចាំសប្តាហ៍
## របស់មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល

-យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**មាត្រា១**. មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញការងារចំនួន ៥ ថ្ងៃ ក្នុងមួយសប្តាហ៍ និង ត្រូវបានអនុញ្ញាតអោយឈប់សំរាកការងារចំនួន ២ ថ្ងៃ ក្នុងមួយសប្តាហ៍ គឺថ្ងៃសៅរ៍ និង ថ្ងៃ អាទិត្យ ។

**មាត្រា២**. មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញការងារអោយបានទៀងទាត់តាមរយៈ ពេលដែលមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ និង ធ្វើការក្នុងមួយថ្ងៃ ចំនួន ៨ ម៉ោងគឺៈ

-ព្រឹកពីម៉ោង ៧ និង ០០នាទី ដល់ម៉ោង ១១ និង ៣០នាទី ។

-ល្ងាចពីម៉ោង ១៤ និង ០០នាទី ដល់ម៉ោង ១៧ និង ៣០នាទី ។

**មាត្រា៣**. រយៈពេលបំរើការងារប្រចាំសប្តាហ៍របស់សាស្រ្តាចារ្យ គ្រូបង្រៀន បុគ្គលិកសិក្សាតាមគ្រឹះស្ថានសិក្សានានា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

**មាត្រា៤**. ប្រតិទិនឈប់សំរាកការងាររបស់មន្ត្រី រាជការស៊ីវិលប្រចាំឆ្នាំ ត្រូវកំណត់ដោយអនុក្រឹត្យ សារាចរ និង លិខិតបទដ្ឋានផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ។

**មាត្រា៥**. បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៦**. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានគ្រប់ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

**នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គនាយកដ្ឋានព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
-ដូចមាត្រា ៦
-កាលប្បវត្តិ -ឯកសារ

❖ អនុក្រឹត្យលេខ ៣៨ អនក្រ.អនក្រ.បក ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ១៩៩៨ របស់រាជរដ្ឋាភិបាល ស្តីពីការសុំច្បាប់ឈប់ពិសេសនៃមន្ត្រីរាជការ ដែលឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ៣៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការសុំច្បាប់ឈប់ពិសេស
## នៃមន្ត្រីរាជការដែលឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ
## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខ ជស រកត ០៨៩៧.១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស រកម ១១៩៧.០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រមលេខ នស រកម ១២៩៧.០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រតាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ១៩៩៨

## **សំរេច**

**មាត្រា១.** អនុលោមតាមព្រះរាជក្រមលេខ នស.រកម.១២៩៧.០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មន្ត្រីរាជការដែលមានចែងក្នុងមាត្រា ៣៥ នៃព្រះរាជក្រមនេះ ដែលគណៈបក្សរបស់ខ្លួនបានជ្រើសរើសជាបេក្ខជនតំណាងរាស្ត្រ មានសិទ្ធិទទួលការអនុញ្ញាតអោយឈប់ពិសេស ដោយរក្សាទុកបៀវត្ស អតីតភាពការងារ និងសោធននិវត្តន៍។ ការឈប់ពិសេសនេះ ត្រូវបញ្ចប់នៅថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោត។

សាមីខ្លួនត្រូវដាក់ពាក្យសុំយ៉ាងតិចប្រាំពីរថ្ងៃ មុនថ្ងៃចាប់ផ្តើមយុទ្ធនាការឃោសនា ជូនអាជ្ញាធរថ្នាក់លើតាមឋានានុក្រម ដែលជាអ្នកចេញច្បាប់អនុញ្ញាតអោយឈប់ ដោយមានសេចក្តីសម្លងមកទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា២.** មន្ត្រីរាជការដែលជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រ ត្រូវដាក់ក្នុងស្ថានភាពក្រៅក្របខ័ណ្ឌដើមក្នុងអំឡុងអាណត្តិជាអ្នកតំណាងរាស្ត្រ។ មន្ត្រីនោះត្រូវធ្វើពាក្យមកក្រសួង ឬ ស្ថាប័នសាមីដែលគ្រប់គ្រងក្របខ័ណ្ឌរបស់ខ្លួន។

**មាត្រា ៣.** ចំពោះបេក្ខជនឈរឈ្មោះតំណាងរាស្ត្រ ដែលជាអនុរដ្ឋលេខាធិការ ត្រូវតែដាក់ពាក្យសុំច្បាប់ឈប់ពិសេសពីនាយករដ្ឋមន្ត្រី ។ ដោយឡែកទីប្រឹក្សាជាមន្ត្រីរាជការ ការឈប់ពិសេសនេះត្រូវសុំទៅប្រធាន ស្ថាប័នតាមការជាក់ស្តែងនីមួយៗ។

**មាត្រា ៤.** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយបានល្អ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៨

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

**អ៊ុង ហួត** **ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ១
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ២
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-គ្រប់ក្រសួង ស្ថាប័ន
-ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២
ដើម្បីចុះហត្ថលេខា

**សហរដ្ឋមន្ត្រី**

ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ស្តីទី**

**សុខ អាន** **ណាឌី តាន់**

# ១២. ការគ្រប់គ្រងវត្ថុមាន និងវិធានការវិន័យ

❖ អនុក្រឹត្យ លេខ ១០ អនក្រ.បក ចុះថ្ងៃទី២៨   ខែមករា   ឆ្នាំ១៩៩៧

ស្តីពីនីតិវិធីនៃការអនុវត្តន៍វិន័យចំពោះមន្ត្រីរាជការស៊ីវិល

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១០ អនក្រ.បក

# អនុក្រឹត្យ
ស្តីពី
## នីតិវិធីនៃការអនុវត្តន៍វិន័យចំពោះមន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០១៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-តាមសំណើរបស់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ដោយមានការយល់ព្រមពីគណៈរដ្ឋមន្ត្រីផង

# សំរេច

## ជំពូកទី១

## កំហុសខាងវិន័យ

**មាត្រា១** : កំហុសខាងវិន័យគឺការកើតឡើងពីការប្រព្រឹត្តិ ដោយចេតនា ឬអចេតនា ការខកខានមិនបានប្រព្រឹត្តិ ការភ្លេចភ្លាំង ការធ្វេសប្រហែស ការខ្ជីខ្ជា និងរាល់ការបំពានទៅលើជំពូកទី ៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣៣ ៣៤ ៣៥ ៣៧ ៣៨ ៣៩ ដែលកំណត់តាមឆន្ទានុសិទ្ធិ នៃអាជ្ញាធរដាក់វិន័យថា ជាការខ្វះខាតក្នុងកាតព្វកិច្ចបំពេញការងារ ។

**មាត្រា២** : រាល់កំហុសខាងវិន័យ ដែលប្រព្រឹត្តដោយអ្នករាជការណាម្នាក់តំរូវអោយរាជការនោះទទួលទណ្ឌកម្មខាងវិន័យ ដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។ កំហុសខាងវិន័យ កំហុសខាងរដ្ឋប្បវេណី និងកំហុសខាងព្រហ្មទណ្ឌមានភាពស្វយ័តរវាងគ្នា ។ ទណ្ឌកម្មរដ្ឋប្បវេណី ឬទណ្ឌកម្មព្រហ្មទណ្ឌ ក៏មានភាពស្វយ័តរវាងគ្នាដែរ ។

## ជំពូកទី២

## និតិវិធីអនុវត្តវិន័យពាក់ព័ន្ធនឹងទណ្ឌកម្មថ្នាក់ទី ១

**មាត្រា៣** : មន្ត្រីរាជការជាប់ចោទប្រកាន់មានសិទ្ធិសុំមើលសំណុំរឿងខ្លួន តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីសហក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ការសុំមើលសំណុំរឿងត្រូវធ្វើឡើងក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីបានទទួលដំណឹងជាផ្លូវការពីប្រធានអង្គភាព ឬ ស្ថាប័នសាមី ។ អ្នកទទួលខុសត្រូវសំណុំរឿងត្រូវរក្សាការសំងាត់នូវឈ្មោះសាក្សី ។ សាមីខ្លួនអាចធ្វើលិខិតត៉វាទៅប្រធានស្ថាប័នក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ ក្រោយពីបានមើលសុំណុំរឿង ។

**មាត្រា៤** : ក្រោយពីបានទទួលការពន្យល់ដោះសា ឬក្នុងករណីដែលគ្មានការដោះសាពីអ្នករាជការក្នុងរយៈពេលកំណត់ដូចខាងលើ ប្រធានស្ថាប័នអាចសំរេចយកចំណុចណាមួយដូចខាងក្រោម :

- ទុកសំណុំរឿងដោយមិនបាច់មានវិធានការបន្តរ
- ធ្វើការស្តីបន្ទោស
- មានវិធានការដាក់ទណ្ឌកម្មខាងវិន័យ ថ្នាក់ទីមួយផ្សេងទៀតតាមនិតិវិធី ។

**មាត្រា៥** : រូបភាពវិន័យស្តីបន្ទោសត្រូវធ្វើជាលិខិតផ្ញើទៅសាមីខ្លួនដោយប្រធានអង្គភាពឬប្រធានស្ថាប័ន ។ លិខិតស្តីបន្ទោសនេះ អស់ប្រសិទ្ធិភាពក្រោយរយៈពេល ១ ឆ្នាំ លើកលែងតែរយៈពេលនោះសាមីខ្លួនបានប្រព្រឹត្តខុសឆ្គងអ្វីមួយបន្ថែមទៀត ។ រូបភាពវិន័យស្តីបន្ទោសដែលមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួនការផ្លាស់ដោយបង្ខំ និងការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ។

ការស្តីបន្ទោសដែលមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំអាចមានប្រសិទ្ធិភាពរយៈពេល ២ ឆ្នាំ ក្នុងករណីសាមីខ្លួនមិនបានប្រព្រឹត្តិខុសថ្មីទៀត ។

ចំពោះការផ្លាស់ដោយបង្ខំសាមីខ្លួនពុំមានសិទ្ធិវិលត្រឡប់មកកាន់តំណែងដើមវិញជាស្វ័យប្រវត្តិ ។

ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ ត្រូវអនុវត្តក្នុងឆ្នាំរហូតដល់ពេលធ្វើតារាងឡើងឋានន្តរស័ក្តិថ្នាក់នៃឆ្នាំបន្ទាប់ ។

ទណ្ឌកម្មនេះនឹងអស់ប្រសិទ្ធិភាពលុះណាតែក្នុងរយៈពេលខាងលើ សាមីខ្លួនពុំបានប្រព្រឹត្តិខុសឆ្គងអ្វីមួយបន្ថែមទៀត ហើយករណីនេះត្រូវបញ្ជាក់ច្បាស់ក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសដាក់ទណ្ឌកម្ម ។

## ជំពូកទី ៣
## នីតិវិធីអនុវត្តវិន័យពាក់ព័ន្ធនឹងទណ្ឌកម្មថ្នាក់ទី ២

**មាត្រា៦** : រូបភាពវិន័យថ្នាក់ទី ២ មាន :

ក. ស្តីបន្ទោសជាទម្ងន់បណ្តាលអោយលុបចេញពីតារាងឡើងឋានន្តរស័ក្តិ ឬ ថ្នាក់បើសិនជាមានចុះឈ្មោះហើយ ឬធ្វើអោយយឺតក្នុងការឡើងឋានន្តរស័ក្តិ ឬថ្នាក់ក្នុងថេរវេលាមួយមានកំណត់តែមិនត្រូវអោយលើសពី២ឆ្នាំក្នុងការតម្លើងឋានន្តរស័ក្តិថ្នាក់តាមវេនជ្រើសរើស ឬ តាមវេនអតីតភាព ។

ខ. ដាក់ឲ្យនៅទំនេរគ្មានបៀវត្ស មិនអោយលើសពី១ឆ្នាំ ។

គ. បន្ថយឋានន្តរស័ក្តិ ឬថ្នាក់ ១ថ្នាក់ ឬច្រើនថ្នាក់ ។

ឃ. ដាក់អោយចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ ។

ង. បណ្តេញចេញពីមុខតំណែងមន្ត្រីរាជការ ។

ការចោទប្រកាន់អំពីកំហុសខាងវិន័យថ្នាក់ទី២ ត្រូវមានការអង្កេតជាមុនសិន ។

ការអង្កេតត្រូវប្រគល់អោយតំណាងប្រធានស្ថាប័នសាមីមួយរូប ឬ ច្រើនរូប ដែលមានឋានន្តរស័ក្តិនិង ថ្នាក់ខ្ពស់ជាងឬមានឋានន្តរស័ក្តិស្មើគ្នា តែមានអតីតភាពការងារច្រើនជាងអ្នករាជការដែលត្រូវជាប់ចោទប្រកាន់។ ក្នុងការអង្កេតសាមីខ្លួន ត្រូវបានអញ្ជើញជាផ្លូវការមកមើលសុំណំរឿងខ្លួន និងតវ៉ាតាមលក្ខខ័ណ្ឌ និងពេលវេលាដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។ ការអង្កេតនេះមានរយៈពេល ២ ខែ យ៉ាងយូរ ។

សំណុំរឿងអង្កេតរួចហើយត្រូវបញ្ជូនទៅប្រធានស្ថាប័ន ដើម្បីពិនិត្យនិងសំរេចថាគួរបញ្ជូនអ្នករាជការជាប់ចោទប្រកាន់នោះឲ្យទៅក្រុមប្រឹក្សាវិន័យ ឬ ក៏សំរេចថាបញ្ឈប់ការចោទប្រកានវិញ ឬដាក់វិន័យត្រឹមថ្នាក់ទី១។ ក្នុងករណីដែលប្រធានស្ថាប័នយល់ថា គួរបន្តការចោទប្រកាន់សំណុំរឿងត្រូវបញ្ជូនទៅក្រុមប្រឹក្សាវិន័យ ។

របាយការណ៍ឬការវាយតំលៃរបស់អធិការដ្ឋាន ឬអគ្គាធិការដ្ឋាន មានលក្ខណៈចាំបាច់សំរាប់ប្រធានស្ថាប័ន ក្នុងករណីដែលការចោទប្រកាន់មិនប៉ះពាល់ដល់អធិការឬអគ្គាធិការ ។

**មាត្រា៧** : ការតែងតាំងក្រុមប្រឹក្សាវិន័យត្រូវសំរេចដោយ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ។ ក្រុមប្រឹក្សាវិន័យត្រូវបានបង្កើតឡើងទៅតាមករណីជាក់ស្តែងនីមួយៗ នៅពេលដែលមានបញ្ហាកើតឡើង ។

**មាត្រា៨** : ក្រុមប្រឹក្សាវិន័យត្រូវមានសមាជិក ៥ រូប :

- អ្នករាជការ ៣នាក់ ចាត់តាំងដោយប្រធានស្ថាប័ន ដែលអ្នករាជការ ជាប់ចោទប្រកាន់នោះនៅក្រោមឱវាទក្នុងនោះម្នាក់បំពេញមុខងារជាប្រធាន ម្នាក់ទៀតបំពេញមុខងារជាសមាជិករាយការណ៍ និងអ្នកទី៣ ជាសមាជិក ។
- អ្នករាជការ ២នាក់ ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នា និងអ្នករាជការជាប់ចោទប្រកាន់ ក៏ប៉ុន្តែមានឋានន្តរស័ក្តិខ្ពស់ជាង ឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា ។

ក្នុងករណីអគ្គនាយក ឬអគ្គាធិការ ត្រូវបញ្ជូនទៅក្នុងក្រុមប្រឹក្សាវិន័យ ក្រុមប្រឹក្សាវិន័យត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្នុងចំណោមមន្ត្រីរាជការ ដែលមានក្របខ័ណ្ឌជាមួយគ្នាមានឋានន្តរស័ក្តិខ្ពស់ជាង ឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា ដែលធ្វើការនៅអង្គភាពផ្សេង នៃស្ថាប័នជាមួយគ្នា ។ ក្នុងករណីពុំមានមន្ត្រីរាជការ ដូចពោលខាងលើរាជរដ្ឋាភិបាលស្នើសុំសំរេចតែងតាំងក្រុមប្រឹក្សាវិន័យ ក្នុងចំណោមមន្ត្រីជាន់ខ្ពស់មកពីស្ថាប័នផ្សេងៗក៏បាន ។

មិនអាចចាត់តាំងអោយចូលក្នុងក្រុមប្រឹក្សាវិន័យនេះបាន អ្នករាជការណា ដែលជាអ្នកធ្វើពាក្យបណ្តឹង ចំពោះអ្នករាជការជាប់ចោទប្រកាន់ ឬជាក្រុមញាតិ រហូតដល់ជួរទី៣ របស់អ្នករាជការជាប់ចោទប្រកាន់នោះ ។

**មាត្រា៩** : ក្រោយពេលក្រុមប្រឹក្សាវិន័យត្រូវបានតែងតាំងរួចហើយ ប្រធានស្ថាប័ន ដែលគ្រប់គ្រងអ្នករាជការនោះ ត្រូវបញ្ជូនសំណុំរឿងទាំងអស់ ពាក់ព័ន្ធនឹងអ្នករាជការជាប់ចោទប្រកាន់ ទៅអោយប្រធានក្រុមប្រឹក្សាវិន័យដែលត្រូវបញ្ជូន ទៅអោយសមាជិករាយការណ៍ ។

**មាត្រា១០** : សមាជិករាយការណ៍ត្រូវអោយអ្នករាជការជាប់ចោទប្រកាន់មើលសំណុំរឿងផ្ទាល់ខ្លួន និងឲ្យផ្តល់នូវបញ្ជីកសិណសាក្សី ព្រមទាំងឈ្មោះតំណាងការពារខ្លួន ។ បន្ទាប់មកសមាជិករាយការណ៍ត្រូវធ្វើអង្កេតស៊ើបសួររឿងនោះដោយ :

- ទាររកសំអាងផ្សេងៗ បើសិនជាការចាំបាច់ ។
- ស្រង់យកចម្លើយរបស់កសិណសាក្សីបើសិនជាមាន ។
- ស្តាប់ការពន្យល់ផ្ទាល់មាត់ និងមតិតំណាងការពារដែលជាអ្នករាជការ ។
- ទទួលយកពាក្យតវ៉ារបស់អ្នករាជការជាប់ចោទប្រកាន់

សមាជិករាយការណ៍ ត្រូវធ្វើរបាយការណ៍ជាលាយល័ក្ខអក្សរពីលទ្ធផលអង្កេតដោយមិនបញ្ចេញយោបល់ផ្ទាល់ខ្លួនក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរ ហើយបញ្ជូនរបាយការណ៍ជាបន្ទាន់ទៅប្រធានក្រុមប្រឹក្សាវិន័យ ។

**មាត្រា១១** : ក្រោយពេលដែលបានទទួលរបាយការណ៍ ក្រុមប្រឹក្សាវិន័យត្រូវកោះប្រជុំយ៉ាងយូរក្នុងរយៈពេល ១៥ថ្ងៃ ។ ក្នុងករណីសំណុំលិខិតមិនទាន់គ្រប់គ្រាន់ ប្រធានអាចបង្គាប់ឲ្យ

សមាជិករាយការណ៍រកព័ត៌មានបន្ថែមទៀត និងពន្យាពេលប្រជុំទៅថ្ងៃក្រោយបាន ព្រមទាំងអាចចាត់វិធានការផ្សេងៗដែលមានសារៈប្រយោជន៍ដើម្បីរកការពិត និងកុំអោយប៉ះពាល់ដល់សេចក្តីវិនិច្ឆ័យរបស់តុលាការ ក្នុងករណីដែលតុលាការបានសំរេចពីមុនមកហើយ ។

ការស្រាវជ្រាវខាងលើនេះ មិនត្រូវអោយលើសពី ២ខែឡើយ ។

ក្នុងករណីចាំបាច់ដែលមានភាពពិបាកក្នុងការស្រាវជ្រាវព័ត៌មានប្រធានក្រុមប្រឹក្សាវិន័យអាចពន្យារពេលប្រជុំបានត្រឹមតែ ២ខែទៀត ។

**មាត្រា១២** : ក្រុមប្រឹក្សាវិន័យបើកការប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ដោយត្រូវតែមានវត្តមានសមាជិកគ្រប់ចំនួន ។ ក្នុងករណីដែលសមាជិកណាមួយអវត្តមាន ដោយមានធុរៈ ប្រធានស្ថាប័ន ត្រូវមានវិធានការបំពេញសមាជិកថ្មី ជំនួសបង្គ្រប់ ។ អ្នករាជការជាប់ចោទប្រកាន់ត្រូវតែចូលបង្ហាញខ្លួនតាមការអញ្ជើញនោះ ។ អ្នករាជការជាប់ចោទប្រកាន់ដែលចូលបង្ហាញខ្លួនតាមការអញ្ជើញ អាចនាំតំណាងការពារខ្លួន ដែលជាអ្នករាជការ និងសាក្សីមកជាមួយ ។

អ្នករាជការជាប់ចោទប្រកាន់នោះ អាចដោះសាបំភ្លឺការពារខ្លួនឯង ឬតាមរយៈតំណាងការពារខ្លួនដោយផ្ទាល់មាត់ ឬដោយលាយលក្ខ័អក្សរ ។

**មាត្រា១៣** : ក្រោយពីពិភាក្សាសាកសួរយកព័ត៌មានចប់សព្វគ្រប់ហើយ ក្រុមប្រឹក្សាវិន័យថយទៅពិគ្រោះពិចារណាសន្និដ្ឋានដោយសម្ងាត់ ។ បន្ទាប់មកក្រុមប្រឹក្សាវិន័យធ្វើការបោះឆ្នោត ដោយសម្ងាត់ជាបន្តបន្ទាប់ ចាប់តាំងពីទណ្ឌកម្មខាងវិន័យកំរិតខ្ពស់បំផុតចុះមក ។ ការបើកសន្លឹកឆ្នោតត្រូវបើកទាំងអស់តែម្តងនៅពេលបោះឆ្នោតតាមកំរិតទណ្ឌកម្មនិមួយៗ រួចហើយបើមានសម្លេងស្មើគ្នាត្រូវបោះឆ្នោតលើកំរិតទណ្ឌកម្មខាងវិន័យនោះម្តងទៀត ។

**មាត្រា១៤** : កំណត់ហេតុលទ្ធផលនៃការពិភាក្សា និងការបោះឆ្នោតសម្ងាត់នេះប្រធានក្រុមប្រឹក្សាវិន័យត្រូវធ្វើភ្លាមរួចបញ្ជូន ទៅប្រធានស្ថាប័នសាមី ព្រមទាំងធ្វើសេចក្តីជូនដំណឹងមួយទៀត ស្តីអំពីកំរិតទណ្ឌកម្មខាងវិន័យ បញ្ជូនទៅសាមីខ្លួន អោយទទួលយកដោយមានចុះហត្ថលេខាបញ្ជាក់មកវិញផង ។ ក្នុងករណី ដែលមន្ត្រីរាជការជាប់ចោទប្រកាន់ មិនព្រមទទួលសេចក្តីជូនដំណឹងនេះទេ ក្រុមប្រឹក្សាវិន័យ ក៏នៅតែមានសិទ្ធិ បញ្ជូនសំណុំរឿងទៅប្រធានស្ថាប័នពិនិត្យនិងសំរេចដោយរាយការណ៍ជាលាយល័ក្ខអក្សរថា សាមីខ្លួនមិនព្រមចុះហត្ថលេខាលើសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាវិន័យទេ ។

**មាត្រា១៥**: ថ្នាក់មានសមត្ថកិច្ចក្នុងការសំរេចដាក់ទណ្ឌកម្មខាងវិន័យមិនចាំបាច់ថាត្រូវតែសំរេចតាមយោបល់របស់ក្រុមប្រឹក្សាវិន័យឡើយ ។ ក្នុងករណីដែលក្រុមប្រឹក្សាវិន័យយល់ឃើញថាមានកំហុស ថ្នាក់មានសមត្ថកិច្ចអាចមិនយកតាមយោបល់របស់ក្រុមប្រឹក្សាវិន័យ ដោយបញ្ជាក់ពីមូលហេតុជាលាយលក្ខ័អក្សរ និងសំរេចដាក់ទណ្ឌកម្មខាងវិន័យថ្នាក់ទី២ ណាមួយស្រាលជាងសំណើរបស់ក្រុមប្រឹក្សាវិន័យ ។

**មាត្រា១៦** : ទណ្ឌកម្មជាស្ថាពរ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ។

## ជំពូកទី៤
## និតិវិធីអនុវត្តវិន័យចំពោះអ្នករាជការជាប់ចោទប្រកាន់ពីបទវិន័យដែលបាត់ខ្លួនរកពុំឃើញ

**មាត្រា១៧** : ក្នុងពេលអនុវត្តន៍វិធីដាក់វិន័យ បើអ្នករាជការជាប់ចោទប្រកាន់បាត់ខ្លួនរកពុំឃើញ ក្នុងរយៈពេល ១៥ថ្ងៃ ជាបន្តបន្ទាប់ក្រោយពីការអញ្ជើញពីរលើក ត្រូវដាក់ឲ្យនៅក្នុងភាពទំនេរគ្មានបៀវត្ស ដោយបញ្ញត្តិ ។ ផុតរយៈពេល ៣ខែ បើសាមីជនជាប់ចោទប្រកាន់នៅតែរកពុំឃើញក្រោយ ពីការជូនដំណឹង ២ដង ត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌ ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៨** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា១៩** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់ រដ្ឋលេខាធិការដ្ឋានត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថ លេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៧

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

បានក្រាបបង្គំទូលថ្វាយ និងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

**រដ្ឋលេខាធិការ**
នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

**ប្រាក់ សុខ**

<u>កន្លែងទទួលៈ</u>
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- ដូចមាត្រា ១៩
- ឯកសារ-កាលប្បវត្តិ

❖ សេចក្តីណែនាំ លេខ ៥១ សហវ សណន.ប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ស្តីពីវិធានការពង្រឹងការគ្រប់គ្រងក្របខ័ណ្ឌនិងវត្តមានមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខៈ ៥១ សហវ. សណន.ប

# សេចក្តីណែនាំ

## ស្តីពី

## វិធានការពង្រឹងការគ្រប់គ្រងក្របខ័ណ្ឌ និង វត្តមានមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ដើម្បីពង្រឹងការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងធានាបាននូវការធ្វើការពេញម៉ោង និងទៀងទាត់របស់មន្ត្រីរាជការស្របតាមបទប្បញ្ញត្តិនៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៦/ន.ស.៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ និង ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំអគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត និង គ្រប់អង្គភាពក្រោមឱវាទក្រសួង អនុវត្តដូចខាងក្រោមៈ

**១-** ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវជំរុញការគ្រប់គ្រងក្របខ័ណ្ឌ និងវត្តមានមន្ត្រីរាជការក្រោមឱវាទឱ្យបានម៉ឺងម៉ាត់ និងហ្មត់ចត់ សំដៅលើកតម្កើងមនសិការវិជ្ជាជីវៈ និងការទទួលខុសត្រូវរបស់មន្ត្រីរាជការដើម្បី ធានាបានប្រសិទ្ធភាពការងាររបស់អង្គភាព។

**២-** ការិយាល័យ ឬ អង្គភាពគ្រប់គ្រងផ្ទាល់ មន្ត្រីរាជការនៅថ្នាក់កណ្តាល នៃអគ្គនាយកដ្ឋាននាយកដ្ឋាន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាខាគយ និងរដ្ឋាករ សាខាពន្ធដារ រតនាគាររាជធានី ខេត្ត និងអង្គភាពក្រោមឱវាទក្រសួង ត្រូវគ្រប់គ្រងបញ្ជីសម្រង់វត្តមានមន្ត្រីរាជការ ផ្អែកតាមគំរូផ្តល់ដោយ

នាយកដ្ឋានបុគ្គលិកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ត្រីរាជការ ត្រូវចុះហត្ថលេខាលើបញ្ជីសម្រង់វត្តមាន សម្រាប់ទាំងពីរពេលនៃម៉ោងធ្វើការនៅរៀងរាល់ថ្ងៃធ្វើការ ។

៣- មន្ត្រីរាជការដែលអវត្តមានដោយគ្មានច្បាប់អនុញ្ញាតរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃ ជាប់គ្នា នឹងត្រូវប្រឈមការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ រយៈពេល ០៣ (បី) ខែ ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ។ ក្នុងករណី មន្ត្រីរាជការនោះមិនបានវិលត្រឡប់មកបំពេញ ការងារវិញនៅពេលផុតកំណត់នៃរយៈពេលដាក់ឱ្យនៅស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ក្រសួងនឹងចាត់វិធានការលុបឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីរាជការ។

៤- នៅរៀងរាល់ដំណាច់ខែ ប្រធានការិយាល័យ និងប្រធានអង្គភាពនៅរដ្ឋបាលថ្នាក់កណ្តាល ដែលទទួលភារកិច្ចគ្រប់គ្រងបញ្ជីសម្រង់វត្តមាន ត្រូវចុះហត្ថលេខា បញ្ជាក់លើបញ្ជីសម្រង់វត្តមានដោយមានការពិនិត្យ និងឯកភាពពីប្រធាននាយកដ្ឋានទទួលបន្ទុក ហើយត្រូវបញ្ជូនបញ្ជីសម្រង់វត្តមាននេះ មកនាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ចម្លងជូននាយកដ្ឋានរដ្ឋបាល និង គ្រប់គ្រង (សម្រាប់អង្គភាពចំណុះអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា) នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ (សម្រាប់អង្គភាពចំណុះអគ្គនាយកដ្ឋាន ពន្ធដារ) និង នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក (សម្រាប់អង្គភាពចំណុះ អគ្គនាយកដ្ឋានរតនាគារជាតិ) យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទី ១ នៃខែបន្ទាប់។

៥- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានសាខាគយ និងរដ្ឋាករ ប្រធានសាខាពន្ធដារ និងប្រធានរតនាគាររាជធានី ខេត្ត ត្រូវចុះហត្ថលេខាបញ្ជាក់ទទួលស្គាល់ លើបញ្ជីសម្រង់វត្តមានប្រចាំខែ និងបញ្ជូនបញ្ជីសម្រង់វត្តមាននេះ មកនាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចម្លងជូននាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង (សម្រាប់អង្គភាពចំណុះអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា) នាយកដ្ឋានបុគ្គលិក និងរដ្ឋបាលហិរញ្ញវត្ថុ(សម្រាប់អង្គភាពចំណុះអគ្គនាយកដ្ឋានពន្ធដារ) និងនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក (សម្រាប់អង្គភាពចំណុះ អគ្គនាយកដ្ឋានរតនាគារជាតិ) យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទី ២ នៃខែបន្ទាប់។

៦- ករណីខកខានមិនបានប្រគល់បញ្ជីសម្រង់វត្តមានតាមការកំណត់ខាងលើ ដោយហេតុកំហុសផ្ទាល់របស់មន្ត្រីទទួលបន្ទុក មន្ត្រីនោះ នឹងត្រូវប្រឈមទណ្ឌកម្មផ្នែករដ្ឋបាលជាយថាហេតុ។

៧- ប្រធានការិយាល័យ ប្រធានអង្គភាពគ្រប់គ្រងបញ្ជីសម្រង់វត្តមាន នៅរដ្ឋបាលថ្នាក់កណ្តាល និង ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានសាខាគយ និងរដ្ឋាករ ប្រធានសាខាពន្ធដារ និង ប្រធានរតនាគាររាជធានី ខេត្ត ត្រូវគ្រប់គ្រង និង រក្សាទុករាល់ឯកសារវត្តមានមន្ត្រីរាជការ និងត្រូវ ទទួលខុសត្រូវចំពោះការក្លែងបន្លំ ឯកសារ និងហត្ថលេខា ។ ក្នុងករណីមន្ត្រីទទួលបន្ទុកត្រូវបាន រកឃើញថាមានកំហុស នឹងត្រូវប្រឈមទណ្ឌកម្មផ្នែករដ្ឋបាល និងព្រហ្មទណ្ឌជាយថាហេតុ។

៨- អគ្គនាយកដ្ឋានព្រមទាំងអង្គភាពក្រោមឱវាទ នាយកដ្ឋាន មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវសហការឱ្យបានជិតស្និទ្ធិជាមួយនាយកដ្ឋានបុគ្គលិក នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាឱ្យដំណើរការគ្រប់គ្រងការត្រួតពិនិត្យក្របខ័ណ្ឌ និងវត្តមាន មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបានប្រសិទ្ធភាពខ្ពស់។

៩- នាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការបូកសរុបរបាយការណ៍អំពីស្ថានភាព នៃការគ្រប់គ្រងក្របខ័ណ្ឌ វត្តមាន និងអវត្តមាន មន្ត្រីរាជការនៅគ្រប់អង្គភាពចំណុះក្រសួង និង ក្នុងករណីចាំបាច់ ត្រូវស្នើវិធានការវិន័យស្រប តាមបទប្បញ្ញត្តិច្បាប់ និងបទបញ្ជាជាធរមានដើម្បីដាក់ ជូនប្រធានស្ថាប័នពិនិត្យ និងសម្រេច។

១០- នាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីចាំបាច់ និង ដោយមានការ អនុញ្ញាតពីប្រធានស្ថាប័ន អាចចុះត្រួតពិនិត្យក្របខ័ណ្ឌ និងស្ថានភាពបំពេញការងារមន្ត្រីរាជការនៅ គ្រប់អង្គភាពក្រោមឱវាទក្រសួងដោយពុំបាច់មានការជូនដំណឹងជាមុន។

គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និង អង្គភាពក្រោម ឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព ខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន:</u>**
-ឯកឧត្តមរដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការ
-ឯកឧត្តមអគ្គលេខាធិការ/អគ្គលេខាធិការរង
"ដើម្បីជូនជ្រាប"
-គ្រប់អគ្គនាយកដ្ឋានព្រមទាំងសាខាគយ និងរដ្ឋាករ សាខាពន្ធដារ រតនាគាររាជធានី ខេត្ត នាយកដ្ឋាន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និង អង្គភាពក្រោមឱវាទក្រសួង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

# ១៣. ការចូលនិវត្តន៍

❖ សារាចរណែនាំ លេខ ០៣ សរ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការដាក់មន្ត្រីរាជការទាំងពីរភេទឲ្យចូលនិវត្តន៍

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៣ សរ

# សារាចរ

## ស្តីពីការដាក់មន្ត្រីរាជការស៊ីវិល
## ទាំងពីរភេទអោយចូលនិវត្តន៍

ផ្អែកតាមខ្លឹមសារនៃព្រះរាជក្រមលេខ ០៦ នស ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រឹត្យលេខ ជសរកត ១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ក្រសួង ស្ថាប័ន មួយចំនួនត្រូវកសាងលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌនីមួយៗ ។ រាជរដ្ឋាភិបាលបានប្រកាសផ្សាយរួចហើយ នូវព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមួយចំនួន ឯលក្ខន្តិកៈដោយឡែកមួយចំនួនទៀត កំពុងតែកសាងឡើងជាបន្តបន្ទាប់ ។ ក្នុងស្ថានភាពដែលយើងពុំទាន់បានធ្វើសមាហរណកម្មក្របខ័ណ្ឌបច្ចុប្បន្នផ្ទេរចូលទៅក្នុងក្របខ័ណ្ឌថ្មី នៃលក្ខន្តិកៈដោយឡែកនោះ ក្រសួង ស្ថាប័ននីមួយៗ ជួបការលំបាកក្នុងការរៀបចំដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ។ ដូចនេះ ដើម្បីអោយស្របនឹងស្ថានភាពជាក់ស្តែង រាជរដ្ឋាភិបាលសូមធ្វើការកំណត់ល័ក្ខខ័ណ្ឌនៃការចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលដូចតទៅ៖

**១-មន្ត្រីដែលដល់អាយុ ៦០ឆ្នាំ ត្រូវចូលនិវត្តន៍:**

ក-មន្ត្រីដែលកំពុងកាន់មុខតំណែងពិតប្រាកដក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធ នៃការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន មានៈ

-អគ្គនាយក - អគ្គលេខាធិការ - អគ្គាធិការ - អភិបាលខេត្ត ក្រុង

-អគ្គនាយករង - អគ្គលេខាធិការរង - អគ្គាធិការរង - អធិការ - ប្រធាននាយកដ្ឋាន - អភិបាលរងខេត្តក្រុង

-អនុប្រធាននាយកដ្ឋាន- អធិការរង -ប្រធានមន្ទីរខេត្ត ក្រុង -អភិបាលស្រុកខ័ណ្ឌ

-និងមុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ។

ខ-មន្ត្រីកំពុងបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ ដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្នចាប់ពី **ក II-៧** ឡើងទៅ ។

គ-មន្ត្រីដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ខ៤ ឬមន្ត្រីដែលមានសញ្ញាប័ត្រសមមូលនឹងបរិញ្ញាប័ត្រឡើងទៅ។

ឃ-មន្ត្រីដែលបំរើការងារក្នុងក្របខ័ណ្ឌគ្រូបង្រៀនរបស់ក្រសួងអប់រំ យុវជន និងកីឡាទាំងអស់ និងគ្រូបង្រៀនអចិន្ត្រៃយ៍នៅតាមសាកលវិទ្យាល័យ មហាវិទ្យាល័យ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងនានា ហើយដែលបានទទួលប្រាក់កំរៃគរុកោសល្យ ។

**២-មន្ត្រីដែលដល់អាយុ ៥៨ឆ្នាំ ត្រូវចូលនិវត្តន៍**

ក-មន្ត្រីដែលកំពុងកាន់មុខតំណែងពិតប្រាកដក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធនៃការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន មានៈ

-ប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល- អភិបាលរងស្រុក ខ័ណ្ឌ- អនុប្រធានមន្ទីរ នៅខេត្ត ក្រុង

-អនុប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល-ប្រធានការិយាល័យនៃមន្ទីរខេត្ត ក្រុង

-អនុប្រធានការិយាល័យនៃមន្ទីរខេត្ត ក្រុង

-និងមុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ។

ខ-មន្ត្រីកំពុងបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ ដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្នចាប់ពី ក II ១០ ដល់ ក II ៨ ។

គ-មន្ត្រីដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ខII ឬ មន្ត្រីដែលមានសញ្ញាប័ត្រសមមូលនឹងសញ្ញាប័ត្រមធ្យមសិក្សាឯកទេស។

**៣-មន្ត្រីដែលដល់អាយុ ៥៥ ឆ្នាំ ត្រូវចូលនិវត្តន៍គឺ:** មន្ត្រីដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ក II-១១ - ខ III - ខ IV - គ I - គ II - គ III និង គ IV ។

៤- ករណីមន្ត្រីដែលមានអាយុ ៥៥ឆ្នាំឡើង ហើយកំពុងកាន់មុខតំណែង ឬមានល័ក្ខខ័ណ្ឌដូចចំណុច១ និង២ ខាងលើ តែមិនទាន់បានដាក់ឱ្យចូលនិវត្តន៍ ត្រូវនៅបន្តការងាររហូតដល់អាយុកំណត់ចូលនិវត្តន៍គឺ ៦០ ឆ្នាំ ឬ ៥៨ ឆ្នាំ ។

បើមានការលំបាកស្មុគស្មាញក្នុងការអនុវត្តន៍ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីពិនិត្យដោះស្រាយ ។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តខ្លឹមសារខាងលើដោយស្មារតីទទួលខុស ត្រូវនិងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួលៈ</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋាន រដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់ខេត្ត ក្រុង
-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ៨០ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨០ អនក្រ បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យ ចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/ ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៩ /អនក្រ /បក ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្ត របបសោធន និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៩ /អនក្រ/បក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០០ ស្តីពីគោលការណ៍ រួមនៃវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១២ ខែ កក្កដា ឆ្នាំ ២០០២

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១** .-

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍តាមអាយុដោយធ្វើការផ្លាស់ប្តូរស្ថានភាពពីមន្ត្រីរាជការ ទៅជានិវត្តន៍ជន ជាពិសេសការផ្លាស់ប្តូរពីការទទួលបៀវត្សនិងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ទៅជាការទទួលប្រាក់សោធននិវត្តន៍ជំនួសវិញ ឲ្យបានទាន់ពេលវេលាដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។

**មាត្រា២**.-

អនុក្រឹត្យនេះ មិនអនុវត្តចំពោះការដាក់ឲ្យចូលនិវត្តន៍តាមការស្នើសុំ ការចូលនិវត្តន៍ដោយបញ្ញត្តិ និងការចូលនិវត្តន៍ដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈទេ។

## ជំពូកទី ២

## ដំណើរការនៃការដាក់ឲ្យចូលនិវត្តន៍តាមអាយុ

**មាត្រា៣**.-

មន្ត្រីរាជការស៊ីវិលទាំងពីរភេទ ត្រូវដាក់ឲ្យចូលនិវត្តន៍ជាកំហិតតាមអាយុ ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ របស់មន្ត្រីរាជការស៊ីវិលទាំងនោះ ។

**មាត្រា៤**.-

ជារៀងរាល់ឆ្នាំគម្រោងផែនការស្ថិតិ និងថវិកា សម្រាប់មន្ត្រីរាជការស៊ីវិល ដែលចូលនិវត្តន៍តាមអាយុត្រូវរៀបចំដោយប្រពន្ធ័ព័ត៌មានវិទ្យា ដើម្បីជួយក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបម្រុងថវិកាសម្រាប់ឆ្នាំបន្ទាប់។ ចំពោះគម្រោងស្ថិតិ និង ថវិកាសម្រាប់មន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ដោយការស្នើសុំដោយប្បញ្ញត្តិ និង ដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈ ជាភារកិច្ចរបស់សាមីក្រសួង ស្ថាប័ននីមួយៗ។

**មាត្រា៥**.-

បញ្ជីរាយនាមមន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍ នៅគ្រប់ក្រសួងស្ថាប័នទាំងអស់ ត្រូវបានបោះពុម្ពដោយប្រព័ន្ធព័ត៌មានវិទ្យាឲ្យបានយ៉ាងតិច ១២ ខែ មុនអាយុចូលនិវត្តន៍ ។ បញ្ជីនេះត្រូវចម្លងជូនសាមីក្រសួង ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា៦**.-

ក្រសួង ស្ថាប័នសាមីទាំងអស់ ត្រូវត្រៀមរៀបចំដាក់មន្ត្រីរាជការស៊ីវិល ក្នុងបញ្ជីឲ្យចូលនិវត្តន៍ស្របតាមនីតិវិធីជាធរមាន ទៅតាមប្រភេទក្របខ័ណ្ឌរបស់សាមីខ្លួននីមួយៗឲ្យបានមុន៦ ខែ នៃអាយុដែលត្រូវចូលនិវត្តន៍។ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាសស្តីពីការដាក់ឱ្យចូលនិវត្តន៍ត្រូវចម្លងជូនក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា៧**.-

ក្នុងករណីយឺតយ៉ាវ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវធ្វើការរំលឹកមួយដងដល់ក្រសួង ស្ថាប័នសាមី ហើយបើនៅតែមានការយឺតយ៉ាវទៀតនោះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវកាត់ឈ្មោះចេញពីតារាងទូទាត់ប្រាក់បៀវត្សជាស្វ័យប្រវត្តិ ហើយសាមីក្រសួង ស្ថាប័ន ត្រូវទទួលខុសត្រូវទាំងស្រុងអំពីបែបបទនៃការដាក់មន្ត្រីរាជការស៊ីវិលរបស់ខ្លួនអោយចូលនិវត្តន៍។

## ជំពូកទី ៣
## អន្តរប្បញ្ញត្តិ

**មាត្រា៨**.-

ចំពោះមន្ត្រីរាជការស៊ីវិលដែលមានអាយុត្រូវចូលនិវត្តិន៍ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះ ចូលជាធរមានរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ការដាក់អោយចូលនិវត្តន៍ត្រូវធ្វើដោយដៃ។

**មាត្រា៩**-

ចំពោះបញ្ជីរាយនាមមន្ត្រីរាជការស៊ីវិលទាំងអស់ដែលមានអាយុចូលនិវត្តន៍នៅឆ្នាំ២០០៣ ត្រូវបោះពុម្ពដោយប្រព័ន្ធព័ត៌មានវិទ្យាអោយបានមុនដំណាច់ខែ សីហា ឆ្នាំ ២០០២។

**មាត្រា១០**-

ចំពោះមន្ត្រីរាជការស៊ីវិលដែលមានអាយុត្រូវចូលនិវត្តន៍ចាប់ពីថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០៣ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៣ ការរៀបចំដាក់ឱ្យចូលនិវត្តន៍ត្រូវធ្វើឱ្យបានមុនថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០២។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា១១**.-

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១២**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួលៈ</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ២២១ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី ការកំណត់កាលបរិច្ឆេទ នៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ២២១ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកំណត់កាលបរិច្ឆេទ នៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តន៍របបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ ស្ដីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តិន៍តាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្ដីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សថ្មី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១**.-

អនុក្រឹត្យនេះមានគោលដៅកំណត់កាលបរិច្ឆេទ នៃការដាក់ចូលនិវត្តិន៍ និងការរៀបចំសោធននិវត្តន៍ចំពោះមន្ត្រីរាជការទាំងឡាយណា ពុំទាន់បានដាក់ឱ្យចូលនិវត្តិន៍ ឬយឺតយូរក្នុងការរៀបចំបែបបទដាក់ឱ្យចូលនិវត្តន៍។

**មាត្រា ២**.-

មន្ត្រីរាជការមុខងារសាធារណៈ ឬមន្ត្រីមុខងារនយោបាយ ដែលមានក្របខ័ណ្ឌមុខងារសាធារណៈដែលបានដល់អាយុចូលនិវត្តន៍ហើយ ប៉ុន្តែនៅពុំទាន់បានដាក់ឱ្យចូលនិវត្តន៍ ឬ យឺតយូរក្នុងការរៀបចំបែបបទដាក់ឱ្យចូលនិវត្តន៍ គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំបែបបទដាក់ឱ្យចូលនិវត្តន៍ឱ្យអស់ យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩។

**មាត្រា ៣**.-

ការរៀបចំសោធននិវត្តន៍ សម្រាប់មន្ត្រីរាជការដូចចែងក្នុងមាត្រា ២ ខាងលើ ត្រូវគិតតាមកាលបរិច្ឆេទនៃថ្ងៃខែឆ្នាំចេញប្រកាស ឬ អនុក្រឹត្យ ឬ ព្រះរាជក្រឹត្យ ស្តីពីការដាក់ឱ្យចូលនិវត្តន៍។

**មាត្រា ៤**.-

ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១០ ទៅ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ឱ្យបានទាន់ពេលវេលាស្របតាមគោលការណ៍ និងនីតិវិធីជាធរមានជាកំហិត។

**មាត្រា ៥**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ១៤. ប្រាក់ឧបត្ថម្ភពេលបញ្ចប់អាជីព

## ១៤.១ ប្រាក់ឧបត្ថម្ភសម្រាប់ការលាឈប់ដោយស្ម័គ្រចិត្ត

- ❖ អនុក្រឹត្យ លេខ ០៥ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩២ ស្តីពី ការកែលម្អរបៀបគ្រប់គ្រងកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

**រដ្ឋកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រុមប្រឹក្សារដ្ឋមន្ត្រី**

លេខៈ០៥ អនក្រ

ភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

**អនុក្រឹត្យ**

**ស្តីពីការកែលំអបៀវត្សកម្មាភិបាល**

**បុគ្គលិក កម្មកររដ្ឋ**

**ក្រុមប្រឹក្សារដ្ឋមន្ត្រី**

-បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

-បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលបានប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

-បានឃើញច្បាប់ស្តីពីការកែប្រែការចាត់តាំងតួនាទី និងភារកិច្ចរបស់ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២

-បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ជា

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩១ ស្តីពីកំរៃម៉ោងបន្ថែម កំរៃគរុកោសល្យសំរាប់បុគ្គលិកសិក្សា និង កំរៃរង់ចាំទទួល និង ប្រគល់កុមារសំរាប់អ្នកគ្រូមត្តេយ្យ

-បានឃើញអនុក្រឹត្យលេខ ០២ អនក្រ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩១ ស្តីពីការកែប្រែមាត្រា ២ នៃអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩១ ស្តីពីកំរៃម៉ោងបន្ថែមកំរៃគរុកោសល្យ សំរាប់បុគ្គលិកសិក្សា និង កំរៃរង់ចាំទទួល និង ប្រគល់កុមារសំរាប់អ្នកគ្រូមត្តេយ្យ

-បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ៨៩ សសរ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៨៣ និង លេខ ១២២ សសរ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៨៤ ស្តីពីប្រព័ន្ធបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

-តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងផែនការ

**សំរេច**

**មាត្រា ១** : តារាងបៀវត្ស "កI" "កII" "កIII" "ខ" និង "គ" នៃសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ៨៩ ស.ស.រ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៨៣ និង លេខ ១២២ ស.ស.រ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ១៩៨៤ ស្តីពីប្រព័ន្ធបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ត្រូវបានកំណត់បរិមាណទឹកប្រាក់ថ្មីតាមប្រភេទ និង កាំនិមួយៗ ដូចមានក្នុងឧបសម្ព័ន្ធជូនជាប់ជាមួយ។

កំរិតប្រាក់បៀវត្សថ្មីខាងលើនេះ បានគិតបញ្ចូលរួចហើយនូវប្រាក់ឧបត្ថម្ភថ្លៃទំនិញ ៩ មុខ "អង្ករ-ប្រេងកាត-បារី-ស្ករស-ទឹកដោះគោ-ត្រីងៀត-អំបិល-សាប៊ូ និង ក្រណាត់" និង ថ្លៃទឹក ថ្លៃអគ្គិសនី។

**មាត្រា២**:ចំពោះរបបឧបត្ថម្ភអ្នកនៅក្នុងបន្ទុករបស់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋនៅរក្សាទុកតែរបបឧបត្ថម្ភកូន និង ប្រពន្ធតែប៉ុណ្ណោះ ដោយត្រូវបំពេញលក្ខខ័ណ្ឌដែលកំពុងអនុវត្តជាធរមានសព្វថ្ងៃនេះ។

កំណត់ប្រាក់ឧបត្ថម្ភកូនម្នាក់ៗចំនួន ២.៥០០៖០០ "ពីរពាន់ប្រាំរយរៀល" ក្នុង ១ ខែ។

កំណត់ប្រាក់ឧបត្ថម្ភប្រពន្ធចំនួន ៣.០០០៖០០ "បីពាន់រៀល" ក្នុង ១ ខែ។

**មាត្រា៣**: កំណត់ប្រាក់កំរៃគរុកោសល្យ និង ប្រាក់កំរៃរង់ចាំទទួល និង ប្រគល់កុមារសំរាប់អ្នកគ្រូមត្តេយ្យដូចខាងក្រោមៈ

<u>១-ប្រាក់កំរៃគរុកោសល្យៈ</u>

| ល.រៈ ឋានានុក្រមបុគ្គលិកសិក្សា | ប្រាក់កំរៃគរុកោសល្យប្រចាំខែ |
|---|---|
| ១.សាស្ត្រាចារ្យថ្នាក់អនុបណ្ឌិតឡើងទៅ | ៣.៥០០៖០០ "បីពាន់ប្រាំរយរៀល" |
| ២.ប្រភេទ ខI | ២.០០០៖០០ "ពីរពាន់រៀល" |
| ៣.ប្រភេទ ខII | ១.៥០០៖០០ "មួយពាន់ប្រាំរយរៀល" |
| ៤.ប្រភេទ ខIII ខIV គI និង គII | ១.២០០៖០០ "មួយពាន់ពីររយរៀល" |

<u>២-ប្រាក់កំរៃរង់ចាំទទួលនិងប្រគល់កុមារសំរាប់អ្នកគ្រូមត្តេយ្យៈ</u>

-កំណត់ ៥០០៖០០ "ប្រាំរយរៀល" ម្នាក់ក្នុងមួយខែ ។

**មាត្រា៤**: កំណត់ប្រាក់ម៉ោងបន្ថែម និង ប្រាក់ប៉ះពាល់សុខភាពសំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋដូចខាងក្រោមៈ

<u>១-ប្រាក់ម៉ោងបន្ថែមៈ</u>

<u>ក-សំរាប់កម្មាភិបាល បុគ្គលិក កម្មករទូទៅៈ</u>

ក១-ប្រាក់ម៉ោងបន្ថែមពេលថ្ងៃៈ កំណត់ស្មើ ១០០ភាគរយ នៃបៀវត្សសុទ្ធសាធ

ក២-ប្រាក់ម៉ោងបន្ថែមពេលយប់ៈ កំណត់ស្មើ ១៥០ភាគរយ នៃបៀវត្សសុទ្ធសាធ

<u>ខ-សំរាប់គ្រូបង្រៀនៈ</u>

| លរ | កំរិតសិក្សា | អនុវិទ្យាល័យ វិទ្យាល័យនិងមធ្យមសិក្សា ឯកទេស | ឧត្តមសិក្សា | ក្រោមឧត្តមសិក្សា |
|---|---|---|---|---|
| | | ប្រាក់ម៉ោងបន្ថែម | ប្រាក់ម៉ោងបន្ថែម | ប្រាក់ម៉ោងបន្ថែម |

| | ឋានានុក្រមគ្រូ | ក្នុង ១ ម៉ោង | ក្នុង ១ ម៉ោង | ក្នុង ១ ម៉ោង |
|---|---|---|---|---|
| ១ | សាស្ត្រាចារ្យថ្នាក់អនុបណ្ឌិតឡើងទៅ | | ១៨០០៖០០<br>មួយពាន់ប្រាំបីរយរៀល | ២.០០០៖០០<br>ពីរពាន់រៀល |
| ២ | ប្រភេទ ខI | ១.៣០០៖០០<br>មួយពាន់បីរយរៀល | ១.៥០០៖០០<br>មួយពាន់ប្រាំរយរៀល | |
| ៣ | ប្រភេទ ខII | ៨០០៖០០<br>ប្រាំបីរយរៀល | | |
| ៤ | គ្រូកីឡាប្រភេទ ខII | ៨០០៖០០<br>ប្រាំបីរយរៀល | ៨០០៖០០<br>ប្រាំបីរយរៀល | |
| ៥ | ប្រភេទ ខIII និង គI ឬ គII | ៥០០៖០០<br>ប្រាំរយរៀល | | |

២-ប្រាក់ប៉ះពាល់សុខភាព:

ក-កំណត់១.៥០០៖០០ «មួយពាន់ប្រាំរយរៀល» ម្នាក់ក្នុង ១ ខែ សំរាប់អ្នកបានទទួលប្រាក់ប៉ះពាល់សុខភាព ២០ភាគរយ ពីមុន។

ខ-កំណត់១.០០០៖០០ «មួយពាន់រៀល»ម្នាក់ក្នុង ១ខែ សំរាប់អ្នកបានទទួលប្រាក់ប៉ះពាល់សុខភាព ១៥ភាគរយ ពីមុន។

គ-កំណត់៥០០៖០០ «ប្រាំរយរៀល» ម្នាក់ក្នុង ១ ខែ សំរាប់អ្នកបានទទួលប្រាក់ប៉ះពាល់សុខភាព ១០ភាគរយ ពីមុន។

**មាត្រា៥**: កំណត់ប្រាក់តំបន់ និង ប្រាក់បំណាច់ភារកិច្ច ដូចតទៅៈ

១-ប្រាក់តំបន់:

កំណត់ប្រាក់តំបន់ស្មើនឹង ១.៥០០៖០០ "មួយពាន់ប្រាំរយរៀល" ក្នុង១ខែចំពោះអ្នកធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាលជំនួសប្រាក់តំបន់ពីមុន។

២-ប្រាក់បំណាច់ភារកិច្ច:

ក-ប្រាក់បំណាច់ភារកិច្ចកម្មាភិបាលគ្រប់គ្រងមន្ទីរពេទ្យ និង សាលារៀនៈ

| លរ | អង្គភាព<br>មុខងារ | សាលារៀន ឬ មន្ទីរពេទ្យធំ | សាលារៀន ឬ មន្ទីរពេទ្យធំ តូច |
|---|---|---|---|
| | | ប្រាក់បំណាច់ភារកិច្ចប្រចាំខែ | ប្រាក់បំណាច់ភារកិច្ចប្រចាំខែ |

| | | | |
|---|---|---|---|
| ១ | នាយកសាលា ឬ ប្រធានមន្ទីរពេទ្យ | ១.០០០៖០០ មួយពាន់រៀល | ៨០០៖០០ ប្រាំបីរយរៀល |
| ២ | នាយករងសាលា ឬ អនុប្រធានមន្ទីរពេទ្យ | ៧០០៖០០ ប្រាំពីររយរៀល | ៦០០៖០០ ប្រាំមួយរយរៀល |
| ៣ | ប្រធានការិយាល័យ | ៦០០៖០០ ប្រាំមួយរយរៀល | ៥០០៖០០ ប្រាំរយរៀល |
| ៤ | អនុប្រធានការិយាល័យ | ៥០០៖០០ ប្រាំរយរៀល | ៤០០៖០០ បួនរយរៀល |

ខ-ប្រាក់បំណាច់ភារកិច្ចអ្នកបើកបររថយន្តជូនថ្នាក់ដឹកនាំជាន់ខ្ពស់:

-កំណត់១.៥០០៖០០ "មួយពាន់ប្រាំរយរៀល" ម្នាក់ក្នុង ១ ខែ សំរាប់អ្នកបានទទួលប្រាក់បំណាច់ភារកិច្ច ៣០ភាគរយ ពីមុន។

-កំណត់១.៣០០៖០០ "មួយពាន់បីរយរៀល" ម្នាក់ក្នុង ១ ខែ សំរាប់អ្នកបានទទួលប្រាក់បំណាច់ភារកិច្ច ២៥ភាគរយ ពីមុន។

-កំណត់១.១០០៖០០ "មួយពាន់មួយរយរៀល" ម្នាក់ក្នុង ១ ខែ សំរាប់អ្នកបានទទួលប្រាក់បំណាច់ភារកិច្ច ២០ភាគរយ ពីមុន។

-កំណត់១.០០០៖០០ "មួយពាន់រយរៀល" ម្នាក់ក្នុង ១ ខែ សំរាប់អ្នកបានទទួលប្រាក់បំណាច់ភារកិច្ច ១៥ភាគរយ ពីមុន។

**មាត្រា៦**:ក្រសួងផែនការត្រូវតាមដានថ្លៃទំនិញដែលមានក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះលើទីផ្សាទីក្រុងភ្នំពេញជាប្រចាំពេលណាកំរិតថ្លៃឡើងលើសពី ១០ភាគរយ គិតជាមធ្យមក្រសួងផែនការត្រូវប្រកាសផ្សាយបរិមាណទឹកប្រាក់ដែលត្រូវថែមទៅលើបៀវត្សទៅតាមសមាមាត្រនៃកំណើននោះ។

**មាត្រា៧**: ប្រាក់សោធននិវត្តន៍ និង ប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មប្រចាំខែរបស់និវត្តជន និង ជនបាត់បង់សមត្ថភាពពលកម្មក៏ត្រូវគិតតាមកំរិតបៀវត្សថ្មីនៃតារាង "កI" "កII" "កIII" "ខ" និង "គ" នៃមាត្រា ១ ខាងលើដែរ។

**មាត្រា៨**: ប្រាក់ឧបត្ថម្ភដល់អ្នកស្ម័គ្រចិត្តសុំឈប់បំរើការងារដើម្បីចេញពីក្របខ័ណ្ឌរដ្ឋ ត្រូវកំណត់ស្មើនឹងប្រាក់បៀវត្សសរុបប្រចាំខែរបស់សាមីខ្លួនគុណនឹងចំនួនឆ្នាំដែលបានបំរើការងារក្នុងរបបនៃរដ្ឋកម្ពុជា។

ប្រាក់ឧបត្ថម្ភនេះត្រូវកំណត់ទាបបំផុតស្មើនឹងបៀវត្ស ៣ ខែ ចំពោះអ្នកបំរើការងរលើសពី ១ ឆ្នាំ និងខ្ពស់បំផុតស្មើនឹងបៀវត្ស ១០ ខែ ចំពោះអ្នកដែលបំរើការងារលើសពី ១០ ឆ្នាំ ។ របៀបគិតផ្តល់ប្រាក់ឧបត្ថម្ភ នេះមិនអនុវត្តចំពោះអ្នកសុំចូលនិវត្តន៍ សុំចូលបាត់បង់សមត្ថភាពពលកម្ម អ្នកដែលឈប់ដោយក្រសួង ឬ ខេត្ត ក្រុង មិនព្រមអោយឈប់ និង អ្នកដែលក្រសួង ខេត្ត ក្រុង ត្រូវបញ្ឈប់ពីការងារដោយសារកំហុស ផ្សេងៗ របស់ខ្លួននោះទេ ។

**មាត្រា៩**: ក្រសួងផែនការ និង ក្រសួងដែលពាក់ព័ន្ធ ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ។

**មាត្រា១០**: រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និង គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា១១**: បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា១២**: អនុក្រឹត្យនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩២ ។

**ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី**
**ប្រធាន**
**ហ៊ុន សែន**

<u>កន្លែងទទួលៈ</u>
-ខុទ្ទកាល័យនៃគណៈកម្មាធិការកណ្ដាល
-ខុទ្ទកាល័យរដ្ឋសភា
-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ "ដើម្បីជ្រាប់ជាពត៌មាន"
-ដូចមាត្រា ១០ "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ

ឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

បៀវត្ស តារាង "ក၊"

| ប្រភេទ \ កាំ | ១ | ២ | ៣ |
|---|---|---|---|
| ក၊-១ | ៧១.០០០៖០០ | | |
| ក၊-២ | ៦៤.៧០០៖០០ | | |
| ក၊-៣ | ៦០.០០០៖០០ | | |
| ក၊-៤ | ៥២.៩០០៖០០ | ៥៥.៣០០៖០០ | ៥៧.៦០០៖០០ |
| ក၊-៥ | ៤៧.៤០០៖០០ | ៤៩.៧០០៖០០ | |
| ក၊-៦ | ៤២.៦០០៖០០ | ៤៤.២០០៖០០ | |
| ក၊-៧ | ៣៩.០០០៖០០ | ៤០.៦០០៖០០ | |
| ក၊-៨ | ៣៥.៥០០៖០០ | ៣៧.១០០៖០០ | |
| ក၊-៩ | ៣២.១០០៖០០ | ៣៣.៦០០៖០០ | |
| ក၊-១០ | ២៨.៥០០៖០០ | ៣០.១០០៖០០ | |
| ក၊-១១ | ២៥.៦០០៖០០ | ២៦.៨០០៖០០ | |

ភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

**អនុរដ្ឋមន្ត្រី**

**ម៉ុន អ៊ុំយ**

ឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

បៀវត្ស តារាង "កII"

| ប្រភេទ \ កាំ | ១ | ២ | ៣ |
|---|---|---|---|
| កII-១ | ៧១.០០០៛០០ | | |
| កII-២ | ៦៤.៧០០៛០០ | | |
| កII-៣ | ៦០.០០០៛០០ | | |
| កII-៤ | ៥២.៩០០៛០០ | ៥៥.៣០០៛០០ | ៥៧.៦០០៛០០ |
| កII-៥ | ៤៧.៤០០៛០០ | ៤៩.៧០០៛០០ | |
| កII-៦ | ៤២.៦០០៛០០ | ៤៤.២០០៛០០ | |
| កII-៧ | ៣៩.០០០៛០០ | ៤០.៦០០៛០០ | |
| កII-៨ | ៣៥.៥០០៛០០ | ៣៧.១០០៛០០ | |
| កII-៩ | ៣២.១០០៛០០ | ៣៣.៦០០៛០០ | |
| កII-១០ | ២៨.៥០០៛០០ | ៣០.១០០៛០០ | |
| កII-១១ | ២៥.៦០០៛០០ | ២៦.៨០០៛០០ | |

ភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

**អនុរដ្ឋមន្ត្រី**

**ម៉ុន អ៊ុំយ**

ឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

បៀវត្ស តារាង "កIII"

| កាំ / ប្រភេទ | ១ | ២ | ៣ |
|---|---|---|---|
| កIII-១ | ៥៥.៣០០៖០០ | ៥៧.៦០០៖០០ | |
| កIII-២ | ៤៧.៤០០៖០០ | ៤៩.៧០០៖០០ | |
| កIII-៣ | ៤២.៦០០៖០០ | ៤៤.២០០៖០០ | |
| កIII-៤ | ៣៩.០០០៖០០ | ៤០.៦០០៖០០ | |
| កIII-៥ | ៣៥.៥០០៖០០ | ៣៧.១០០៖០០ | |
| កIII-៦ | ៣២.១០០៖០០ | ៣៣.៦០០៖០០ | |
| កIII-៧ | ២៨.៥០០៖០០ | ៣០.១០០៖០០ | |
| កIII-៨ | ២៥.៦០០៖០០ | ២៦.៨០០៖០០ | |

ភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

**អនុរដ្ឋមន្ត្រី**

**ប៊ុន អ៊ុយ**

ឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

បៀវត្ស តារាង "ខ"

| កាំ / ប្រភេទ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|
| ខI | ៣២.១០០៛០០ | ៣៤.៧០០៛០០ | ៣៨.១០០៛០០ | ៤១.៥០០៛០០ | ៤៤.៩០០៛០០ | ៤៨.៥០០៛០០ |
| ខII | ២៧.០០០៛០០ | ២៩.២០០៛០០ | ៣១.៩០០៛០០ | ៣៤.៧០០៛០០ | ៣៧.៦០០៛០០ | ៤០.៦០០៛០០ |
| ខIII | ២២.០០០៛០០ | ២៣.៧០០៛០០ | ២៦.០០០៛០០ | ២៨.៣០០៛០០ | ៣០.៦០០៛០០ | ៣៣.៤០០៛០០ |
| ខIV | ១៩.២០០៛០០ | ២០.៦០០៛០០ | ២២.៦០០៛០០ | ២៤.៧០០៛០០ | ២៦.៧០០៛០០ | ២៨.៧០០៛០០ |

ភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

**អនុរដ្ឋមន្ត្រី**

**ប៊ុន អ៊ុយ**

ឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២
តារាងរាយមុខទំនិញត្រូវតាមដានដើម្បីពិនិត្យកែសំរួល
បៀវត្សកម្មាភិបាល បុគ្គលិក កម្មករ រដ្ឋ

| ល.រ | មុខទំនិញ | ផ្សេងៗ |
|---|---|---|
| I | <u>**គ្រឿងឧបភោគ និង បរិភោគៈ**</u> | |
| ១ | អង្ករខ្សាយស្រែលេខ ២ | |
| ២ | ត្រីរស់ស្រស់លេខ ១ | |
| ៣ | សាច់គោលេខ ១ | |
| ៤ | សាច់ជ្រូកលេខ ១ | |
| ៥ | បន្លែ | |
| ៦ | ស្ករត្នោតលេខ ១ | |
| ៧ | អំបិលគ្រួស | |
| ៨ | ផ្លែឈើ | |
| ៩ | អុស | |
| ១០ | ធ្យូង | |
| II | <u>**សំលៀកបំពាក់**</u> | |
| ១ | ក្រណាត់ខោតេហ្គាល់ឡែន | |
| ២ | ក្រណាត់អាវតេតូរ៉ុង | |
| ៣ | ឈ្នួលដេរខោជើងវែង | |
| ៤ | ឈ្នួលដេរអាវដៃវែង | |
| ៥ | ស្បែកជើងផ្ទាត់ | |
| III | <u>**ការស្នាក់នៅ**</u> | |
| ១ | ឈ្នួលផ្ទះ | |
| ២ | ទឹក | |
| ៣ | ភ្លើងអគ្គីសនី | |
| IV | <u>**ទំនិញផ្សេងៗ**</u> | |
| ១ | សាប៊ូម្សៅ | |
| ២ | ប្រេងកាត | |
| ៣ | ប្រេងសាំង | |
| ៤ | ឈ្នួលកាត់សក់ | |

ភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២
ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

**អនុរដ្ឋមន្ត្រី**

**ប៊ុន អ៊ុយ**

ឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

បៀវត្ស តារាង "គ"

| កាំ / ប្រភេទ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|
| គI | ២៦.៤០០៛០០ | ២៨.៦០០៛០០ | ៣១.៤០០៛០០ | ៣៤.៣០០៛០០ | ៣៧.១០០៛០០ | ៤០.០០០៛០០ |
| គII | ២៤.០០០៛០០ | ២៦.៤០០៛០០ | ២៩.៤០០៛០០ | ៣២.៥០០៛០០ | ៣៥.៥០០៛០០ | ៣៨.៥០០៛០០ |
| គIII | ២១.៦០០៛០០ | ២៣.៧០០៛០០ | ២៥.៩០០៛០០ | ២៨.២០០៛០០ | ៣០.៤០០៛០០ | ៣៣.២០០៛០០ |
| គIV | ១៥.៨០០៛០០ | ១៧.២០០៛០០ | ១៩.២០០៛០០ | ២១.០០០៛០០ | ២៣.០០០៛០០ | ២៥.២០០៛០០ |

ភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

**អនុរដ្ឋមន្ត្រី**

**ម៉ិន អ៊ុយ**

## ១៤.២ របបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

❖ អនុក្រឹត្យ លេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការអនុវត្តរបបសោធននិវត្តន៍ និង
# សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល
# នៃព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦ នស ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦/១៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត ០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-តាមសេចក្តីស្នើសុំពីរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៧

# សំរេច

## ជំពូកទី១

## របបសោធននិវត្តន៍

**មាត្រា ១** : អ្នករាជការទាំងពីរភេទ ត្រូវបានទទួលរបបសោធននិវត្តន៍ ប្រចាំខែបាន លុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា៥៤និងមាត្រា៥៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

**មាត្រា២**: អ្នករាជការទាំងពីរភេទ ត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាពស្មើនឹង៨០ភាគរយ នៃបៀវត្សសុទ្ធសាធ របស់សាមីខ្លួន លុះត្រាតែបានបំពេញការងារយ៉ាងតិច៣០ឆ្នាំ ។

ប្រាក់សោធនអតីតភាពនេះ ត្រូវបានអនុវត្តតាមករណីដូចខាងក្រោមៈ

-អ្នករាជការមានអាយុ ៥៥ឆ្នាំ យ៉ាងតិច និងមានអតីតភាពការងារ ៣០ឆ្នាំ យ៉ាងតិច។

-អ្នករាជការដែលមានអតីតភាពការងារ៣០ឆ្នាំឡើងទៅ ហើយបានស្ម័គ្រចិត្តសុំចូលនិវត្តន៍មុនអាយុ ៥៥ឆ្នាំ។

**មាត្រា ៣** : ចំពោះអ្នករាជការដែលបានបំពេញល័ក្ខខ័ណ្ឌចូលនិវត្តន៍ ដូចមានចែងក្នុងមាត្រា១ខាងលើ ហើយមានអតីតភាពការងារ២០ឆ្នាំយ៉ាងតិច ត្រូវបានទទួលប្រាក់សោធននិវត្តន៍ អប្បបរិមាស្មើនឹង៦០ភាគរយ នៃបៀវត្សសុទ្ធសាធរបស់សាមីខ្លួន ។ អ្នករាជការដែលបានបំពេញការងារលើសពី២០ឆ្នាំឡើងត្រូវបានទទួលប្រាក់ សមាមាត្របន្ថែម២ភាគរយក្នុង១ឆ្នាំ លើបៀវត្សសុទ្ធសាធរបស់សាមីខ្លួន ។ ប្រាក់សោធននិវត្តន៍សមាមាត្រនេះ ត្រូវបានគិតតាមករណីពីរយ៉ាងដូចខាងក្រោមៈ

១-មិនត្រូវខ្ពស់ជាងប្រាក់សោធននិវត្តន៍ អតីតភាព ៨០ ភាគរយឡើយ ។

២-មិនត្រូវទាបជាងប្រាក់បៀវត្សអប្បបរមាសុទ្ធសាធប្រចាំខែ នៃតារាងកាំប្រាក់របស់សាមីខ្លួនឡើយ។

**មាត្រា៤** : ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗ ត្រូវបានគិតបន្ថែមប្រាក់តំបន់នៅតាមតំបន់ដែលសាមីខ្លួនរស់នៅ ប្រាក់ប៉ះពាល់សុខភាព ចំពោះអ្នករាជការដែលធ្វើការងារធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាព ដូចពេលកំពុងបំរើការងារមុនពេលចូលនិវត្តន៍ ប្រាក់ឧបត្ថម្ភប្រពន្ធកូន ក្រោមអាយុ១៥ឆ្នាំ និងចាប់ពីអាយុ១៥ឆ្នាំ ឡើងទៅ ត្រូវមានលិខិតបញ្ជាក់ការសិក្សាពីស្ថាប័នមានសមត្ថកិច្ច និងប្រាក់ឧបត្ថម្ភផ្សេងៗទៀតដែលរដ្ឋបានកំណត់ ។

**មាត្រា ៥** : អ្នករាជការដែលត្រូវបានក្រសួង ស្ថាប័ន ប្រកាសចូលនិវត្តន៍ ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងបៀវត្សសរុបប្រចាំខែចំនួន ៨ខែ ។

**មាត្រា៦**: អ្នករាជការដែលមានអាយុគ្រប់ចូលនិវត្តន៍ ប៉ុន្តែមានអតីតភាពការងារតិចជាង២០ឆ្នាំ មិនត្រូវផ្តល់ប្រាក់សោធននិវត្តន៍ឡើយ ។ ក្នុងករណីនេះ រដ្ឋផ្តល់ប្រាក់ឧបត្ថម្ភជាប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកនិងប្រាក់ឧបត្ថម្ភផ្សេងៗទៀតតែមួយលើក ។ ប៉ុន្តែនៅពេលមិនទាន់បានបង្កើតបេឡាសោធននិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈ រដ្ឋត្រូវចំណាយប្រាក់ឧបត្ថម្ភនេះ ដោយគិត

តាមចំនួនឆ្នាំ ដែលសាមីខ្លួនបានបំរើការងាររដ្ឋ រហូតដល់ថ្ងៃបញ្ឈប់ពីការងារ។ ប្រាក់ឧបត្ថម្ភនេះ ត្រូវគិតតាមចំនួនឆ្នាំដែលបំរើការងាររដ្ឋ ដោយកំណត់ទាបបំផុតស្មើនឹងបៀវត្សសរុបប្រចាំខែរបស់សាមីខ្លួនគុណនឹង៤ ហើយខ្ពស់បំផុតស្មើនឹងបៀវត្សសរុបប្រចាំខែរបស់សាមីខ្លួនគុណនឹង១០។

**មាត្រា៧**: ពោះអ្នករាជការដែលដល់អាយុចូលនិវត្តន៍ និងមានអតីតភាពការងារគ្រប់៣០ឆ្នាំ ដូចមានចែងក្នុងមាត្រា ៥៦ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ហើយត្រូវបានរដ្ឋអនុញ្ញាតឱ្យបន្តការងារបន្ថែមទៀត មិនត្រូវកាត់ទុកប្រាក់សោធននិវត្តន៍ទៀតឡើយ ។

**មាត្រា៨**: របៀបគិតអតីតភាពការងាររបស់អ្នករាជការ ត្រូវបានកំណត់ដូចខាងក្រោមៈ

រយៈពេលបំរើការងាររួមនៃអ្នករាជការស៊ីវិល គឺជារយៈពេលបំរើការងាររដ្ឋគ្រប់របបសង្គម ។ ដោយឡែក ចំពោះអ្នករាជការដែលធ្លាប់បានបំរើការងាររដ្ឋមុនឆ្នាំ១៩៧៥ ហើយពុំបានបំរើការងារក្នុងរបបប៉ុលពត ក៏ត្រូវបានគិតបន្ថែមរយៈពេលបំរើការងារ ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ ថែមទៀតដែរ ។

រយៈពេលបំរើការងារនៃអ្នករាជការស៊ីវិលរួមមានៈ

-រយៈពេលបំរើការងារ ក្នុងក្របខ័ណ្ឌពេញសិទ្ធិ នៅតាមក្រសួង ស្ថាប័ននានារបស់រដ្ឋ

-រយៈពេលធ្វើកម្មសិក្សា ឬ បណ្តុះបណ្តាលមុខវិជ្ជាជីវៈ ក្នុង ឬ ក្រៅប្រទេសរបស់អ្នករាជការ ក្នុងក្របខ័ណ្ឌរដ្ឋ

-រយៈពេលដែលរដ្ឋចាត់ឱ្យទៅបំរើការងារនៅក្រៅប្រទេស

-រយៈពេលឃាត់ ឬ ឃុំខ្លួន តែក្រោយមករកកំហុសពុំឃើញ

-រយៈពេលបំរើការងារ ក្នុងកងយោធពលខេមរភូមិន្ទ និង នគរបាលជាតិ

-រយៈពេលធ្វើកម្មសិក្សា មុនបញ្ចូលក្របខ័ណ្ឌពេញសិទ្ធិ

មិនត្រូវចាត់ទុកជារយៈពេលបំរើការងារ គឺរយៈពេលត្រូវបានអនុញ្ញាតឱ្យឈប់ទំនេរដោយមិនទទួលបៀវត្ស ។

**មាត្រា៩**: អ្នករាជការស៊ីវិលទាំងពីរភេទ ដែលមានអាយុលើសពី៥៥ឆ្នាំ អាចបន្តការងារបានលុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌក្នុងមាត្រា ៦៣ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនិងអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៦ ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យមន្ត្រីរាជការស៊ីវិល ដែលស្នើសុំពន្យាពេលចូលនិវត្តន៍ ។

**មាត្រា១០**: នៅពេលនិវត្តជនទទួលមរណៈភាព គ្រួសារនៃសពត្រូវបានរដ្ឋ ផ្តល់ប្រាក់ឧបត្ថម្ភមួយលើកចំនួន១២ខែ លើប្រាក់សោធននិវត្តន៍សរុបប្រចាំខែរបស់សាមីខ្លួន ដើម្បីធ្វើបុណ្យតាមប្រពៃណី ។ ដោយឡែកចំពោះសហព័ទ្ធនៃសពត្រូវបានបន្តទទួលប្រាក់ឧបត្ថម្ភប្រចាំខែ រហូតដល់ពេលគាត់ស្លាប់ ឬ មានគ្រួសារថ្មី ។ កូនកំព្រានៃសព ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែដូចកូនកំព្រានៃសពមន្ត្រីរាជការ រហូតដល់អាយុ ១៥ឆ្នាំ និងចាប់ពីអាយុ១៥ឆ្នាំឡើងទៅ ត្រូវមានលិខិតបញ្ជាក់ការសិក្សា ពីស្ថាប័នមានសមត្ថកិច្ច ។

# ជំពូកទី២
# របបសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

**មាត្រា១១**: អ្នករាជការទាំងពីរភេទ ដែលបាត់បង់សម្បទាវិជ្ជាជីវៈ ហើយមានអតីតភាពការងារចាប់ពី ២០ឆ្នាំ ទៅដល់ក្រោម៣០ឆ្នាំ ហើយពុំគ្រប់អាយុចូលនិវត្តន៍ មានសិទ្ធិទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។ ក្នុងករណីមិនគ្រប់ល័ក្ខខ័ណ្ឌនេះ ត្រូវបានបញ្ឈប់ពីការងារនៅពេលណាក៏បាន ហើយត្រូវបានទទួលប្រាក់ឧបត្ថម្ភ និងប្រាក់កាត់ទុកតែម្តងគត់ដូចអ្នករាជការពុំគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ដែរ ។

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អតិបរិមាត្រូវបានកំណត់ ៦៥ភាគរយ នៃបៀវត្សសុទ្ធសាធ ប្រាក់សោធននេះ ត្រូវអនុវត្តចំពោះអ្នករាជការណាដែលបាត់បង់សម្បទាវិជ្ជាជីវៈដោយគ្រោះថ្នាក់ការងារនិងបំពេញបេសកកម្ម ។

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អប្បបរិមាត្រូវបានកំណត់ ៥០ភាគរយនៃបៀវត្សសុទ្ធសាធប្រាក់សោធននេះ ត្រូវអនុវត្តចំពោះអ្នករាជការណា ដែលបាត់បង់សម្បទាវិជ្ជាជីវៈ ដោយជម្ងឺ ឬ គ្រោះថ្នាក់ផ្សេងៗ ។ ចំពោះអ្នករាជការដែលមានអតីតភាពការងារលើសពី២០ឆ្នាំឡើងទៅ ត្រូវបានទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមា និងត្រូវបានទទួលប្រាក់សមាមាត្របន្ថែម១,៥ភាគរយ ក្នុងមួយឆ្នាំលើបៀវត្សសុទ្ធសាធរបស់សាមីខ្លួន ។ ប៉ុន្តែ ប្រាក់សោធនសមាមាត្រនេះមិនត្រូវលើសប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរិមា ឬ មិនត្រូវទាបជាង៩០ភាគរយនៃប្រាក់បៀវត្សអប្បបរមាសុទ្ធសាធ នៃតារាងកាំប្រាក់របស់សាមីខ្លួនឡើយ ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈនៃអ្នករាជការស៊ីវិល ត្រូវសំរេចដោយគណៈកម្មការមួយដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

**មាត្រា១២**: អ្នករាជការបាត់បង់សម្បទាវិជ្ជាជីវៈម្នាក់ៗ ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រាក់តំបន់ ប្រាក់ប៉ះពាល់សុខភាព ប្រាក់ឧបត្ថម្ភប្រពន្ធ កូន និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀត ដូចជានិវត្តជនដែរ ។

**មាត្រា១៣**: អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានអនុវត្តរបៀបគិតរយៈពេលបំពេញការងារដូចជា និវត្តជនដែរ ។

**មាត្រា១៤**: អ្នករាជការដែលក្រសួង ស្ថាប័ន តម្រូវអោយចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានទទួលប្រាក់ឧបត្ថម្ភ ម្តងគត់ស្មើនឹងបៀវត្សសរុបប្រចាំខែចំនួន ៧ខែ ។

**មាត្រា១៥**: អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលទទួលមរណៈភាព គ្រួសារនៃសពត្រូវបានរដ្ឋឧបត្ថម្ភប្រាក់ដូចជានិវត្តជនដែរ ។

## ជំពូកទី៣
## ភារកិច្ច និង សមត្ថកិច្ច នៃការគ្រប់គ្រង
## បើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

**មាត្រា១៦**: ជារៀងរាល់ឆ្នាំក្រសួង ស្ថាប័ននីមួយៗត្រូវលើកគំរោងផែនការស្ថិតិ និង ថវិកាសំរាប់អ្នករាជការក្រោមឱវាទ ដែលគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ ជូនក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំរុងថវិកាសំរាប់បើកផ្តល់ជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ។

ក្រសួង ស្ថាប័ននីមួយៗមានភារកិច្ច លើកគំរោងផែនការថវិកា និង បើកប្រាក់ឧបត្ថម្ភលើកដំបូង ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ។ ការបើកប្រាក់ឧបត្ថម្ភលើកដំបូងនេះ ត្រូវស្នើទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ការគ្រប់គ្រង និង ការបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន រហូតដល់ពេលបង្កើតបានបេឡាសោធននិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈ ។

**មាត្រា១៧**: និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែកន្លងមក ត្រូវបានគិតបញ្ចូលប្រាក់ឧបត្ថម្ភ ប្រពន្ធ កូន ដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ ។

**មាត្រា១៨**: ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១៩**: សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**អ៊ឹង ហួត ហ៊ុន សែន**

<u>កន្លែងទទួល</u>:

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទាំង២

-គ្រប់ក្រសួង ស្ថាប័ន

-ឯកសារ-កាលប្បវត្តិ

បានជម្រាបជូន

**នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២**

**ស៊ុយ សែម**

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

❖ អនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២

ស្តីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍និងសោធនបាត់បង់

សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១១៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសំរួលការអនុវត្ត
## របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ
## ចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់ សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កម្រៃគរុកោសល្យក្នុងវិស័យអប់រំ

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០២

# សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.**

អនុក្រឹត្យនេះ មានគោលបំណងកែសំរួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការដែលបានចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ តាមប្រព័ន្ធបៀវត្សចាស់ និងការអនុវត្តប្រាក់សោធនចំពោះមន្ត្រីរាជការចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈតាមប្រព័ន្ធបៀវត្សថ្មី ដោយអនុលោមតាមខ្លឹមសារព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល និង អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កម្រៃគរុកោសល្យក្នុងវិស័យអប់រំ។

## ជំពូកទី២

## ការអនុវត្តប្រាក់សោធនក្នុងប្រព័ន្ធបៀវត្សចាស់

**មាត្រា២.**

និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធនគិតតាមប្រព័ន្ធបៀវត្សចាស់ មកដល់ត្រឹមថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ ត្រូវបានកែសំរួលប្រាក់សោធនប្រចាំខែអោយដូចប្រាក់សោធននៃមន្ត្រីរាជការចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ តាមប្រព័ន្ធបៀវត្សថ្មីដែរ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ តទៅ។ ប្រាក់សោធនប្រចាំខែម្នាក់ៗ ដែលគិតតាមប្រព័ន្ធបៀវត្សថ្មី មិនត្រូវទាបជាងប្រាក់សោធនគិតតាមប្រព័ន្ធបៀវត្សចាស់ ដែលសាមីជនកំពុងទទួលឡើយ។ ក្នុងករណីទាបជាង ត្រូវផ្តល់ប្រាក់បង្គ្រប់ជូនសាមីជននោះ។

## ជំពូកទី៣

## ការអនុវត្តប្រាក់សោធនតាមប្រព័ន្ធបៀវត្សថ្មី

**មាត្រា៣.**

ប្រាក់សោធនប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលដែលចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈក្រោយថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ ការផ្តល់ប្រាក់សោធន ត្រូវគណនាតាមបៀវត្សមូលដ្ឋានប្រចាំខែចុងក្រោយនៃមន្ត្រីរាជការស៊ីវិលទាំងនោះ។

ប្រាក់សោធនប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈម្នាក់ៗ ត្រូវបានគិតបន្ថែមប្រាក់ហានិភ័យ និងប្រាក់វិភាជន៍គ្រួសារ។ ប្រាក់វិភាជន៍សំរាប់កូនក្នុងបន្ទុកត្រូវផ្តល់ជូនរហូតដល់អាយុ១៥ឆ្នាំ។ ការផ្តល់ជូននេះអាចបន្តរហូតដល់អាយុ២១ឆ្នាំ ក្នុងករណីមានលិខិតបញ្ជាក់ការសិក្សា។

ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗទៀតមិនត្រូវបានរាប់បញ្ចូលឡើយ។

របៀបគណនាប្រាក់សោធនត្រូវរក្សាទុកដូចមានចែងក្នុងអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល។

**មាត្រា៤.**

មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈដែលកំពុងទទួលមុខតំណែងជាអ្នកនយោបាយ នៅពេលគ្រប់លក្ខខណ្ឌចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានផ្តល់សៀវភៅបើកប្រាក់សោធនប្រចាំខែ ដូចមន្ត្រីរាជការដទៃទៀតដែរ។ ប៉ុន្តែប្រាក់សោធននេះមិនត្រូវបានបើកផ្តល់ជូនទេ ក្នុងរយៈពេលកាន់មុខតំណែងជាអ្នកនយោបាយ ។ ក្រោយពេលបញ្ចប់មុខតំណែងជាអ្នកនយោបាយ សាមីជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីត្រៀមលក្ខណៈបើកផ្តល់ប្រាក់សោធនជាប្រចាំខែចាប់ពីពេលបញ្ចប់មុខតំណែងតទៅ។

និវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលកំពុងទទួលប្រាក់សោធនប្រចាំខែ ហើយមានប្រាក់ឧបត្ថម្ភក្នុងមុខតំណែងជាអ្នកនយោបាយ ត្រូវផ្អាកការបើកប្រាក់សោធន ចាប់ពីពេលដែលអនុក្រឹត្យនេះចូលជាធរមាន។ ប្រាក់សោធននេះត្រូវបន្តបើកផ្តល់ជូនចាប់ពីពេលបញ្ចប់មុខតំណែងជាអ្នកនយោបាយ ហើយត្រូវជូនដំណឹងទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាដូចវាក្យខ័ណ្ឌទី១ខាងលើដែរ។

ប្រាក់សោធនប្រចាំខែ ដែលត្រូវផ្អាកក្នុងរយៈពេលកាន់មុខតំណែងជាអ្នកនយោបាយ មិនត្រូវបានគិតប្រាក់រំលឹកជូនសាមីជនឡើយ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៥.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសារធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***<u>កន្លែងទទួលៈ</u>***
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចមាត្រា ៦
-ឯកសារ-កាលប្បវត្តិ

## ១៤.៣ ការកែសម្រួលប្រាក់ឧបត្ថម្ភនិង ប្រាក់សោធន

- អនុក្រឹត្យ លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការបន្ថែមបៀវត្សជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ៥៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការបន្ថែមបៀវត្សរ៍ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០១/ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២៩៩ /១៥ ចុះថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ២០០៨

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា១**- ត្រូវបានអនុញ្ញាតឲ្យបន្ថែមប្រាក់បៀវត្ស ២០% សំរាប់ឆ្នាំ ២០០៨ លើបៀវត្សសុទ្ធសាធជូនជនពិការ និវត្តជន និង ជនបាត់បង់សមត្ថភាពការងារ ដែលជាអតីតយុទ្ធជន។

**មាត្រា២**- ប្រាក់តំឡើងដូចបានកំណត់ក្នុងមាត្រា១ ខាងលើ ចាប់អនុវត្តពីខែ មករា ឆ្នាំ២០០៨ តទៅ។

**មាត្រា៣**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ដែលជាប្រធាន ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**អ៊ុក រ៉ាប៊ុន**

**រដ្ឋមន្ត្រីស្តីទី**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

❖ អនុក្រឹត្យ លេខ ២០១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភម្តងគត់ជូនមន្ត្រីរាជការស៊ីវិល ថៅក្រម និងព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តមុនកាលកំណត់ និងមិនគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ២០១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និង ព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២ ស្តីពីការកែលំអបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា

-បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សថ្មី

-បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូង និង ប្រាក់សោធនជូនចៅក្រម និង ព្រះរាជអាជ្ញាដែលត្រូវចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ

-យោងតាមការចាំបាច់

## សម្រេច

**មាត្រា ១.**

អនុក្រឹត្យនេះ មានគោលដៅកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ជូនមន្ត្រីរាជការស៊ីវិល មន្ត្រីរាជការដែលមានក្របខ័ណ្ឌមុខងារសាធារណៈទទួលមុខតំណែងនយោបាយ ចៅក្រម និង ព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និង មិនគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ ។

**មាត្រា ២.**

មន្ត្រីរាជការស៊ីវិល មន្ត្រីរាជការដែលមានក្របខ័ណ្ឌមុខងារសាធារណៈទទួលមុខតំណែងនយោបាយ ចៅក្រម និង ព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈមរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និង មិនគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានទទួលប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ ស្មើនឹងប្រាក់បៀវត្សមូលដ្ឋានចុងក្រោយគុណនឹងចំនួនខែដូចដែលបានកំណត់ក្នុងមាត្រា ៨ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២ ស្តីពីការកែលំអបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ មាត្រា ៥.៦ និង មាត្រា ១៤ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១ នៃអនុក្រឹត្យ ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រាក់លើកដំបូង និង ប្រាក់សោធនជូនចៅក្រម និង ព្រះរាជអាជ្ញាដែលត្រូវចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ប្រការ ៥ ចំណុច ក២ និង ចំណុច ខ២ នៃសេចក្តីសម្រេចលេខ ២៤៥ សសរ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ១៩៨៨ ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និង ជនបាត់បង់សមត្ថភាពពលកម្ម និង សេចក្តីណែនាំលេខ ០០៨ ស.អ.យ. ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូង និង ប្រាក់សោធនជូនមន្ត្រីរាជការមានក្របខ័ណ្ឌមុខងារសាធារណៈទទួលមុខតំណែងនយោបាយដែលត្រូវចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ។

**មាត្រា ៣.**

អនុក្រឹត្យនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១០ តទៅ ។

**មាត្រា ៤.**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់គ្រងក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-គ្រប់សាលាខេត្ត-រាជធានី
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

❖ អនុក្រឹត្យ លេខ ៤២ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០ ស្តីពីការកែសម្រួលការអនុវត្តបើកប្រាក់សោធនចំពោះមន្ត្រីរាជការ ដែលជា និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:៤២ អនក្រ. បក

## អនុក្រឹត្យ

## ការកែសម្រួលការអនុវត្តន៍បើកប្រាក់សោធនចំពោះមន្ត្រីរាជការ ដែលជា និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញក្រឹត្យលេខ ១០ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្ដីពី បៀវត្សរ៍មូលដ្ឋាននិង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០១០៨/០៣៩ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ស្ដីពី របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តន៍ របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ ស្ដីពីការគ្រប់គ្រង ដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិល ឱ្យចូលនិវត្តន៍តាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា

-បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្ដីពីការកែសម្រួលការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សរ៍ថ្មី

-បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ស្ដីពីការអនុវត្តន៍ របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧ ស្ដីពីរបបឧបត្ថម្ភ យោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្ដីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ស្ដីពីរបបឧបត្ថម្ភ គោលនយោបាយ ចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

-បានឃើញអនុក្រឹត្យលេខ ២០១ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្ដីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និង ព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និង មិនគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីការកំណត់ប្រាក់ ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.**

អនុក្រឹត្យនេះ កំណត់ការកែសម្រួលការអនុវត្តន៍បើកប្រាក់សោធន ចំពោះមន្ត្រីរាជការ ដែលជា និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និង គ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ និង អ្នកនៅក្នុងបន្ទុក។

**មាត្រា២.**

និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ ដែលទទួលមុខតំណែងជាអ្នកនយោបាយ ត្រូវបានអនុញ្ញាតឱ្យបើកប្រាក់សោធនប្រចាំខែឡើងវិញ។ ចំពោះប្រាក់សោធនប្រចាំខែ ដែលត្រូវបានផ្អាកក្នុងរយៈពេលទទួលមុខតំណែងជាអ្នកនយោបាយ មិនត្រូវបាន គិតប្រាក់រំលឹកជូនសាមីជនវិញឡើយ។

ចំពោះគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ និងអ្នកនៅក្នុងបន្ទុកត្រូវបានអនុញ្ញាតឱ្យបើកប្រាក់ឧបត្ថម្ភប្រចាំខែផងដែរ ស្របតាមគោលការណ៍ដែលបានកំណត់។

**មាត្រា៣.**

មន្ត្រីដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ក្នុងពេលបំពេញមុខដំណែង ហើយទទួលបានប្រាក់បំណាច់តាមមុខដំណែង និង ប្រាក់សោធនប្រចាំខែឡើងវិញហើយនោះ មិនត្រូវបានអនុញ្ញាតឱ្យមានឈ្មោះជាមន្ត្រីជាប់កិច្ចសន្យា និងទទួលបានប្រាក់កំរៃជាមន្ត្រីជាប់កិច្ចសន្យាបន្ថែមទៀតឡើយ។

**មាត្រា៤.**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

## ១៤.៤ សារាចរណែនាំការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

❖ សារាចរណែនាំ លេខ០០៨ ស.អ.យ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ស្តីពីការអនុវត្តសោធននិវត្តន៍ និងសោធនបាត់ បង់សម្បទាវិជ្ជាជីវៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ០០៨ ស.អ.យ　　　　　　　　　　រាជធានីភ្នំពេញថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៤

# សារាចរណែនាំ

ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព នូវអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៥៩ អនក្របក ចុះថ្ងៃទី. ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សូមធ្វើការណែនាំអនុវត្តដូចខាងក្រោម៖

## I -របបសោធននិវត្តន៍

អ្នករាជការស៊ីវិលទាំងពីរភេទ មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍លុះត្រាតែបានបំពេញតាមលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១.២.៣ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ។

### ក -ប្រាក់សោធននិវត្តន៍អតីតភាព

អ្នករាជការស៊ីវិលទាំងពីរភេទ មានសិទ្ធិទទួលរបបសោធននិវត្តន៍អតីតភាពស្មើ ៨០ ភាគរយ នៃបៀវត្សសុទ្ធសាធរបស់សាមីខ្លួន លុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌពីរយ៉ាងដូចខាងក្រោម៖

១ -មានអាយុ៥៥ ឆ្នាំយ៉ាងតិចនិងមានអតីតភាពការងារ ៣០ ឆ្នាំយ៉ាងតិច

២ -មានអតីតភាពការងារ ៣០ ឆ្នាំឡើងទៅ ហើយបានស្ម័គ្រចិត្តសុំចូលនិវត្តន៍ មុនអាយុ ៥៥ ឆ្នាំ។ ពាក្យស្នើសុំត្រូវធ្វើតាមរយៈអង្គភាពគ្រប់គ្រងផ្ទាល់ទៅប្រធានស្ថាប័ន របស់សាមីខ្លួន។

៖ ប្រាក់សោធននិវត្តន៍អតីតភាពត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម

| |
|---|
| សនិសុទ្ធសាធ=៨០%ប |

ប = ប្រាក់បៀវត្សសុទ្ធសាធ

សនិសុទ្ធសាធ = ប្រាក់សោធននិវត្តន៍សុទ្ធសាធ

ប្រាក់សោធននិវត្តន៍នេះត្រូវបានគិតបន្ថែម ប្រាក់តំបន់នៅតាមតំបន់ដែលសាមីខ្លួនរស់នៅ ប្រាក់ប៉ះពាល់សុខភាព(ចំពោះអ្នករាជការដែលធ្វើការងារធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាព មុនចូលនិវត្តន៍) ប្រាក់ឧបត្ថម្ភ ប្រពន្ធ និងកូន និងប្រាក់ឧបត្ថម្ភផ្សេងៗទៀតដែលរដ្ឋបានកំណត់។

| |
|---|
| សនិ = ៨០% ប + ៣០% ប+ត+ប្រាក់ប៉ះពាល់សុខភាព+ប្រាក់ឧបត្ថម្ភប្រពន្ធ+ប្រាក់ឧបត្ថម្ភកូន+<br>ប្រាក់ឧបត្ថម្ភផ្សេងៗទៀត (បើមាន ) |

សនិ = ប្រាក់សោធននិវត្តន៍សរុបប្រចាំខែ

៣០% ប = ប្រាក់ឧបត្ថម្ភ៣០% លើបៀវត្សសុទ្ធសាធ

ត = ប្រាក់តំបន់ដែលសាមីរស់នៅ (បើមាន)

**ខ- ប្រាក់សោធននិវត្តន៍អប្បបរមា**

អ្នករាជការស៊ីវិលទាំងពីរភេទ មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍អប្បបរមាស្មើ និង ៦០% នៃ ប្រាក់បៀវត្សសុទ្ធសាធរបស់សាមីខ្លួនលុះត្រាតែបានបំពេញលក្ខខ័ណ្ឌដូចខាងក្រោម ៖

- មានអាយុ ៥៥ ឆ្នាំ យ៉ាងតិច
- មានអតីតភាពការងារ ពី ២០ ឆ្នាំ ឡើង

ក្នុងករណីមានអតីតភាពការងារលើសពី ២០ឆ្នាំ អ្នករាជការនោះមានសិទ្ធិទទួលប្រាក់សមាមាត្របន្ថែម ២% ក្នុងមួយឆ្នាំលើប្រាក់បៀវត្សសុទ្ធសាធរបស់សាមីខ្លួន ។ ប្រាក់សោធនសមាមាត្រនេះ មិនត្រូវខ្ពស់ជាងប្រាក់សោធននិវត្តន៍អតីតភាព ៨០% ឡើយ បើមានករណីខ្ពស់ជាងត្រូវបន្ថយឲ្យស្មើនឹង ៨០% នៃប្រាក់បៀវត្សសុទ្ធសាធវិញ និងមិនត្រូវទាបជាងប្រាក់បៀវត្សអប្បបរមាសុទ្ធសាធប្រចាំខែនៃតារាងកាំប្រាក់របស់សាមីខ្លួនឡើយ។ បើមានករណីទាបជាងប្រាក់បៀវត្សអប្បបរមាសុទ្ធសាធ ត្រូវដំឡើងអោយ ស្មើនឹងប្រាក់បៀវត្សអប្បបរមាសុទ្ធសាធនៃតារាងកាំប្រាក់របស់សាមីខ្លួន ។

សនិ =[៦០%+២%(ឆ-២០)]ប+30%ប+ត+ ប្រាក់ប៉ះបាល់សុខភាព+ប្រាក់ឧបត្ថម្ភប្រពន្ធ+ ប្រាក់ឧបត្ថម្ភកូន + ប្រាក់ឧបត្ថម្ភផ្សេងៗទៀត (បើមាន)

សនិ = ប្រាក់សោធននិវត្តន៍សរុបប្រចាំខែ

ប = ប្រាក់បៀវត្សសុទ្ធសាធ

ឆ = ចំនួនឆ្នាំលើសពី ២០ ឆ្នាំ ដល់ក្រោម ៣០ ឆ្នាំ ២០(<ឆ<៣០)

[៦០%+២%(ឆ-២០)]ប = ប្រាក់សោធននិវត្តសុទ្ធសាធ

ប្រាក់បៀវត្សអប្បបរមា ≤[៦០%+២%(ឆ-២០)]ប≤៨០%

៣០% ប = ប្រាក់ឧបត្ថម្ភបន្ថែម ៣០% លើបៀវត្សសុទ្ធសាធ

**គ** - អ្នករាជការដែលត្រូវក្រសួង ស្ថាប័នប្រកាសអោយចូលនិវត្តន៍ ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងបៀវត្សសរុបប្រចាំខែចំនួន ៨ ខែ ។ ប្រាក់ឧបត្ថម្ភនេះអាស្រ័យដោយក្រសួងស្ថាប័នរបស់សាមីជនជាអ្នកទទួលបន្ទុកដោះស្រាយ ។

**ឃ** - អ្នករាជការដែលត្រូវអាយុគ្រប់ចូលនិវត្តន៍ ប៉ុន្តែមានអតីតភាពការងារយ៉ាងតិច ២០ ឆ្នាំ មិនត្រូវផ្តល់ប្រាក់សោធននិវត្តន៍ឡើយ។ ក្នុងករណីនេះរដ្ឋផ្តល់ប្រាក់ឧបត្ថម្ភម្តងគត់ដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យលេខ ៥៩ អនក្រ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ១៩៩៧ ។ ការដោះស្រាយប្រាក់ឧបត្ថម្ភមួយលើកអាស្រ័យដោយស្ថាប័នគ្រប់គ្រងរបស់សាមីខ្លួន ។

បស×៤ ≤ បឧ ≤ បស×១០

បស =ប្រាក់បៀវត្សសរុបប្រចាំខែ
បឧ =ប្រាក់ឧបត្ថម្ភមួយលើក

**ង** - ការកំណត់ប្រាក់តំបន់ ប្រាក់ប៉ះពាល់សុខភាព ប្រាក់ឧបត្ថម្ភប្រពន្ធ កូន ត្រូវអនុវត្តតាមអនុក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ០៥ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩២ ស្តីពីការកែលំអប្រាក់បៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និងសារាចរណែនាំអនុវត្តអនុក្រឹត្យនេះរបស់ក្រសួងពីរដូចខាងក្រោម ៖

១ - ក្រសួងផែនការលេខ ០១ សរណេន ផក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩២

២- ក្រសួងការងារ និង សង្គមកិច្ចលេខ ០៣ សរណេនចស ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩២

ការបន្ថែមប្រាក់ ១០ % លើបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ ត្រូវអនុវត្តតាមលិខិតរបស់ក្រសួងផែនការលេខ ៣១២ ផក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩២ ។

ការបន្ថែមប្រាក់ ២០% លើបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ ត្រូវអនុវត្តតាមលិខិតលេខក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០៣២ កហវ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

**ច**- របៀបគិតរយៈពេលបំពេញការងាររបស់អ្នករាជការ ត្រូវបានអនុវត្តតាមមាត្រា ៨ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ។

រយៈពេលបំពេញការងារក្រៅក្របខ័ណ្ឌរដ្ឋ មិនត្រូវបានគិតជារយៈពេលបំរើការងារឡើយ ។

**ឆ**- នៅពេលនិវត្តជនទទួលមរណភាព គ្រួសារនៃសពត្រូវបានរដ្ឋផ្តល់ប្រាក់ឧបត្ថម្ភដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ១៩៩៧ ។ ការផ្តាច់ប្រាក់សោធននិវត្តន៍ប្រចាំខែ របស់និវត្តជនដែលបានទទួលមរណៈភាពខាងលើនេះ ត្រូវបានអនុវត្តនៅខែបន្ទាប់។ ឧទាហរណ៍និវត្តជនមួយនាក់ស្លាប់នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ការផ្តាច់ប្រាក់សោធន ត្រូវបានអនុវត្តនៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។ ក្នុងករណីគ្រួសារសពនិវត្តជន ពុំបានផ្តល់ពត៌មាន និង សំបុត្រមរណភាពអោយបានទាន់ក្នុងខែដែលបានស្លាប់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវអនុវត្តការបើកប្រាក់សោធនជូនគ្រួសារសពតាមធម្មតា ប៉ុន្តែក្រោយបានទទួលពត៌មាន និង សំបុត្រមរណភាពត្រូវផ្តាច់ប្រាក់សោធននៅខែបន្ទាប់នៃការស្លាប់។ ប្រាក់សោធនដែលបានបើករួចហើយត្រូវទូទាត់សងរដ្ឋវិញ។ កូនកំព្រាពីសពនិវត្តជន ត្រូវបានទទួលប្រាក់ ឧបត្ថម្ភដូចកូនកំព្រានៃសពអ្នករាជការស៊ីវិលដែរ ។ ការផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែនេះ ត្រូវបានអនុវត្តចំពោះកូនកំព្រាដែលមានអាយុរហូតដល់ ១៥ ឆ្នាំ និងចាប់ពីអាយុ ១៥ ឆ្នាំឡើងទៅ ត្រូវមានលិខិតបញ្ជាក់ការសិក្សាពីនាយកសាលា ដែលកូនកំព្រានោះបានសិក្សារៀនសូត្រ ។ លិខិតបញ្ជាក់ការសិក្សារបស់កូនកំព្រាទាំងនោះត្រូវផ្ញើមក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជារៀងរាល់ចុងខែវិច្ឆិកា នៃឆ្នាំនីមួយៗក្នុងករណីដល់អាយុត្រូវបញ្ជាក់ការសិក្សា ហើយសាមីគ្រួសារកូនកំព្រាទាំងនោះ ពុំបានបំពេញ តាមការណែនាំរបស់ក្រសួង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវធ្វើសំណើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីពិនិត្យផ្តាច់ប្រាក់ឧបត្ថម្ភប្រចាំខែនៃកូនកំព្រាទាំងនោះចាប់ពីថ្ងៃទី ០១ ខែ មករា នៃឆ្នាំបន្ទាប់ ។

ចំពោះសហព័ទ្ធនៃសពជាប្តី ឬប្រពន្ធ ដែលត្រូវបន្តទទួលប្រាក់ឧបត្ថម្ភប្រចាំខែបានលុះត្រាតែប្តី ឬប្រពន្ធនោះពុំបានបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ ។ ប្រាក់ឧបត្ថម្ភប្រចាំខែរបស់ប្តីត្រូវអនុវត្តដូចប្រាក់ឧបត្ថម្ភប្រពន្ធដែរ ។ ការបើកប្រាក់ឧបត្ថម្ភនេះត្រូវបានអនុវត្តជារៀងរហូតដល់ពេលសហព័ទ្ធនៃសពត្រូវស្លាប់ ឬមានគ្រួសារថ្មី ។ នៅពេលសហព័ទ្ធនៃសពត្រូវបានទទួលមរណភាព ឬមានប្តី ប្រពន្ធថ្មីទៀត មន្ទីរសង្គមកិច្ច

អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង ត្រូវធ្វើសំណើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីលុបឈ្មោះ និងចុះទិដ្ឋាការលើសៀវភៅបើកប្រាក់ឧបត្ថម្ភ ។

**II-របបសោធនបាត់បង់សម្បទាវិជ្ជាជីវ**:

អ្នករាជការស៊ីវិលទាំងពីរភេទ មានសិទ្ធិទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈបាន លុះត្រាតែបានបំពេញលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១១ និង ១២ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល។

**ក -ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អតិបរមា**

អ្នករាជការទាំងពីរភទ ដែលបាត់បង់សម្បទាវិជ្ជាជីវៈ ដោយគ្រោះថ្នាក់ការងារ ឬ បេសកកម្មត្រូវបានទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរមា ៦៥% នៃប្រាក់បៀវត្សសុទ្ធសាធ។

**១- អំពីគ្រោះថ្នាក់ការងារ**

ត្រូវបានចាត់ទុកជាគ្រោះថ្នាក់ការងារ គឺគ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬ ក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន ទោះមានហេតុយ៉ាងណាក៏ដោយ ឬមានកំហុសមកពីអ្នករាជការ ឬ គ្មានក៏ដោយហើយបណ្តាលអោយបាត់បង់សម្បទាវិជ្ជាជីវៈការងារទាំងស្រុង និង ជាអចិន្ត្រៃយ៍ ។

ឧទាហរណ៍ គ្រោះថ្នាក់កើតឡើងក្នុងពេលម៉ោងធ្វើការទាំងក្នុង និង ក្រៅក្រសួង ស្ថាប័នដែលអ្នករាជការបានបំពេញភារកិច្ចរបស់ខ្លួន ។

- គ្រោះថ្នាក់ក្នុងរយៈពេលធ្វើការ និង នៅពេលមុន ឬ ក្រោយពេលធ្វើការ ដែលអ្នករាជការរៀបចំសំភារៈពលកម្ម ឬ ម៉ាស៊ីន ។
- គ្រោះថ្នាក់ក្នុងការបំពេញសេចក្តីត្រូវការផ្ទាល់របស់ខ្លួន ក្នុងរយៈពេលធ្វើការ ដូចជាពេលសំរាកហូបចុក និងពេលបំបៅកូនកណ្តាលវេន ពេលសំអាតខ្លួននៅពេលធ្វើការ ។
- គ្រោះថ្នាក់ដែលបណ្តាលមកពីកត្តាដែលមានគ្រោះថ្នាក់មានពុល ដោយមិនដឹងខ្លួនជាមុនក្នុងក្រសួង ស្ថាប័ន និង ក្នុងផលិតកម្ម ហើយបណ្តាលអោយមានរបួសពុលសន្លប់ដល់អ្នករាជការ ហើយធ្វើអោយបាត់បង់សម្បទាវិជ្ជាជីវៈ ជាស្ថាពរនូវសមត្ថភាពការងារ ។
- គ្រោះថ្នាក់ដែលធ្លាក់លើអ្នករាជការ ក្នុងពេលអ្នកទាំងនោះធ្វើដំណើរពីលំនៅដ្ឋានខ្លួនឆ្ពោះត្រង់ទៅ កន្លែងធ្វើការ ឬ វិលមកវិញដោយគ្មានឈប់ ឬ ដោយគ្មានវៀងទៅទីណាជាប្រយោជន៍ផ្ទាល់ខ្លួន ។

**២-អំពីគ្រោះថ្នាក់ការងារក្នុងពេលបេសកកម្ម**

- គ្រោះថ្នាក់នៅពេលអ្នករាជការបញ្ចេញនូវវីរៈភាព ក្នុងការបំពេញបេសកកម្ម ដែលក្រសួងស្ថាប័នអង្គភាព ប្រគល់អោយ ហើយបានលះបង់ជីវិតរបស់ខ្លួន ។
- គ្រោះថ្នាក់ដែលកើតឡើងក្នុងពេលអ្នករាជការការពារទ្រព្យសម្បត្តិរដ្ឋ ឬ សាធារណៈ ដូចជាភ្លើងឆេះផ្ទះ ទឹកជំនន់ ។ ល ។
- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវអតិបរមា ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម៖

| សពិសុទ្ធសាធ ៦៥ ប % |
|---|

សពិសុទ្ធសាធ=ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធ

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈនេះ ត្រូវបានគិតបន្ថែមប្រាក់តំបន់នៅតាមតំបន់ដែលមានសាមីខ្លួនរស់នៅ ប្រាក់ប៉ះពាល់សុខភាព (ចំពោះអ្នករាជការដែលធ្វើធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាព ដូចពេលកំពុងបំរើការងារមុនពេលចូលបាត់បង់សម្បទាវិជ្ជាជីវៈ) ប្រាក់ឧបត្ថម្ភប្រពន្ធ កូន និងប្រាក់ឧបត្ថម្ភ ផ្សេងៗទៀតដែលរដ្ឋបានកំណត់៖

| |
|---|
| សពិ= ៦៥%ប+៣០%ប+ត+ប្រាក់ប៉ះពាល់សុខភាព+ប្រាក់ឧបត្ថម្ភប្រពន្ធ+ប្រាក់ឧបត្ថម្ភកូន +ប្រាក់ឧបត្ថម្ភផ្សេងៗទៀត(បើមាន) |

សពិ= ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែ

៣០%ប=ប្រាក់ឧបត្ថម្ភ៣០% លើប្រាក់បៀវត្សសុទ្ធសាធ

## ខ- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អប្បបរមា

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បរមា ត្រូវកំណត់៥០% នៃប្រាក់បៀវត្សសុទ្ធសាធ ។ ប្រាក់សោធននេះត្រូវអនុវត្តតែចំពោះអ្នករាជការណាដែលបាត់បង់សម្បទាវិជ្ជាជីវៈដោយសារជំងឺ ឬ គ្រោះថ្នាក់ផ្សេងៗ។ ចំពោះអ្នករាជការដែលមានអតីតភាពការងារលើសពី ២០ ឆ្នាំឡើងទៅ ត្រូវទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមា និងត្រូវបានទទួលប្រាក់សមាមាត្របន្ថែម ១,៥ % ឆ្នាំ ក្នុងមួយលើកប្រាក់បៀវត្សសុទ្ធសាធរបស់សាមីខ្លួន ។ ប៉ុន្តែប្រាក់សោធនសមាមាត្រនេះ មិនត្រូវលើសប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរមា ឬ មិនត្រូវទាបជាង ៩០% នៃប្រាក់បៀវត្សអប្បបរមាសុទ្ធសាធ នៃតារាងកាំប្រាក់របស់សាមីខ្លួនឡើយ។

| |
|---|
| សពិសុទ្ធសាធ=[៥០%+១,៥%+(ឆ-២០]ប |

ឆ = ចំនួនឆ្នាំដែលបានបំរើការងារលើសពី២០ឆ្នាំ

២០ឆ្នាំ < ឆ < ៣០ឆ្នាំ

៩០ % ប≤ [៥០%+១,៥%(ឆ-២០)]ប≤៦៥%ប

| |
|---|
| សពិ = [៥០%+១,៥%(ឆ-២០)]ប+៣០%ប+ត+ប្រាក់ប៉ះពាល់សុខភាព+ប្រាក់ឧបត្ថមប្រពន្ធ+ ប្រាក់ឧបត្ថម្ភកូន+ប្រាក់ឧបត្ថម្ភផ្សេងៗទៀត(បើមាន) |

**គ** -ការកំណត់ប្រាក់តំបន់ ប្រាក់ប៉ះពាល់សុខភាព ប្រាក់ឧបត្ថម្ភប្រពន្ធ កូន ត្រូវបានអនុវត្តដូចនិវត្តជនដែរ ។

**ឃ**- អ្នករាជការដែលដែលបានបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានអនុវត្តរបៀបគិតរយៈពេលបំពេញការងារដូចជានិវត្តជនដែរ ។ ដោយឡែកក្រោយពេលតំរូវអោយចូលបាត់បង់សម្បទាវិជ្ជាជីវៈត្រូវទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើប្រាក់បៀវត្សសរុប ប្រចាំខែចំនួន ៧ ខែ ។ ប្រាក់ឧបត្ថម្ភនេះ អាស្រ័យដោយក្រសួងស្ថាប័ន របស់សាមីជនជាអ្នកទទួលបន្ទុកដោះស្រាយ ។

ខ -អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈនៅពេលទទួលមរណភាព គ្រួសារនៃសពត្រូវបានទទួលប្រាក់ឧបត្ថម្ភ ដូចមានចែងក្នុងមាត្រា ១៥ នៃអនុក្រឹត្យលេខ ៥៩ អនក្រ បកចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ ១៩៩៧ ។

ចំពោះរបៀបរបបអនុវត្តការផ្តាច់ប្រាក់សោធន និង ការផ្តល់ប្រាក់ឧបត្ថម្ភគ្រួសារក្នុងបន្ទុកត្រូវអនុវត្តដូចនិវត្តជនទទួលមរណៈភាពដែរ ។

## III-ការបញ្ចូលប្រាក់ឧបត្ថម្ភប្រពន្ធ កូនសំរាប់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលប្រាក់សោធនប្រចាំខែកន្លងមក :

ការគិតបញ្ចូលប្រាក់ឧបត្ថម្ភ ប្រពន្ធ កូន ជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដូចមានចែងក្នុងមាត្រា ១៧ នៃអនុក្រឹត្យ លេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៧ ត្រូវបានអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៨ តទៅ ។

និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធនកន្លងមក ត្រូវគិតបញ្ចូលប្រាក់ឧបត្ថម្ភប្រពន្ធ ដែលពុំបានបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ និង ប្រាក់ឧបត្ថម្ភកូនក្នុងបន្ទុកដែលមានអាយុរហូតដល់១៥ឆ្នាំ និងចាប់ពី អាយុ ១៥ ឆ្នាំឡើង ត្រូវមានលិខិតបញ្ជាក់ការសិក្សាពីនាយកសាលាដែលកូននោះកំពុងសិក្សារៀនសូត្រ ។ ប្រពន្ធ និង កូន ដែលត្រូវផ្តាច់ប្រាក់ឧបត្ថម្ភប្រចាំខែ លុះត្រាតែមានករណីដូចខាងក្រោម៖

- ប្រពន្ធស្លាប់
- កូនលើសអាយុ ១៥ ឆ្នាំ គ្មានលិខិតបញ្ជាក់ការសិក្សា ឬ មានអាហារូបត្ថម្ភ ។

## IV-ភារកិច្ច និង សមត្ថកិច្ចនៃការគ្រប់គ្រងបើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

### ក.ភារកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ មានដូចខាងក្រោម៖

- ត្រូវការលើកគំរោងផែនការស្ថិតិ និង ថវិកាប្រចាំឆ្នាំ សំរាប់អ្នករាជការក្រោមឳវាទដែលគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយបានមុនដំណាច់ខែសីហានៃឆ្នាំ ដើម្បីបំរុងថវិកាសំរាប់បើកផ្តល់ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ។ ចំពោះក្រសួង ស្ថាប័ន ដែលគ្មានគំរោងផែនការស្ថិតិ និង ថវិកាផ្ញើមកតាមការកំណត់នោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ពុំអាចចេញសៀវភៅនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជូនបានឡើយ ។

- លើកគំរោងផែនការថវិកា និង បើកប្រាក់ឧបត្ថម្ភលើកដំបូងជូនអ្នករាជការ ដែលបានប្រកាសអោយចូលនិវត្តន៍ និង ចូលបាត់បង់សម្បទាវិជ្ជាជីវៈ។ ប្រាក់ឧបត្ថម្ភលើកដំបូងនេះ ត្រូវស្នើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ត្រូវធ្វើសំណើសុំសៀវភៅនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អោយបានបីខែមុនពេលប្រកាសអោយអ្នករាជការក្រោមឳវាទចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ។ ករណីយឺតយ៉ាវ មិនទាន់តាមការកំណត់នេះ ក្រសួងមិនទទួលដោះស្រាយជូនឡើយ។

បណ្តាសំណុំលិខិតដែលត្រូវបញ្ជូន មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាមានដូចតទៅ ៖

- ពាក្យស្នើសុំចេញសៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ០១ ច្បាប់
- ប្រកាសអោយចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ (ច្បាប់ដើម០១) ចំនួន ០២ ច្បាប់
- លិខិតបញ្ជាក់អំពីរយៈពេលបំពេញការងាររបស់អ្នករាជការ ចំនួន ០២ ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីជន ចំនួន ០២ ច្បាប់
- ពាក្យសុំចូលនិវត្តន៍ របស់អ្នករាជការ ដែលមានអតីតភាពការងារ ៣០ ឆ្នាំឡើង មិនទាន់គ្រប់អាយុ ហើយស្ម័គ្រចិត្តចូលនិវត្តន៍ ចំនួន ០១ ច្បាប់
- សេចក្តីសំរេចអោយបន្តការងារមួយឆ្នាំម្តងៗ បើអ្នករាជការនោះមានអាយុ លើសពី ៥៥ ឆ្នាំ ឡើង ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ការងារប៉ះពាល់សុខភាព បើអ្នករាជការនោះធ្វើការនៅ កន្លែងប៉ះពាល់សុខភាព ចំនួន ០១ ច្បាប់
- វិញ្ញាបនប័ត្របញ្ជាក់បាត់បង់សម្បទាវិជ្ជាជីវៈចេញដោយគណៈកម្មការ វាយតំលៃសុខភាពបើអ្នករាជការនោះបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ០១ ច្បាប់
- កំណត់ហេតុស្តីពីគ្រោះថ្នាក់ការងារ ឬបេសកកម្ម បើអ្នករាជការនោះ ទទួលគ្រោះថ្នាក់ដោយបំពេញការងារឬបេសកកម្ម ចំនួន ០១ ច្បាប់
- រូបថតទំហំ ៤ គុណ ៦ ចំនួន ០៣ សន្លឹក
- រូបថតទំហំ ៣ គុណ ៤ ចំនួន ០១ សន្លឹក

ទំរង់បែបបទសំខាន់ៗខាងលើ ដូចមានគំរូជូនភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធ ។

## ខ-ភារកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

### ១ - ថ្នាក់កណ្តាល

- ពិនិត្យសំណើសុំចេញសៀវភៅនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ នៃអ្នករាជការរបស់ក្រសួង ស្ថាប័នរដ្ឋ ។
- ចេញសៀវភៅបើកប្រាក់សោធនប្រចាំខែ និង អត្តសញ្ញាណប័ណ្ណ ជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ។
- ពិនិត្យ និង ចេញប្រកាសលុបឈ្មោះនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលមុខសញ្ញាទទួលមរណភាព និង ចេញសៀវភៅបើកប្រាក់ឧបត្ថម្ភជូនគ្រួសារសព តាមសំណើរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង ។
- ពិនិត្យ និង ចេញសៀវភៅសោធនទុតិយតារបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈនៅពេលសៀវភៅបើកប្រាក់សោធនប្រចាំខែត្រូវបាត់បង់ ឬ ប្រើប្រាស់អស់ ។
- ពិនិត្យ និង ផ្ទេរការផ្លាស់ប្តូរទីលំនៅរបស់និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ តាមសំណើរបស់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាខេត្ត ក្រុង ។
- គ្រប់គ្រង តាមដានត្រួតពិនិត្យ និង វាយតំលៃការអនុវត្តន៍គោលនយោបាយសោធននិវត្ត សោធនបាត់បង់សម្បទាវិជ្ជាជីវៈ នៅគ្រប់លំដាប់ថ្នាក់ក្រោមឱវាទរបស់ក្រសួង ។

## ២- ថ្នាក់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង

- គ្រប់គ្រង និង បើកប្រាក់សោធនប្រចាំខែជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលរស់នៅតាមខេត្តក្រុងរបស់ខ្លួន ។

- ជារៀងរាល់ឆ្នាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង ត្រូវធ្វើគំរោងផែនការស្ថិតិ និង ថវិកា និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ និង គ្រួសារក្នុងបន្ទុកដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខេត្ត ក្រុង នោះដើម្បីផ្ញើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អោយបានមុនដំណាច់ខែ សីហា នៃឆ្នាំ ។

- ធ្វើសំណើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាវិជ្ជាជីវៈ ដើម្បី៖

២-១- លុបឈ្មោះនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលមុខសញ្ញា នោះបានទទួលមរណភាពដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម ៖

- ពាក្យសុំប្រាក់ឧបត្ថម្ភគ្រួសារ ចំនួន០១ច្បាប់
- សំបុត្របញ្ជាក់មរណភាពរបស់និវត្តជនឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន០១ច្បាប់
- វិញ្ញាបនប័ត្រផ្តាច់ប្រាក់សោធននិវត្តន៍
- សៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ
- តារាងរៀបរាប់ស្ថានភាពគ្រួសារសព ចំនួន០១ច្បាប់

២-២- សុំផ្ទេរការស្នាក់នៅរបស់និវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលសាមីជន មានសំណើមកមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ សំណុំលិខិតត្រូវភ្ជាប់មកក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាមាន៖

- ពាក្យសុំផ្ទេរការស្នាក់នៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ចំនួន០១ច្បាប់
- តារាងទូទាត់ប្រាក់សោធនប្រចាំខែចុងក្រោយរបស់សាមីជន ចំនួន០១ច្បាប់
- ពាក្យស្នើសុំផ្ទេររបស់និវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន០១ច្បាប់
- សៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ

២-៣- សោធនទុតិយសុំចេញសៀវភៅតា ចំពោះករណីនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបាត់បង់សៀវភៅសោធនចាស់។ សំណុំលិខិតភ្ជាប់មកជាមួយរួមមាន៖

- ពាក្យសុំចេញសៀវភៅទុតិយតារបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ចំនួន ០១ច្បាប់
- កំណត់ហេតុស្ដីពីការបាត់បង់សៀវភៅ ចំនួន ០១ច្បាប់
- តារាងប្រាក់សោធនប្រចាំខែ ចំនួន ០១ច្បាប់

២-៤- សុំចេញសៀវភៅថ្មីជូននិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវ ក្នុងករណីសៀវភៅចាស់ត្រូវបានប្រើប្រាស់អស់ ។ សំណុំលិខិតផ្ញើរមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារួមមាន៖

- ពាក្យសុំចេញសៀវភៅថ្មី ដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ចំនួន ០១ច្បាប់
- សៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានប្រើប្រាស់អស់

២-៥- សុំបញ្ចូលប្រាក់ឧបត្ថម្ភកូន របស់និវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលកន្លងមកពុំបានទទួលប្រាក់ឧបត្ថម្ភ។ សំណុំលិខិតភ្ជាប់មកជាមួយនេះរួមមាន៖

- លិខិតស្នើសុំប្រាក់ឧបត្ថម្ភរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ចំនួន០១ ច្បាប់
- សៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ
- តារាងរៀបរាប់ស្ថានភាពគ្រួសារ ដែលត្រូវបានទទួលឧបត្ថម្ភប្រចាំខែ ចំនួន០១ ច្បាប់

(តារាងនេះត្រូវមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខ័ណ្ឌ)

២-៦-សុំចេញអត្តសញ្ញាណប័ណ្ណជូននិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលកំពុងរស់នៅតាមខេត្តក្រុងរបស់ខ្លួនដោយភ្ជាប់មកជាមួយនូវបញ្ជីរាយនាម និងរូបថតទំហំ ៣ គុណ ៤ ចំនួន០១ សន្លឹក

- ជារៀងរាល់ត្រីមាសនៃឆ្នាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវផ្តល់បញ្ជីបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាវិជ្ជាជីវៈ និងតារាងបើកប្រាក់ឧបត្ថម្ភគ្រួសារសពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

-រាល់ការបើកប្រាក់សោធន និង ប្រាក់ឧបត្ថម្ភគ្រួសារប្រចាំខែរបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវមានវត្តមានរបស់មន្ត្រីតំណាងការិយាល័យសង្គមកិច្ច ថ្នាក់ខេត្ត ក្រុង ថ្នាក់ស្រុក ខ័ណ្ឌ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង។

-អនុវត្តកម្មវិធីតាមដានត្រួតពិនិត្យ និង វាយតំលៃ ស្ថានភាពជីវភាពរបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ព្រមទាំងគ្រួសារក្នុងបន្ទុក អោយបានជាប់ជាប្រចាំក្នុងមួយឆ្នាំយ៉ាងតិច ២ ដង ។ លទ្ធផលការងារនេះ ត្រូវមានរបាយការណ៍បញ្ជូនទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- កំណត់ណែនាំភារកិច្ច ជាក់ស្តែងសំរាប់ការិយាល័យក្រោមឱវាទរបស់មន្ទីរផ្ទាល់ ។

ទំរង់បែបបទសំខាន់ៗខាងលើ ដូចមានគំរូជូនភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធ ។

## V-អវសានប្បញ្ញត្តិ

ប្រកាសណែនាំអនុវត្តលេខ ៥៧ ប្រក.ណាន ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់ក្រសួងសង្គមកិច្ច ការងារ អតីតយុទ្ធជន ត្រូវចាត់ទុកជានិរាករណ៍ ។

សារាចរណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**

**អ៊ិត សំហេង**

**<u>ចម្លងជូន:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

  (ដើម្បីជូនជ្រាប)
- គ្រប់ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល .
- គ្រប់អង្គភាពក្រោមឱវាទ ក្រសួង ស អយ.
- គ្រប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តក្រុង-

  "ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ -

❖ សារាចរណែនាំ លេខ ០០៧ ស.អ.យ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការតម្លើងប្រាក់សោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់និវត្តជន និងជនបាត់សម្បទាវិជ្ជាជីវៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**
លេខៈ០០៧ ស.អ.យ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ២០០៧

# សារាចរណែនាំ
# ស្តីពី
# ការតម្លើងប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ សំរាប់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ

-យោងអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល។

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ណែនាំអំពីនីតិវិធី និង រូបមន្តគណនាតម្លើងប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ សំរាប់មន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដូចតទៅ៖

**១-ប្រាក់សោធនរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ**

**ក.និវត្តជន**

ការគណនាប្រាក់សោធនរបស់និវត្តជន ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម៖

> ប្រាក់សោធននិវត្តន៍សរុបប្រចាំខែថ្មី = ប្រាក់សោធនសុទ្ធសាធ + ប្រាក់តម្លើងអោយស្មើបៀវត្សមូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមអោយស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងៗទៀតប្រសិនបើមាន

**ប្រាក់សោធនសុទ្ធសាធ = សន្ទស្សន៍បៀវត្សមូលដ្ឋាន × ៥០០ × អត្រាភាគរយប្រាក់សោធន**

**ខ.ជនបាត់បង់សម្បទាវិជ្ជាជីវៈ**

ការគណនាប្រាក់សោធនរបស់ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម៖

> ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ សរុបប្រចាំខែថ្មី = ប្រាក់សោធនសុទ្ធសាធ + ប្រាក់តម្លើងអោយស្មើ៩០%នៃបៀវត្សមូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមអោយស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងៗទៀតប្រសិនបើមាន

## ២-ប្រាក់សោធនរបស់មន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍ និង ចូលបាត់បង់សម្បទាវិជ្ជាជីវៈ

មន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈក៏ត្រូវគណនាប្រាក់សោធនដូចរូបមន្តខាងលើដែរ ។

## ៣-ប្រាក់សោធននេះត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៧ តទៅ។

## ៤-ទំរង់បែបបទស្នើសុំប្រាក់សោធន

សំណុំលិខិតស្នើសុំប្រាក់សោធនថ្មីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រប់ខេត្ត/ក្រុងមានដូចខាងក្រោម៖

-លិខិតស្នើសុំតម្លើងប្រាក់សោធនជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ០១ ច្បាប់

-តារាងបើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែចុងក្រោយ ០១ ច្បាប់

-តារាងបើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែថ្មី ០៣ ច្បាប់

បន្ទាប់ពីមានការយល់ព្រមជាគោលការណ៍ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា លើតារាងប្រាក់សោធន ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រប់ខេត្ត/ក្រុង មានសិទ្ធិចុះហត្ថលេខានៅលើទំព័រត្រង់ "ប្តូរប្រាក់បៀវត្ស គិតពីថ្ងៃទី ខែ ឆ្នាំ" របស់សៀវភៅនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង/ស្ថាប័ន និង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រប់ខេត្ត/ក្រុង ត្រូវអនុវត្តអោយបានមានប្រសិទ្ធភាព។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

<u>ចម្លងជូន</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-គ្រប់ក្រសួង/ស្ថាប័ននៃរាជរដ្ឋាភិបាល

-គ្រប់សាលាខេត្ត/ក្រុង

-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រប់ខេត្ត/ក្រុង

-ឯកសារ កាលប្បវត្តិ

❖ សារាចរណែនាំ លេខ០០៨ ស.អ.យ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៧ របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការបន្ថែមប្រាក់ពី ១៥ ទៅ ២៥ ភាគរយ ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**
លេខៈ០០៨ ស.អ.យ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ២០០៧

**សារាចរណែនាំ**
**ស្តីពីការបន្ថែមប្រាក់ពី១៥ ទៅ ២៥ ភាគរយ ជូន ជនពិការ និង និវត្តជន**
**និង បាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន**

យោងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាល កម្ពុជា ស្តីពីការបន្ថែមបៀវត្ស ជូនកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់ សមត្ថភាពពលកម្ម និងយុទ្ធជនពិការ ។

យោងតាមសារាចរណែនាំលេខ ០៣ សអយ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្តីពីការតំឡើងប្រាក់របប ១៥ ភាគរយ ជូនជនពិការ និវត្តជន និង ជនបាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន ។

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ធ្វើការណែនាំអនុវត្ត ដូចខាងក្រោមៈ

**១**-របៀបបន្ថែមប្រាក់ពី ១៥ ទៅ ២៥ ភាគរយ ត្រូវអនុវត្តតាមរូបមន្តដូចតទៅៈ

**ក**-ចំពោះជនពិការគ្រប់ប្រភេទ និវត្តជន និង ជនបាត់បង់សមត្ថភាពការងារ ជាអតីតកងកម្លាំង ប្រដាប់អាវុធម្នាក់ៗ ត្រូវបានបន្ថែម ១០ ភាគរយ តាមរូបមន្តអនុវត្តៈ$\frac{១០ \times \text{បៀវត្សឋានន្តរស័ក្តិ}}{១០០}$

**ខ**-ចំពោះជនពិការជា អតីតក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ម្នាក់ៗត្រូវបានបន្ថែម ១០ ភាគរយ តាម រូបមន្តអនុវត្តៈ$\frac{១០ \times \text{បៀវត្សសុទ្ធសាធ}}{១០០}$

**គ**-ចំពោះជនពិការ ជាអតីតកងសេនាជន ប្រជាជន កងជីវពល ម្នាក់ៗត្រូវបានបន្ថែម ១០ ភាគរយ តាមរូបមន្តអនុវត្តៈ$\frac{១០ \times \text{បៀវត្ស ឋានន្តរស័ក្តិពលទោ}}{១០០}$

**២**-ប្រាក់បន្ថែមដូចបានកំណត់ក្នុងចំណុចទី១ ខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៧ នេះតទៅ និងត្រូវបញ្ចូលក្នុងបញ្ជីរាយនាមជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ដែលត្រូវទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ទៅក្នុងខ្ទង់ប្រាក់បន្ថែមភាគរយ ។

៣-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់ខេត្ត ក្រុង ត្រូវបំពេញបែបបទ និងស្នើសុំសេចក្ដីសម្រេចពីរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអនុវត្ត ។

-នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវពិនិត្យ និង លើកមតិជូនឯកឧត្តមរដ្ឋមន្ត្រីសម្រេចជាផ្លូវការ ។

នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋាន នាយកដ្ឋានសោធនអតីតយុទ្ធជន នាយកដ្ឋានពាក់ព័ន្ធ និង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់ខេត្ត ក្រុង ត្រូវអនុវត្តសារាចរណែនាំនេះឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
-ក្រសួងមហាផ្ទៃ
-ក្រសួងការពារជាតិ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-គ្រប់សាលាខេត្ត-ក្រុង
-គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
-ឯកសារ កាលប្បវត្តិ

❖ សារាចរណែនាំ លេខ០០១ សរ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការតម្លើងប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់និវត្តន៍ជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**

លេខៈ០០១ ស.អ.យ

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០០៩

## សារាចរណែនាំ
## ស្តីពីការតម្លើងប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ

យោងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៩ ស្តីពីការកែប្រែតម្លៃឯកតានៃបៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមណែនាំអំពីនីតិវិធីនិងរូបមន្តគណនាតម្លើងប្រាក់សោធននិវត្ត និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តន៍ជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដូចទៅ៖

**១.ប្រាក់សោធនរបស់និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ**

**ក.និវត្តជន**

ការគណនាប្រាក់សោធននិវត្ត ត្រូវអនុវត្តដូចខាងក្រោម៖

| |
|---|
| ប្រាក់សោធននិវត្តន៍សរុបប្រចាំខែថ្មី= ប្រាក់សោធនសុទ្ធសាធ + ប្រាក់តម្លើងឲ្យស្មើបៀវត្សមូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមឲ្យស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងៗទៀតបើមាន |

**ប្រាក់សុទ្ធសាធ = សន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន x ៧២០ x អត្រាភាគរយប្រាក់សោធន**

**ខ.ជនបាត់បង់សម្បទាវិជ្ជាជីវៈ**

ការគណនាប្រាក់សោធនរបស់ជនបាត់បង់សម្បទាវិជ្ជាជីវៈត្រូវអនុវត្តដូចខាងក្រោម៖

| |
|---|
| ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសរុបប្រចាំខែថ្មី= ប្រាក់សោធនសុទ្ធសាធ + ប្រាក់តម្លើងឲ្យស្មើ ៩០% នៃបៀវត្សមូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមឲ្យស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងៗទៀតបើមាន |

**ប្រាក់សុទ្ធសាធ = សន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន x ៧២០ x អត្រាភាគរយប្រាក់សោធន**

**២.ប្រាក់សោធនរបស់មន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ**

មន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ ក៏ត្រូវគណនាប្រាក់សោធនដូចរូបមន្តខាងលើ។

**៣.ប្រាក់សោធននេះត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ តទៅ**

**៤.ទម្រង់បែបបទស្នើសុំប្រាក់សោធន**

សំណុំលិខិតប្រាក់សោធនថ្មីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់រាជធានី-ខេត្ត មានដូចខាងក្រោម៖

- លិខិតស្នើសុំតម្លើងប្រាក់សោធននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តនិងសោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែចុងក្រោយ ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តនិងសោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែថ្មី ០៣ ច្បាប់

បន្ទាប់ពីមានការយល់ព្រមជាគោលការណ៍ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លើតារាងប្រាក់សោធន ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់រាជធានី ខេត្ត មានសិទ្ធចុះហត្ថលេខានៅលើទំព័រដែលចែងពីកាលបរិច្ឆេទប្តូរប្រាក់សោធននៃសៀវភៅនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង / ស្ថាប័ន និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់រាជធានីខេត្ត សូមសហការអនុវត្តឲ្យមានប្រសិទ្ធភាព។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
-ក្រសួងមហាផ្ទៃ
-ក្រសួងការពារជាតិ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-គ្រប់សាលាខេត្ត-ក្រុង
-គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
-ឯកសារ កាលប្បវត្តិ

❖ សារាចរណែនាំ លេខ០៥ សរ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការបើកប្រាក់សោធនសំរាប់និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ដែលកំពុងទទួលមុខតំណែងក្នុងមុខងារនយោបាយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ០៥ សរ

**សារាចរ**

**ស្តីពី**

**ការបើកប្រាក់សោធនសម្រាប់ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ដែលកំពុងទទួលមុខតំណែងក្នុងមុខងារនយោបាយ**

កន្លងមករាជរដ្ឋាភិបាល បានពិនិត្យឃើញថា អតីតមន្ត្រីរាជការ រួមមាននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និង អតីតយុទ្ធជន រួមមានយោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ដែលមានបទពិសោធន៍ និង ស្នាដៃបម្រើជាតិមាតុភូមិត្រូវបានផ្តល់មុខតំណែងក្នុងមុខងារនយោបាយនៅតាមក្រសួង ស្ថាប័ន ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

ដោយអនុលោមតាមបទប្បញ្ញត្តិ និង លិខិតបទដ្ឋានដែលនៅជាធរមាន និង ក្នុងគោលបំណងដើម្បីពង្រឹងការអនុវត្តគោលនយោបាយអភិបាលកិច្ចល្អឱ្យមានប្រសិទ្ធិភាព រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅៈ

១-គ្រប់ក្រសួង ស្ថាប័ន ត្រូវផ្តល់បញ្ជីរាយនាម និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ហើយដែលបច្ចុប្បន្នទទួលមុខតំណែងក្នុងមុខងារនយោបាយទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ឱ្យបានឆាប់បំផុតជាកំហិត។

២-ចំពោះនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្មទាំងឡាយណាដែលកំពុងទទួលទាំងប្រាក់សោធនប្រចាំខែ និង ទាំងប្រាក់ឧបត្ថម្ភក្នុងមុខងារនយោបាយក្នុងពេលជាមួយគ្នា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវផ្អាកការបើកប្រាក់សោធនជាបន្ទាន់។ ប្រាក់សោធនទាំងនេះ និង ប្រាក់សោធនដែលបានបើករួចហើយជូននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ដែលកំពុងទទួលមុខតំណែងក្នុងមុខងារនយោបាយត្រូវបង្វែរចូលថវិកាជាតិវិញជាកំហិត។ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម អាចជ្រើសយកប្រាក់ឧបត្ថម្ភណាមួយដែលខ្ពស់ជាងគេក្នុងចំណោមប្រាក់ឧបត្ថម្ភច្រើនកន្លែង ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តទៅតាមនីតិវិធី។

៣-បន្ទាប់ពីបញ្ចប់មុខតំណែងក្នុងមុខងារនយោបាយនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិន ចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីទទួលបានប្រាក់សោធនប្រចាំខែ ចាប់ពីពេលបញ្ចប់មុខតំណែងក្នុងមុខងារនយោបាយតទៅ។ ប្រាក់សោធនប្រចាំខែដែលត្រូវបានផ្អាកក្នុងរយៈពេលកាន់មុខតំណែងក្នុងមុខងារនយោបាយមិនត្រូវបានគិតរំលឹកជូនវិញឡើយ។

គ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវសហការអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*

*-គ្រប់ក្រសួង ស្ថាប័ន*

*-គ្រប់សាលាខេត្ត-រាជធានី ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់*

*-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*

❖ សារាចរណែនាំ លេខ០០៥ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការតម្លើងប្រាក់សោធនសម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**

លេខៈ០០៥ ស.អ.យ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១០

# សារាចរណែនាំ
# ស្តីពី
# ការតម្លើងប្រាក់សោធនសម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ

ដោយអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រោមមាគ៌ាដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កន្លងមកបានយកចិត្តទុកដាក់តម្លើងប្រាក់សោធនជាបន្តបន្ទាប់ ដើម្បីជួយសម្រួលជីវភាពរស់នៅរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ បច្ចុប្បន្ននេះ ត្រូវបានតម្លើងបន្តទៀតតាមអនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពីការកែប្រែតម្លៃឯកតាសន្ទស្សន៍នៃបៀវត្សរ៍មូលដ្ឋាន និងការបង្កើនបៀវត្សរ៍សុទ្ធសាធរបស់មន្ត្រីរាជការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សូមធ្វើការណែនាំដល់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រាជធានី ខេត្តដូចតទៅ៖

**១**- ការគណនាប្រាក់សោធនរបស់និវត្តជន ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម៖

| | |
|---|---|
| ប្រាក់សោធនសរុបប្រចាំខែថ្មី = | **ប្រាក់សោធនសុទ្ធសាធ** + ប្រាក់តម្លើងឲ្យស្មើបៀវត្សរ៍មូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមឲ្យស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងទៀត បើមាន |
| **ប្រាក់សោធនសុទ្ធសាធ** | = សន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន x ៨៧០ x អត្រាភាគរយប្រាក់សោធន |

**២**- ការគណនាប្រាក់សោធនរបស់ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម៖

| | |
|---|---|
| ប្រាក់សោធនសរុបប្រចាំខែថ្មី = | **ប្រាក់សោធនសុទ្ធសាធ** + ប្រាក់តម្លើងឲ្យស្មើ៩០% នៃបៀវត្សរ៍មូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមឲ្យស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ +ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងទៀត បើមាន |
| **ប្រាក់សោធនសុទ្ធសាធ** | = សន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន x ៨៧០ x អត្រាភាគរយប្រាក់សោធន |

**៣**- ត្រូវរៀបចំសំណុំលិខិតស្នើសុំប្រាក់សោធនថ្មីដូចខាងក្រោមៈ

- លិខិតស្នើសុំតម្លើងប្រាក់សោធននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនជនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែចុងក្រោយ ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនជនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែថ្មី ០៣ ច្បាប់

បន្ទាប់ពីមានការយល់ព្រមជាគោលការណ៍ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា លើតារាងប្រាក់សោធន ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រាជធានីខេត្ត មានសិទ្ធចុះហត្ថលេខានៅលើទំព័រដែលចែងពីកាលបរិច្ឆេទប្តូរប្រាក់សោធន នៃសៀវភៅនិវត្តជន និងសៀវភៅជនបាត់បង់សម្បទាវិជ្ជាជីវៈ។

**៤**- ចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានដាក់ឲ្យចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ ដោយក្រសួងស្ថាប័ននានា ក៏ត្រូវគណនាប្រាក់សោធនតាមរូបមន្តដូចខាងលើនេះផងដែរ។

**៥**- ការគណនាប្រាក់សោធនសម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១០ តទៅ។

គ្រប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រាជធានី ខេត្ត ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ២០០៩ និងសារាចរនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អាជ្ញាធរសេវនកម្មជាតិ
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-គណៈកម្មាធិការត្រួតពិនិត្យការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្ត
-គ្រប់សាលារាជធានី ខេត្ត
"ដើម្បីជូនជ្រាប"
-គ្រប់អង្គភាពក្រោមឱវាទក្រសួង ស.អ.យ
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ